# អដ្ឋកថា បបញ្ចសូទនី

## នៃព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

## បញ្ចមភាគ

## លេខ ២៤

ពុទ្ធសករាជ ២៥៥៤

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

## បញ្ចមភាគ

## ភាគ ២៤

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**បរិព្វាជកវគ្គ - រាជវគ្គ**

**រួមទាំងអស់មាន ២០ សូត្រ**

# ស្រៈនិងស្រៀយ

# *Signes et accents:*

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ǀ | ា | ិ | ី | ុ | ូ | េ | េ | ា |
| ឡូប<br>Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | | *o* |
| សៀម<br>Siamois | ǀ | า | ิ | ี | ุ | ู | เ | | โ |
| លាវ<br>Laotien | ǀ | າ | ິ | ີ | ຸ | ູ | ເ | ເ | າ |
| សិង្ហ<br>Cinghalais | ǀ | ා | ි | ී | ු, ු | ූ, ූ | ෙ | ෙ | ා |
| ភូមា<br>Birman | ǀ | ါ | ိ | ီ | ု | ူ | ေ | ေ | ါ |

# ស្រៈពេញតួ
# Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូប Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

c

# ព្យញ្ជនៈ

# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

## D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ្ដ | ឋ្ឋ | ឌ្ឌ | ឍ្ឍ | ណ្ណ |
| ឡូម Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ᨭ | ᨮ | ᨯ | ᨰ | ᨱ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

F

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រូប Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| សិង្ហ Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ប | ផ | ព | ភ | ម |
| ឡូម<br>Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម<br>Siamois | ป | ผ | พ | ภ | ม |
| លាវ<br>Laotien | ປ | ຜ | ພ | ຟ | ມ |
| លង្កា<br>Cinghalais | ප | ඵ | බ | භ | ම |
| ភូមា<br>Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| សិង្ហ Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភុតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

*រីករាយ និងសួរជាបន្ត ៗ ទៅ ។*

*ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖*

> **ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**
> **ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**
> **មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**
> **បណ្ឌិតគប្បីដឹងបាន ។**

*ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។*

*ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖*

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** *ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។*

**២ ទ្រង់សម្ដែងធម៌មានហេតុផល** *ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។*

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទះរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទះក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ភាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសវីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមទឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីបាន ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់ ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង ឧបាសិកា ប៉ែន រម្មណីយ

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ ទូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សីងហួត

ឧបាសក ឈួន សំណាង ឧបាសក យឿម សារ៉េន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| **បរិព្វាជកវគ្គ** | |
| **អដ្ឋកថា ចូឡវច្ឆគោត្តសូត្រ ទី១** | **១** |
| *គិហិសញ្ញោជនៈ* | *៣* |
| **អដ្ឋកថា អគ្គិវច្ឆគោត្តសូត្រ ទី ២** | **៦** |
| *អធិប្បាយពីទិដ្ឋិ* | *៦* |
| **អដ្ឋកថា មហាវច្ឆគោត្តសូត្រ ទី ៣** | **១១** |
| **អដ្ឋកថា ទីឃនខសូត្រ ទី ៤** | **១៧** |
| *រឿង ល្អាងសូករខាតា* | *១៧* |
| *ទិដ្ឋិរបស់ទីឃនខៈ* | *១៨* |
| *គប្បីជ្រាបវារៈទី ២* | *២២* |
| *ការសម្រេចព្រះអរហន្តរបស់ព្រះសារីបុត្ត* | *២៩* |
| **អដ្ឋកថា មាគណ្ឌិយសូត្រ ទី ៥** | **៣១** |
| *ការពោលអំពីអាយតនៈ* | *៣៧* |
| *សេចក្តីប្រៀបកាមដូចជាទិព្វ* | *៤៣* |
| *សេចក្តីប្រៀបដូចបុរសកើតឃ្លង់* | *៤៥* |
| *សេចក្តីមិនមានរោគជាលាភដ៏ប្រសើរ* | *៤៧* |
| *គប្បីជ្រាបវារៈទី ២* | *៥០* |
| **អដ្ឋកថា សន្ទកសូត្រ ទី ៦** | **៥២** |

ការពោលតិរច្ឆានកថា ៥៣
វិនិច្ឆ័យក្នុងព្រហ្មចរិយវាសទី ៤ ៦៦
បទមានជាដើមថា បថវីកាយោ ៦៧
កម្ម ៣ , បុរិសភូមិ ៨..... ៦៩
សញ្ញីគភ៌ អសញ្ញីគភ៌ ទេវតា ៧ បីសាច ......... ៧១

**អដ្ឋកថា សក្កុលុទាយិសូត្រ ទី ៧** ៧៨
ការមានអាហារតិច ៨៣
ការសមាទានធុតង្គ ៨៤
សម្មប្បធាន ៤ ៩០
រឿងសាមណេរ ១ រូប វិនាសឈាន ៩៣
រឿងភិក្ខុ ៣០ រូប ១០១
សេចក្តីលាមក ៤ យ៉ាង ១០៤
កម្មលាមក ៤ យ៉ាងដទៃទៀត ១០៥
មគ្គរមែងចេញចាកឧបាទិន្ន និងអនុបាទិន្ន ១១០
អធិប្បាយ វិមោក្ខ ១១១
អធិប្បាយ អភិភាយតនៈ ១១៨
អធិប្បាយ កសិណកថា ១២០
ពស់សកសំណាកពជយ ៤ ប្រការ ១២៥
អធិប្បាយ ទិព្វសោត ១២៦
អធិប្បាយចេតោបរិយញ្ញាណ ១២៧

**អដ្ឋកថា សមណមុណ្ឌិកសូត្រ ទី ៨** ១៣០
ពោលអំពី អកុសលធម៌ ១៣៦
កាមសញ្ញាជាដើម ១៣៨

**អដ្ឋកថា ចូឡសកុលុទាយិសូត្រ ទី ៩** ១៤០
រឿងបិសាចធូលី ១៤៣
សច្ចកិរិយា ២ ប្រការ ១៤៩
ប្រវត្តិព្រះអស្សគុត្តត្ថេរ ១៥០

**អដ្ឋកថា វេខណាសសូត្រ ទី ១០** ១៥៣
កាមបុគ្គល និងនេក្ខម្មបុគ្គល ១៥៤

## រាជវគ្គ

**អដ្ឋកថា ឃដិការសូត្រ ទី ១** ១៥៧
ពោលអំពីការសើច ១៥៨
ការធ្វើស្រែល្អ ១៦៥
ព្រះធីតាឧរច្ឆទា ១៦៧
អាជីវៈរបស់ឃដិការស្មូនឆ្នាំង ១៦៨
ទីផ្ទះរបស់ឃដិការសម្បីភ្លៀង.....មិនអាចបៀតបៀនអស់នៃកប្ប ១៧១

**អដ្ឋកថា រដ្ឋបាលសូត្រ ទី ២** ១៧៥
ប្រវត្តិព្រះរដ្ឋបាល ១៧៥
ដំណើរបព្វជារបស់ព្រះរដ្ឋបាល ១៧៨
ការទៅមាតបិតានៃព្រះរដ្ឋបាល ១៨៤
បិតាលួងលោមព្រះរដ្ឋបាល ១៩២
ធម្មកថារបស់ព្រះរដ្ឋបាល ១៩៧
ធម្មុទ្ទេសៈ ២០៣

| | |
|---|---|
| **អដ្ឋកថា ទេវទូតសូត្រ ទី ៣** | **២០៩** |
| ព្រះសាស្តាកាលជាមឃទេវពោធិសត្វ | ២០៩ |
| មច្ចុ គឺ ទេវទូត | ២១១ |
| មង្គល ៥ ប្រការ | ២១៤ |
| គុណ ២ ប្រការ | ២១៦ |
| ការត្រិះរិះរបស់ព្រះបាទនិមិរាជ | ២១៧ |
| ការទៅកាន់ទេវលោករបស់ព្រះរាជានិមិរាជ | ២២០ |
| សេចក្តីប្រណែនរបស់សក្កទេវរាជ | ២២៥ |
| ព្រះពោធិសត្វស្តេចទ្រង់ទៅកាន់ទេវលោក ៤ ដង | ២២៦ |
| **អដ្ឋកថា មធុរសូត្រ ទី ៤** | **២២៨** |
| ការគោរព ២ ប្រការ | ២៣០ |
| **អដ្ឋកថា ពោធិរាជកុមារសូត្រ ទី ៥** | **២៣២** |
| ការមិនមានបុត្ត | ២៣៣ |
| ប្រវត្តិរបស់ព្រះបាទឧទេន | ២៣៦ |
| ប្រវត្តិរបស់ពោធិរាជកុមារ | ២៣៩ |
| សទ្ធា ៤ ប្រការ | ២៣៩ |
| **អដ្ឋកថា អង្គុលិមាលសូត្រ ទី ៦** | **២៤៤** |
| ប្រវត្តិព្រះអង្គុលិមាល | ២៤៤ |
| ការជ្រោសចំពោះអង្គុលិមាល | ២៥០ |
| ការតាមចាប់ចោររបស់ព្រះរាជា | ២៥៦ |
| អំណាចអង្គុលិមាល | ២៥៩ |

សេចក្តីករុណាដល់ព្រះអង្គុលិមាលក្នុងកិច្ចា ២៦០
សច្ចកិរិយារបស់ព្រះអង្គុលិមាល ២៦១
វិបាកនៃកម្មរបស់ព្រះអង្គុលិមាល ២៦៣
ការបរិភោគ ៤ ប្រការ ២៧០

អដ្ឋកថា បិយជាតិកសូត្រ ទី ៧ ២៧៣

អដ្ឋកថា ពាហិតិយសូត្រ ទី ៨ ២៧៧

អដ្ឋកថា ធម្មចេតិយសូត្រ ទី ៩ ២៨០
ការប្រហារពន្ធុលសេនាបតី និងបុត្ត ៣២ នាក់ ២៨០
គំនុំរបស់ការាយនៈជាក្មួយរបស់ពន្ធុលៈ ២៨២
ការគោះទ្វារ ៣ ប្រការ ២៨៤
ការដណ្តើមរាជ្យរបស់ការាយនសេនាបតី ២៨៦
ព្រះបាទបសេនទិកោសលទ្រង់វិលាល័យ ២៩០

អដ្ឋកថា កណ្ណកត្ថលសូត្រ ទី ១០ ២៩៤
ការផ្សេងគ្នានៃសេចក្តីព្យាយាម ២៩៧
សទ្ធា ៤ ប្រការ ២៩៨
ឧបមាដូចសត្វដំរី ២៩៩
ការដណ្តើមរាជ្យរបស់ការាយនសេនាបតី ២៨៦

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ

## ឈ្មោះ បបញ្ចសូទនី

## ភាគ ២៤

# បរិព្វាជកវគ្គ

## អ ដ្ឋ ក ថា

## តេវិជ្ជវច្ឆសូត្រ[១] ទី ១

**[១]** *តេវិជ្ជវច្ឆសូត្រ មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះថា* ***ឯកបុណ្ឌរិកេ*** *ដើមស្វាយសហោកហៅថា បុណ្ឌរិកៈ ។ ឈ្មោះថា* ***ឯកបុណ្ឌរិកោ*** *ព្រោះបុណ្ឌរិកនោះមានមួយដើមក្នុងអារាមនោះ ។ បទថា* ***ឯតទហោសិ*** *គឺ ព្រះមាន ព្រះភាគទ្រង់មានព្រះតម្រិះ ព្រោះមានព្រះបំណងស្ដេចចូលទៅក្នុងបរិព្វាជការាមនោះ ។ បទថា* ***ចិរស្សំ ខោ ភន្តេ*** *បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គស្ដេចនឹងមកយូរតែម្ដង សំដៅដល់ស្ដេចធ្លាប់មកតាមប្រក្រតី ។*

---

*១- បាលីថា ចូឡវច្ឆគោត្តសូត្រ ។*

[២] ក្នុងបទថា **ធម្មស្ស ច អនុធម្មំ** ធម៌សមគួរដល់ធម៌នេះ សព្វញ្ញុ-តញ្ញាណ ឈ្មោះថា ធម៌ ។ ការព្យាករណ៍ដល់មហាជន ឈ្មោះថា អនុធម៌ (ធម៌សមគួរ) ។ បទដ៏សេសមានន័យដូចពោលហើយក្នុងជីវកសូត្រនុ៎ះឯង ។ បទថា **ន មេ** មិនជាការពោលតាមពាក្យដែលយើងពោលហើយ គឺ តាំងនៅក្នុងសេចក្តីមិនឃើញប្រពៃ បដិសេធសូម្បីសេចក្តីឃើញប្រពៃ ។ ព្រោះព្រះសព្វញ្ញូមានប្រក្រតីឃើញវត្ថុទាំងពួង ទ្រង់បដិញ្ញាញាណទស្សនៈមិនមានចំណែកសល់ ដូច្នោះ ញាណទស្សនៈនេះគួរដឹងតាម ។ បទថា **ចរតោ ច មេ បច្ចុប្បដ្ឋិតំ** កាលយើងដើរទៅក្តី ញាណទស្សនៈប្រាកដហើយ មិនសមគួរដឹងតាម ។ ព្រោះព្រះមានព្រះភាគទ្រង់រលឹកដោយព្រះសព្វញ្ញុតញ្ញាណហើយទ្រង់ដឹង ។ ដូច្នោះ ទ្រង់តាំងនៅក្នុងសេចក្តីមិនឃើញប្រពៃ បដិសេធសូម្បីសេចក្តីឃើញប្រពៃ ទើបត្រាស់យ៉ាងនេះ ។

[៣] ក្នុងបទថា **អាសវានំ ខយា** នេះ ព្រះមានព្រះភាគ មិនបានត្រាស់ថាត្រឹមណា ។ ព្រោះអាសវៈទាំងឡាយដែលអស់ទៅហើយក្នុងគ្រាតែមួយ មិនមានអាសវៈដែលនឹងគប្បីអស់ទៅទៀត ។ ព្រះមានព្រះភាគទ្រង់ពោលសន្សេបព្រះគុណទាំងអស់ដោយវិជ្ជា ៣ ទាំងនេះ គឺ ទ្រង់សម្តែង

គុណ គឺ សេចក្តីដឹងក្នុងអតីតដោយបុព្វេនិវាសញ្ញាណ ១ ទ្រង់សម្តែងគុណ គឺ សេចក្តីដឹងក្នុងបច្ចុប្បន្នដោយទិព្វចក្ខុញ្ញាណ ១ ទ្រង់សម្តែងលោកុត្តរ-ញ្ញាណដោយអាសវក្ខយញ្ញាណ ១ ។

[៤] បទថា **គិហិសំយោជនំ** សញ្ញោជនៈរបស់គ្រហស្ថ គឺ សេចក្តីជាប់ជំពាក់របស់គ្រហស្ថ គឺ សេចក្តីប្រាថ្នាក្នុងបរិក្ខាររបស់គ្រហស្ថ ។ បទថា **នត្ថិ ខោ វច្ឆ** ម្នាលវច្ឆៈ មិនមានឡើយ គឺ អ្នកមិនទាន់លះគិហិសញ្ញោ-ជនៈ ឈ្មោះថា នឹងធ្វើទីបំផុតទុក្ខរមែងមិនមាន ។ សូម្បីបុគ្គលពួកណាតាំងក្នុងភេទគ្រហស្ថ គឺ សន្តតិមហាអាមាត្រ ឧគ្គសេនៈ សេដ្ឋីបុត្រវីតសោក-ធារកៈ ក៏សម្រេចព្រះអរហត្តបាន ។ សូម្បីបុគ្គលទាំងនោះ ក៏ញុំាងសេចក្តីប្រាថ្នាក្នុងសង្ខារទាំងពួងឲ្យស្ងួតទៅដោយមគ្គ ទើបសម្រេចបាន ។ តែកាលសម្រេចហើយ ក៏មិនតាំងនៅដោយភេទនោះ ។ ឈ្មោះថា ភេទជាគ្រហស្ថហើយ មិនអាចទ្រទ្រង់គុណដែលខ្ពស់បំផុតបាន ។ ព្រោះដូច្នោះ អ្នកតាំងនៅក្នុងភេទគ្រហស្ថនោះ សម្រេចព្រះអរហត្តហើយ រមែងបួស ឬបរិនិព្វានក្នុងថ្ងៃនោះឯង ។ តែភូម្មទេវតាតាំងនៅបាន ។ ព្រោះហេតុអ្វី ។ ព្រោះមានឱកាសដែលនឹងលាក់បាំងខ្លួនបាន ។

ក្នុងកាមភពដ៏សេស ព្រះអរិយបុគ្គល ៣ ពួក មានព្រះសោតាបន្ន ជាដើម អាចតាំងនៅបានក្នុងមនុស្សលោក ។ ក្នុងកាមាវចរទេវលោក ព្រះសោតាបន្ន និងព្រះសកទាគាមីតាំងនៅបាន ។ តែព្រះអនាគាមី និងព្រះខីណាស្រពនឹងតាំងនៅក្នុងកាមាវចរទេវលោកនេះមិនបាន ។ ព្រោះហេតុអ្វី ។ ព្រោះទីនោះមិនមែនជាទីនៅរបស់ជនអ្នកខ្មាសហើយ ។ និងទីនោះមិនមែនជាទីបិទបាំងដែលសមគួរដល់វិវេករបស់ព្រះខីណាស្រពទាំងនោះ ។

ដោយប្រការដូច្នេះ ព្រះខីណាស្រព ទើបបរិនិព្វានក្នុងទីនោះ ។ ព្រះអនាគាមីចុតិហើយទៅកើតក្នុងជាន់សុទ្ធាវាស ។ ព្រះអរិយៈសូម្បី ៤ ពួក រមែងតាំងនៅក្នុងភូមិខាងលើពីកាមាវចរទេវលោកបាន ។ បទថា **សោ-ចាបិ កម្មវាទី** គឺ អាជីវកដែលជាកម្មវាទី ។ បទថា **កិរិយវាទី** ព្រះមាន-ព្រះភាគទ្រង់ជំទាស់អ្នកដទៃ ហើយទ្រង់ពោលដល់ព្រះអង្គឯងប៉ុណ្ណោះ ក្នុងទីបំផុត ៨៩[១] កប្ប ។ បានឮថា ក្នុងគ្រានោះ ព្រះមហាសត្វទ្រង់ព្រះផ្នួសដើម្បីទ្រង់ដេញដោលសួរលទ្ធិបាសណ្ឌៈ (ជាលទ្ធិជាប់ទាក់ទងជាមួយតណ្ហានិងទិដ្ឋិ) ។ គ្រាទ្រង់ជ្រាបថា លទ្ធិបាសណ្ឌៈនោះមិនមានផល ទ្រង់ក៏មិន

(១) បាលីថា ៩១ កប្ប

បានលើកលះបង់សេចក្ដីព្យាយាម បានជាកិរិយាទៅកើតជានសួគ៌ ។ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ដោយប្រការដូច្នេះ ។

“ ចប់អដ្ឋកថាតេវិជ្ជវច្ឆសូត្រទី ១ ”

# អ ដ្ឋ ក ថា

## អគ្គិវច្ឆគោត្តសូត្រទី ២

[៥] *អគ្គិវច្ឆគោត្តសូត្រ* មានបទផ្តើមថា *ឯវមេ្មំ សុតំ* ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

[៦] ក្នុងបណ្តាបទទាំងនោះ បទថា **ន ខោ អហំ** យើងមិនបានឃើញយ៉ាងនោះ គឺ ព្រះមានព្រះភាគត្រាស់ក្នុងគ្រាដំបូងថា តថាគតមិនឃើញថា លោកទៀង ។ ក្នុងលើកទី ២ ត្រាស់ថា តថាគតមិនឃើញថា លោកសូន្យ ។ គប្បីជ្រាបការបដិសេធក្នុងគ្រប់វារៈ ដោយពាក្យមានជាដើមថា លោកមានទីបំផុត និងមិនមានទីបំផុត ដោយប្រការដូច្នេះ ។ វាទៈនេះថា **ហោតិ ច ន ច ហោតិ** សត្វស្លាប់ទៅហើយកើតទៀតខ្លះក៏មាន មិនកើតទៀតខ្លះក៏មាន ជាវាទៈថា ទៀងយ៉ាងណាមួយក្នុងទីនេះ ។ វាទៈនេះថា សត្វស្លាប់ទៅហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន គប្បីជ្រាបថា ជាអមរាវិក្ខេបៈ (ទិដ្ឋិបោះពាក្យបោះសំដីមិនឲ្យស្លាប់ខ្លួន) ។

[៨] បទថា **សទុក្ខំ** ប្រព្រឹត្តទៅដោយទុក្ខ គឺ ប្រព្រឹត្តទៅមួយអន្លើ

ដោយទុក្ខ ដោយទុក្ខដែលកើតពីកិលេស និងដោយទុក្ខដែលកើតពីវិបាក ។ បទថា **សវិឃាតំ** ប្រព្រឹត្តទៅជាមួយសេចក្តីលំបាក គឺ ប្រព្រឹត្តទៅព្រមទាំងដោយសេចក្តីលំបាក ដោយអំណាចទុក្ខ ២ ពួកនោះ ។ បទថា **សឧបា-យាសំ** ប្រព្រឹត្តទៅដោយសេចក្តីចង្អៀតចង្អល់ គឺ ប្រព្រឹត្តទៅព្រមដោយសេចក្តីចង្អៀតចង្អល់ដោយអំណាចទុក្ខទាំងនោះ ។ បទថា **សបរិឡាហំ** ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្តៅផ្សាដោយអំណាចនៃទុក្ខទាំងនោះឯង ។ បទថា **កិញ្ចិ ទិដ្ឋិគតំ** សេចក្តីថា វច្ឆៈទូលសួរថា សូម្បីសេចក្តីឃើញណាៗដែលព្រះអង្គទ្រង់ឃើញប្រពៃ ទ្រង់ពេញចិត្តហើយកាន់យកមានឬ ។ បទថា **អបនីតំ** នាំចេញទៅហើយ គឺ តថាគតកម្ចាត់ហើយ មិនចូលទៅរកទៀត ។ បទថា **ទិដ្ឋំ** គឺ ឃើញដោយបញ្ញា ។ បទថា **តស្មា** ព្រោះដូច្នោះ តថាគតបានឃើញការកើត និងការសាបសូន្យនៃខន្ធ ៥ ។ បទថា **សព្វមញ្ញិតានំ** ដែលសេចក្តីសម្គាល់ទាំងពួង គឺ ដែលសេចក្តីសម្គាល់ គឺ តណ្ហា ទិដ្ឋិ និងមានះសូម្បីទាំង ៣ ។ សូម្បីបទថា **មត្ថិតានំ** ក៏ជាវេវចនៈរបស់បទទាំងនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគគ្រាទ្រង់ចែកបទទាំងនោះហើយ កាល

នឹងទ្រង់សម្ដែង ទើបត្រាស់ថា **សព្វាហង្ការមមង្ការមានានុសយានំ** សេចក្ដីប្រកាន់ថាយើង ថារបស់យើង និងសេចក្ដីប្រកាន់ខ្លួនដែលដេកត្រាំនៅក្នុងសន្ដានទាំងពួង ។ ពិតណាស់ ក្នុងបទនេះគប្បីជ្រាបសេចក្ដីដូច្នេះ ។

សេចក្ដីប្រកាន់ថា យើង ជាទិដ្ឋិ ។ សេចក្ដីកាន់ថា របស់យើង ជាតណ្ហា ។ សេចក្ដីប្រកាន់ខ្លួនដែលដេកត្រាំនៅក្នុងសន្ដានជាមានះ ។ បទថា **អនុបាទា វិមុត្តោ** តថាគតផុតវិសេសហើយអំពីសេចក្ដីប្រកាន់មាំ គឺ ផុតព្រោះមិនប្រកាន់ធម៌ណាៗ ដោយឧបាទាន ៤ ។

**[៩]** បទថា **ន ឧបេតិ** គឺ មិនគួរ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងបទនេះ ដូចតទៅនេះ ៖

បទថា **ន ឧប្បជ្ជតិ** មិនកើតនេះ គួរដឹងតាម ។ តែព្រោះកាលត្រាស់យ៉ាងនេះ បរិព្វាជកនោះ គប្បីកាន់យកសេចក្ដីដាច់សូន្យ ។

ម្យ៉ាងទៀត បទថា **ឧប្បជ្ជតិ** រមែងកើត ។ គប្បីកាន់យកសេចក្ដីទៀងតែម្យ៉ាង ។ បទថា **ឧប្បជ្ជតិ ច នោ ឧប្បជ្ជតិ ច** កើតក៏មាន មិនកើតក៏មាន គប្បីកាន់យកសេចក្ដីទៀងចំណែកខ្លះ ។

បទថា **នេវ ឧប្បជ្ជតិ ន ច ឧប្បជ្ជតិ** កើតក៏មិនមែន មិនកើតក៏មិន

មែន ជាការឃើញបោះពាក្យបោះសំដីមិនឲ្យស្លាប់ខ្លួន ដូច្នោះ ព្រះមានព្រះ-ភាគទើបត្រាស់ថា វច្ឆបរិព្វាជកនេះ មិនមានទីពឹង មិនមានទីតោង នឹងមិនបានទីចូលទៅនៅជាសុខឡើយ ហើយទ្រង់តាំងនៅក្នុងសេចក្ដីមិនឃើញប្រពៃ ទ្រង់បដិសេធសេចក្ដីឃើញប្រពៃ ។

[១១] បទថា **អលំ** គួរហើយ គឺ អាចចាត់ចែង ។ បទថា **ធម្មោ** បានដល់ ធម៌ គឺ បច្ចយាការ ។ បទថា **យោគេន** គឺ មានសេចក្ដីព្យាយាមក្នុងផ្លូវដទៃ ។ បទថា **អាចរិយគេន** គឺ នៅក្នុងសម្នាក់របស់អាចារ្យដទៃអ្នកមិនដឹងបច្ចយាការ ។ បទថា **តេនហិ វច្ឆ** ម្នាលវច្ឆៈ អ្នកពោលថាតថាគតដល់ការឈ្លក់វង្វេង ដូច្នោះ តថាគតនឹងសួរអ្នកក្នុងសេចក្ដីនេះ ។ បទថា **អនាហារោ និព្វុតោ** ភ្លើងមិនមានគ្រឿងឆេះរលត់ទៅហើយ គឺ មិនមានបច្ច័យជាគ្រឿងឆេះ ។

[១២] បទថា **យេន រូបេន** ដោយរូបណា គឺ គប្បីបញ្ញត្តិសត្វថាមានរូបដោយរូបណា ។ បទថា **គម្ភីរោ** គឺ មានគុណដ៏ជ្រៅ ។ បទថា **អប្បមេយ្យោ** ដែលអ្នកណាៗ ប្រមាណមិនបាន គឺ មិនអាចកាន់យកប្រមាណបាន ។ បទថា **ទុប្បរិយោគាឡ្ហោ** ដល់បាន ដោយលំបាក គឺ ដឹងបាន

លំបាក ។ បទថា **សេយ្យថាបិ មហាសមុទ្ទោ** គឺ ដូចមហាសមុទ្រជ្រៅ ប្រមាណមិនបាន ដឹងបានលំបាក យ៉ាងណា សូម្បីព្រះនិព្វានក៏ដូច្នោះ ។ បទមានជាដើមថា **ឧបបជ្ជតិ** មិនគួរទាំងអស់ ព្រោះប្រារព្ធព្រះនិព្វានស្រេច នោះ ។ យ៉ាងណា ។ ដូចបទមានជាដើមថា បុគ្គលទៅកាន់ទិសខាងកើត ព្រោះប្រារព្ធភ្លើងដែលរលត់ហើយ មិនគួរទាំងអស់ ដូច្នេះ ។

បទថា **អនិច្ចតា** ព្រោះសេចក្តីមិនទៀង ។

បទថា **សារេ បតិដ្ឋិតំ** គឺ នៅសល់តែខ្លឹម គឺ លោកុត្តរធម៌ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ ។

" ចប់អដ្ឋកថា អគ្គិវច្ឆសូត្រទី ២ "

# អ ដ្ឋ ក ថា

## មហាវច្ឆគោត្តសូត្រទី ៣

[១៣] មហាវច្ឆសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះ បទថា សហកថី ពោលរួមគ្នា គឺ ឲ្យរលឹកដល់វត្ថុដែលធ្វើហើយ បានបន្តមេត្រីចំពោះគ្នាមកថា ខ្ញុំធ្លាប់ពោលនឹងលោកមកច្រើនហើយ ។

ព្រះមានព្រះភាគ ត្រាស់ពីរសូត្រមុនដល់វច្ឆបរិព្វាជកនោះ ។ ត្រាស់អព្យាវដ្ឋសំយុត្ត ក្នុងសំយុត្តនិកាយដល់វច្ឆបរិព្វាជកនោះ ។ នៅមានសេចក្តីដែលវច្ឆបរិព្វាជកពោលនឹងព្រះមានព្រះភាគ ទុកក្នុងអង្គុត្តរនិកាយ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន លោកទៀងឬហ្ន៎ វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃជាមោឃៈ ព្រោះហេតុនោះ ព្រះអង្គទ្រង់មិនបានព្យាករណ៍ប្រការនេះទុក ។ ព្រោះដូច្នោះ វច្ឆបរិព្វាជកទើបពោលយ៉ាងនេះ ។ សូម្បីព្រះសម្មាសម្ពុទ្ធទ្រង់ក៏នៅធ្វើការសង្គ្រោះ ទ្រង់បានឲ្យឱកាសដល់វច្ឆបរិព្វាជកនោះ អ្នកមក

ហើយ ព្រោះហេតុអ្វី ។ ព្រោះវច្ឆបរិព្វាជកនេះ ជាសស្សតទិដ្ឋិ (មានការឃើញថាទៀង) ។ ម្យ៉ាងទៀត អ្នកជាសស្សតទិដ្ឋិទាំងឡាយ រមែងមិនលះបង់លទ្ធិក្នុងពេលឆាប់ៗ នោះ រមែងបរិសុទ្ធិបានដោយវេលាយូរ ដូចសំពត់ចាស់ប្រលាក់ប្រេងកាវ ។ ព្រះមានព្រះភាគទ្រង់ឃើញថា បរិព្វាជកនេះទៅមកៗ នឹងលះបង់លទ្ធិហើយ បួសក្នុងសម្នាក់របស់តថាគត នឹងធ្វើឲ្យជាក់ច្បាស់អភិញ្ញា ៦ ហើយនឹងជាអរិយសាវកអ្នកបានអភិញ្ញា ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបធ្វើការសង្គ្រោះ ទ្រង់ឲ្យឱកាសដល់វច្ឆបរិព្វាជកអ្នកមកហើយមកទៀត នេះជាការទៅលើកចុងបន្លាស់របស់វច្ឆបរិព្វាជកនោះ ។ ព្រោះក្នុងសូត្រនេះ វច្ឆបរិព្វាជកនោះ សម្រេចចិត្តថា ទោះជាស្លាប់ក៏ដោយ ឃើងនឹងទៅគាល់ព្រះសមណគោតម ហើយនឹងបួស ដូចបុគ្គលសួនឈើប្រត់ចុះទៅក្នុងទឹក ដូច្នោះ ។ ព្រោះដូច្នោះ វច្ឆបរិព្វាជកកាលនឹងទូលសូមព្រះធម៌ទេសនា ទើបពោលពាក្យមានជាដើមថា **សាធុ មេ ភវំ គោតមោ** ខ្ញុំព្រះអង្គសូមឱកាស សូមព្រះគោតមដ៏ចម្រើន ចូរទ្រង់សម្តែងធម៌ទាំងដែលជាកុសល និងអកុសល ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគទ្រង់សម្តែងទេសនាយ៉ាងសង្ខេប ដោយមូលរបស់កុសលាកុសល យ៉ាងពិស្តារដោយ

កម្មបថ ៗម្យ៉ាងទៀត ក្នុងទីនេះទេសនាដោយអំណាចមូល ទ្រង់សង្ខេបទេសនាទុកដោយអំណាចកម្មបថ ទ្រង់សង្ខេបទុក ក៏ដូចគ្នានឹងទ្រង់សម្តែងដោយពិស្តារ ៗម្យ៉ាងទៀត ឈ្មោះថា ទេសនាយ៉ាងពិស្តារ ដោយការសម្តែងជាបអស់ មិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះសូម្បីសមន្តបដ្ឋាន ២៤ និងមូលទាំងពួង ក៏ទ្រង់នៅសង្ខេបចុះក្នុងអភិធម្មបិដក ៧ គម្ពីរ ដូច្នោះគប្បីជ្រាបថា ទ្រង់សម្តែងសង្ខេបដោយអំណាចនៃមូលខ្លះ នៃកម្មបថខ្លះ ៗ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទ មានជាដើមថា **បាណាតិបាតា វេរមណី កុសលំ** ចេតនាគ្រឿងវៀរចាកបាណាតិបាត ជាកុសលដូចតទៅនេះ ៖

កាមាវចរធម៌ ៧ តាមលំដាប់, ធម៌ ៣ មានអនភិជ្ឈាជាដើម ប្រព្រឹត្តទៅក្នុងភូមិ ៤ រមែងគួរ ៗ បទថា **យតោ ខោ វច្ឆ ភិក្ខុនោ** ម្នាលវច្ឆៈ ព្រោះតណ្ហាដែលភិក្ខុលះបានហើយ អ្នកមិនបានកំណត់ទុកក៏ពិត ៗ តែគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់បទនេះទុក ទ្រង់សំដៅដល់ព្រះអង្គប៉ុណ្ណោះ ក្នុងជីវកសូត្រ ក្នុងចង្កីសូត្រ និងក្នុងសូត្រនេះ យ៉ាងនេះ ៗ បទថា **អត្ថិ បន** នៅមានឬ វច្ឆៈទូលសួរថា ខ្ញុំព្រះអង្គសូមសួរថា នៅមានឬ ៗ ន័យថា ដូច្នោះ មានលទ្ធិថា ក្នុងសាសនានោះមានសាស្តាប៉ុណ្ណោះ ជាអរហន្ត ៗ

ចំណែកសាវកដែលសម្រេចព្រះអរហត្តមិនមាន ។ម្យ៉ាងទៀត ព្រះសមណ-គោតមត្រាស់ដូចការត្រាស់ចំពោះភិក្ខុមួយរូបថា **យតោ ខោ វច្ឆ ភិក្ខុនោ** ដូច្នេះ ។ វច្ឆៈសួរដោយគិតថា យើងនឹងសួរសេចក្តីនេះថា សាវករបស់ព្រះសមណគោតម សម្រេចព្រះអរហត្តមានឬទេហ្ន៎ ។

ក្នុងបទទាំងនោះ បទថា **តិដ្ឋតុ** គឺ ព្រះគោតមចូរលើកទុក ។ អធិប្បាយថា ព្រោះព្រះគោតមជាព្រះអរហន្ត ប្រាកដហើយក្នុងលោក ។ កាលព្រះអង្គទ្រង់ព្យាករណ៍ហើយ វច្ឆៈទូលសួរបញ្ហាជាប់ទាក់ទងនឹងភិក្ខុនីជាដើមតទៅ ។ សូម្បីព្រះមានព្រះភាគ ទ្រង់ក៏ព្យាករណ៍ដល់គេហើយ ។ បទថា **អារាធកោ** អ្នកពេញចិត្ត អ្នកឲ្យសម្រេច អ្នកធ្វើឲ្យបរិបូរណ៌ ។ បទថា **សេក្ខាយ វិជ្ជាយ បត្តព្វំ** គប្បីសម្រេចវិជ្ជារបស់ព្រះសេក្ខៈ គឺ សម្រេចផល ៣ ខាងក្រោម ។ ព្រះមានព្រះភាគត្រាស់ថា ទាំងអស់នោះតថាគតសម្រេចហើយ ។ ចំណែកអាចារ្យទណ្ឌវាទី (អ្នកពោលជំទាស់) ពោលថា ភិក្ខុនោះសម្រេចអរហត្តមគ្គប៉ុណ្ណោះ តែមិនទាន់សម្រេចផល ព្រោះពាក្យថា សេក្ខ-ធម៌ដូចម្តេច ? មគ្គ ៤ មិនទាន់ដល់ទីបំផុត និងសាមញ្ញផល ៣ ក៏ជាខាងក្រោម ។ ដោយហេតុនោះ រមែងពោលដល់សេចក្តីព្យាយាមឲ្យក្រែ-

លែងៗ ឡើងទៅដើម្បីសម្រេចផលនោះ ។ គួរឲ្យអ្នកនោះដឹងយ៉ាងនេះថា បើអ្នកណាលះកិលេសទាំង ៥ បានហើយ ជាព្រះសេក្ខៈបរិបូណ៌ មានធម៌មិនសាបសូន្យ ដល់កាពជំនាញផ្លូវចិត្ត មានឥន្ទ្រិយតាំងមាំ អ្នកនោះឯងលោកពោលថា ជាអ្នកមានខ្លួនរឹងមាំហើយ ។

ពិតណាស់ ព្រះអនាគាមីបុគ្គល ជាព្រះសេក្ខៈបរិបូណ៌ដោយចំណែកមួយ ។ វច្ឆៈពោលថា គប្បីសម្រេចវិជ្ជារបស់ព្រះសេក្ខៈ សំដៅដល់ ព្រះអនាគាមីបុគ្គលនោះ ។

ឈ្មោះថា ពាក្យសួរ រមែងមិនមានដល់អ្នកតាំងនៅក្នុងអនាគាមិមគ្គនោះ ព្រោះមគ្គមានខណៈចិត្តតែមួយ ។ បើសួរថា ដោយសូត្រនេះ សូម្បីមគ្គក៏មានច្រើនខណៈចិត្ត ដូច្នោះឬ ។

ឆ្លើយថា នោះមិនមែនព្រះពុទ្ធវចនៈ ទាំងសេចក្តីនៃកថាដែលពោលហើយក៏ខុស ។ ព្រោះដូច្នោះ គប្បីជ្រាបថា អ្នកតាំងនៅក្នុងអនាគាមិផលហើយ រមែងចម្រើនវិបស្សនាដើម្បីអរហត្តមគ្គ ក៏ព្រោះអរហត្តមគ្គមិនបានជាឧបនិស្ស័យដល់សុទ្ធអរហត្តតែម្យ៉ាង រមែងជាឧបនិស្ស័យសូម្បីដល់អភិញ្ញា ៦ ។ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា វច្ឆភិក្ខុនេះ ធ្វើកម្មក្នុងសមថៈ

យ៉ាងនេះហើយ នឹងញុំាងអភិញ្ញា ៥ ឲ្យកើត ។ ធ្វើកម្មក្នុងវិបស្សនាហើយ ទើបនឹងសម្រេចព្រះអរហត្ត ។ នឹងជាមហាសាវកអ្នកបានអភិញ្ញា ៦ ដូច្នេះ ទើបទ្រង់មិនពោលត្រឹមតែវិបស្សនា ទ្រង់ប្រាប់ទាំងសមថៈ និងវិបស្សនា ។ បទថា **សតិ សតិ អាយតនេ** គឺ កាលហេតុមានហើយ ។ ហេតុក្នុងទីនេះ គឺអ្វី ។ គប្បីជ្រាបថា ឈានដែលជាបាទនៃអភិញ្ញាក្តី ព្រះអរហត្តក្នុងទីបំផុតក្តី វិបស្សនាដើម្បីព្រះអរហត្តក្តី ឈ្មោះថាជាហេតុ ។ បទថា **បរិចិណ្ណោ មេ ភគវា** ខ្ញុំព្រះអង្គបានបម្រើព្រះមានព្រះភាគហើយ សេចក្តីថា ពិតហើយ ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា អ្នកបម្រើព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ជាអ្នកដែលព្រះខីណាស្រពបម្រើហើយ ។ ដោយប្រការដូច្នេះ ព្រះថេរៈកាលព្យាករណ៍ព្រះអរហត្តដោយសង្ខេប ទើបពោលយ៉ាងនេះ ។ មួយវិញទៀត ភិក្ខុទាំងនោះមិនដឹងសេចក្តីនោះ ។ កាលមិនដឹងក៏មិនទទួលពាក្យរបស់ព្រះថេរៈនោះ ទើបនាំគ្នាទៅក្រាបទូលព្រះមានព្រះភាគ ។ បទថា **ទេវតា** បានដល់ ទេវតាអ្នកបានគុណទាំងនោះ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា មហាវច្ឆគោត្តសូត្រទី ៣ "

# អ ដ្ឋ ក ថា

## ទីឃនខសូត្រទី ៤

[៣០] *ទីឃនខសូត្រ* មានបទចាប់ផ្តើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះ បទថា ***សូករខាតាយំ*** ក្នុងល្អាងដែលមានឈ្មោះយ៉ាងនេះថា សូករខាតា ។ មានរឿងពោលទុកថា កាលសាសនាព្រះពុទ្ធកស្សបៈ ល្អាងនោះ កើតខាងក្នុងផ្ទៃផែនដីដែលដុះឡើងក្នុងមួយពុទ្ធន្តរ ។ ថ្ងៃមួយ ជ្រូកមួយក្បាលកឈ្ងុសដីក្នុងទីជិតខត្តបិទល្អាងនោះ ។ កាលភ្លៀងធ្លាក់ បានប្រាកដខត្តបិទនោះ ព្រោះត្រូវភ្លៀងហូរប្រោះ ព្រានព្រៃម្នាក់ឃើញក៏ចូលទៅ ទើបគិតថា កាលមុនមិនមានអ្នកមានសីលនៅក្នុងល្អាង ។ យើងនឹងរៀបចំល្អាងនោះ ។ ទើបនាំធូលីចេញ បោសល្អាងឲ្យស្អាត ហើយធ្វើជញ្ជាំងជុំវិញ ធ្វើទ្វារ និងបង្អួច ធ្វើល្អាងឲ្យមានបរិវេណក្រាលដោយខ្សាច់ដូចផែនប្រាក់ ធ្វើយ៉ាងវិចិត្រ លាបកំបោរសជាបសម្រេចរៀបរយយ៉ាងល្អ ហើយតម្កល់គ្រែ និងតាំង បានថ្វាយទីប្រថាប់របស់ព្រះ-

មានព្រះភាគ ។ ល្អាងជ្រៅ តែឡើងចុះស្រួល ។ បទថា **សូករខាតាយំ** នេះ លោកពោលសំដៅដល់ល្អាងនោះ ។ បទថា **ទីឃនខោ** ជាឈ្មោះរបស់បរិព្វាជកនោះ ។ បទថា **ឧបសង្កមិ** ចូលទៅគាល់ ព្រោះហេតុអ្វី ទីឃនខ-បរិព្វាជក ទើបចូលទៅគាល់ ។ ដំណាលមកថា ទីឃនខបរិព្វាជកនោះ កាលព្រះថេរៈបួសបានកន្លះខែ គិតថា លោកអ៊ំរបស់យើងទៅកាន់លទ្ធិដទៃដែលខុសហើយ តាំងនៅអស់កាលដ៏យូរ ។ តែឥឡូវនេះ កាលលោកអ៊ំទៅគាល់ព្រះសមណគោតមបានកន្លះខែហើយ ប្រាថ្នានឹងទៅដោយសង្ឃឹមថា យើងនឹងស្តាប់ដំណឹងរបស់លោកអ៊ំ ។ យើងនឹងដឹងពាក្យទូន្មានដ៏ពីរោះនោះ ។ ព្រោះដូច្នោះ ទីឃនខៈទើបចូលទៅគាល់ ។ បទថា **ឯកមន្តំ ឋិតោ** បានឈរក្នុងទីដ៏សមគួរមួយ ន័យថា ក្នុងខណៈនោះព្រះថេរៈឈរបក់ផ្លិតថ្វាយព្រះមានព្រះភាគ ។ បរិព្វាជកដោយមានហិរិឱត្តប្បៈក្នុងលោកអ៊ំ ទើបឈរទូលសួរបញ្ហា ដោយហេតុនោះលោកទើបពោលថា **ឯកមន្តំ ឋិតោ** ដូច្នេះ ។ បទថា **សព្វំ មេ ន ខមតិ** វត្ថុទាំងពួងមិនគួរដល់យើង គឺ វត្ថុដែលកើតឡើងទាំងអស់ មិនគួរដល់យើង ។ បរិព្វាជកពោលដោយសេចក្តីប្រាថ្នាថាបដិសន្ធិទាំងឡាយមិនគួរ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ទើបបរិព្វាជកនោះ

សម្តែងថា យើងជាអ្នកមានវាទៈថា ដាច់សូន្យ ។ តែព្រះមានព្រះភាគ កាល នឹងទ្រង់បិទបាំងសេចក្តីប្រាថ្នារបស់បរិព្វាជកនោះហើយ ទ្រង់សម្តែងដល់ ទោសក្នុងសេចក្តីមិនគួរ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **យាបិ ខោ តេ** ដូច្នេះ ។ ក្នុងបទនោះមានសេចក្តីថា សូម្បីសេចក្តីឃើញរបស់អ្នក ក៏ មិនគួរ គឺ សូម្បីសេចក្តីឃើញដែលអ្នកពេញចិត្តប្រកាន់ទុកលើកដំបូង ក៏ មិនគួរ ។ បទថា **ឯសា ចេ មេ ភោ គោតម ទិដ្ឋិខមេយ្យ** បពិត្រ ព្រះគោតមដ៏ចម្រើន បើសេចក្តីឃើញនេះគួរដល់ខ្ញុំ សេចក្តីថា បើសេចក្តី ឃើញថា វត្ថុទាំងពួងមិនគួរដល់យើង យើងជាអ្នកឃើញថា ព្រោះវត្ថុទាំង ពួងមិនគួរដល់យើង គប្បីគួរទេ ។ លោកទើបពោលថា **សព្វំ មេ ន ខមតិ** វត្ថុទាំងពួងមិនគួរដល់យើង ។ សូម្បីសេចក្តីឃើញនោះ ក៏គប្បីជាដូច្នោះ ។ សូម្បីសេចក្តីឃើញនោះក៏គួរ ដូចសេចក្តីឃើញនេះ សូម្បីកាន់យកដោយ ការកាន់យកវត្ថុទាំងពួង ដូច្នោះ ។ បរិព្វាជកពោលដោយយល់ថា យើងដឹង ទោសដែលលើកក្នុងវាទៈរបស់ខ្លួនឡើងយ៉ាងនេះ ហើយរក្សាវាទៈនោះ ។ តែដោយអត្ថ រមែងទទួលថា សេចក្តីឃើញនោះរបស់បរិព្វាជក មិនគួរដល់ យើងដូច្នេះ ។ម៉្យាងទៀត វត្ថុទាំងពួងមិនពេញចិត្តដល់យើងដោយការឃើញ

របស់អ្នកដែលមានការឃើញ មិនគួរ មិនប្រពៃ ព្រោះហេតុនោះ ទើបជាសេចក្ដីឃើញដែលពេញចិត្ត ។ សូម្បីអ្នកនោះ គប្បីជាអ្នកមិនគួរមិនពេញចិត្ត ព្រោះហេតុនោះ ទើបរមែងទទួលបានថា វត្ថុទាំងពួងរមែងគួរ រមែងពេញចិត្ត ។ តែបរិព្វាជកនោះ មិនទទួលសេចក្ដីនោះ ។ រមែងប្រកាន់សេចក្ដីដាច់សូន្យនៃឧច្ឆេទទិដ្ឋិសូម្បីនោះតែម្យ៉ាងប៉ុណ្ណោះ ។ ដោយហេតុនោះព្រះមានព្រះ-ភាគ ទើបត្រាស់ថា **អតោ ខោ តេ អគ្គិវេស្សន ។ល។ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយន្តិ** សេចក្ដីថា ម្នាលអគ្គិវេស្សនៈ ជនក្នុងលោកដែលពោលយ៉ាងនេះថា សូម្បីសេចក្ដីឃើញនោះ ក៏គប្បីជាដូច្នោះ សូម្បីសេចក្ដីឃើញនោះក៏គប្បីជាដូច្នោះទាំងនោះ ដូច្នេះ ជនទាំងនោះ លះសេចក្ដីឃើញនោះមិនបាន និងនៅប្រកាន់សេចក្ដីឃើញដទៃច្រើនជាង គឺ ច្រើនជាងអ្នកដែលលះបាន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អតោ** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថថា អ្នកលះបាន ។ សេចក្ដីថា បុគ្គលពួកណាលះបាន បុគ្គលពួកនោះនឹងសួរថា បុគ្គលពួកណាហ្នឹ លះមិនបាន ។ និងបុគ្គលទាំងនោះឯងមានច្រើនជាង ។ **ហិ** អក្សរក្នុងបទនេះថា **ពហូ ហិ ពហុតរា** មានច្រើន គឺ ច្រើនជាង នេះត្រឹម

តែនិបាត ។ អធិប្បាយថា ច្រើនជាង ច្រើនជាង ។ សូម្បីក្នុងបទថា តនូ ហិ តនុតរា មានតិច គឺ តិចជាង សេចក្តីខាងក្រោយក៏មានន័យនេះដូចគ្នា ។

បទថា យេ ឯវមាហំសុ គឺ ជនពួកណាពោលហើយយ៉ាងនេះ ។ បទថា តំ ចេវទិដ្ឋឹ ។បេ។ ឧបាទិយន្តិ ជនទាំងនោះលះសេចក្តីឃើញនោះ មិនបាន និងនៅប្រកាន់សេចក្តីឃើញដទៃនោះ គឺ នៅលះសេចក្តីឃើញពីខាងដើមមិនបាន ។ នៅប្រកាន់សេចក្តីឃើញដទៃទៀត ។

មួយ៉ាងទៀត ក្នុងបទនេះមានអធិប្បាយដូចតទៅនេះ ប្រកាន់សូម្បីសេចក្តីទៀងហើយ ក៏មិនលះសេចក្តីទៀងនោះ មិនអាចនឹងប្រកាន់សេចក្តីដាច់សូន្យ ឬសេចក្តីទៀងណាមួយបាន ។ ប្រកាន់សូម្បីសេចក្តីដាច់សូន្យហើយ ក៏មិនលះសេចក្តីដាច់សូន្យនោះ មិនអាចនឹងប្រកាន់សេចក្តីទៀង ឬសេចក្តីទៀងណាមួយបាន ។ ប្រកាន់សូម្បីសេចក្តីទៀងណាមួយហើយ មិនលះសេចក្តីទៀងណាមួយនោះ មិនអាចប្រកាន់សេចក្តីទៀង ឬសេចក្តីដាច់សូន្យបាន មួយ៉ាងទៀត មិនលះសេចក្តីទៀងខាងដើម អាចប្រកាន់សេចក្តីដទៃបានយ៉ាងណា ។ ព្រោះសម័យមួយប្រកាន់ថា រូបទៀងហើយ សម័យត.មកមិនប្រកាន់រូបសុទ្ធៗ ប៉ុណ្ណោះថា ទៀង សូម្បីវេទនាក៏ទៀង សូម្បីវិញ្ញាណ

ក៏ទៀត ។ ក្នុងសេចក្តីដាច់សូន្យក្តី ក្នុងសេចក្តីទៀងណាមួយក្តី ក៏មានន័យនេះដូចគ្នា ។ គប្បីយល់ថា សូម្បីក្នុងអាយតនៈក៏ដូចក្នុងខន្ធ ។ លោកពោលបទថា **តំ ចេវ ទិដ្ឋឹ ។បេ។ ឧបាទិយន្តិ** លះសេចក្តីឃើញនោះមិនបាន និងនៅប្រកាន់សេចក្តីឃើញដទៃ ដូច្នេះ សំដៅដល់សេចក្តីនេះ ។

គប្បីជ្រាបសេចក្តីក្នុងវារៈទី ២ ដូចតទៅនេះ ៖

បទថា **អតោ** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថថា នៅលះមិនបាន សេចក្តីថា បុគ្គលណានៅលះមិនបាន ព្រោះដូច្នោះ បុគ្គលនោះនឹងសួរថា បុគ្គលណាហ្ន៎លះបាន ។ បុគ្គលនោះឯងមានតិចជាង ។ បទថា **តំ ចេវ ទិដ្ឋឹ ។បេ។ នឧបាទិយន្តិ** ជនទាំងនោះលះសេចក្តីឃើញនោះបាន និងមិនទាន់ប្រកាន់សេចក្តីឃើញដទៃសេចក្តីថា លះសេចក្តីឃើញពីដើមនោះបាន និងមិនប្រកាន់យកសេចក្តីឃើញដទៃ ។ យ៉ាងណា ។ ព្រោះក្នុងសម័យមួយ ប្រកាន់ថា រូបទៀង ហើយសម័យត.មកឃើញទោសក្នុងសេចក្តីឃើញនោះ ហើយលះបានដោយគិតថា សេចក្តីឃើញរបស់យើងនេះគ្រោតគ្រាត គឺ រមែងលះបង់បានថា មិនមែនសេចក្តីឃើញថា រូបទៀងតែម្យ៉ាងប៉ុណ្ណោះ គ្រោតគ្រាត ឃើញថា សូម្បីវេទនាក៏ទៀងគ្រោតគ្រាត សូម្បីវិញ្ញាណក៏ទៀងគ្រោតគ្រាត

ដូចគ្នា ។ ក្នុងសេចក្តីដាច់សូន្យក្តី ក្នុងសេចក្តីទៀងណាមួយក្តី ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបថា សូម្បីក្នុងអាយតនៈក៏ដូចក្នុងខន្ធ ដូច្នោះ ។ ដោយប្រការដូច្នេះ ឈ្មោះថា លះបង់សេចក្តីឃើញពីដើមនោះបាន និងមិនប្រកាន់សេចក្តីឃើញដទៃ ។

[៣១] បទថា **សន្តិ អគ្គិវេស្សន** ព្រះមានព្រះភាគទ្រង់ប្រារព្ធឡើង ព្រោះហេតុអ្វី ម្ចាស់លទ្ធិដែលប្រកាន់ថា ដាច់សូន្យនេះ រមែងបិទបាំងលទ្ធិរបស់ខ្លួន តែកាលពោលគុណរបស់លទ្ធិនោះ នឹងធ្វើលទ្ធិរបស់ខ្លួនឲ្យប្រាកដ ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្តែងលទ្ធិដ៏សេសតែម្យ៉ាងដូចគ្នាហើយ ដើម្បីទ្រង់សម្តែងចែកពីគ្នា ទើបទ្រង់ប្រារព្ធទេសនានេះ ។

គប្បីជ្រាបសេចក្តីក្នុងបទមានជាដើមថា **សរាគាយ សន្តិកេ** ក្នុងទីជិតនៃកិលេស ដែលប្រព្រឹត្តទៅដោយសេចក្តីពេញចិត្ត ដូចតទៅនេះ ។ ជិតកិលេសជាគ្រឿងត្រេកអរក្នុងវដ្តៈ ដោយអំណាចរាគៈ គឺ ជិតកិលេសជាគ្រឿងចងក្នុងវដ្តៈ ដោយគ្រឿងចង គឺ តណ្ហា និងទិដ្ឋិ អធិប្បាយថា លេបដោយសេចក្តីត្រេកអរក្នុងតណ្ហា និងទិដ្ឋិ ដោយអំណាចនៃតណ្ហា និងទិដ្ឋិនុ៎ះឯង ហើយជិតសេចក្តីប្រកាន់ និងសេចក្តីប្រកាន់មាំ ។ គប្បីជ្រាបសេចក្តី

ក្នុងបទមានជាដើមថា **វិភគាយ សន្តិកេ** ក្នុងទីជិតដើម្បីកម្ចាត់សេចក្តីពេញចិត្ត ដូចតទៅនេះ គប្បីជ្រាបសេចក្តីដោយន័យមានជាដើមថា ជិតគ្រឿងត្រេកអរក្នុងវដ្តៈ ។ មួយាំងទៀត ក្នុងបទនេះ សេចក្តីឃើញថា ទៀង មានទោសតិច យឺតយូរក្នុងការលះ ។ សេចក្តីឃើញថា ដាច់សូន្យ មានទោសច្រើន មានការលះបង់រហ័ស ។ យ៉ាងណា ។ ព្រោះអ្នកមានវាទៈថា ទៀង រមែងមិនដឹងលោកនេះ និងលោកមុខថា មាន ។ រមែងដឹងផលនៃកម្មល្អ កម្មអាក្រក់ថា មាន ទើបធ្វើកុសល កាលធ្វើអកុសលរមែងខ្លាច មិនពេញចិត្ត មិនត្រេកអរក្នុងវដ្តៈ ។ នៅចំពោះមុខព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ រមែងមិនអាចលះបង់ការឃើញបានរហ័ស ដូច្នោះលោកទើបពោលថា ការឃើញថា ទៀងនោះ មានទោសតិចលះបង់បានយឺត ។ ចំណែកអ្នកមានវាទៈថាដាច់សូន្យ រមែងដឹងលោកនេះ លោកខាងមុខថា មាន ។ តែមិនដឹងផលរបស់កម្មល្អ និងកម្មអាក្រក់ថា មាន ទើបមិនធ្វើកុសល ។ កាលធ្វើអកុសល រមែងមិនខ្លាច មិនពេញចិត្ត មិនត្រេកអរក្នុងវដ្តៈ នៅចំពោះមុខព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ រមែងលះបង់ការឃើញបានរហ័ស អាចបំពេញបារមីជាព្រះពុទ្ធបាន ។ កាលមិនអាច ក៏សន្សំ បុណ្យបារមីជាសាវក ហើយ

និព្វាន ។ ព្រោះដូច្នោះ លោកទើបពោលថា សេចក្ដីឃើញថា ដាច់សូន្យ មានទោសច្រើន លះបង់បានរហ័ស ។ តែបរិព្វាជកនោះ កំណត់សេចក្ដីនោះ មិនបាន ទើបពណ៌នា សរសើរសេចក្ដីឃើញនោះ លុះកំណត់បានថា សេចក្ដីឃើញរបស់យើងល្អពិតប្រាកដ ទើបពោលពាក្យមានជាដើមថា **ឧក្កំសេតិ មេ ភវំ** ព្រះគោតម ទ្រង់លើកសរសើរការឃើញរបស់ខ្ញុំព្រះអង្គ ។

ឥឡូវនេះ ព្រោះបរិព្វាជកនេះពោរពេញដោយសេចក្ដីឃើញថា ដាច់សូន្យប៉ុណ្ណោះ ដូចកុណ្ឌីពេញដោយទឹកល្វីង ។ បរិព្វាជកនោះ នៅលះបង់ទឹកនោះមិនបាន ទើបមិនអាចដាក់ប្រេង ទឹកឃ្មុំជាដើម ចុះក្នុងកុណ្ឌីនោះ ។ សូម្បីដាក់ចុះទៅហើយ ក៏កាន់យកមិនបាន យ៉ាងណា បរិព្វាជកនោះនៅលះបង់សេចក្ដីឃើញនោះមិនបាន ទើបមិនគួរដើម្បីបានមគ្គផល ដូច្នោះ ។ ព្រោះដូច្នោះ ដើម្បីឲ្យបរិព្វាជកលះទិដ្ឋិនោះ ទើបទ្រង់ផ្ដើមបទមានជាដើមថា **តត្រ អគ្គិវេស្សន** ។ បទថា **វិគ្គហោ** គឺ ការឈ្លោះ ។

**[៣២]** បទថា **ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ** ការលះបង់ទិដ្ឋិទាំងនោះ រមែងមានដោយប្រការដូច្នេះ គឺ គ្រាឃើញទោសនៃការឈ្លោះហើយ ទើបលះបង់ទិដ្ឋិទាំងនោះបាន ។ បរិព្វាជកនោះ គិតថា ប្រយោជន៍អ្វីដល់

យើងដោយការឈ្មោះជាដើមនេះ ។ ទើបលះសេចក្តីឃើញថា ដាច់សូន្យនោះបាន ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា តថាគតនឹងឲ្យបរិព្វាជកបំពេញឱសថជាអមតៈទុកក្នុងហទយៈ ដូចបុគ្គលដាក់ទឹកដោះថ្លា និងខ្លាញ់ខាប់ជាដើម ចុះក្នុងកុណ្ឌីដែលចាក់ទឹកចេញហើយ ដូច្នោះ កាលនឹងទ្រង់ប្រាប់វិបស្សនាដល់បរិព្វាជកនោះ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **អយំ ខោ បន អគ្គិវេស្សន កាយោ** ម្នាលអគ្គិវេស្សនៈ ក៏កាយនេះ ជាទីប្រជុំមហាភូតរូបទាំង ៤ ដូច្នេះ ។ លោកពោលសេចក្តីនៃបទនោះទុកហើយក្នុងវម្មិកសូត្រ ។ សូម្បីបទមានជាដើមថា **អនិច្ចតោ** ក៏ពោលទុកពិស្តារហើយក្នុងខាងក្រោយ ។

បទថា **យោ កាយស្មឹ ឆន្ទោ** បានដល់ ការពេញចិត្តក្នុងកាយ ។

បទថា **ស្នេហោ** សេចក្តីស្នេហា គឺ សេចក្តីស្រឡាញ់ដោយតណ្ហា ។

បទថា **កាយន្វយតា** គឺ ការនៅក្នុងអំណាចរបស់កាយ ។ អធិប្បាយថា កិលេស ដែលចូលទៅប្រកាន់កាយ ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងរូបកម្មដ្ឋានយ៉ាងនេះហើយ ឥឡូវ

នេះ កាលទឹងទ្រង់សម្តែងអរូបកម្មដ្ឋាន ទើបត្រាស់ថា **តិស្សោ ខោ** វេទនា ៣ ជាដើម ។ កាលទឹងទ្រង់ សម្តែងសេចក្តីដែលវេទនា ៣ ទាំងនោះមិនលាយគ្នា ទើបត្រាស់ថា **យស្មឹ អគ្គិវេស្សនសមយេ** ម្នាលអគ្គិវេ-ស្សនៈ ក្នុងសម័យណាជាដើម សេចក្តីសង្ខេបក្នុងបទនោះមានដូច្នេះ សម័យណាសោយវេទនាតែម្យ៉ាង ក្នុងបណ្តាសុខវេទនាជាដើម សម័យនោះវេទនាដែលឈ្មោះថា អន្តុយឃ្លាំមើលវារៈ ឬឱកាសរបស់ខ្លួន រមែងមិនមាន ។ ដោយពិត វេទនាមិនទាន់កើត ឬវិនាសទៅដូចក្រពេញទឹកបែក ។ បទមានជាដើមថា **សុខាបិ ខោ** លោកពោលដើម្បីសម្តែងសេចក្តីដែលវេទនា ៣ ទាំងនោះជាធម៌ដ៏ល្អិត ។ បទថា **ន កេនចិ វិវទតិ** រមែង មិនវិវាទទាស់ទែងនឹងអ្នកណាៗ គឺ រមែងមិនពោលរួមគ្នា និងសូម្បីពួកអ្នកមានវាទៈថា ដាច់សូន្យថា យើងជាអ្នកមានវាទៈថា ទៀង ព្រោះមានទិដ្ឋិថា ទៀង ។ រមែងមិនវិវាទទាស់ទែងនឹងអ្នកមានវាទៈថា ទៀង ពួកខ្លះថា យើងជាអ្នកមានវាទៈថា ទៀង ព្រោះកាន់យកទិដ្ឋិថា ទៀងនោះឯង គប្បីប្រកបផ្ទាស់ប្តូរវាទៈសូម្បី ៣ យ៉ាង ដោយប្រការដូច្នេះ ។ បទថា **យញ្ច លោកេ វុត្តំ** វោហារណាដែលអ្នកស្រុកនិយាយគ្នា គឺ និយាយទៅតាមវោហារដែលអ្នកស្រុកនិយាយ

គ្នា ។

បទថា **អបរាមសំ** មិនប្រកាន់ គឺ មិនប្រកាន់ធម៌អ្វីៗ ដោយការប្រកាន់មាំ ។ សមដូចដែលលោកពោលទុកថា ភិក្ខុណា ជាអ្នកមានអាសវៈអស់ហើយ ព្រោះសម្រេចព្រះអរហត្ត ជាអ្នកទ្រទ្រង់រាងកាយទុកជាគ្រាចុងក្រោយបង្អស់ ភិក្ខុនោះ គប្បីពោលថា យើងរមែងពោលដូច្នេះខ្លះ គប្បីពោលថា ពួកគេរមែងពោលចំពោះយើងដូច្នេះខ្លះ ជាអ្នកឆ្លាត ដឹងវត្ថុ កំណត់ដឹងគ្នាក្នុងលោក គប្បីនិយាយទៅតាមវោហារនោះ ។ លោកពោលតទៅទៀតថា ម្នាលចិត្តគហបតី តថាគតនិយាយទៅតាមវត្ថុដែលដឹងគ្នាក្នុងលោក ភាសារបស់អ្នកស្រុក វោហាររបស់អ្នកស្រុក បញ្ញត្តិរបស់អ្នកស្រុក តែមិនប្រកាន់ដោយទិដ្ឋិ ។

បទថា **អភិញ្ញា បហានមាហ** ព្រះមានព្រះភាគ ត្រាស់ការលះធម៌ទាំងនោះ ដោយបញ្ញាដ៏ក្រៃលែង សេចក្តីថា ព្រះមានព្រះភាគទ្រង់ដឹងការទៀងនៃធម៌ទាំងនោះ ក្នុងបណ្តាសេចក្តីទៀងជាដើម ដោយបញ្ញាដ៏ក្រៃលែងហើយ ទើបត្រាស់ដល់ការលះសេចក្តីទៀង ។ ទ្រង់ដឹងសេចក្តីដាច់សូន្យសេចក្តីទៀងតែម្យ៉ាងដោយបញ្ញាដឹងដ៏ក្រៃលែងហើយ ទើបត្រាស់ដល់ការ

លះសេចក្តីទៀងតែម្យ៉ាង ។ ទ្រង់ដឹងរូបដោយបញ្ញាដ៏ក្រៃលែងហើយ ទើបត្រាស់ដល់ការលះបង់រូប គប្បីជ្រាបសេចក្តីក្នុងបទនេះ ដោយន័យមានជាដើម ដូច្នេះឯង ។ បទថា **បដិសញ្ចិក្ខតោ** កាលព្រះសារីបុត្រ សញ្ជឹងគិត គឺ ឃើញជាក់ច្បាស់ ។ បទថា **អនុបាទាយ អាសវេហិ ចិត្តំវិមុច្ចិ** ចិត្តរួចផុតពីអាសវៈ ព្រោះមិនប្រកាន់មាំ គឺ ចិត្តរួចផុតហើយអំពីអាសវៈទាំងឡាយដែលរលត់ហើយ ដោយសេចក្តីរលត់ស្និទ្ធ គឺ មិនកើតទៀត ព្រោះមិនប្រកាន់មាំ ។

ដោយហេតុប្រមាណប៉ុណ្ណេះ ព្រះសារីបុត្រដូចបុគ្គលបរិភោគអាហារដែលគេដួសឲ្យអ្នកដទៃ ហើយបន្ទោបង់សេចក្តីហេវហត់បាន កាលបញ្ជូនញាណទៅក្នុងធម៌ទេសនា ដែលប្រារព្ធអ្នកដទៃ ទើបចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ចាក់ដុះទីបំផុតនៃសាវកបារមីញាណ និងបញ្ញា ១៦ ហើយតាំងនៅ ។ ចំណែកទីឃនខៈ បានសម្រេចសោតាបត្តិផល ហើយតាំងនៅក្នុងសរណៈទាំងឡាយ ។

ចំណែកព្រះមានព្រះភាគ កាលព្រះអាទិត្យកំពុងប្រាកដ ទ្រង់បញ្ចប់ទេសនានេះហើយ ស្តេចចុះអំពីភ្នំគិជ្ឈកូដ ស្តេចទៅព្រះវិហារវេឡុវ័ន ទ្រង់

បានប្រជុំព្រះសាវក ។ បានមានសន្និបាតប្រកបដោយអង្គ ៤ ។ អង្គទាំង ៤ នេះ គឺ ថ្ងៃនោះជាថ្ងៃឧបោសថ ១៥ កើត ប្រកបដោយមាឃនក្សត្រ ១ , ភិក្ខុ ១.២៥០ រូប ប្រជុំគ្នាតាមធម្មតារបស់ខ្លួន មិនមានអ្នកណាណាត់ទុកមក ១ , ភិក្ខុទាំងនោះមិនមានសូម្បីត្រឹមតែមួយរូបដែលជាបុថុជ្ជន ឬព្រះសោ-តាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តដែលសុក្ខវិបស្សកៈ ភិក្ខុទាំងអស់ ជាអ្នកបានអភិញ្ញា ៦ ទាំងអស់ ១ , មិនបានកោរសក់ដោយកាំបិតកោរសូម្បីតែរូប ភិក្ខុទាំងអស់ជាឯហិភិក្ខុ ១ ។

" ចប់ អដ្ឋកថា ទីឃនខសូត្រទី ៤ "

# អ ដ្ឋ ក ថា

## មាគណ្ឌិយសូត្រទី ៥

[៣៧] មាគណ្ឌិយសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះ បទថា អគ្យាគារេ គឺ ក្នុងរោងបូជាភ្លើង ។ បទថា តិណសន្ថារកេ គឺ លើកម្រាលដែលធ្វើដោយស្មៅ ។ មាគណ្ឌិយ-បរិព្វាជក ២ នាក់ អាំនិងក្មួយ ។ ក្នុង ២ នាក់នោះ អាំបួសបានសម្រេចព្រះអរហត្ត ។ សូម្បីក្មួយ ក៏មានឧបនិស្ស័យ បួសមិនយូរនឹងបានសម្រេចព្រះអរហត្ត ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ឃើញឧបនិស្ស័យរបស់មាគណ្ឌិយបរិព្វាជកនោះ ទ្រង់ចេញពីព្រះគន្ធកុដិដូចជាទេវស្ថាន ទ្រង់ឲ្យក្រាលគ្រឿងក្រាលដែលធ្វើដោយស្មៅ ត្រង់រោងបូជាភ្លើងនោះ ស្មោកគ្រោកទៅដោយផេះ ស្មៅ និងសម្រាម ស្តេចប្រថាប់នៅ ២-៣ ថ្ងៃ ដើម្បីទ្រង់ធ្វើការសង្គ្រោះអ្នកដទៃ ។ លោកពោលបទថា តេនុបសង្កមិ ស្តេចចូលទៅ សំដៅដល់រោងបូជាភ្លើងនោះ ។ តែព្រោះរោងបូជាភ្លើងនោះ មិនបាននៅជិតស្រុក

នោះឯង ពេលថ្ងៃប៉ុណ្ណោះ ពួកក្មេងប្រុស និងក្មេងស្រីនាំគ្នាទៅលេង មិនមានសេចក្តីស្ងាត់ ។ ដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់ឲ្យពេលថ្ងៃកន្លងទៅអស់កាលក្នុងព្រៃស្រោង ។ ក្នុងពេលល្ងាច ទើបស្តេចចូលទៅក្នុងរោងបូជាភ្លើងនោះ ដើម្បីប្រថាប់នៅ ។

[៣៨] បទថា **អទ្ទសា ខោ តិណសន្ថរកំ បញ្ញត្តំ** មាគណ្ឌិយបរិ-ព្វាជក បានឃើញកម្រាលដែលធ្វើដោយស្មៅក្រាលទុក គឺ ព្រះមានព្រះ-ភាគ ទ្រង់តាក់តែងកម្រាលធ្វើដោយស្មៅក្នុងថ្ងៃដទៃ ហើយទ្រង់ធ្វើគ្រឿងសម្គាល់តាំងទុក ស្តេចត្រឡប់ទៅ ។ ក្នុងថ្ងៃនោះឯង ទ្រង់បានឲ្យក្រាលហើយស្តេចទៅ ។ ព្រោះហេតុអ្វី ។ ព្រោះក្នុងកាលនោះ ពេលជិតភ្លឺព្រះអង្គទ្រង់ប្រមើលមើលលោក ទ្រង់បានឃើញថា ថ្ងៃនេះមាគណ្ឌិយៈនឹងមកក្នុងទីនេះ គ្រាឃើញកម្រាលធ្វើដោយស្មៅនេះហើយ នឹងសន្ទនាប្រារព្ធកម្រាលធ្វើដោយស្មៅ នឹងភារទ្វាជព្រាហ្មណ៍ ។ តពីនោះ តថាគតនឹងមកសម្តែងធម៌ ។ មាគណ្ឌិយព្រាហ្មណ៍ស្តាប់ធម៌ហើយនឹងបួស ក្នុងសម្នាក់របស់តថាគត ហើយសម្រេចព្រះអរហត្ត ។ ពិតណាស់ តថាគតបំពេញបារមីមកក៏ដើម្បីធ្វើការសង្គ្រោះអ្នកដទៃ ទើបទ្រង់ឲ្យក្រាលកម្រាលដែលធ្វើដោយស្មៅ ហើយស្តេច

ទៅ ។

បទថា **សមណសេយ្យានុរូបំ មញ្ញេ** ឃើញទីដេកដែលសមគួរដល់សមណៈ គឺ សម្គាល់កម្រាលនេះថា ជាទីដេកសមគួរដល់សមណៈ ។

ម្យ៉ាងទៀត កម្រាលនេះមិនមែនទីនៅរបស់សមណៈអ្នកមិនសង្រួមទេ ។ សេចក្តីពិតនោះ ទីកម្រាលនេះ មិនបានប្រាកដដែលត្រូវកៀរដោយដៃ ដែលត្រូវប៉ះដោយសីសៈ ឬដែលត្រូវកៀរដោយជើង ។ កម្រាលនេះមិនប្រឡាក់ប្រឡូស មិនត្រូវចាក់ដោត មិនត្រូវទម្លាយ ដូចជាចិត្រករដែលឆ្លាតយកដីលាបកម្រាលទុក ដូចជាទីនៅរបស់សមណៈអ្នកសង្រួមហើយ ។ មាគណ្ឌិយព្រាហ្មណ៍ ទើបសួរថា លោកដ៏ចម្រើន ទីនៅរបស់អ្នកណា ។

បទថា **ភូនហនស្ស** អ្នកកម្ចាត់សេចក្តីចម្រើនចោល ដូច្នោះ គឺ អ្នកសាងមារយាទ ។ ព្រោះហេតុអ្វី មាគណ្ឌិយៈទើបពោលយ៉ាងនោះ ។ ព្រោះគេមានលទ្ធិ គឺ ធ្វើឲ្យសេចក្តីចម្រើនប្រាកដក្នុងទ្វារ ៦ ។ នេះជាលទ្ធិរបស់គេ គឺ គួរឲ្យចក្ខុលូតលាស់ចម្រើន ។ គប្បីឃើញរូបដែលមិនធ្លាប់ឃើញ ។ រូបដែលឃើញហើយគួរកន្លងទៅ ។ គួរឲ្យសោតៈលូតលាស់ចម្រើន ។ គួរស្តាប់សំឡេងដែលមិនធ្លាប់ស្តាប់ ។ សំឡេងដែលស្តាប់ហើយគួរកន្លងទៅ ។

គួរឲ្យឃានៈលូតលាស់ចម្រើន គួរធុំក្លិនដែលមិនធ្លាប់ធុំ ។ ក្លិនដែលធុំហើយគួរកន្លងទៅ ។ គួរឲ្យជិវ្ហាលូតលាស់ចម្រើន ។ គួរភ្លក់រសដែលមិនធ្លាប់ភ្លក់ ។ រសដែលភ្លក់ហើយគួរកន្លងទៅ ។ គួរឲ្យកាយលូតលាស់ចម្រើន ។ គួរប៉ះខ្ទប់ផោដ្ឋព្វៈដែលមិនទាន់ធ្លាប់ប៉ះខ្ទប់ ។ ផោដ្ឋព្វៈដែលប៉ះខ្ទប់ហើយគួរកន្លងទៅ ។ គួរឲ្យមនៈលូតលាស់ចម្រើន ។ គួរដឹងធម៌ដែលមិនធ្លាប់ដឹង ។ ធម៌ដែលដឹងហើយគួរកន្លងទៅ ។ មាគណ្ឌិយៈបញ្ញត្តិសេចក្តីចម្រើនក្នុងទ្វារ ៦ ទុក ដោយប្រការដូច្នេះ ។ តែព្រះមានព្រះភាគទ្រង់បញ្ញត្តិសេចក្តីសង្រួមក្នុងទ្វារ ៦ ទុកថា ៖

ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ ឃានេន សំវរោ សាធុ សាធុ ជិវ្ហាយ សំវរោ កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ សព្វត្ថ សំវុតោ ភិក្ខុ សព្វទុក្ខា បមុច្ចតីតិ ។

សេចក្តីសង្រួមចក្ខុជាការល្អ សេចក្តីសង្រួមសោតៈជាការល្អ សេចក្តីសង្រួមឃានៈជាការល្អ សេចក្តីសង្រួមជិវ្ហាជា

ការល្អ សេចក្តីសង្រួមកាយជាការល្អ សេចក្តីសង្រួមវាចា ជាការល្អ សេចក្តីសង្រួមចិត្តជាការប្រពៃ សេចក្តីសង្រួម (ក្នុងទ្វារ) ទាំងពួងជាការប្រពៃ ភិក្ខុសង្រួម (ក្នុងទ្វារ) ទាំងពួង រមែងរួចចាកទុក្ខទាំងពួង ។

ព្រោះដូច្នោះ មាគណ្ឌិយព្រាហ្មណ៍សម្គាល់ថា ព្រះសមណគោតមនោះ ជាអ្នកកម្ចាត់សេចក្តីចម្រើន ជាអ្នកសាងមារយាទ ទើបពោលថា ភូនហុនោ ជាអ្នកកម្ចាត់សេចក្តីចម្រើន ។ បទថា **អរិយេ ញាយេ ធម្មេ កុសលេ** គឺ ក្នុងហេតុ ក្នុងធម៌បរិសុទ្ធិមិនមានទោស ។

ដោយបទនេះ ទ្រង់សម្តែងទុកដូចម្តេច ។ ដែលនឹងពោលវាចាដល់អ្នកមានយស មានភាពខ្ពង់ខ្ពស់ ដែលស្គាល់គ្នាទូទៅបែបនេះ គួរពិចារណារិះគិត មិនគួរនិយាយដោយមិនប្រយ័ត្នមាត់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបទ្រង់សម្តែងថា អ្នកកុំនិយាយរៀបរាប់ អ្នកចូរប្រុងប្រយ័ត្នមាត់ ។ បទថា **ឯវំ ហិ នោ សុត្តេ ឱចរតិ** ព្រោះថា ពាក្យដូច្នេះ ត្រូវគ្នាក្នុងសូត្ររបស់ពួកយើង សេចក្តីថា ព្រោះថា ពាក្យដូច្នេះ មកក្នុងសូត្ររបស់ពួកយើង ។ ពួកយើងមិននិយាយត្រឹមតែប្រាថ្នានឹងឲ្យល្អតាមផ្លូវមាត់ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ពួកយើងកាលនិយាយពាក្យដែលមកហើយក្នុងសូត្រ នឹងគប្បីនិយាយដល់អ្នកណា ។ ដូច្នោះ យើងនឹងនិយាយចំពោះមុខព្រះសមណ-គោតមនោះ ។ បទថា **អប្បោស្សុក្កោ** ជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច សេចក្ដីថា មិនខ្វល់ខ្វាយ គឺ មិនកង្វល់ដើម្បីនឹងរក្សាយើង ។ បទថា **វុត្តោ ច នំ វទេយ្យ** យើងពោលទុកហើយ ក៏គប្បីពោលនឹងសមណគោ-តមនោះចុះ សេចក្ដីថា ការទ្វាជៈដ៏ចម្រើន យើងបានពោលទុកហើយ សូម្បីមិនសួរ ក៏តាំងពាក្យនិយាយបាន កាន់យកស្វាយ និងព្រីងជាដើមហើយ មិនទាន់គ្រប់ ក៏គប្បីពោលនឹងព្រះសមណគោតម ដោយទំនងដែលយើងពោលហើយចុះ ។

[៣៩] បទថា **អស្សោសិ ខោ** សេចក្ដីថា ព្រះសាស្ដាទ្រង់ចម្រើនអាលោកកសិណ ទ្រង់បានឃើញមាគណ្ឌិយព្រាហ្មណ៍ ដែលមកក្នុងទីនោះ ដោយទិព្វចក្ខុ ទ្រង់បានស្ដាប់សូម្បីសំឡេងរបស់ជនទាំងពីរសន្ទនាគ្នា ដោយទិព្វសោត ។

បទថា **បដិសល្លានា វុដ្ឋិតោ** ព្រះមានព្រះភាគស្ដេចចេញចាកទីពួនសម្ងំ គឺ ស្ដេចចេញចាកផលសមាបត្តិ ។ បទថា **សំវិគ្គោ** គឺ ការទ្វាជ-

ព្រាហ្មណ៍ក្វាក់ផ្អើល ញាប់ញ័រ ដោយកម្លាំងនៃបីតិ ។ ន័យថា ភារទ្វាជ-ព្រាហ្មណ៍នោះមានសេចក្តីត្រិះរិះថា មាគណ្ឌិយៈ និងយើងក៏មិនបាននិយាយនឹងព្រះសមណគោតម បុគ្គលដទៃក្រៅពីយើងទាំងពីរនាក់ ក្នុងទីនេះមិនមានបុគ្គលទី ៣ ។ បុរសអ្នកមានសោតៈរហ័ស នឹងបានឮសំឡេងរបស់យើងទាំងពីរពិត ។

លំដាប់នោះ ភារទ្វាជព្រាហ្មណ៍កើតបីតិខាងក្នុងរណ្តៅរោម ៩ ម៉ឺនបានបះឡើង ។ ដោយហេតុនោះ លោកទើបពោលថា **សំវិគ្គោ លោមហដ្ឋជាតោ** ភារទ្វាជព្រាហ្មណ៍ក្វាក់ផ្អើល កើតសេចក្តីព្រឺរោមឡើង ។

លំដាប់នោះ មាគណ្ឌិយបរិព្វាជក ទាំងដែលមានញាណចាស់ក្លាដូចគ្រាប់ពូជដែលមានមាត់ហាហើយ មិនអាចអង្គុយស្ងៀម បានដើរទៅមក មកគាល់ព្រះសាស្តាទៀត ហើយអង្គុយក្នុងទីសមគួរមួយ ។ ដើម្បីសម្តែងដល់មាគណ្ឌិយៈនោះ ទើបពោលបទមានជាដើមថា **អថ ខោ មាគណ្ឌិយោ** គ្រានោះមាគណ្ឌិយៈ ដូច្នេះ ។

[៤០] បានឮថា ព្រះសាស្តាមិនបានត្រាស់យ៉ាងនេះថា ម្នាលមាគណ្ឌិយៈ អ្នកបានពោលចំពោះតថាគតហើយ ដូច្នេះ ទ្រង់ប្រារព្ធព្រះធម៌ទេសនា

ដល់បរិព្វាជកថា **ចក្ខុ ខោ មាគណ្ឌិយ** ដូច្នេះ ។ ក្នុងបទនេះមានអធិប្បាយដូចតទៅនេះ ៖

ឈ្មោះថា **ចក្ខុ រូបារាមំ** ព្រោះរូបជាទីត្រេកអរនៃចក្ខុ ដោយអត្ថថាជាទីអាស្រ័យ ។ ឈ្មោះថា **រូបរតំ** ព្រោះចក្ខុត្រេកអរក្នុងរូប ។ ឈ្មោះថា **រូបសម្មុទិតំ** ព្រោះចក្ខុដែលរូបឲ្យរីករាយហើយ ។ បទថា **ទន្តំ** ទូន្មានហើយ គឺ ឲ្យអស់អស្មិមានះហើយ ។ បទថា **គុត្តំ** គឺ ឃុំគ្រងហើយ ។ បទថា **រក្ខិតំ** រក្សាហើយ គឺ តាំងការរក្សាទុកហើយ ។ បទថា **សំវុតំ** សង្រួមហើយ គឺ បិទហើយ ។ បទថា **សំវរាយ** ដើម្បីសង្រួម គឺ ដើម្បីត្រូវការបិទ ។

**[៤១]** បទថា **បរិចារិតបុព្វោ** ធ្លាប់បានបម្រើ គឺ ធ្លាប់និយាយចរចាប្រាស្រ័យ ។ បទថា **រូបបរិឡាហំ** ក្តៅក្រហាយព្រោះរូប គឺ សេចក្តីក្តៅក្រហាយកើតឡើងព្រោះប្រារព្ធរូប ។ បទថា **ឥមស្ស បន តេ មាគណ្ឌិយ កិមស្ស វចនីយំ** ម្នាលមាគណ្ឌិយៈ ចុះអ្នកនឹងគប្បីថាអ្វី ដល់បុគ្គលនេះដូចម្តេច គឺ អ្នកនឹងគប្បីពោលពាក្យអ្វីដល់ព្រះឱណាស្រេពនេះ អ្នកកំណត់រូបហើយសម្រេចព្រះអរហត្ត ។ សួរថា គួរនឹងពោលថា ព្រះសមណគោតមជាអ្នកកម្ចាត់សេចក្តីចម្រើន ជាអ្នកសាងមារយាទ ដូច្នេះ ឬមិនគួរពោល ។

បទថា **ន កិញ្ចិ ភោ គោតម** គឺ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរពោល ពាក្យណាៗ ឡើយ ។ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។

**[៤២]** ឥឡូវនេះ ព្រោះព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងថា មិនមានពាក្យណាៗ ដែលអ្នកគួរនឹងពោលដល់ព្រះទីណាស្រេពអ្នកកំណត់ខន្ធ ៥ ហើយ សម្រេចព្រះអរហត្ត ហើយតថាគតក៏កំណត់ខន្ធ ៥ ហើយសម្រេចព្រះសព្វញ្ញូ ។ ដូច្នោះ មាគណ្ឌិយៈនោះ នឹងគួរពោលអ្វីចំពោះតថាគតដូច្នេះ ទើបត្រាស់ថា **អហំ ខោ បន** ដូច្នេះ ។ បទថា **តស្ស មយ្ហំ មាគណ្ឌិយ** ម្នាលមាគណ្ឌិយៈ ប្រាសាទរបស់តថាគតនោះ គឺ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងសម្បត្តិរបស់ព្រះអង្គ កាលគ្រានៅជាគ្រហស្ថ ទើបត្រាស់ ។ គប្បីជ្រាបសេចក្តីក្នុងបទមានជាដើមថា **វស្សិកោ** នោះ ដូចតទៅនេះ ៖

សេចក្តីសុខ រមែងមានក្នុងទីនៅក្នុងរដូវភ្លៀងនេះ គឺ ប្រាសាទដែលនៅក្នុងរដូវភ្លៀង ។ សូម្បីក្នុងបទក្រៅនោះ ក៏មានន័យនេះដូចគ្នា ។ តែក្នុងបទនេះ មានអធិប្បាយពាក្យដូចតទៅនេះ ៖

ឈ្មោះថា **វស្សិកោ** ព្រោះគួរនៅរហូតដល់អស់រដូវភ្លៀង ។ សូម្បី

ក្នុងបទក្រៅពីនេះ ក៏មានន័យនេះដូចគ្នា ។ ក្នុងបទនោះ ប្រាសាទជាទីនៅក្នុងរដូវភ្លៀង មិនខ្ពស់ពេក មិនទាបពេក ។ សូម្បីទ្វារ និងបង្អួចរបស់ប្រាសាទនោះ ក៏មិនតិចពេក មិនច្រើនពេក កម្រាលផែនដី របស់ទំពារ របស់បរិភោគក្នុងប្រាសាទនេះ មានច្រើន ។ ក្នុងប្រាសាទជាទីនៅក្នុងរដូវត្រជាក់ សសរក្ដី ជញ្ជាំងក្ដីទាប ។ ទ្វារ និងបង្អួចមានតិច មានប្រហោងតូច ។ យកប្រហោងជញ្ជាំងចេញដើម្បីត្រូវការឲ្យកំដៅចូលទៅ ។ ម្យ៉ាងទៀត ក្នុងប្រាសាទនេះ កម្រាលផែនដី គ្រឿងក្រាល គ្រឿងស្លៀកដណ្ដប់គួរជាសំពត់កម្ពលជាដើម ដែលជួយឲ្យកក់ក្ដៅបាន ។ របស់ទំពារ របស់បរិភោគ ល្អិតល្អន់ ឆ្ងាញ់ និងមានរសខាប់ ។ ក្នុងប្រាសាទដែលជាទីនៅក្នុងរដូវក្ដៅ សសរក្ដី ជញ្ជាំងក្ដីខ្ពស់ ។ ទ្វារ និងបង្អួចក្នុងប្រាសាទនេះមានច្រើន មានពន្លឺទូទៅ ។ កម្រាលផែនដីជាដើម គួរជាសំពត់សាច់ល្អ ។ របស់ទំពារ របស់បរិភោគ មានរសផ្អែម ធ្វើឲ្យបានទទួលភាពត្រជាក់ ។ ម្យ៉ាងទៀត ក្នុងទីជិតបង្អួចក្នុងប្រាសាទនេះ តាំងពាងទឹកទុក ៩ ពាង ពេញដោយទឹកដាំឈូកខៀវជាដើមទុក ។ ក្នុងទីនោះធ្វើទឹកបាញ់ទុក ខ្សែទឹកនឹងបាញ់ដូចកាលភ្លៀងធ្លាក់ ។ តែរបស់ព្រះពោធិសត្វ គេដាំគុម្ពឈូកខៀវទុក

ក្នុងថ្នាំងមាស និងថ្នាំងប្រាក់ មួយៗ ១០៨ ថ្នាំង ពេញទៅដោយទឹកក្រអូប តម្កល់ព័ទ្ធបន្ទប់ដេក ។ គេដាក់ល្បាប់កក់ឲ្យពេញក្នុងជើងលោហៈធំ ដាំឈូកខៀវ ឈូកក្រហម ឈូកសជាដើម តាំងទុកក្នុងទីនោះៗ ដើម្បីកាន់យកឧតុ ។ ផ្កាឈើទាំងឡាយ រមែងរីកដោយស្មើរបស់ព្រះអាទិត្យ ។ ពួកភមរជាតិច្រើនប្រភេទ ហើរចូលទៅកាន់ប្រាសាទ ត្រាច់ហិតរសក្នុងផ្កាឈើទាំងឡាយ ។ ប្រាសាទមានក្លិនក្រអូបផ្សាយទៅដ៏ក្រៃលែងណាស់ ។ ក្នុងចន្លោះជញ្ជាំង បានតាំងនាឡិលោហៈហើយអុជភ្លើងព្រឹមៗ ទុកក្នុងទីបំផុតមណ្ឌបកែវលើទីទួលអាកាសខាងលើប្រាសាទ ៩ ជាន់ ។ ក្រាលស្បែកក្របីស្ងួតទុកក្នុងកន្លែងមួយ ។

ក្នុងវេលាព្រះពោធិសត្វលេងទឹក គេចោលកូនថ្មទៅត្រង់ស្បែកក្របី ។ គ្រឿងយន្តវិលទៅខាងក្រោម ដូចសំឡេងផ្គរលាន់ ។ ទឹកបាញ់ឡើង ហើយធ្លាក់ទៅត្រង់អណ្តាតភ្លើង ។ ដូចជាទឹកភ្លៀងធ្លាក់ ។ គ្រានោះព្រះពោធិសត្វទ្រង់ស្លៀកសំពត់ខៀវ ដណ្តប់សំពត់ខៀវ ទ្រង់ប្រដាប់គ្រឿងប្រដាប់ពណ៌ខៀវ ។ សូម្បីពួកបរិវាររបស់ព្រះពោធិសត្វមានអ្នករបាំ ៤ ម៉ឺន ប្រដាប់ដោយពណ៌ខៀវ តែងខ្លួនពណ៌ខៀវ ហែហមព្រះមហាបុរស ទៅកាន់មណ្ឌប

កែវ ។ ព្រះពោធិសត្វទ្រង់លេងកីឡាក្នុងទឹករហូតមួយថ្ងៃ សោយសេចក្តីសុខក្នុងរដូវត្រជាក់ ។ ក្នុងទិសទាំង ៤ របស់ប្រាសាទ មានស្រះ ៤ ។ ក្នុងពេលថ្ងៃ ហ្វូងសត្វច្រើនប្រភេទ ចេញចាកស្រះទិសខាងកើត ស្រែកយំរងំ ហើរទៅកាន់ស្រះទិសខាងលិចតាមកំពូលប្រាសាទ ។ ចេញពីស្រះទិសខាងលិច ហើរទៅកាន់ទិសខាងកើត ។ ចេញពីស្រះទិសខាងត្បូង ហើរទៅកាន់ស្រះទិសខាងជើង ។ ចេញពីស្រះទិសខាងជើង ហើរទៅកាន់ស្រះទិសខាងត្បូង ដូចជាសម័យក្នុងចន្លោះរដូវភ្លៀង ។ តែប្រាសាទជាទីនៅក្នុងរដូវត្រជាក់មាន ៥ ជាន់ ។ ប្រាសាទជាទីនៅក្នុងរដូវភ្លៀងមាន ៧ ជាន់ ។

បទថា **និប្បុរិសេហិ** មិនមានបុរសគឺ វៀរចាកបុរស ។

ម្យ៉ាងទៀត មិនមែនតន្រ្តីប៉ុណ្ណោះ ដែលមិនមានបុរសឡាយ ។ សូម្បីក្នុងទីគ្រប់កន្លែងក៏មិនមានបុរសដូចគ្នា ។ សូម្បីអ្នកចាំទ្វារក៏ជាមនុស្សស្រី ។ សូម្បីអ្នកធ្វើបរិការ មានការងូតទឹកឲ្យជាដើម ក៏ជាមនុស្សស្រី ។ ន័យថា ព្រះរាជាទ្រង់តាំងមនុស្សស្រីទុកក្នុងកិច្ចគ្រប់យ៉ាង ដោយទ្រង់ព្រះត្រិះរិះថា កាលព្រះពោធិសត្វសោយឥស្សរិយសម្បត្តិ និងសុខសម្បត្តិបែបនោះ នឹងកើតការប្រែកចិត្តក្នុងបុរស ពេលឃើញបុរស ។ ការប្រែកចិត្តនោះកុំបានមាន

ដល់ឱរសរបស់យើងឡើយ ។ បទថា **តាយ រតិយា រមមានោ** ត្រេកអរដោយសេចក្ដីត្រេកអរនោះ នេះ លោកពោលសំដៅដល់សេចក្ដីត្រេកអរក្នុងផលសមាបត្តិ ដែលប្រកបដោយឈានទី ៤ ។

**[៤៣]** គប្បីជ្រាបសេចក្ដីក្នុងបទនេះថា **គហបតិ វា គហបតិបុត្តោ វា** ដូចតទៅនេះ ៖

ព្រោះក្សត្រិយ៍ទាំងឡាយ រមែងមានសេចក្ដីប្រាថ្នាក្នុងស្វេតឆត្រទាំងនោះ ។ សេចក្ដីប្រាថ្នាធំ ជាការយឺតយូររបស់ក្សត្រិយ៍ទាំងនោះ ។ ព្រាហ្មណ៍ទាំងឡាយមិនឆ្អែតដោយមន្ត ទើបស្វែងរកមន្ត ។ ចំណែកគហបតីទាំងឡាយរមែងសោយសម្បត្តិតាំងពីកាលរៀនត្រឹមតែគណនា ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្សត្រិយ៍ និងព្រាហ្មណ៍ ទើបត្រាស់ថា **គហបតិ វា គហបតិបុត្តោ វា** ដូច្នេះ ។ បទថា **អាវដ្ដេយ្យ** គប្បីវិលមក សេចក្ដីថា គប្បីវិលមកព្រោះហេតុនៃកាមដែលជារបស់មនុស្ស ។ បទថា **អភិក្កន្តតរា** គួរប្រាថ្នាក្រៃលែងជាង គឺ ប្រសើរជាង ។ បទថា **បណីតតរា** ប្រណីតជាង គឺ មិនតិចជាង ។ សមដូចដែលលោកពោលដល់ប្រការនេះទុកថា ៖

កាមដែលជារបស់មនុស្ស កាលប្រៀបធៀបនឹងកាមដែល

ជាទិព្វ ដូចជាទឹកដែលជាប់ដោយចុងស្បូវ ប្រៀបធៀបនឹង

ទឹកក្នុងសមុទ្រ ដូច្នោះ ។

បទថា **សមធិគ្គយ្ហ តិដ្ឋតិ** កាន់យកសុខដែលជាទិព្វតាំងនៅ គឺ កាន់យកសុខដែលជាទិព្វប្រសើរជាងនោះ តាំងនៅ ។

ម្យ៉ាងទៀត គប្បីជ្រាបប្រការប្រៀបធៀបក្នុងសេចក្ដីនេះ ដូចតទៅនេះ ៖

កាលសេចក្ដីត្រេកអរត្រេងកណ្ដាលស្ត្រី ៤ ម៉ឺន ក្នុងប្រាសាទទាំង ៣ ខ្នង របស់ព្រះពោធិសត្វ ដូចជាការប្រកបព្រមដោយកាមគុណ ៥ របស់គហបតី ដូច្នោះ ។ កាលព្រះពោធិសត្វទ្រង់ព្រះផ្នួស ហើយចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណក្នុងពោធិបល្ល័ង្ក ដូចកាលដែលគហបតីនោះបំពេញសុចរិតហើយកើតក្នុងសួគ៌ ដូច្នោះ ។ កាលដែលព្រះតថាគតញុំាងវេលាឲ្យកន្លងទៅដោយសេចក្ដីត្រេកអរក្នុងផលសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងឈានទី ៤ ដូចកាលដែលគហបតីនោះ សោយសម្បត្តិក្នុងនន្ទវ័ន ដូច្នោះ ។ កាលព្រះតថាគតញុំាងវេលាឲ្យកន្លងទៅ ដោយសេចក្ដីត្រេកអរក្នុងផលសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងឈានទី ៤ ទ្រង់មិនប្រាថ្នាសេចក្ដីសុខរបស់ជនអាក្រក់ ដែលជារបស់

មនុស្ស ដូចកាលដែលគហបតីនោះ មិនប្រាថ្នាកាមគុណ ៥ ដែលជារបស់មនុស្ស ដូច្នោះ ។

**[៤៤]** បទថា **សុខី** មានសេចក្តីសុខ គឺ បានទទួលទុក្ខមុន ខាងក្រោយគប្បីមានសេចក្តីសុខ ។

បទថា **សេរី** មានសេរីភាព គឺ មានពេទ្យជាសម្លាញ់មុន ខាងក្រោយគប្បីមានសេរីភាព គឺ គប្បីជាបុគ្គលម្នាក់ ។ បទថា **សយំវសី** មានអំណាចក្នុងខ្លួនឯង គឺ នៅក្នុងអំណាចរបស់ពេទ្យមុន កាលពេទ្យប្រាប់ថា ចូរអង្គុយក៏អង្គុយ ប្រាប់ថា ចូរដេកក៏ដេក ប្រាប់ថា ចូរបរិភោគក៏បរិភោគ ប្រាប់ថា ចូរផឹកក៏ផឹក ខាងក្រោយទើបមានអំណាចក្នុងខ្លួនឯង ។

បទថា **យេន កាមង្គមោ** នឹងទៅណាបានតាមសេចក្តីពេញចិត្ត គឺ មិនបានទៅកាន់ទីដែលខ្លួនត្រូវការមុន ខាងក្រោយកាលរោគជាល្អហើយទើបទៅណាបានតាមសេចក្តីពេញចិត្ត សូម្បីក្នុងការសរសើរព្រៃ សរសើរល្ហាន និងសរសើរភ្នំជាដើម គប្បីទៅបានក្នុងទីដែលប្រាថ្នានឹងទៅ ។

ក្នុងបទនេះ មានសេចក្តីប្រៀបធៀបដូចតទៅនេះ ៖

កាលព្រះពោធិសត្វប្រថាប់នៅក្នុងកណ្តាលប្រាសាទ ដូចកាលដែល

បុរសកើតរោគឃ្លង់ ដូច្នោះ , កាមវត្ថុណាមួយ ដូចក្បៀងដាក់រងើកភ្លើង ដូច្នោះ ។ កាមវត្ថុ ២ ដូចក្បៀង ២ បន្ទុះ ។ អ្នករបាំ ៣ កោដិកន្លះ ដូចក្បៀងដាក់រងើកភ្លើង ៣ កោដិកន្លះ របស់ស្តេចសក្កទេវរាជ ដូច្នោះ ។ ការសេពវត្ថុកាម ដូចជាខ្វារមុខជំបៅដោយក្រចក ហើយទៅផ្ដើរលើក្បៀងដាក់រងើកភ្លើង ដូច្នោះ ។

កាលព្រះពោធិសត្វ ឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងនេក្ខម្មៈ ហើយស្ដេចចេញបួស បានជាព្រះពុទ្ធ ។ និងកាលព្រះតថាគតញ៉ាំងវេលាឲ្យកន្លងទៅ ដោយសេចក្ដីត្រេកអរក្នុងផលសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងឈានទី ៤ ដូចកាលបុរសកើតឃ្លង់អាស្រ័យថ្នាំហើយ ជារោគ ដូច្នោះ ។

កាលព្រះតថាគតញ៉ាំងវេលាឲ្យកន្លងទៅ ដោយសេចក្ដីត្រេកអរនោះ ទ្រង់មិនប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងបុគ្គលអាក្រក់ ដូចកាលឃើញបុរសកើតរោគឃ្លង់ដទៃហើយ មិនប្រាថ្នានឹងឃើញទៀត ដូច្នោះ ។

**[៤៥]** បទថា **ឧបហតិន្ទ្រិយោ** មានឥន្ទ្រិយដែលរោគកម្ចាត់ចេញហើយ គឺ មានកាយប្បសាទដែលរោគឃ្លង់កម្ចាត់ហើយ ។ បទថា **ឧបហតិន្ទ្រិយា** មានឥន្ទ្រិយដែលទោសកម្ចាត់ហើយ គឺ មានបញ្ចិន្ទ្រិយដែល

ទោសកម្ចាត់ហើយ ។ សត្វទាំងឡាយនោះ ព្រោះបញ្ចិន្ទ្រិយត្រូវកម្ចាត់បាន ដោយសេចក្តីសម្គាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សជាទុក្ខ ថាជាសុខ ដូចជាបុរសរោគឃ្លង់នោះ មានកាយិន្ទ្រិយត្រូវរោគកម្ចាត់បាន ដោយសេចក្តីសម្គាល់ខុសក្នុងភ្លើង ដែលមានសម្ផស្សជាទុក្ខ ថាជាសុខ ដូច្នោះ ។

[៤៦] គប្បីជ្រាបសេចក្តីក្នុងបទថា **អសុចិត្រានិ ចេវ** មិនស្អាតក្រៃលែងឡើងជាដើម ដូចតទៅនេះ ៖

តាមប្រក្រតីមុខដំបៅទាំងនោះមិនស្អាត មានក្លិនអាក្រក់ និងស្អុយ តែឥឡូវនេះរឹងរិតតែមិនស្អាត រឹងរិតតែមានក្លិនស្អុយ និងរឹងរិតតែស្អុយឡើងទៀត ។ បទថា **កាចិ** គឺ ដង្កូវទាំងឡាយ រមែងចូលទៅខាងក្នុងដំបៅត្រង់កំដៅភ្លើង និងត្រង់មុខដែលខ្វារ ឈាម និងខ្ទុះដែលគួរខ្ពើមក៏ហូរចេញពីដំបៅយ៉ាងនោះ នឹងមានសេចក្តីរីករាយតិចតួចបាន យ៉ាងណា ។

[៤៨] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថា ថា **អារោគ្យា បរមា លាភា** សេចក្តីមិនមានរោគ ជាលាភយ៉ាងក្រៃលែង ដូចតទៅនេះ ៖

ការបានទ្រព្យក្តី ការបានយសក្តី ការបានបុត្រក្តី យ៉ាងណាមួយ សេចក្តីមិនមានរោគ ជាលាភដ៏ក្រៃលែងជាងលាភទាំងនោះ ។ លាភក្រៃ-

លែងជាងសេចក្ដីមិនមានរោគនោះមិនមាន ព្រោះហេតុនោះ សេចក្ដីមិនមានរោគ ទើបជាលាភយ៉ាងក្រៃលែង ។ សុខកើតពីឈានក្ដី សុខកើតពីមគ្គក្ដី សុខកើតពីផលក្ដី យ៉ាងណាមួយ បណ្ដាសុខទាំងនោះ និព្វានជាសុខយ៉ាងក្រៃលែង ។ សុខក្រៃលែងជាងនិព្វាននោះមិនមាន ព្រោះហេតុនោះ និព្វានទើបជាសុខយ៉ាងក្រៃលែង ។ បទថា **អដ្ឋង្គិកោ ច មគ្គានំ** បណ្ដាផ្លូវទាំងឡាយដែលឲ្យដល់អមតធម៌ ដោយការទៅដែលជាចំណែកខាងដើម មគ្គដែលជាចំណែកខាងដើមទាំងឡាយ មគ្គមានអង្គ ៨ ជាផ្លូវដ៏ក្សេម ។ ផ្លូវដទៃក្សេមក្រៃលែងជាងមគ្គមានអង្គ ៨ នោះមិនមាន ។ មយ៉ាងទៀត បទថា **ខេមំ** ក្ដី បទថា **អមតំ** ក្ដី ក្នុងបទថា **ខេមំ អមតំ** នេះ ជាឈ្មោះរបស់និព្វានទុះឯង ។

ក្នុងបទនេះ មានសេចក្ដីថា សមណព្រាហ្មណ៍អ្នកពោលជំទាស់ជាច្រើន កាន់យកដោយលទ្ធិថា ផ្លូវដែលជាផ្លូវក្សេម និងផ្លូវដែលឲ្យដល់អមតធម៌ មគ្គមានអង្គ ៨ ជាផ្លូវយ៉ាងក្រៃលែង គឺ ប្រសើរជាង មគ្គទាំងឡាយដែលជាផ្លូវក្សេម និងជាផ្លូវអមតៈទាំងអស់នោះ ។ បទថា **អាចរិយបាចរិយានំ** នៃអាចារ្យ និងបាចារ្យ គឺ នៃអាចារ្យ និងនៃអាចារ្យរបស់អាចារ្យទាំងឡាយ ។ បទថា **សមេតិ** រមែងសមគ្នា គឺ ដូចគ្នា មិនផ្សេងគ្នា ដូច

វាល់ដោយនាឡិតែមួយ ដូចថ្លឹងដោយក្អែកជញ្ជីងតែមួយ ។ បទថា **អនោ-មជ្ជតិ** ស្ទាបខ្លួន គឺ មាគណ្ឌិយបរិព្វាជក យកបាតដៃ ដាក់ខាងក្រោមស្ទាបខ្លួន ។ បទថា **ឥទន្តំ ភោ គោតម អារោគ្យំ អទន្តំ និព្វានំ** បពិត្រព្រះគោតមដ៏ចម្រើន នេះគឺ សេចក្ដីមិនមានរោគ នេះគឺ សេចក្ដីសុខ គឺមាគណ្ឌិយបរិព្វាជកស្ទាបសីសៈតាមវេលា ស្ទាបពោះតាមវេលា ទើបពោលយ៉ាងនេះ ។

[៨៩] បទថា **ឆេកំ** គឺ ថ្វាផូរផង់ ។ បទថា **ពាហុលិចីវរេន** មានសំពត់ក្រាស់ គឺ សំពត់សាច់គ្រោតគ្រាតធ្វើដោយរោមចៀមខ្មៅ ។ អាចារ្យទាំងឡាយពោលថា **សង្ការចោឡកេន** ខ្វះ ប្រែថា សំពត់ដែលគេចោលក្នុងគំនរសម្រាម ។ បទថា **វាចំ និច្ឆរេយ្យ** បញ្ចេញវាចា សេចក្ដីថា បញ្ចេញវាចាស្ទាបអង្អែលត្រង់ជាយ ត្រង់ចុង ត្រង់កណ្ដាលតាមវេលា ។ បទថា **បុព្វកេហេសា** កាត់បទជា **បុព្វកេហិ ឯសា** សេចក្ដីថា ព្រះមានព្រះភាគព្រះនាមថា វិបស្សីខ្វះ ។ល។ ព្រះនាមថា កស្សបៈខ្វះ ប្រថាប់អង្គុយកណ្ដាលបរិស័ទទាំង ៤ បានត្រាស់ព្រះគាថានេះ ។ គាថាអាស្រ័យប្រយោជន៍ ព្រោះហេតុនោះមហាជនទើបបានរៀន ។ កាលព្រះសាស្ដាស្ដេចបរិនិព្វានហើយខាងក្រោយ គាថាទាំងឡាយទើបចូលកាន់ចន្លោះពួកបរិព្វាជក ។ បរិព្វាជក

ទាំងនោះកត់ទុកក្នុងស្ទឹករីត រក្សាទុក ២ បទប៉ុណ្ណោះ ។ ព្រោះដូច្នោះ លោកទើបពោលថា គាថានោះ ឥឡូវនេះ ជាគាថារបស់បុថុជ្ជនតាមលំដាប់ ។ ឈ្មោះថា **រោគភូតោ** ជារោគ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **អរិយំ ចក្ខុំ** ចក្ខុដ៏ប្រសើរ គឺ វិបស្សនាញាណ និងមគ្គ-ញាណបរិសុទ្ធិ ។

[៥០] បទថា **បហោតិ** ត្រឹមតែល្មម គឺ អាច ។ បទថា **ភេសជ្ជំ ករេយ្យ** គប្បីផ្សំថ្នាំ គឺ គប្បីផ្សំថ្នាំបន្សាបក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ភ្នែក ថ្នាំស្នោរជាដើម ។ បទថា **ន ចក្ខូនិ ឧប្បាទេយ្យ** មើលមិនឃើញ សេចក្តីថា ចក្ខុបសាទ របស់បុគ្គលណាត្រូវប្រម៉ាត់ និងស្លេស្មជាដើមកម្ចាត់ហើយ ក្នុងវាង ។ បុគ្គលនោះអាស្រ័យពេទ្យដែលឆ្លាត ទទួលទានថ្នាំដែលសប្បាយទើបមើលឃើញបាន ។ តែភ្នែករបស់បុគ្គលខ្វាក់ពីកំណើត ខ្វាក់តាំងពីនៅក្នុងគភ៌មាតា ។ ព្រោះដូច្នោះ គេនឹងឃើញមិនបានឡើយ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ន ចក្ខូនិ ឧប្បាទេយ្យ** មើលមិនឃើញ ដូច្នេះ ។

[៥១] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ២ ដូចតទៅនេះ ៖

បទថា **ជច្ចន្ធោ** ខ្វាក់ពីកំណើត គឺ ខ្វាក់ដោយប្រមាត់ជាដើម តាំងពីវេលាកើត ។ កាលមុនលោកពោលថា **អមុស្មឹ** គឺ ក្នុងគ្រាឯណោះ ។

បទថា **អមិត្តតោ ទហេយ្យ** គេគប្បីតាំងបុរសនោះទុក ដោយភាពជាសត្រូវ គឺ គប្បីតាំងទុកដោយភាពជាសត្រូវយ៉ាងនេះថា បុរសនេះជាសត្រូវរបស់យើង ដូច្នេះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **ឥមិនា ចិត្តេន** ដោយចិត្តដូងនេះ គឺ ដោយចិត្តដែលប្រព្រឹត្តទៅក្នុងវដ្តៈ ។ បទថា **តស្ស មេ ឧបាទានប្បច្ចយា** ព្រោះឧបាទានជាបច្ច័យ កពទើបមានដល់យើង គឺ លោកពោលដល់បច្ចយាការ ដែលមានសន្ធិ ១ និងសង្ខេប ២ , ប្រកាសវដ្តៈឲ្យជាក់ច្បាស់ ។ បទថា **ធម្មានុធម្មំ** ធម៌សមគួរដល់ធម៌ គឺ បដិបទាដែលសមគួរដល់ធម៌ ។ បទថា **ឥមេ រោគា គណ្ឌា សល្លា** រោគ បូសកូនសរ គឺ សេចក្តីនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ខន្ធ ៥ ។ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងដល់វិវដ្តៈ ទើបត្រាស់ថា **ឧបាទាននិរោធា** ព្រោះឧបាទានរលត់ ដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងនោះឯង ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា មាគណ្ឌិយសូត្រទី ៥ "

# អ ដ្ឋ ក ថា

## សន្ទកសូត្រទី ៦

[៥៤] *សន្ទកសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា* ***បិលក្ខគុហាយំ*** *ត្រង់ទ្វារល្អាងនោះមានដើមល្វៀប ព្រោះដូច្នោះ ទើបឈ្មោះថា* ***បិលក្ខគុហា*** *។ បទថា* ***បដិសល្លានា វុដ្ឋិតោ*** *ព្រះអានន្ទចេញចាកទីពួនសម្ងំ គឺ ចេញចាកវិវេក ។ បទថា* ***ទេវកតសោព្ភោ*** *អណ្ដូងទឹកដែលទឹកភ្លៀងប្រោះ គឺ ស្រះទឹកជំកើតក្នុងទីដែលត្រូវទឹកភ្លៀងប្រោះ ។ បទថា* ***គុហា*** *ក្នុងបទថា* ***គុហាទស្សនាយ*** *ដើម្បីមើលល្អាងនេះ ជាល្អាងពេញទៅដោយធូលី ។ ល្អាងនោះបានទៅក្នុងទីដែលរួចផុតទឹក ជាទីទួល ។ ជនទាំងឡាយធ្វើខម្មគ្គ ហើយនាំជន្ទត់ឈើនិងធូលីចេញ លើកសសរទុកខាងក្នុង ខាងលើបំផុតប្រក់ដោយក្ដា ធ្វើជាផ្ទះមួយរយៈ ។ ពួកបរិព្វាជកទាំងនោះ នៅរួមគ្នាក្នុងល្អាងនោះ ។ ល្អាងនោះ ក្នុងរដូវភ្លៀងមានទឹកដក់ពេញ ។ ដល់រដូវប្រាំង បរិព្វាជកនាំគ្នាទៅ*

នៅក្នុងល្អាងនោះ ព្រះអានន្ទពោលថា **គុហាទស្សនាយ** សំដៅដល់ល្អាង នោះ ។ ពិតណាស់ ការទៅដើម្បីមើលវិហារ ឬថា ដើម្បីមើលសមុទ្រ និងភ្នំ ព្រោះពិចារណាដល់សង្សារវដ្ដ ដែលមានខាងដើម និងខាងចុងដែល បុគ្គលតាមដឹងមិនបាន រមែងគួរ ។ បទថា **ឧន្នាទិនិយា** ដោយសំឡេងហ៊ោ គឺ លាន់ឮសំឡេងខ្លាំង ។ តិរច្ឆានកថានោះ លាន់ឮសំឡេងយ៉ាងនេះ គឺ សំឡេងទ្រហឹងអ៊ឹងកង សំឡេងខ្ពស់ សំឡេងខ្លាំង ខ្ចរខ្ចាយទៅក្នុងទិសទាំង ឡាយ ។ ព្រោះហេតុនេះ ទើបឈ្មោះថា **ឧច្ចាសទ្ទមហាសទ្ទា** ព្រោះសំឡេង ខ្ពស់ និងសំឡេងខ្លាំង ។ បរិព្វាជកទាំងនោះ ក្រោកឡើងពីព្រឹកព្រលឹមហើយ គួរធ្វើចេតិយវត្ត ពោធិវត្ត អាចរិយវត្ត ឧបជ្ឈាយវត្ត ឬយោនិសោមនសិ-ការ មិនមានឡើយ ។ ពួកគេក្រោកពីព្រឹកព្រលឹម ពេលថ្ងៃប្រជុំគ្នា ពេល ល្ងាចប្រជុំសន្ទនាគ្នា ដើម្បីរកសេចក្ដីសប្បាយ ។ ផ្ដើមជជែកគ្នាដល់រឿង ដៃ និងជើងជាដើមនៃគ្នានិងគ្នាយ៉ាងនេះថា ដៃរបស់អ្នកនេះល្អ ជើងរបស់ អ្នកនេះល្អ ឬជជែកគ្នាដល់ពណ៌សម្បុរ របស់បុរស ស្ត្រី ក្មេងស្រី និងក្មេង ប្រុស ឬរឿងដទៃៗ ដូចជាការលើកសរសើរក្នុងកាម និងការលើកសរសើរ ក្នុងភពជាដើម ។ ហើយពោលតិរច្ឆានកថាច្រើនយ៉ាង មាននិយាយដល់

រឿងព្រះរាជាជាដើម ដោយលំដាប់ ។ ពិតណាស់ ការនិយាយដែលជាការជំទាស់ផ្លូវសួគ៌ និងនិព្វាន ឈ្មោះថា តិរច្ឆានកថា ព្រោះមិននាំចេញចាកភពបាន ក្នុងកថាទាំងនោះ ការនិយាយដល់រឿងព្រះរាជា ប្រព្រឹត្តទៅដោយន័យមានជាដើមថា ព្រះបាទមហាសម្មតិរាជ ព្រះបាទមន្ធាធាតុរាជ ព្រះបាទធម្មាសោកករាជ មានអានុភាពយ៉ាងនេះ ឈ្មោះថា **រាជកថា** ។ ក្នុងចោរកថាជាដើម ក៏មានន័យនេះដូចគ្នា ។ ការនិយាយអាស្រ័យកាមគុណ ដោយន័យមានជាដើមថា ព្រះរាជាអង្គឯណោះ ព្រះរូបព្រះឆោមស្រស់ល្អ គួរសរសើរ ដូច្នេះ ក៏ជាតិរច្ឆានកថា ។ តែការនិយាយដោយទំនងយ៉ាងនេះថា សូម្បីព្រះរាជាអង្គនោះ មានអានុភាពច្រើនយ៉ាងនេះ ក៏នៅសោយទិវង្គត ដូច្នេះ ឈ្មោះថា រមែងតាំងនៅក្នុងភាពជាកម្មដ្ឋានកថា ។

សូម្បីក្នុងចោរទាំងឡាយ ការនិយាយអាស្រ័យកាមគុណថា ឱ គេក្លាហាន ព្រោះអាស្រ័យកម្មរបស់ចោរទាំងនោះថា ចោរឈ្មោះ មូលទេវមានអានុភាពច្រើនយ៉ាងនេះ ចោរឈ្មោះ មាឃមាលៈ មានអានុភាពច្រើនយ៉ាងនេះ ដូច្នេះ ក៏ជាតិរច្ឆានកថា ។ សូម្បីការប្រយុទ្ធ ការនិយាយក្នុងរឿងការតយុទ្ធជាដើម ដោយការពេញចិត្តក្នុងកាមថា អ្នកឯណោះត្រូវអ្នក

ឯណោះសម្ងាប់ យ៉ាងនេះ ត្រូវចាក់យ៉ាងនេះ ដូច្នេះ ក៏ជាតិរច្ឆានកថា ។ តែការនិយាយក្នុងរឿងទាំងអស់ដោយទំនងយ៉ាងនេះថា សូម្បីជនទាំងនោះ ក៏រមែងស្លាប់បាន ដូច្នេះ ជាកម្មដ្ឋានកថា ។

ម្យ៉ាងទៀត ក្នុងរឿងបាយជាដើម មិនគួរនិយាយដោយអំណាចការលើកសរសើរក្នុងកាមថា យើងទំពារ ស៊ី ផឹក បរិភោគបាយជាដើម មានពណ៌ មានក្លិន មានរស មានផស្សៈយ៉ាងនេះ ។ តែគួរនិយាយដល់រឿងដែលប្រកបដោយប្រយោជន៍ថា យើងបានថ្វាយបាយ សំពត់ ទឹកដេក ផ្កាឈើ របស់ក្រអូបដែលសម្បូរណ៍ដោយពណ៌យ៉ាងនេះ ដល់លោកអ្នកមានសីលក្នុងគ្រាមុន ។ យើងបានធ្វើការបូជាដល់ព្រះចេតិយ ដូច្នេះ ។ សូម្បីក្នុងការនិយាយដល់រឿងញាតិជាដើម ក៏មិនគួរនិយាយដោយអំណាចការលើកសរសើរថា ញាតិរបស់យើងជាអ្នកខ្លាំងក្លា ជាអ្នកអាច ឬថា កាលមុនយើងបានត្រាច់ទៅដោយយានដែលស្អាតល្អយ៉ាងនេះ ។ តែគួរនិយាយធ្វើឲ្យមានប្រយោជន៍ថា សូម្បីញាតិរបស់យើងទាំងនោះ ក៏បានស្លាប់អស់ទៅហើយ ។ ឬថា កាលមុន យើងបានថ្វាយស្បែកជើងប្រភេទនេះដល់ព្រះសង្ឃ ។ សូម្បីនិយាយរឿងស្រុក ក៏មិនគួរនិយាយដោយអំណាចសេចក្តីថា នៅល្អ នៅ

អាក្រក់ អាហារល្អ អាហារខ្វះខាតជាដើម ឬនិយាយដោយអំណាចការលើក សរសើរថា អ្នកនៅស្រុកឯណោះ ជាអ្នកខ្លាំងក្លា ជាអ្នកអាច ។ តែគួរ និយាយធ្វើឲ្យមានប្រយោជន៍ថា សូម្បីអ្នកខ្លាំងក្លា ដែលមានសទ្ធាជ្រះថ្លា ក៏នៅស្តាប់បាន ។ សូម្បីក្នុងការនិយាយរឿងនិគម រឿងនគរ រឿងជនបទ ក៏មានន័យនេះដូចគ្នា ។ សូម្បីការនិយាយរឿងស្ត្រី ក៏មិនគួរនិយាយដោយ អំណាចការលើកសរសើរ អាស្រ័យពណ៌សម្បុរ និងទ្រង់ទ្រាយជាដើម ។ គួរនិយាយយ៉ាងនេះថា ស្ត្រីដែលមានសទ្ធាជ្រះថ្លា ក៏នៅស្តាប់បាន ។ សូម្បី និយាយដល់រឿងអ្នកក្លាហាន ក៏មិនគួរនិយាយដោយការពេញចិត្តថា អ្នក ចម្បាំងឈ្មោះសន្ទិមិត បានជាអ្នកក្លាហាន គួរនិយាយយ៉ាងនេះថា អ្នកចម្បាំង សូម្បីមានសទ្ធាក៏នៅស្តាប់បាន ។ សូម្បីនិយាយរឿងច្រកផ្លូវ ក៏មិនគួរនិយាយ ដោយការពេញចិត្តថា ច្រកផ្លូវឯណោះ តាំងនៅល្អ តាំងនៅមិនល្អ មានអ្នក ខ្លាំងក្លា មានអ្នកអាច ។ គួរនិយាយថា អ្នកខ្លាំងក្លា អ្នកអាចដែលនៅច្រក ផ្លូវនោះ ក៏នៅស្តាប់បាន ។

បទថា **កុម្ភដ្ឋានកថា** និយាយរឿងកំពង់ទឹក គឺ ទីតាំងរបស់ឆ្នាំង ទឹក លោកហៅថា កំពង់ទឹក ។ បទថា **កុម្ភទាសីកថា** និយាយរឿងនាង

កុម្ភទាសី សូម្បីនាងកុម្ភទាសីនោះ ក៏មិនគប្បីនិយាយដោយសេចក្ដីលើកសរសើរថា នាងកុម្ភទាសីគួរស្រឡាញ់ ច្លាតក្នុងរបាំ រាំច្រៀង ។ គួរនិយាយដោយន័យមានជាដើមថា **សទ្ធាសម្បន្នា** ទុំះឯង ។ បទថា **បុព្វបេតកថា** និយាយរឿងអ្នកដែលស្លាប់ទៅហើយ គឺ និយាយរឿងញាតិក្នុងអតីត ។ ក្នុងបទថា **បុព្វបេតកថា** នោះ ដូចគ្នានឹងនិយាយរឿងញាតិដែលនៅមានជីវិតនៅ ។ បទថា **នានត្តកថា** និយាយរឿងផ្សេងៗ គឺ និយាយរឿងមិនមានប្រយោជន៍ មានសភាពផ្សេងៗ ក្រៅអំពីនិយាយរឿងមុន និងរឿងក្រោយ ។ បទថា **លោកក្ខាយិកា** និយាយរឿងលោក គឺ សន្ទនាគ្នារឿងលោកាយតសាស្ត្រ និងរឿងក្រៅគម្ពីរ មានជាដើមយ៉ាងនេះថា លោកនេះអ្នកណាសាង លោកនេះអ្នកឯណោះសាង ក្អែកស ព្រោះឆ្អឹងស សត្វកុកក្រកក្រហម ព្រោះឈាមក្រហម ការនិយាយរឿងឈ្មោះគ្មានប្រយោជន៍ មានជាដើមយ៉ាងនេះថា ព្រោះហេតុអ្វី ទើបហៅថា សមុទ្រ , ព្រោះហេតុអ្វី ទើបហៅថា សាគរ ។ ដែលហៅថា សមុទ្រ ព្រោះលើកដៃប្រកាសថា យើងជីក ។ ឈ្មោះថា សាគរ ព្រោះសាគរទេវជីក ឈ្មោះថា និយាយរឿងសមុទ្រ និយាយដល់ហេតុគ្មានប្រយោជន៍ មិនជាចំណែចថា សេចក្ដី

ចម្រើនយ៉ាងនេះ សេចក្តីសាបសូន្យយ៉ាងនេះ ឈ្មោះថា និយាយរឿងនៃសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ដោយប្រការនោះៗ ។ម្យ៉ាងទៀត ក្នុងបទនេះ សេចក្តីឃើញថា ទៀង គឺ សេចក្តីចម្រើន ។ សេចក្តីឃើញថាសូន្យ គឺ សេចក្តីសាបសូន្យ ។ សេចក្តីចម្រើន គឺ **ភវ** សេចក្តីសាបសូន្យ គឺ **អភវ** ។ កាមសុខ គឺ សេចក្តីចម្រើន ។ ការធ្វើខ្លួនឲ្យលំបាក គឺ សេចក្តីសាបសូន្យ ។

ឈ្មោះថា តិរច្ឆានកថាមាន ៣២ យ៉ាង រួមជាមួយ **អតិតកវាភវកថា** (និយាយរឿងចម្រើន និងសាបសូន្យ) ៦ យ៉ាងនេះ ដោយប្រការដូច្នេះ ។ សន្ទកបរិព្វាជក អង្គុយរួមនឹងអ្នកនិយាយតិរច្ឆានកថា មានសភាពដូច្នេះ ។ តអំពីនោះ សន្ទកបរិព្វាជកក្រឡេកមើលបរិព្វាជកទាំងនោះ គិតថា បរិព្វាជកទាំងនេះ មិនគោរពកោតក្រែងគ្នានិងគ្នាឡើយ ។ ម្យ៉ាងទៀត ពួកយើងតាំងពីព្រះសមណគោតមប្រាកដឡើង ប្រៀបដូចជាអំពិលអំពែកក្នុងវេលាព្រះអាទិត្យរះឡើង ។ សូម្បីលាភសក្ការៈរបស់ពួកយើងក៏សាបសូន្យ ។ បើព្រះសមណគោតម ឬសាវករបស់ព្រះគោតម សូម្បីឧបដ្ឋាកដែលនៅជាគ្រហស្ថរបស់ព្រះសមណគោតមនោះ គប្បីមកកាន់ទីនេះ នឹងគួរខ្មាសយ៉ាង

ក្រៃលែង ។ ក៏ទោសក្នុងបរិស័ទ រមែងកើតឡើងក្នុងខាងលើ របស់អ្នកចម្រើនក្នុងបរិស័ទ ។ ទើបសម្លឹងមើលខាងឯណោះខាងនេះ បានឃើញព្រះថេរៈ ។

ដោយហេតុនោះ លោកទើបពោលថា **អទ្ទសា ខោ សន្ទកោ បរិព្វាជកោ ។ល។ តុណ្ហីអហេសុំ** សន្ទកបរិព្វាជក បានឃើញព្រះអានន្ទមកពីចម្ងាយ ទើបហាមបរិស័ទរបស់ខ្លួនឲ្យស្ងាត់សំឡេងថា លោកដ៏ចម្រើនទាំងឡាយ ចូរនិយាយឲ្យមានសំឡេងតិចចុះ លោកដ៏ចម្រើនទាំងឡាយកុំធ្វើសំឡេងខ្លាំងតទៅទៀតឡើយ នេះសាវករបស់ព្រះសមណគោតម ជាសមណៈឈ្មោះ អានន្ទកំពុងមកហើយ ។ សមណៈឈ្មោះអានន្ទនេះ ជាសាវកមួយអង្គ ក្នុងបណ្ដាសាវករបស់ព្រះគោតម ដែលអាស្រ័យនៅក្នុងក្រុងកោសម្ពី ក៏លោកអ្នកមានអាយុទាំងនោះ ជាអ្នកប្រាថ្នាក្នុងភាពជាអ្នកមានសំឡេងតិច ណែនាំក្នុងភាពមានសំឡេងតិច ពោលសរសើរសំឡេងតិច ធ្វើដូចម្ដេច ឲ្យសមណៈឈ្មោះអានន្ទនោះជ្រាបថា បរិស័ទមានសំឡេងតិច ហើយគប្បីសម្គាល់ការចូលមកជិត ។ លំដាប់នោះ បរិព្វាជកទាំងនោះបានស្ងៀមនៅ ។

ក្នុងបទទាំងនោះ បទថា **សណ្ណបេសិ** ឲ្យស្ងប់សំឡេង គឺ ធ្វើបន្ទំបានដល់ បិទបាំងទោសរបស់បរិស័ទនោះ ។ ញុំាងបរិស័ទឲ្យតាំងនៅ ដោយអាការដែលតាំងនៅហើយដោយល្អ ។ ដូចបុរស កាលចូលទៅកាន់កណ្តាលបរិស័ទ រមែងស្លៀកដណ្តប់រៀបរយដើម្បីបិទបាំងទោស ។ បោសទីប្រឡាក់ប្រឡូសដោយល្អងធូលី យ៉ាងណា ។ សន្ទុកបរិព្វាជក ហាមបរិស័ទថាលោកដ៏ចម្រើនទាំងឡាយ ចូរនិយាយសំឡេងតិចៗ ដើម្បីបិទបាំងទោសរបស់បរិស័ទនោះ ។ អធិប្បាយថា ឲ្យបរិស័ទតាំងនៅដោយអាការតាំងនៅដោយល្អ ។ បទថា **អប្បសទ្ទកាមក** សាវកទាំងឡាយប្រាថ្នាក្នុងភាពជាអ្នកមានសំឡេងតិចៗ គឺ ប្រាថ្នាសំឡេងស្រាល ។ អន្តុយតែម្នាក់ឯងឈរតែម្នាក់ឯង មិនច្របូកច្របល់ដោយពួក ។

បទថា **អប្បសទ្ទវិនីតា** ណែនាំក្នុងសេចក្តីមានសំឡេងតិចៗ គឺព្រះពុទ្ធអ្នកមានសំឡេងតិចៗ មានសំឡេងមិនខ្លាំង ទ្រង់ណែនាំទុកហើយ ។ បទថា **អប្បសទ្ទស្ស វណ្ណវាទិនោ** អ្នកពោលសរសើរសំឡេងតិច គឺ ពោលសរសើរកន្លែងដែលមានសំឡេងតិច និងមិនមានសំឡេង ។

បទថា **ឧបសង្កមិតព្វំ មញ្ញេយ្យ** គប្បីសម្គាល់ការនឹងចូលមកជិត

គឺ គប្បីសម្គាល់ដល់ការចូលទៅក្នុងទីនេះ ។

ក៏ព្រោះហេតុអ្វី សន្ទកបរិព្វាជកនោះ ទើបបំណងនឹងចូលទៅជិតព្រះថេរៈហ្ន៎ ។ ព្រោះប្រាថ្នាសេចក្ដីចម្រើនដល់ខ្លួន ។ បានឮថា បរិព្វាជកទាំងឡាយ កាលព្រះពុទ្ធ ឬកាលសាវករបស់ព្រះពុទ្ធមកកាន់សម្នាក់របស់ខ្លួន ទើបលើកខ្លួនឡើងក្នុងសម្នាក់របស់ពួកឧបដ្ឋាកថា ថ្ងៃនេះព្រះសមណគោតមមកកាន់សម្នាក់របស់ពួកយើង ព្រះសារីបុត្រក៏មក ។ លោកទាំងនោះ មិនទៅរកអ្នកណាៗ ឡើយ ។ ពួកលោកចូរឃើញថា ពួកយើងខ្ពស់ប៉ុណ្ណា ។ រមែងតាំងខ្លួនទុកក្នុងទីខ្ពស់ ។ ព្យាយាមនឹងទទួលយកឧបដ្ឋាកសូម្បីរបស់ព្រះមានព្រះភាគ ។ ន័យថា បរិព្វាជកទាំងនោះ ឃើញពួកឧបដ្ឋាករបស់ព្រះមានព្រះភាគ ទើបពោលយ៉ាងនេះថា សូម្បីព្រះគោតមដ៏ចម្រើនសាស្ដារបស់ពួកលោក សូម្បីសាវករបស់ព្រះគោតម គង់មកកាន់សម្នាក់របស់ពួកយើង ។ ពួកយើងព្រមព្រៀងគ្នានិងគ្នា ។ ចំណែកពួកលោកមិនប្រាថ្នានឹងសម្លឹងមើលពួកយើង មិនធ្វើសាមីចិកម្ម ។ ពួកយើងធ្វើខុសអ្វីដល់ពួកលោកឬ ។ គ្រានោះ មនុស្សពួកខ្លះគិតថា សូម្បីព្រះពុទ្ធក៏គង់ស្ដេចមកដល់សម្នាក់បរិព្វាជកទាំងនេះ ។ និយាយប្ញីដល់ពួកយើង ។ តាំង

ពីនោះពួកមនុស្ស ឃើញបរិព្វាជកហើយ ក៏មិនធ្វេសប្រហែស ។ បទថា **តុណ្ហី អហេសុំ** បរិព្វាជកទាំងនោះបាននៅស្ងៀម គឺ អង្គុយលោមព័ទ្ធ សន្ទុកបរិព្វាជក ។ បទថា **ស្វាគតំ ភោតោ អានន្ទស្ស** ព្រះអានន្ទមកល្អហើយ លោកសម្តែងទុកថា កាលលោកដ៏ចម្រើនមករកពួកយើង ជាព្រះអានន្ទ ។

កាលលោកទៅក៏នឹងពេញចិត្ត ។ បទថា **ចិរស្សំ ខោ** នេះ ជាពាក្យពោលសម្តែងសេចក្តីគួរស្រឡាញ់ ។

ចំណែកព្រះថេរៈ ទៅអារាមរបស់បរិព្វាជកតាមវេលា ដើម្បីត្រូវការចារិក ព្រោះហេតុនោះ សន្ទុកបរិព្វាជកកាន់យកអាការដែលធ្លាប់មកក្នុងកាលមុន ទើបពោលយ៉ាងនេះ ។ គ្រាបរិព្វាជកពោលយ៉ាងនេះហើយ ក៏មិនបានជាអ្នករឹងត្អឹងដោយមានះ ហើយអង្គុយ ។ ទើបក្រោកពីអាសនៈរបស់ខ្លួន ហើយបោសអាសនៈនោះ និមន្តព្រះថេរៈឲ្យអង្គុយលើអាសនៈ ពោលថា ព្រះអានន្ទ ចូរអង្គុយចុះ ។ នេះអាសនៈក្រាលទុកហើយ ។

**[៥៥]** បទថា **អន្តរាកថា វិប្បកតា** រឿងអ្វីដែលពួកលោកបញ្ឈប់ទុកក្នុងចន្លោះ ។ ព្រះអានន្ទសួរថា កថាអ្វីដែលពួកលោកបញ្ឈប់ក្នុងចន្លោះ

តាំងពីពួកលោកអគ្គិយសន្ទនាគ្នាដរាបដល់ខ្ញុំមក ។ កថាអ្វី ដែលនៅមិនទាន់ចប់ ព្រោះខ្ញុំមកជាហេតុ ។ លំដាប់នោះ បរិព្វាជកកាលនឹងសម្តែងថា កថាគ្មានប្រយោជន៍ មិនមានសារៈ អាស្រ័យវដ្តៈ មិនសមគួរនឹងពោលចំពោះមុខលោក ទើបពោលពាក្យមានជាដើមថា **តិដ្ឋតេសា ភោ** លោកដ៏ចម្រើនរឿងនោះ សូមលើកទុកចុះ ។ បទថា **នេសា ភោតោ** សន្ទកបរិព្វាជកពោលថា បើលោកដ៏ចម្រើនប្រាថ្នានឹងស្តាប់ សូម្បីខាងក្រោយក៏នឹងបានស្តាប់ដោយមិនលំបាក ។ កថានេះ មិនមានប្រយោជន៍ដល់ពួកយើងឡើយ ។ ពួកយើងបានការមករបស់លោកដ៏ចម្រើនហើយ ប្រាថ្នានឹងស្តាប់កថាដែលមានហេតុផលល្អយ៉ាងដទៃផ្សេង ។ សន្ទកៈ កាលនឹងអង្វរសូមព្រះធម៌ទេសនា ទើបពោលពាក្យមានជាដើមថា **សាធុវត ភវន្តំយេវ** ល្អណាស់ហ្ន៎ កថាដែលជាធម៌ ចូរជាក់ច្បាស់ដល់លោកដ៏ចម្រើនចុះ ។ ក្នុងបទទាំងនោះ បទថា **អាចរិយកេ** គឺ ក្នុងលទ្ធិរបស់អាចារ្យ ។ បទថា **អនស្សាសិកានិ** ព្រហ្មចរិយដែលវៀរសេចក្តីត្រេកអរ គឺ មិនមានសេចក្តីរួចផុតស្រឡះ ។ បទថា **សសក្កំ** ជានិបាតចុះក្នុងអត្ថពោលអំពីចំណែកតែមួយ ។ អធិប្បាយថា វិញ្ញូជនមិនគប្បីនៅប្រព្រឹត្តដោយចំណែកតែមួយ ។

លោកអធិប្បាយថា ចំណែកវិញ្ញូជន កាលនៅប្រព្រឹត្តមិនគប្បីឲ្យត្រេកអរ មិនគប្បីឲ្យសម្រេច មិនគប្បីធ្វើឲ្យបរិបូរណ៍ ។ បទថា **ញាយំ ធម្មំ កុសលំ** ញុំាងកុសលធម៌ជាគ្រឿងចេញទៅ គឺ ឈ្មោះថា កុសលធម៌ ព្រោះអត្ថថា មិនមានទោសដែលជាហេតុ ។ បទថា **ឥធ** គឺ ក្នុងលោកនេះ ។ បទមានជាដើមថា **នត្ថិ ទិន្នំ** ទានដែលឲ្យហើយមិនមានផល លោកពោលទុកហើយក្នុងសាលេយ្យកសូត្រ ។ បទថា **ចាតុមហាភូតិកោ** គឺ សម្រេចដោយមហាភូតរូប ៤ ។ បទថា **បឋវី បឋវីកាយំ** ធាតុដីទៅតាមធាតុដី គឺ ធាតុដីខាងក្នុងទៅតាមធាតុដីខាងក្រៅ ។ បទថា **អនុបេតិ** គឺ ទៅតាម ។ បទថា **អនុបគច្ឆតិ** ទៅតាម ជាវេវចនៈរបស់បទថា **អនុបេតិ** ។ នោះជា **អនុគច្ឆតិ** ក៏មាន ។ សូម្បីដោយបទទាំងពីរនេះ លោកសម្ដែងថា **ឧបេតិ ឧបគច្ឆតិ** គឺ ចូលទៅ ។ សូម្បីក្នុងធាតុទឹកជា ដើមក៏មានន័យនេះដូចគ្នា ។ បទថា **ឥន្ទ្រិយានិ** គឺ ឥន្ទ្រិយ មានមនិន្ទ្រិយជាទី ៦ រមែងត្រាច់ទៅកាន់អាកាស ។ បទថា **អាសន្ទិបញ្ចមា** គឺ មានគ្រែជាគម្រប់ ៥ គឺ មានគ្រែអន្ទុយជាទី ៥ ។ អធិប្បាយថា គ្រែ និងបុរស ៤ អ្នកឈរចាប់ជើងគ្រែទាំង ៤ ។ បទថា **យាវ អាឡាហនា** គ្រាន់តែព្រៃជាទីចោលសាកសព ។

បទថា **បទានិ** គឺ រាងកាយ ។ គុណបទទាំងឡាយប្រព្រឹត្តទៅហើយ ដោយន័យមានជាដើមថា អ្នកនេះមានសីលយ៉ាងនេះ ទ្រុស្តសីលយ៉ាងនេះ ។ ក្នុងបទថា **បទានិ** នេះ លោកបំណងយកសរីរៈ ។ បទថា **កាបោតកានិ** គឺ មានពណ៌ប្រផេះ ។ អធិប្បាយថា មានពណ៌ដូចជាស្លាបនៃសត្វព្រាប ។

បទថា **ភស្មន្តា** គឺ មានផេះជាទីបំផុត ។ ក្នុងបទនេះ បាលីជាយ៉ាងនេះ ។ បទថា **អាហុតិយោ** ការបូជា សេចក្តីថា ទានដែលឲ្យហើយ មានប្រភេទជាគ្រឿងសក្ការៈជាដើម ដែលជាគ្រឿងបូជាទាំងអស់នោះ មានផេះជាទីបំផុត ។ តពីនោះមិនឲ្យផលឡើយ ។ បទថា **ទត្តុប្បញ្ញត្តំ** ទានដែលបុគ្គលល្ងង់ខ្លៅបញ្ញត្តិទុក គឺ បុគ្គលល្ងង់ខ្លៅ ជនពាលបញ្ញត្តិទុក បទនេះលោកអធិប្បាយថា ទាននេះ ជនពាលល្ងង់ខ្លៅបញ្ញត្តិទុក ។ មិនមែនបណ្ឌិតបញ្ញត្តិ ។ ជនពាលឲ្យ បណ្ឌិតទទួល ។ បទថា **អត្ថិកវាទំ** វាទៈថាមានផល បុគ្គលពួកខ្លះពោលវាទៈថា មានផល ផលនៃទានដែលឲ្យហើយមាន ។ ពាក្យរបស់អ្នកទាំងនោះ ជាពាក្យទទេ ពាក្យកុហក ពាក្យផ្តេសផ្តាស់ បទថា **ពាលោ ច បណ្ឌិតោ ច** គឺ ពាល និងបណ្ឌិត ។ បទថា **អកតេន មេ ឯត្ថ កតំ** កម្មក្នុងលទ្ធិនេះ ដែលយើងមិនបានធ្វើឡើយ ជាការ

ធ្វើហើយ គឺ កម្មក្នុងលទ្ធិនេះ ដោយកម្មរបស់សមណៈដែលយើងមិនបាន ទម្លាយ ឈ្មោះថា ជាការធ្វើហើយ ។ ព្រហ្មចរិយៈដែលយើងមិនធ្លាប់នៅ ឈ្មោះថា ជាការនៅហើយ ។ បទថា **ឯត្ថ** គឺ ក្នុងធម៌របស់សមណៈនេះ ។

បទថា **សមសមា** ជាអ្នកស្មើៗ គ្នា គឺ ស្មើគ្នាដ៏ល្អ ឬស្មើគ្នាដោយ គុណដែលស្មើ ។ បទថា **បំ បត្តា** គឺ ដល់ភាពជាអ្នកស្មើគ្នា ។ បទមានជា ដើមថា **ករតោ** កាលបុគ្គលធ្វើដោយខ្លួនឯង លោកពោលទុកហើយក្នុង អបណ្ណកសូត្រ ។

**[៦០]** បទមានជាដើមថា **នត្ថិ** ហេតុមិនមែនហេតុ ក៏ដូច្នោះ ។

**[៦៣] គប្បីជ្រាបវិនិច្ឆ័យក្នុងព្រហ្មចរិយវាសទី ៤** ដូចតទៅនេះ

ឈ្មោះថា **អកតា** ព្រោះមិនមានអ្នកណាធ្វើ ។ បទថា **អកតវិធា** គឺ មិនមានអ្នកណាធ្វើ ។ អធិប្បាយថា មិនមានអ្នកណាៗ បង្គាប់ឲ្យធ្វើថា លោកចូរធ្វើយ៉ាងនេះ ។ បទថា **អនិម្មិតា** មិនមានអ្នកណានិម្មិត គឺ មិនមាន អ្នកណានិមិត្តសូម្បីដោយឫទ្ធិ ។ បទថា **អនិម្មាតា** គឺ មិនមានអ្នកណានិមិត្ត ឲ្យ ។ អាចារ្យពួកខ្លះពោលបទថា **អនិម្មិតព្វា** មិនគប្បីនិមិត្តឲ្យ ។ បទនោះ មិនប្រាកដក្នុងបាលី មិនប្រាកដក្នុងអដ្ឋកថា ។ បទថា **វញ្ឈា** មានសភាព

អារ ដូចសត្វចិញ្ចឹមជាមេអារ មិនបង្កើតដល់សត្វណាៗ ដូចត្នោតជាដើម មិនមានផល ។ ដោយបទនេះ បដិសេធសេចក្តីដែលបឋវីធាតុជាដើម ឲ្យកើតរូបជាដើម ។ ឈ្មោះថា **កូដដ្ឋា** ព្រោះតាំងនៅមាំដូចកំពូលភ្នំ ។ បទថា **ឯសិកដ្ឋាយិដ្ឋិតា** គឺ តាំងនៅមាំដូចសសរខឿនក្នុងស្មោងដំណោកទន្សាយ ។ ក្នុងបទនោះ មានអធិប្បាយថា វត្ថុណាដែលលោកពោលថារមែងកើត វត្ថុនោះមាននៅដូចសសរខឿន ចេញផុតអំពីស្មោងដំណោកទន្សាយ ។ បាឋៈថា **ឯសិកដ្ឋាដ្ឋិតា** ក៏មាន ។ អធិប្បាយថា សសរខឿនដែលកប់ទុកល្អហើយ មិនញាប់ញ័រ តាំងនៅរឹងមាំ ។ សភាវៈ ៧ កង តាំងមាំហើយយ៉ាងនោះ ។ សូម្បីដោយបទទាំង ២ នេះ លោកសម្តែងដល់សេចក្តីមិនវិនាសទៅនៃសភាវៈ ៧ កងទាំងនោះ ។ បទថា **ន ឥញ្ជន្តិ** សភាវៈ ៧ កងមិនញាប់ញ័រ គឺ មិនកម្រើក ព្រោះតាំងនៅរឹងមាំដូចសសរខឿន ដូច្នោះ ។ បទថា **ន វិបរិណមន្តិ** មិនប្រែប្រួល គឺ មិនលះប្រក្រតីទៅ ។ បទថា **អញ្ញមញ្ញំ ព្យាពាធេន្តិ** គឺ មិនបៀតបៀនគ្នានិងគ្នា ។ បទថា **នាលំ** គឺ មិនអាច ។

គប្បីជ្រាបសេចក្តីក្នុងបទមានជាដើមថា **បឋវីកាយោ** ពួកធាតុដីដូច

តទៅនេះ កងដី ឬពូកដី ។ បទថា **តត្ថ** គឺ ក្នុងកងមានជីវៈជាទី ៧ ទាំងនោះ ។ បទថា **នត្ថិ ហន្តា វា** អ្នកសម្លាប់ដោយខ្លួនឯងមិនមាន លោកសម្ដែងទុកថា មិនមានអ្នកអាចដើម្បីសម្លាប់ខ្លួនឯងក្ដី ប្រើឲ្យអ្នកដទៃសម្លាប់ក្ដី ដើម្បីឲ្យក្ដៅក្រហាយក្ដី ដើម្បីប៉ះទង្គិចក្ដី ដើម្បីញុំាងគេសោកសៅដោយខ្លួនឯងក្ដី ដើម្បីញុំាងអ្នកដទៃឲ្យធ្វើនៅសេចក្ដីសោកសៅក្ដី ដើម្បីបានឮខ្លួនឯងក្ដី ដើម្បីយល់ខ្លួនឯងក្ដី ។ បទថា **សត្តន្នំត្វេវ កាយានំ** នៃសភាវៈ ៧ កង លោកសម្ដែងទុកថា ដូចសស្ត្រាដែលចាក់ក្នុងគំនរសណ្ដែកបាយជាដើម រមែងចូលទៅក្នុងចន្លោះគំនរសណ្ដែកបាយ យ៉ាងណា សស្ត្រាស៊កចូលទៅត្រង់ចន្លោះសភាវៈ ៧ កង ក៏ដូច្នោះ សស្ត្រាត្រឹមតែជាសញ្ញាមយ៉ាងប៉ុណ្ណោះថា យើងនឹងសម្លាប់អ្នកនេះចេញ ។ បទថា **យោនិប្បមុខសតសហស្សានិ** លោកសម្ដែងទិដ្ឋិគ្មានប្រយោជន៍ ដោយត្រឹមតែប៉ាន់ស្មានតែម្យ៉ាងថា កំណើតដែលជាប្រធាន និងកំណើតខ្ពស់បំផុត ១,៤០៦,៦០០ កម្ម ។ បទថា **បញ្ច-កម្មុនោ សតានិ** សេចក្ដីថា ៥០០ កម្ម ។ សូម្បីក្នុងបទមានជាដើមថា **បញ្ច ច កម្មានិ តីណិ ច កម្មានិ** កម្ម ៥ និងកម្ម ៣ ក៏មានន័យនេះដូចគ្នា ។ តែអាចារ្យពួកខ្លះពោលថា បទថា **បញ្ច កម្មានិកម្ម** ៥ លោកពោលដោយ

អំណាចឥន្ទ្រិយ ៥ ។ បទថា **តីណិ** កម្ម ៣ លោកពោលដោយអំណាចកាយកម្មជាដើម ។ តែក្នុងបទថា **កម្មេ ច អន្តរកម្មេ ច** កម្ម ១ កម្មកន្លះនេះ គឺ លទ្ធិរបស់កម្មនោះ គឺ កាយកម្ម និងវចីកម្ម ។ មនោកម្ម ជាកម្មពាក់កណ្ដាល ។ បទថា **ទិដ្ឋិបដិបទា** លោកពោលដល់បដិបទាក្នុងទិដ្ឋិ ៦២ ។ បទថា **ទ្វដ្ឋន្តរកប្បា** អន្តរកប្ប ៦២ គឺ ក្នុងកប្បមួយៗ មាន ៦៤ អន្តរកប្ប ។ ព្រះអានន្ទត្ថេរកាលមិនដឹង ២ កប្ប យ៉ាងដទៃ ទើបពោលយ៉ាងនេះ ។ អភិជាតិ ៦ ពោលទុកពិស្ដារហើយក្នុងអបណ្ណកសូត្រ ។ បទថា **អដ្ឋ បុរិសភូមិយោ** បុរិសភូមិ ៨ លោកពោលទុកថា បុរិសភូមិ ៨ ទាំងនេះ គឺ មន្ទភូមិ (ភូមិខ្សោយ) ១ ខិឌ្ឌាភូមិ (ភូមិលេង) ១ បទវីមំ-សកភូមិ (ភូមិហាត់ដើរ) ១ ឧជុគតភូមិ (ភូមិដើរ) ១ សេក្ខភូមិ (ភូមិសិក្សា) ១ សមណភូមិ (ភូមិសមណៈ) ១ ជិនភូមិ (ភូមិរៀនដឹង) ១ បន្នភូមិ (ភូមិសម្រេចហើយ) ១ ។

ក្នុងភូមិទាំងនោះ លោកពោលថា សត្វទាំងឡាយជាអ្នកនៅខ្សោយនៅល្ងង់ខ្លៅ ព្រោះតាំងពីថ្ងៃប្រសូតចេញចាកទីចង្អៀតក្នុង ៧ ថ្ងៃ នេះ ឈ្មោះថា មន្ទភូមិ ។ ម្យ៉ាងទៀត សត្វពួកណាមកពីទុគ្គតិ សត្វទាំងនោះ រមែងស្រែក

និងស្រែកខ្លាំងរឿយៗ ។ សត្វមកពីសុគតិ រលឹកដល់សុគតិនោះៗ ហើយសើច នេះឈ្មោះថា ខិឌ្ឌាភូមិ ។ ការចាប់ដៃ ឬជើងរបស់មាតាបិតា ឬគ្រែតាំង ហើយជាន់ជើងចុះលើផែនដី ឈ្មោះថា បទវីមំសកភូមិ ។ គ្រាដែលអាចដើរទៅដោយជើងបាន ឈ្មោះថា ឧជុគតភូមិ ។ គ្រាសិក្សាសិល្បៈ ឈ្មោះថា សេក្ខភូមិ ។ គ្រាចេញចាកផ្ទះហើយបួស ឈ្មោះថា សមណភូមិ ។ គ្រាសេពគប់អាចារ្យហើយចេះដឹង ឈ្មោះថា ជិនភូមិ ។ ម្យ៉ាងទៀត ភិក្ខុដែលចេះដឹងសម្រេចហើយ មិនរៀនអ្វីទៀត ព្រោះហេតុនោះ សមណៈអ្នកមិនត្រូវរៀនយ៉ាងនេះ ឈ្មោះថា បន្នភូមិ ។

បទថា **ឯកូនបញ្ញាស[១] អាជីវសតេ** គឺ លោកពោលថា ពួកអាជីវកទាំង ១៤៩ ។ បទថា **ឯកូនបញ្ញាស បរិព្វាជកសតេ** គឺ ការបព្វជ្ជារបស់បរិព្វាជក ១៤៩ ។ បទថា **ឯកូនបញ្ញាស នាគាវាសសតេ** គឺ នាគមណ្ឌល ១៤៩ ។ បទថា **វីសេ អន្ទ្រិយសតេ[២]** គឺ ឥន្ទ្រិយ ១២០ ។ បទថា **តឹសេ-និរយសតេ[៣]** គឺ នរក ១៣០ ។ បទថា **រជោធាតុយោ** គឺ ដែលពាសពេញ

---

១-ឯកូនបញ្ញាស អដ្ឋកថា ៤.៩០០ , ២- អដ្ឋកថា ២.០០០ ។ ៣-អដ្ឋកថា ៣.០០០ បិដកទំព័រ ១០៩-១១០ = ១៤៩ , ១២០ , ១៣០

ដោយធូលី ។ លោកពោលសំដៅដល់ខ្នងដៃ និងខ្នងជើងជាដើម ។ បទថា **សត្ត សញ្ញិគព្ភា** សញ្ញីគភ៌ ៧ លោកពោលសំដៅដល់ អូដ្ឋ គោ លា ពពែ សត្វចិញ្ចឹម ម្រឹគ និងក្របី ។ បទថា **អសញ្ញិគព្ភា** បានដល់ អសញ្ញីគភ៌ ៧ លោកពោលសំដៅដល់ ស្រូវសាលី ស្រូវខ្សាយ ស្រូវជំណើប សណ្តែក-បាយ ស្កួយ ស្មៅ និងស្រងែ ។

បទថា **និគន្ឋគព្ភា** និគន្ឋគភ៌ គឺ គភ៌កើតក្នុងនិគន្ឋៈ ។ លោកពោលសំដៅដល់ អំពៅ ឫស្សី ដើមបបុស ។

បទថា **សត្ត ទេវា** ទេវតា ៧ ។ បទថា **សត្តបីសាចា** បីសាច ៧ គឺ បីសាចច្រើន លោកក៏ពោលថា ៧ ។ បទថា **សរា** គឺ ស្រះធំ លោកពោលសំដៅដល់ស្រះឈ្មោះថា កណ្ណមុណ្ឌកៈ រថការៈ អនោតត្តៈ សីហ-ប្បបាត ឆទ្ទន្តៈ មុចលិន្ទៈ កុណាលទហៈ ។ បទថា **បវុដា** បានដល់ ម្ចាស់តម្រា ។ បទថា **សត្តបបាតា** បានដល់ ជ្រោះធំ ៧ ។ បទថា **សត្ត-បបាតសតានិ** បានដល់ ជ្រោះតូច ៧០០ ។ បទថា **សត្តសុបិនា** បានដល់ សុបិនធំ ៧ ។ បទថា **សត្ត សុបិនសុតានិ** បានដល់ សុបិនតូច ៧០០ ។ បទថា **មហាកប្បិនោ** បានដល់ មហាកប្ប ។ ក្នុងបទនេះ លោកពោលថា

គ្រប់ៗ ១០០ ឆ្នាំ យកចុងស្បូវជ្រលក់ទឹក នាំចេញទៅម្ដងមួយតំណក់ ៧ ដង កាលធ្វើឲ្យទឹកអស់អំពីស្រះនោះ ទើបហៅថា ១ មហាកប្ប ។ ជនពាល និងបណ្ឌិតញុំាងមហាកប្ប ៨,៤០០,០០០ បែបនោះ ឲ្យអស់ទៅ ទើបនឹងធ្វើទីបំផុតទុក្ខបាន នេះជាលទ្ធិរបស់គេ ។ ន័យថា សូម្បីបណ្ឌិតក៏មិនអាចធ្វើឲ្យបរិសុទ្ធិបានក្នុងចន្លោះ ។ សូម្បីជនពាល ក៏មិនលើសអំពីនោះបាន ។ បទថា **សីលេន** គឺ ដោយសីលនោះ សូម្បីលោកពោលអំពីអចេលសីល ឬសីលដទៃណាមួយ ។ បទថា **វតេ្តន** គឺ ដោយវត្តនោះ ។ បទថា **តបេន** គឺ ដោយការធ្វើសេចក្ដីព្យាយាមជាគ្រឿងដុតបាប អធិប្បាយថា បុគ្គលណាគិតថា យើងជាបណ្ឌិត ដូច្នេះ នឹងបរិសុទ្ធមុនវេលា បុគ្គលនោះ ឈ្មោះថា រមែងអប់រំកម្មដែលនៅមិនទាន់ផ្ដល់ផលឲ្យ បុគ្គលនោះគិតថា យើងជាពាល បណ្ដោយវេលាទុកតាមរយៈវេលាដែលពោលទុក បុគ្គលនោះ ឈ្មោះថា ពាល់ត្រូវសម្ផស្សដែលកម្មឲ្យផលហើយ ធ្វើឲ្យអស់ទីបំផុត ។

បទថា **ហេវំ នត្ថិ** គឺ រមែងមិនមានដោយអាការយ៉ាងនេះ លោកសម្ដែងថា សូម្បីទាំងពីរករណីនោះ មិនអាចធ្វើបាន ។ បទថា **ទោណមិតេ** គឺ វាល់របស់ដោយនាឡិ ។ បទថា **សុខទុកេ្ខ** បានដល់ សុខ និងទុក្ខ ។

ពាក្យថា **បរិយន្តកតេ** គឺ ធ្វើទីបំផុតឲ្យអស់បានតាមការកំណត់វេលា ដូចពោលហើយ ។ បទថា **មិនមានសេចក្តីសាបសូន្យ និងសេចក្តីចម្រើន** គឺ សេចក្តីវិនាស និងសេចក្តីចម្រើនរមែងមិនមាន អធិប្បាយថា សង្សារវដ្តមិនបានសាបសូន្យដល់បណ្ឌិត មិនបានចម្រើនដល់បុគ្គលពាល ។ បទថា **ឧក្កំ សាវកំសេ** គឺ ការលូតលាស់ឡើង និងការរិចរិល ។ ពាក្យនោះ ជាវេវចនៈនៃសេចក្តីវិនាស និងសេចក្តីចម្រើន ។

ឥឡូវនេះ កាលបើនឹងស្វាធ្យាយសេចក្តីនោះដោយឧបមា សាស្តា (ម្ចាស់លទ្ធិ) ទើបពោលពាក្យជាដើមថា **សេយ្យថិ នាម** ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **សុត្តគុឡេ** បានដល់ ដូចអំបោះដែលមូរទុក ។ បទថា **និព្វេឋិយមានមេវ បលេតិ** សេចក្តីថា កាលបុគ្គលឈរនៅលើភ្នំ ឬចុងឈើហើយគ្រវែងអំបោះទៅ រមែងរលាចេញទៅរហូតអំបោះនោះអស់ កាលអំបោះអស់ ក៏ឈប់នៅទីនោះ គឺ មិនកន្លងហួសទៅ ។ លោកសម្តែងថា បណ្ឌិត និងពាលនោះ នឹង (បរិសុទ្ធិ) ទៅឯង ដូចវេលាដែលពោលទុកហើយយ៉ាងនោះ មិនបាន ។

**[៦៥]** បទថា **កិមិទំ** សេចក្តីថា សាស្តាខ្លះក្នុងលោកនេះ កាលគេ

សួរយ៉ាងនេះ សេចក្តីនេះលោកមិនដឹងឬ ? លោកឈ្មោះថា ជាសព្វញ្ញូឬ ? ក៏គេចទៅក្នុងនិយតវាទ ពោលថា យើងចូលទៅកាន់ផ្ទះស្ងាត់ជាដើម ។

[៦៦] បទថា **អនុស្សវិកោ ហោតិ** គឺ ជាអ្នកអាស្រ័យការស្តាប់តាមគ្នាមក ។ បទថា **មនុស្សវសេច្ចា** គឺ ប្រកាន់តាមដែលស្តាប់មកពិតៗ ។ បទថា **បិដកសម្បទាយ** គឺ ការយល់ព្រមដោយគន្ថៈ គឺ បិដក ចាត់ជាវគ្គជាបណ្ណាសកៈ ។

[៦៨] បទថា **មន្ទោ** គឺ មានបញ្ញាទន់ខ្សោយ ។ បទថា **មោមូហោ** គឺ ជាមនុស្សល្ងង់ខ្លៅ គឺ ជាបុគ្គលល្ងង់យ៉ាងក្រៃលែង ។ បទថា **វាចាវិក្ខេបំ អាបជ្ជតិ** គឺ រមែងពោលបោះពាក្យបោះសំដីដោយវាចា អធិប្បាយថា ពាក្យនិយាយដូច្នេះ រមែងបោះពាក្យបោះសំដីទៅ ឈ្មោះថា បោះពាក្យបោះសំដីមិនឲ្យស្ទាប់ខ្លួន មិនមានទីបំផុត ។ម្យ៉ាងទៀត ត្រីមួយប្រភេទឈ្មោះអមរា កាលត្រាច់ទៅក្នុងទឹកដោយការផុសឡើង និងមុជចុះជាដើម នរណាៗមិនអាចចាប់បាន យ៉ាងណា សូម្បីវាទៈនេះក៏ដូច្នោះដែរ រមែងត្រាច់ទៅខាងនេះ ខាងនោះ រមែងមិនចូលដល់អាការដែលនឹងចាប់បាន ព្រោះហេតុនោះ វាទៈនោះ ទើបហៅថា **អមរាវិក្ខេប** ដូចត្រីអមរា ។

ក្នុងពាក្យថា **ឯវន្តិបិ មេ នោ** ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះ ។ សាស្តានោះ កាលគេសួរថា វត្ថុនេះជាកុសលឬ ក៏ពោលថា ការឃើញរបស់យើងថា សូម្បីយ៉ាងនោះក៏មិនមែន បន្ទាប់ពីនោះ កាលគេសួរថា អ្វីជាអកុសល? ក៏ពោលថា ការឃើញរបស់យើងថា សូម្បីយ៉ាងនោះក៏មិនមែន កាលគេសួរថា មានអ្វីយ៉ាងដទៃពីកុសល និងអកុសលទាំង ២ ឬ? ក៏ពោលថា ការឃើញរបស់យើងថា សូម្បីដោយប្រការដទៃក៏មិនមែន បន្ទាប់ពីនោះ កាលគេសួរថា ការឃើញរបស់លោកថា សូម្បីទាំងបីចំណែកក៏មិនមែនឬ? ក៏ពោលបណ្តោះបណ្តោយយ៉ាងនេះទៀតថា ការឃើញរបស់យើងថា មែនក៏មិនមែន មិនមែនក៏មិនមែន ដូច្នេះ រមែងមិនតាំងនៅសូម្បីក្នុងចំណែកណាមួយ ។

បទថា **និព្វិជ្ជ បក្កមតិ** នឿយណាយហើយចៀសចេញទៅ គឺ សាស្តានោះមិនអាចជាទីពឹងសូម្បីដល់ខ្លួនបាន នឹងអាចជាទីពឹងដល់យើងបាន យ៉ាងណា ព្រោះហេតុនោះ ទើបនឿយណាយចៀសចេញទៅ ។ សូម្បីក្នុងអនស្សាសិកព្រហ្មចរិយមុន ក៏មានន័យនេះដូចគ្នា ។

បទថា **សន្និធិការកំ កាមេ បរិភុញ្ជិតុំ** មិនគួរធ្វើការសន្សំ បរិភោគ

កាម គឺ ជាគ្រហស្ថមកពីមុនធ្វើការសន្សំហើយបរិភោគវត្ថុកាម ។ ឥឡូវ នេះ មិនគួរធ្វើការសន្សំក្នុក បាយ និងទឹកដោះថ្លាជាដើមយ៉ាងនេះហើយ បរិភោគ រមែងប្រាកដក្នុងឋានៈរបស់ព្រះវីណាស្រេព មិនមែនឬ ព្រោះហេតុ នោះ ទើបមិនប្រាកដដល់ពួកយើង ។ តពីនោះ មិនបានតាំងទុកដើម្បីប្រ- យោជន៍ដល់ខ្លួន របស់លោកតាំងទុកដើម្បីប្រយោជន៍ដល់អ្នកបួស ដែល មិនសប្បាយជាដើម ។ ដើម្បីព្រះអនាគាមី យ៉ាងណា ? ព្រះអនាគាមីនោះ លះកាមគុណ ៥ បានដោយប្រការទាំងពួង តែព្រះអនាគាមី ពិចារណាវត្ថុ ដែលលោកបានដោយធម៌ដោយស្មើហើយ ទើបបរិភោគ ។ បទថា **បុត្តមតាយ បុត្តា** អាជីវកទាំងនោះឈ្មោះថា ជាបុត្ររបស់មាតាអ្នកមានបុត្រស្លាប់ហើយ គឺ ន័យថា សន្ទកបរិព្វាជកនោះ ស្តាប់ធម៌នេះហើយ សម្គាល់ថា អាជីវក ស្លាប់ហើយ ទើបពោលយ៉ាងនេះ ។ ក្នុងបទនេះ មានអធិប្បាយដូចតទៅ នេះ អាជីវកទាំងឡាយឈ្មោះថា ស្លាប់ហើយ មាតារបស់អាជីវកទាំងនោះ ឈ្មោះថា ជាមាតាអ្នកមានបុត្រស្លាប់ហើយ ដោយប្រការដូច្នេះ អាជីវក ទាំងឡាយ ទើបជាអ្នកឈ្មោះថា ជាបុត្ររបស់មាតាអ្នកមានបុត្រស្លាប់ហើយ ។ បទថា **សមណោ គោតមេ** លោកសម្តែងថា ការប្រព្រឹត្តព្រហ្មចរិយៈ មាន

*នៅក្នុងព្រះសមណគោតម ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងនោះ ។*

" ចប់អដ្ឋកថា សន្ទកសូត្រទី ៦ "

# អ ដ្ឋ ក ថា

## មហាសកុលុទាយិសូត្រទី ៧

**[៧៥]** *មហាសុកុលុទាយិសូត្រ មានបទផ្ដើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា* ***មោរនិវាបេ*** *គឺ ក្នុងទីនោះ ជនទាំងឡាយ បានប្រកាសឲ្យអភ័យដល់សត្វក្ងោកទាំងឡាយ ហើយបានឲ្យអាហារ ។ ព្រោះដូច្នោះ ទីនោះទើបឈ្មោះថា* ***មោរនិវាប*** *ជាទីឲ្យចំណីដល់សត្វក្ងោក ។ បទថា* ***អន្នភារោ*** *ជាឈ្មោះរបស់បរិព្វាជកមួយនាក់ ។ ដូចវរតៈ ក៏ជាឈ្មោះបរិព្វាជកដូចគ្នា ។ បទថា* ***អញ្ញេ ច*** *មិនត្រឹមតែបរិព្វាជក ៣ នាក់នេះប៉ុណ្ណោះ សូម្បីបរិព្វាជកដទៃៗ ដែលមានឈ្មោះបោះសំឡេងក៏មានច្រើន ។*

**[៧៦]** *ក្នុងបទនេះថា* ***អប្បសទ្ទស្ស វណ្ណវាទី*** *ព្រះសមណគោតមទ្រង់ពោលសរសើរតែសំឡេងតិចៗ លោកមិនពោលថា* ***អប្បសទ្ទវិនីតោ*** *នែនាំឲ្យមានសំឡេងតិច ទើបពោលបទនេះ ។ ព្រោះហេតុអ្វី ។ ព្រោះព្រះមានព្រះភាគ ទ្រង់មិនបានណែនាំអ្នកដទៃ ។*

**[៧៧]** បទថា **បុរិមានិ** ថ្ងៃមុនៗ គឺ ថ្ងៃមុនៗ សំដៅដល់កាលថ្ងៃម្សិលមិញ ។ ក្រោយពីថ្ងៃនោះ គឺ ក្រោយពីថ្ងៃម្សិលមិញ ។ មិនមានសាលាចំពោះ ទើបឈ្មោះថា កុតូហលសាលា (សាលាផ្សាយដំណឹង) ។ សាលាដែលពួកតិរ្ថិយផ្សេងៗ សមណព្រាហ្មណ៍ប្រជុំសន្ទនាគ្នាច្រើនយ៉ាង លោកហៅថា កុតូហលសាលា ព្រោះជាទីផ្សាយដំណឹងរបស់ជនច្រើន អ្នកនេះនិយាយអ្វី អ្នកនេះនិយាយអ្វី ។ បាឋៈថា **កោតូហលសាលា** ខ្លះ ។ បទថា **លាភា** សេចក្ដីថា នេះជាលាភរបស់អ្នកអង្គៈ មគធៈ ដែលនឹងបានឃើញសមណព្រាហ្មណ៍សួរបញ្ហា ឬស្ដាប់ធម្មកថារបស់ព្រាហ្មណ៍ទាំងនោះ ។

គប្បីជ្រាបសេចក្ដីក្នុងបទមានជាដើមថា **សង្ឃិនោ** មានពួក ដូចតទៅនេះ ៖

ឈ្មោះថា **សង្ឃិនោ** ព្រោះមានពួក គឺ ពួកបព្វជិត ។ ឈ្មោះថា **គណិនោ** មានគណៈ ព្រោះមានគណៈនោះឯង ។ ឈ្មោះថា **គណាចរិយា** ព្រោះជាអាចារ្យរបស់គណៈនោះ ដោយឲ្យសិក្សាដល់អាចារៈ ។ បទថា **ញាតា** គឺ មានឈ្មោះល្បីល្បាញ ជាអ្នកប្រាកដ ។ ឈ្មោះថា **យសស្សិនោ** ព្រោះមានយសខ្ពង់ខ្ពស់ដោយគុណដែលមិនពិត និងដោយគុណតាមពិត ។

ក៏បូរណកស្សបៈជាដើម មានយសល្បីល្បាញ ដោយន័យមានជាដើមថា ជាអ្នកមានសេចក្ដីប្រាថ្នាតិច សន្ដោស សូម្បីសំពត់ក៏មិនស្លៀក ព្រោះជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ យសរបស់ព្រះតថាគតល្បីល្បាញ ដោយព្រះគុណតាមសេចក្ដីពិត មានជាដើមថា **ឥតិបិ សោ ភគវា** ដូច្នេះ ។ បទថា **តិត្ថករា** គឺ មេលទ្ធិ ។

បទថា **សាធុសម្មតា** គឺ ជនជាច្រើនសន្មតិគ្នាយ៉ាងនេះថា ល្អ ល្អ ជាសប្បុរស ។

បទថា **ពហុជនស្ស** ជនជាច្រើន គឺ មនុស្សអន្ធពាល និងពាល-បុថុជ្ជនអ្នកមិនមានការសិក្សា និង **បណ្ឌិតជនស្ស** គឺ អ្នកមានបញ្ញា ។ ក្នុងជនទាំងនោះ ពួកតិរ្ថិយគេសម្មតិថា ជាពាលជន ។ ព្រះតថាគតគេសម្មតិថា ជាបណ្ឌិតជន ។ ដោយន័យនេះ គប្បីជ្រាបសេចក្ដីក្នុងបទមានជាដើមថា **បូរណោ កស្សបោ សង្ឃី** បូរណកស្សបៈនេះ មានពួក ។ ព្រោះព្រះ-មានព្រះភាគ ទ្រង់ចែកអារម្មណ៍ ៣៨ ទ្រង់ធ្វើកំពង់ជាទីធ្លាក់ចុះកាន់និព្វានទុកច្រើន ដូច្នោះ គួរពោលថា ជា **តិត្ថករោ** អ្នកធ្វើកំពង់ ។ ក៏ព្រោះហេតុអ្វី មេលទ្ធិទាំងអស់នោះ ទើបមកប្រជុំគ្នាក្នុងទីនោះ ។ ដើម្បីរក្សាឧបដ្ឋាក

និងដើម្បីលាភសក្ការៈ ។ បានឮថា មេលទ្ធិទាំងនោះមានវិតក្កៈថា ឧបដ្ឋាក របស់ពួកយើងគប្បីនាំគ្នាដល់ព្រះសមណគោតមថា ជាទីពឹង ។ ពួកយើង នឹងថែរក្សាឧបដ្ឋាកទាំងនោះ ។ សូម្បីឧបដ្ឋាករបស់ពួកយើង ឃើញឧបដ្ឋាក របស់ព្រះសមណគោតមធ្វើសក្ការៈ ក៏នឹងធ្វើសក្ការៈដល់ពួកយើងខ្លះ ។ ព្រោះ ដូច្នោះ មេលទ្ធិទាំងអស់នោះ ទើបនាំគ្នាទៅប្រជុំក្នុងទីដែលព្រះមានព្រះភាគ ប្រជុំ ។

**[៧៨]** បទថា ***វាទំ អារោបេត្វា*** នាំគ្នាលើកទោស គឺ លើកទោស ក្នុងវាទៈ ។ បទថា ***អបក្កន្តា*** គឺ នាំគ្នាចៀសទៅ ពួកខ្លះនាំគ្នាចៀសទៅ កាន់ទិស ។ ពួកខ្លះសឹក ពួកខ្លះមកកាន់សាសនានេះ ។ បទថា ***សហិតម្មេ*** ពាក្យរបស់យើងជាប្រយោជន៍ គឺ ពាក្យរបស់យើងមានប្រយោជន៍ដ៏ក្រៃ- លែងប្រកបដោយអត្ថ ប្រកបដោយហេតុ ។ បទថា ***អសហិតំ*** គឺ ពាក្យ របស់លោកមិនប្រកបដោយប្រយោជន៍ ។ បទថា ***អធិចិណ្ណន្តេ វិបរាវត្តំ*** អ្នកឯងសន្សំតែវត្ថុខុសមកច្រើនហើយ សេចក្តីថា អ្នកឯងធ្លាប់មានការស្ទាត់ ជំនាញល្អ ដោយការសន្សំមកជាវេលាយូរ បានប្រែប្រួលទៅហើយ ដោយ ពាក្យនិយាយត្រឹមតែពាក្យមួយរបស់យើង មិនកើតអ្វីឡើង ។ បទថា ***អា-***

*រោបិតោ តេ វាទោ* គឺ យើងចាប់កំហុសពាក្យរបស់លោកបានហើយ ។ បទថា ***ចរ វាទប្បមោក្ខាយ*** លោកចូរដោះវាទៈរបស់លោកចេញ សេចក្តីថា ចូរប្រព្រឹត្តដើម្បីដោះកំហុស គឺ ចូរសិក្សាដើម្បីទៅក្នុងទីនោះៗ ។ បទថា ***និព្វេធេហិ វា សចេ បហោសិ*** ឬចូរកែខ្លួចេញបើអាច គឺ បើអាចដោយខ្លួនឯង ចូរកែខ្លួចេញក្នុងកាលឥឡូវនេះតែម្តង ។ បទថា ***ធម្មេក្កាសេន*** ពាក្យតិះដៀលដោយធម៌ គឺ ដោយពាក្យតិះដៀលដែលជាការពិត ។

**[៧៩]** បទថា ***តន្នោ សោស្សាម*** គឺ យើងទាំងឡាយនឹងស្តាប់ធម៌ដែលព្រះមានព្រះភាគត្រាស់ដល់ពួកយើង ។ បទថា ***ខុទ្ទំ មធុំ*** គឺ សំបុកឃ្មុំដែលជាសត្វមានខ្លួនតូចធ្វើទុកហើយ ។ បទថា ***អនេលកំ*** មិនមានទោស គឺ សំបុកឃ្មុំដែលប្រាសចាកមេឃ្មុំ ។ បទថា ***បីឡេយ្យ*** គឺ គប្បីច្របាច់ ។ បទថា ***បច្ចាសីសមានរូបោ*** ពួកមហាជនធ្លាប់ប្រាថ្នាហើយ គឺ កាន់ភាជនៈតាំងសេចក្តីប្រាថ្នាថា បុរសនោះនឹងឲ្យយើងដរាបពេញភាជនៈឬហ្ន៎ ។ បទថា ***សម្បយោជេត្វា*** ទាស់ទែងគ្នា គឺ ប្រកែកគ្នាបន្តិចបន្តួច ។

**[៨១]** បទថា ***ឥតរីតរេន*** គឺ តាមមានតាមបាន ។

**[៨៤]** បទថា ***បវិវិត្តោ*** ព្រះមានព្រះភាគជាអ្នកស្ងាត់ បរិញ្ញជកពោល

ពាក្យនេះសំដៅដល់ត្រឹមតែកាយវិវេក ។ តែព្រះមានព្រះភាគ ទ្រង់ស្ងាត់ដោយវិវេក ៣ ។

**[៨៥]** បទថា **កោសកាហារា** គឺ មានអាហារត្រឹមតែមួយកូនផ្តិល ក្នុងផ្ទះរបស់ទានបតី មានភាជនៈតូចដើម្បីដាក់អាហារយ៉ាងល្អ ។ ទានបតីទាំងឡាយ ដាក់អាហារល្អទុកក្នុងភាជនៈតូចនោះ ហើយបរិភោគ ។ កាលបព្វជិតមកដល់ ក៏ថ្វាយអាហារដល់បព្វជិតនោះ ភាជនៈតូចនោះ ហៅថា កោសកៈ (កូនផ្តិល) ព្រោះដូច្នោះ បុគ្គលណាញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយអាហារមួយភាជនៈតូច បុគ្គលនោះឈ្មោះថា **កោសកាហារា** មានអាហារត្រឹមតែមួយកូនផ្តិល ។ បទថា **វេឡុវាហារា** គឺ មានអាហារត្រឹមតែប៉ុនសំបកផ្លែព្នៅ ។ បទថា **សមតិត្តិកំ** ស្មើកណ្តាប់មាត់ គឺ ស្មើវណ្ណខាងក្រោមនៃកណ្តាប់មាត់បាត្រ ។ បទថា **ឥមិនា ធម្មេន** គឺ ដោយធម៌ព្រោះភាពជាអ្នកមានអាហារតិចនេះ ។ម្យ៉ាងទៀត ក្នុងបទនេះមិនគួរពោលថា ព្រះមានព្រះភាគទ្រង់មានអាហារតិចដោយអាការទាំងពួង ។ ទ្រង់មានអាហារតិចរហូតអស់ ៦ ឆ្នាំ ក្នុងកាលទ្រង់បំពេញព្យាយាម ។ ទ្រង់ញ៉ាំងព្រះជន្មឲ្យប្រព្រឹត្តទៅដោយបាយកំបង់ និងទឹកមួយបំពង់រហូតអស់ ៣ ខែ ក្នុងក្រុងវេរញ្ជា ។ ទ្រង់

ញុំាងព្រះជន្មឲ្យប្រព្រឹត្តទៅដោយមើមឈូកប៉ុណ្ណោះ រហូតដល់អស់ ៣ ខែ ក្នុងបារិលេយ្យកៈព្រៃស្រោង ។ តែក្នុងទីនេះ ព្រះអង្គទ្រង់សម្ដែងដល់សេចក្ដីនេះថា តថាគតមានអាហារតិចក្នុងកាលមួយ តែសាវកទាំងឡាយរបស់តថា-គត មិនទម្លាយធុតង្គរហូតអស់ជីវិតតាំងពីសមាទានធុតង្គ ។ ព្រោះដូច្នោះ បើសាវកទាំងឡាយនោះ គប្បីសក្ការៈតថាគតដោយធម៌នេះ ។ ព្រោះថា សាវកទាំងនោះ ជាអ្នកវិសេសចពោះយើង រមែងសក្ការៈតថាគតដោយធម៌ដទៃដែលមានហើយ ។ លោកសម្ដែងទុកដូច្នេះ ។ ដោយន័យនេះ គប្បីជ្រាបយោជនាក្នុងគ្រប់វារៈ ។

[៨៦] បទថា *បំសុកូលិកា* កាន់សំពត់បង្សុកូលជាវត្ត គឺ សមាទានបង្សុកូលិកង្គធុតង្គ ។

បទថា *លូខចីវរធរា* ទ្រទ្រង់ចីវរសៅហ្មងដោយអំបោះ ១០០ សរសៃ ។ បទថា *នន្តកានិ* សំពត់ចាស់ គឺ ចំរៀកសំពត់ដែលមិនមានជាយ ។ ពិតណាស់ ប្រសិនបើ សំពត់ទាំងនោះគប្បីមានជាយ សំពត់ទាំងនោះ ហៅថា *បិលោតិកា* កំណាត់សំពត់ ។ បទថា *ឧច្ចិនិត្វា* ជ្រើសរើស គឺ ហែកចោលចំណែកដែលប្រើមិនបាន កាន់យកចំណែកដែលនៅប្រើបានប៉ុណ្ណោះ ។ បទ

ថា **អលាវុលោមសានិ** គឺ មានសរសៃអំបោះដូចជារោមឃ្លោក ។ លោកសម្តែងថា លុ្ខិតសុខុម ។ ក៏ដោយហេតុត្រឹមតែប៉ុណ្ណោះ មិនគួរពោលថា ព្រះសាស្តាទ្រង់មិនបានសន្តោសដោយចីវរ ។ ព្រោះក្នុងថ្ងៃដែលព្រះអង្គទ្រង់ទទួលយកសំពត់បង្សុកូលធ្វើដោយសំបកឈើ ដែលនាងបុណ្ណទាសីនាំមកពីព្រៃជាទីចោលសាកសពមកថ្វាយ មហាប្រឹថពីបានញ័រដរាបដល់ទឹកជាទីបំផុត ព្រះអង្គទ្រង់សម្តែងសេចក្តីក្នុងបទនេះទុកថា តថាគតទទួលសំពត់បង្សុកូលគ្រាតែម្តងប៉ុណ្ណោះ ។ តែសាវកទាំងឡាយរបស់តថាគតមិនទម្លាយធុតង្គដរាបរហូតដល់អស់ជីវិត ចាប់តាំងពីសមាទានធុតង្គ ។

**[៨៧]** បទថា **បិណ្ឌបាតិកា** កាន់បិណ្ឌបាតជាវត្ត គឺ បដិសេធអតិរេកលាភ សមាទានបិណ្ឌបាតិកង្គធុតង្គ ។ បទថា **សបទានចារិនោ** គឺ ត្រាច់ទៅតាមលំដាប់ច្រកផ្លូវជាវត្ត គឺ បដិសេធលោលុបបចារ (ការត្រាច់ទៅដោយសេចក្តីលោភ) ហើយសមាទានសបទានចារិកវត្ត ។ បទថា **ឧញ្ឆាបកេ វត្តេ រតា** ត្រេកអរក្នុងវត្តជាន់ខ្ពស់របស់ខ្លួន សេចក្តីថា ត្រេកអរក្នុងវត្តតាមប្រក្រតីរបស់ភិក្ខុទាំងឡាយ ពោលគឺ ការត្រាច់ទៅដើម្បីអាហារចិញ្ចឹមជីវិត ជាអ្នកឈរត្រង់ទ្វារផ្ទះទាំងខ្ពស់ និងទាប សង្រួមអាហារដែល

លាយគ្នាជាដុំហើយឆាន់ ។ បទថា **អន្តរឃរំ** ចន្លោះស្រុក គឺ ចន្លោះផ្ទះ តាំងពីធរណីទ្វារ ដូចបានពោលក្នុងព្រហ្មាយុសូត្រ ។ ក្នុងទីនេះលោកបំណង តាំងពីសសរខឿន ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ មិនគួរពោលថា ព្រះសាស្តា ទ្រង់មិនសន្តោសដោយបិណ្ឌបាត ។ ទាំងអស់គប្បីឲ្យពិស្តារដោយទំនងតែ មួយដែលពោលហើយ ព្រោះភាពជាអ្នកមានអាហារតិច ។ សូម្បីក្នុងទីនេះ ព្រះអង្គក៏ទ្រង់សម្តែងសេចក្តីនេះទុកថា តថាគតមិនត្រេកអរទទួលនិមន្តក្នុង វេលាតែមួយប៉ុណ្ណោះ ។ តែសាវកទាំងឡាយរបស់តថាគត មិនទម្លាយធុតង្គ រហូតដល់អស់ជីវិត តាំងពីសមាទានធុតង្គ ។

[៨៨] បទថា **រុក្ខមូលិកា** សមាទានការនៅក្បែរគល់ឈើជាវត្ត គឺ បដិសេធទីប្រក់បាំង សមាទានរុក្ខមូលិកង្គធុតង្គ ។ បទថា **អព្ភោកាសិកា** សមាទានការនៅទីវាលជាវត្ត គឺ បដិសេធទីប្រក់បាំង និងគល់ឈើ ហើយ សមាទានអព្ភោកាសិកង្គធុតង្គ ។ បទថា **អដ្ឋមាសេ** រហូតដល់អស់ ៨ ខែ គឺ អស់ខែខាងក្នុងហេមន្តរដូវ និងគិមហន្តរដូវ ។ តែខាងក្នុងរដូវភ្លៀង ចូលទៅកាន់ទីប្រក់បាំងដើម្បីរក្សាចីវរ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ មិន គួរពោលថា ព្រះសាស្តាទ្រង់មិនសន្តោសដោយសេនាសនៈ ។ តែគប្បី

សម្ដែងការសន្ដោសក្នុងសេនាសនៈរបស់ព្រះអង្គ ដោយមហាបធាន រហូតដល់អស់ ៦ ឆ្នាំ និងដោយបារិលេយ្យកៈព្រៃស្រោង តែក្នុងទីនេះព្រះអង្គទ្រង់សម្ដែងសេចក្ដីនេះទុកថា តថាគតមិនចូលទៅកាន់ទីប្រក់បាំងក្នុងកាលមួយប៉ុណ្ណោះ ។ តែសាវករបស់តថាគត មិនទម្លាយធុតង្គរហូតដល់អស់ជីវិត តាំងពីសមាទានធុតង្គ ។

[៨៨] បទថា **អារញ្ញកា** សមាទានការនៅព្រៃជាវត្ត គឺ បដិសេធសេនាសនៈចុងស្រុក ហើយសមាទានអរញ្ញិកង្គធុតង្គ ។ បទថា **សង្ឃមជ្ឈេ ឱសរន្តិ** រមែងមកប្រជុំគ្នាត្រង់កណ្ដាលសង្ឃ លោកពោលដល់អព័ទ្ធសីមា (សីមាដែលមិនបានចង) ។ តែសាវកអ្នកនៅក្នុងពទ្ធសីមា រមែងធ្វើឧបោសថក្នុងទីនៅរបស់ខ្លួន ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ មិនគួរពោលថាព្រះសាស្ដាទ្រង់មិនស្ងាត់ ព្រោះសេចក្ដីស្ងាត់រមែងប្រាកដដល់ព្រះអង្គ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីពួនសម្ងំនៅរហូតដល់អស់ ៨ ខែ ។ តែក្នុងទីនេះព្រះអង្គទ្រង់សម្ដែងសេចក្ដីនេះទុកថា តថាគតពួនសម្ងំនៅក្នុងកាលមានសភាពបែបនោះមួយគ្រាៗ ។ តែសាវករបស់តថាគត មិនទម្លាយធុតង្គរហូតដល់អស់ជីវិត តាំងពីសមាទានធុតង្គ ។

[៩០] បទថា **មមំ សាវកា** គឺ សាវកទាំងឡាយរបស់តថាគត ។

[៩១] បទថា **សនិទានំ** មានហេតុ គឺ មានបច្ច័យ ។ ក៏ព្រះសាស្តាទ្រង់មិនសម្តែងដល់និព្វានដែលមិនមានបច្ច័យឬ ។ មិនសម្តែងមិនមែន ។ តែទ្រង់សម្តែងធ្វើទេសនានោះឲ្យមានហេតុ ។ បទថា **នោ អហេតុកំ** មិនមែនសម្តែងធម៌មិនមានហេតុ ។ បទថា **សប្បាដិហារិយំ** ទ្រង់សម្តែងធម៌ មានសេចក្តីអស្ចារ្យ នេះជាវេវចនៈរបស់បទមុន ។ អធិប្បាយថា មានហេតុ ។ **វត** ក្នុងបទថា **តំ វត** ត្រឹមតែនិបាត ។

[៩២] បទថា **អនាគតវាទបថំ** គន្លងនៃវាទៈក្នុងអនាគត គឺ គន្លងនៃវាទៈដែលតាំងនៅក្នុងថ្ងៃនេះ ហើយមកខាងលើនៃបញ្ហានោះៗ ក្នុងថ្ងៃស្អែកនេះ ខានស្អែកនេះ កន្លះខែ ឬឆ្នាំមុខ ។ បទថា **ន ទក្ខតិ** រមែងមិនឃើញ គឺ មិនឃើញដោយអាការដែលសច្ចកនិគ្រន្ថ ញាំងហេតុដែលខ្ជួនមកដើម្បីនឹងសង្កត់សង្កិនឲ្យវិសេស កាលនឹងពោលទើបមិនបានឃើញ ព្រោះហេតុនោះ ប្រការនោះមិនមែនឋានៈនឹងមានបាន ។ បទថា **សហធម្មេន** ប្រព្រឹត្តទៅជាមួយធម៌ គឺ មានហេតុ ។ បទថា **អន្តរន្តរា កថំ ឱបាតេយ្យុំ** នឹងគប្បីជំទាស់ឲ្យធ្លាក់ទៅក្នុងចន្លោះៗ សេចក្តីថា កាត់ការសន្ទនារបស់យើង ហើយ

សិក្ខការសន្ទនារបស់ខ្លួនចូលទៅក្នុង ចន្លោះៗ ។ បទថា **ន ខោ បនាហំ** ឧទាយិសេចក្តីថា ម្នាលឧទាយី យើងមិនប្រាថ្នាពាក្យទូន្មានក្នុងសាវកទាំងឡាយនេះថា កាលការសន្ទនាគ្រាធំជាមួយនឹងអម្ពដ្ឋៈ សោណទណ្ឌៈ កូដ-ទណ្ឌៈ និងសច្ចកនិគ្រន្ថជាដើម សូម្បីប្រព្រឹត្តទៅ បើការប្រើសាវករបស់យើងមួយរូប គួរនាំឧបមា ឬហេតុមកពោល ។ បទថា **មមយេវ** គឺ ក្នុងឋានៈយ៉ាងនេះ សាវកទាំងឡាយក៏មិនបានប្រាថ្នាឱវាទដែលជាពាក្យទូន្មានរបស់យើង ។

**[៩៣]** បទថា **តេសាហំ ចិត្តំ អារាធេមិ** យើងញុំាងចិត្តរបស់សាវកទាំងនោះឲ្យត្រេកអរ គឺ យើងនឹងកាន់យកចិត្តរបស់សាវកទាំងនោះឲ្យដល់ព្រម ឲ្យបរិបូណ៌ ដោយការព្យាករណ៍បញ្ហារបស់ព្រះអរហន្ត ។ សួរមួយព្យាករណ៍មួយ ដូចសួរស្វាយ ព្យាករណ៍ខ្នុរសម្ល ។ សួរខ្នុរសម្ល ព្យាករណ៍ស្វាយ ដូច្នោះ ។ម្យ៉ាងវិញទៀត ក្នុងបទនេះ លោកពោលដល់សីលរបស់ព្រះពុទ្ធ ក្នុងទីដែលពោលទុកហើយថា **អធិសីលេ សម្ភាវេន្តិ** សរសើរព្រោះអធិសីល ។ លោកពោលដល់សព្វញ្ញុតញ្ញាណ ក្នុងទីដែលពោលទុកហើយថា **អភិក្កន្តេ ញាណទស្សនេ សម្ភាវេន្តិ** សរសើរ ព្រោះញាណទស្សនៈ

ដ៏ប្រសើរ ។ លោកពោលដល់បញ្ញាដែលឲ្យកើតឋានៈ ក្នុងទីដែលលោកពោលទុកថា **អធិប្បញ្ញាយ សម្មាវេន្តិ** សរសើរ ព្រោះអធិប្បញ្ញា ។ លោកពោលដល់បញ្ញាព្យាករណ៍សច្ចៈ ក្នុងទីដែលពោលទុកថា **យេន ទុក្ខេន** ដោយទុក្ខណា បញ្ញាដ៏សេស វៀរសព្វញ្ញុតញ្ញាណ និងបញ្ញាព្យាករណ៍សច្ចៈ រមែងជាអធិប្បញ្ញា ។

**[៩៤]** ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់កាលនឹងប្រាប់បដិបទារបស់សាវកទាំងនោះជាអ្នកសម្រេច ទើបត្រាស់ថា **បុន ច បរំ ឧទាយិ** ម្នាលឧទាយី ប្រការដទៃនៅមានទៀតជាដើម ។ ក្នុងបទទាំងនោះ បទថា **អភិញ្ញាវោសានបារមិប្បត្តា** សាវករបស់យើងជាច្រើនបានសម្រេចបារមី ដែលជាទីបំផុតនៃអភិញ្ញា គឺ សម្រេចអរហត្ត ដែលជាទីបំផុតនៃអភិញ្ញា និងដែលជាបារមីនៃអភិញ្ញា ។

**[៩៥]** បទថា **សម្មប្បធានេ** សម្មប្បធាន ៤ គឺ សេចក្តីព្យាយាមដែលជាឧបាយ ។ បទថា **ឆន្ទំ ជនេតិ** ញុំាងសេចក្តីពេញចិត្តឲ្យកើត គឺ ញុំាងសេចក្តីពេញចិត្តក្នុងកុសល ដែលជាកត្តុកាម្យតាឆន្ទៈឲ្យកើត ។

បទថា **វាយមតិ** គឺ ធ្វើសេចក្តីព្យាយាម ។ បទថា **វីរិយំ អារព្ភតិ**

គឺ ប្រារព្ធសេចក្តីព្យាយាម បានដល់ ញុំាងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ ។ បទថា **ចិត្តំ បគ្គណ្ហាតិ** រមែងផ្គងចិត្ត គឺ លើកចិត្តឡើង ។ បទថា **បទហតិ** រមែងតាំង គឺ ធ្វើសេចក្តីព្យាយាមដោយឧបាយ ។ បទថា **ភាវនាយ បារិបូរិយា** គឺ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសម្បូរណ៍ ។ ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបថា សេចក្តីតាំងមាំណា នោះជាសេចក្តីមិនវង្វេង សេចក្តីបរិបូណ៌ណា នោះជាសេចក្តីចម្រើន និងសេចក្តីសម្បូរណ៍ ។ បទមុន ជាអធិប្បាយរបស់បទក្រោយ ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត បុព្វភាគបដិបទារបស់ព្រះសាវក លោកពោលទុកដោយបរិយាយនៃកស្សបសំយុត្ត ដែលព្រះមហាកស្សបត្ថេរពោលទុក ដោយរឿងសម្មប្បធាន ៤ ទាំងនេះ សមពិតដូចពាក្យដែលលោកពោលទុកក្នុងកស្សបសំយុត្តនោះថា ម្នាលអាវុសោ សម្មប្បធានរបស់យើងមាន ៤ សម្មប្បធាន ៤ ដូចម្តេច ? ម្នាលអាវុសោ ភិក្ខុក្នុងព្រះធម្មវិន័យនេះ ធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ដោយគិតថា អកុសលធម៌ដ៏លាមកដែលនៅមិនទាន់កើតឡើងដល់យើង កាលកើតឡើង នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសប្រយោជន៍ ធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ដោយគិតថា អកុសល-

ធម៌ដ៏លាមក ដែលកើតឡើងហើយដល់យើង កាលយើងនៅលះមិនបាន នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសប្រយោជន៍ ធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ដោយគិតថា កុសលធម៌ដែលនៅមិនទាន់កើតឡើងដល់យើង កាលនៅមិនទាន់កើតឡើង នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសប្រយោជន៍ ធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ដោយគិតថា កុសល-ធម៌ដែលកើតឡើងហើយដល់យើង កាលវលត់ នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសប្រយោជន៍ ។

ម្យ៉ាងទៀត ក្នុងបទនេះគប្បីជ្រាបថា អកុសលដ៏លាមក បានដល់លោភៈជាដើម ។ បទថា **អនុប្បន្នា កុសលា ធម្មា** កុសលធម៌ដែលនៅមិនទាន់កើត បានដល់ សមថវិបស្សនា និងមគ្គប៉ុណ្ណោះ ។ សមថវិបស្សនាឈ្មោះថា កុសលដែលកើតឡើងហើយ ។ ចំណែកមគ្គកើតឡើងក្នុងគ្រាតែមួយ ហើយវលត់ទៅ មិនឈ្មោះថា ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ។ ព្រោះមគ្គនោះ ឲ្យបច្ច័យដល់ផលហើយទើបវលត់ ។ ឬសូម្បីបទមុន លោកពោលថា គប្បីកាន់យកសមថៈ និងវិបស្សនា តែប្រការនោះមិនត្រូវ ។ សមថៈ និងវិបស្សនាកើតឡើងហើយក្នុងកុសលធម៌នោះ កាលវលត់ទៅ

រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ។ ដើម្បីសេចក្តីជាក់ច្បាស់ក្នុងសេចក្តីនេះ នឹងនាំរឿងមកដំណាលដូចតទៅនេះ ៖

បានឮថា ព្រះថេរៈជាខីណាស្រពមួយរូប គិតថា យើងនឹងថ្វាយបង្គំព្រះមហាចេតិយ និងព្រះមហាពោធិ៍ ទើបមកកាន់មហាវិហារអំពីជនបទជាមួយសាមណេរអ្នកកាន់កណ្ឌៈដែលបានសមាបត្តិ ហើយចូលទៅកាន់បរិវេណវិហារក្នុងពេលល្ងាច កាលភិក្ខុសង្ឃពួកធំកំពុងថ្វាយបង្គំព្រះចេតិយ ក៏មិនចេញទៅដើម្បីថ្វាយបង្គំព្រះចេតិយ ។ ព្រោះហេតុអ្វី ។ ព្រោះព្រះខីណាស្រព មានសេចក្តីគោរពយ៉ាងដ៏ក្រៃលែងក្នុងព្រះរតនត្រ័យ ។ ដូច្នោះកាលភិក្ខុសង្ឃថ្វាយបង្គំត្រឡប់ទៅហើយ ក្នុងវេលាដែលពួកមនុស្សបរិភោគអាហារក្នុងពេលល្ងាច សូម្បីសាមណេរក៏មិនឲ្យដឹង គិតថា យើងនឹងថ្វាយបង្គំព្រះចេតិយ ទើបចេញទៅតែម្នាក់ឯងប៉ុណ្ណោះ ។ សាមណេរគិតថា ព្រះថេរៈទៅតែមួយអង្គឯង ទៅក្នុងកាលដែលមិនមែនវេលា យើងនឹងដឹង ទើបចេញតាមស្នាមជើងព្រះឧបជ្ឈាយ៍ ។ ព្រះថេរៈមិនដឹងថា សាមណេរមក ព្រោះមិនបានទឹកដល់ ទើបឡើងកាន់លានព្រះចេតិយផ្លូវទ្វារទិសខាងត្បូង ។ សាមណេរក៏ឡើងតាមស្នាមជើងទៅ ។ ព្រះមហាថេរៈក្រឡេកមើល

ព្រះមហាចេតិយ បីតិក៏កើតឡើង ព្រោះមានព្រះពុទ្ធជាអារម្មណ៍ មានចិត្តមូលតែមួយ ត្រេកអរ រីករាយ ថ្វាយបង្គំព្រះចេតិយ សាមណេរឃើញអាការថ្វាយបង្គំរបស់ព្រះថេរៈ ទើបគិតថា ព្រះឧបជ្ឈាយ៍របស់យើង មានចិត្តជ្រះថ្លាយ៉ាងក្រៃលែង ថ្វាយបង្គំព្រះចេតិយ បានផ្កាឈើហើយ គប្បីធ្វើការបូជាឬហ្ន៎ ។ កាលព្រះថេរៈក្រោកឡើង លើកអញ្ជលីលើសីសៈ ឈរក្រឡេកមើលព្រះមហាចេតិយ ។ សាមណេរគ្រហែមឲ្យព្រះថេរៈដឹងថា ខ្លួនមក ។ ព្រះថេរៈក្រឡេកមើល ហើយសួរថា លោកមកកាលណា ។ សាម-ណេរឆ្លើយថា លោកម្ចាស់ ក្នុងវេលាលោកថ្វាយបង្គំព្រះចេតិយ លោកម្ចាស់ជ្រះថ្លាយ៉ាងក្រៃលែង ទើបថ្វាយបង្គំព្រះចេតិយ ។ លោកម្ចាស់បានផ្កាឈើហើយ គប្បីបូជាឬ ។ ព្រះថេរៈឆ្លើយថា ត្រូវហើយសាមណេរ ឈ្មោះថា ការបញ្ចុះព្រះធាតុប្រមាណប៉ុណ្ណេះ ក្រៅអំពីក្នុងព្រះចេតិយនេះហើយ រមែងមិនមាន ។ អ្នកណាបានផ្កាឈើហើយនឹងមិនគប្បីបូជាមហាសថូបមានសភាពដូច្នេះ បានឬហ្ន៎ ។ សាមណេរពោលថា លោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់រង់ចាំសិន ខ្ញុំនឹងនាំផ្កាឈើមក ។ ក្លាមនោះឯងសាមណេរក៏ចូលឈាន ហើយទៅព្រៃហិមពាន្តដោយឫទ្ធិ កាច់ផ្កាឈើសម្បូរ

ដោយពណ៌ និងក្លិន ដាក់ក្នុងធម្មក្រកដរាបពេញ កាលព្រះមហាថេរៈមិនទាន់ដល់ទ្វារខាងក្រោយ អំពីទ្វារខាងត្បូង ។ សាមណេរត្រឡប់មក ដាក់សំពត់ធម្មក្រកខ្ចប់ផ្កាឈើទុកត្រង់ដៃ ហើយពោលថា សូមលោកម្ចាស់ចូរបូជាចុះ ។ ព្រះថេរៈពោលថា សាមណេរ ផ្កាឈើរបស់លោកតិចណាស់ ។ សាមណេរពោលថា លោកម្ចាស់ សូមលោកម្ចាស់ចូរទៅរលឹកដល់គុណរបស់ព្រះមានព្រះភាគហើយ បូជាចុះ ។ ព្រះថេរៈឡើងជណ្ដើរទ្វារខាងក្រោយផ្ដើមធ្វើការបូជាដោយផ្កាឈើក្នុងជាន់ទីមួយ ។ ជាន់ទីមួយបូជាពេញទាំងអស់ ។ ផ្កាឈើធ្លាក់ចុះទៅពេញក្នុងជាន់ទី ២ ត្រង់ផ្ទៃព្រះចេតិយប្រមាណត្រឹមជង្គង់ ។ ព្រះថេរៈចុះអំពីជាន់ទី ២ ញ៉ាំងផ្កាត្រឹមខ្នងជើងឲ្យពេញ ។ សូម្បីផ្កាឈើប៉ុណ្ណោះក៏ពេញ ។ ព្រះថេរៈ ដឹងថាពេញ ទើបចាក់រោយត្រង់ផ្ទៃខាងក្រោម ហើយបានចុះចាកពីទីនោះ ។ លានព្រះចេតិយមានផ្កាឈើពេញទាំងអស់ ។ កាលលានព្រះចេតិយពេញហើយ ព្រះថេរៈពោលថា សាមណេរ ផ្កាឈើមិនទាន់អស់ ។ សាមណេរឆ្លើយថា លោកម្ចាស់ចូរផ្កាប់ធម្មក្រកចុះ ។ ព្រះថេរៈផ្កាប់ធម្មក្រកហើយអង្រួន ។ ក្នុងកាលនោះផ្កាឈើក៏អស់ ។ ព្រះថេរៈឲ្យ ធម្មក្រកដល់សាមណេរ ហើយធ្វើប្រទក្សិណ

ព្រះចេតិយមានកំពែងខ្ពស់ ៦០ ហត្ថ ៣ ជុំ ថ្វាយបង្គំក្នុងទីទាំង ៤ កន្លែង ហើយត្រឡប់ទៅកាន់បរិវេណ គិតថា សាមណេរនេះមានឫទ្ធិច្រើនពិត នឹងអាចរក្សាឥទ្ធានុភាពនេះទុកបានឬហ្ន៎ ។ តអំពីនោះ ព្រះថេរៈឃើញថា នឹងមិនអាចរក្សាទុកបាន ទើបពោលនឹងសាមណេរថា សាមណេរ ឥឡូវនេះលោកមានឫទ្ធិច្រើន ក្នុងខាងក្រោយគ្រាឫទ្ធិសាបសូន្យ នឹងផឹកទឹកបាយដោយដៃរបស់ស្ត្រីតម្បាញខ្វាក់ភ្នែកម្ខាង ។ នេះឈ្មោះថា ជាទោសនៃភាពកម្មោះសាមណេរនោះ ញុំាំរន្ធត់ចិត្តក្នុងពាក្យរបស់ព្រះឧបជ្ឈាយ៍ (តែ) មិនសូមអង្វរថា លោកម្ចាស់ សូមលោកចូរប្រាប់កម្មដ្ឋានដល់ខ្ញុំព្រះករុណាចុះ ។ សាមណេរគិតថា ព្រះឧបជ្ឈាយ៍របស់យើងនិយាយអ្វី ធ្វើដូចមិនបានឮពាក្យនោះបាន ហើយក៏ទៅ ។ ព្រះថេរៈកាលថ្វាយបង្គំព្រះមហាចេតិយ និងព្រះមហាពោធិ៍ហើយ ទើបឲ្យសាមណេរទទួលបាត្រ និងចីវរ ទៅកាន់កុដេឡិតិស្សមហាវិហារ សាមណេរដើរតាមព្រះឧបជ្ឈាយ៍ មិនទៅបិណ្ឌបាត ។ តែសួរថា លោកម្ចាស់ លោកនឹងចូលទៅស្រុកណា លុះដឹងថា ឥឡូវនេះព្រះឧបជ្ឈាយ៍របស់យើងនឹងទៅកាន់ស្រុក ទើបកាន់បាត្រ និងចីវររបស់ខ្លួន និងរបស់ព្រះឧបជ្ឈាយ៍ ហើយហោះទៅ ថ្វាយបាត្រ និងចីវរដល់ព្រះថេរៈ

ហើយ ទើបចូលទៅបិណ្ឌបាត ។

ព្រះថេរៈប្រៀនប្រដៅរហូតអស់វេលាថា សាមណេរ លោកកុំបាន ធ្វើយ៉ាងនោះ ឈ្មោះថា ឫទ្ធិរបស់បុថុជ្ជនទន់ជ្រាយ មិនពិតប្រាកដ ពេល បានអារម្មណ៍ មានរូបជាដើមមិនជាទីសប្បាយ ត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ក៏វិនាស ។ កាលការសាបសូន្យអំពីសមាបត្តិ មាននៅការប្រព្រឹត្តព្រហ្ម- ចរិយៈ ក៏មិនអាចទ្រាំទ្របាន ។ សាមណេរមិនប្រាថ្នានឹងស្តាប់ ព្រះឧប- ជ្ឈាយ៍របស់យើងពោលអ្វី ក៏ធ្វើទំនងដូចមុន ។ ព្រះថេរៈថ្វាយបង្គំព្រះចេ- តិយទៅដោយលំដាប់ហើយ ទើបទៅកាន់កម្ពិទវិហារ ។ សូម្បីកាលព្រះ ថេរៈនៅក្នុងវិហារនោះ សាមណេរក៏នៅធ្វើយ៉ាងនោះ ។ ថ្ងៃមួយធីតារបស់ ជាងតម្បាញម្នាក់មានរូបល្អ តាំងនៅក្នុងបឋមវ័យ ចេញពីស្រុកកម្ពិទៈ ចុះទៅកាន់ស្រះឈូកស្រែកច្រៀងបេះផ្កាឈូក ។ ក្នុងសម័យនោះ សាម- ណេរទៅដល់ម្ខាងស្រះ ជាប់ចិត្តនឹងសំឡេងស្រែកច្រៀងរបស់ស្រីនោះ ដូច អ្នកលក់ត្រីខ្វាក់ភ្នែក ជាប់ចិត្តនឹងសំឡេងរបស់អ្នកចម្រៀង ដូច្នោះ ។ ក្នាម នោះឯង ឫទ្ធិរបស់សាមណេរនោះ ក៏វិនាសទៅ ដូចជាក្អែកបាក់ស្លាប ។ តែដោយផលរបស់សមាបត្តិដែលនៅមាន សាមណេរ មិនធ្លាក់ទៅត្រង់ផ្ទៃ

ទឹកនោះ ធ្លាក់ចុះដូចប៉ុយរកាដោយលំដាប់ បានឈរនៅជិតមាត់ស្រះបទុម ។ សាមណេរប្រញាប់ទៅថ្វាយបាត្រ និងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់ ។ ព្រះមហាថេរៈគិតថា យើងឃើញហេតុការណ៍មកមុនហើយ សូម្បីហាម សាមណេរក៏គង់មិនត្រឡប់ ទើបមិននិយាយអ្វីៗ ចូលទៅបិណ្ឌបាតទៅ ។ សាមណេរទៅឈរត្រង់មាត់ស្រះឈូក រង់ចាំស្ត្រីនោះឡើង ។ សូម្បីស្ត្រីនោះ ក៏ឃើញសាមណេរទាំងខណៈហោះ និងខណៈមកឈរ ដឹងថា សាមណេរនេះអផ្សុក ព្រោះអាស្រ័យយើងដោយពិត ទើបពោលថា ចៀសចេញទៅសាមណេរ ។ សាមណេរនោះទើបចៀសចេញទៅ ។ ស្ត្រីនោះឡើងមកស្លៀកសំពត់ហើយ ចូលទៅរកសាមណេរសួរថា សាមណេរត្រូវការអ្វីឬ ។ សាមណេរប្រាប់សេចក្តីនោះ ។ នាងទើបសម្តែងដល់ទោសក្នុងការគ្រប់គ្រងផ្ទះ ដោយហេតុច្រើនយ៉ាង និងអានិសង្សក្នុងការប្រព្រឹត្តព្រហ្មចរិយៈ សូម្បីទូន្មានហើយ ក៏មិនអាចបន្ទោបង់សេចក្តីអផ្សុករបស់សាមណេរនោះបាន គិតថា សាមណេរនេះវិនាសឫទ្ធិបែបនេះ ព្រោះយើងជាហេតុ ឥឡូវនេះមិនគួរនឹងលះបង់ ទើបពោលថា សាមណេរ លោកចូររង់ចាំនៅត្រង់នេះចុះ ហើយទៅផ្ទះប្រាប់រឿងនោះដល់មាតាបិតា ។

សូម្បីមាតាបិតាក៏មកហើយទូន្មានច្រើនយ៉ាង បានពោលនឹងសាមណេរអ្នកមិនជឿ ឲ្យដឹងថា លោកកុំយល់ថាពួកយើងមានត្រកូលខ្ពង់ខ្ពស់ ។ ពួកយើងត្រឹមតែជាជាងត្បាញអាចធ្វើបានត្រឹមតែការងារត្បាញប៉ុណ្ណោះ ។ សាមណេរពោលថា ឧបាសក ធម្មតាគ្រហស្ថគួរធ្វើការងារតម្បាញ ឬគួរធ្វើការងារវែងជាលក៏បាន ។ ប្រយោជន៍អ្វីដោយត្រឹមតែសំពត់សាដកនេះ លោកចូរធ្វើការងារទៅចុះ ។ ជាងតម្បាញឲ្យសំពត់សាដកដែលចងពោះហើយនាំទៅផ្ទះ លើកកូនក្រមុំឲ្យ ។ នាយកម្មោះនោះ (សឹកពីសាមណេរហើយ) រៀនការងាររបស់ជាងតម្បាញ ធ្វើការងារត្រង់រោងជាមួយពួកជាងតម្បាញ ។ បណ្តាស្ត្រីរបស់ជាងតម្បាញពួកដទៃ បានត្រៀមអាហារនាំមកពីព្រឹកព្រលឹម ។ ភរិយារបស់នាយកម្មោះនោះមិនទាន់មក ។ នាយកម្មោះនោះ កាលអ្នកដទៃសម្រាកការងារបរិភោគអាហារ ក៏នៅអង្គុយខារបំពង់អំបោះ ។ ភរិយាបានទៅខាងក្រោយ ។ នាយកម្មោះនោះទើបនិយាយគំហកដាក់ភរិយាថា នាងនេះមកយឺតហួសប្រមាណ ។ ធម្មតាមាតុគ្រាមដឹងថា សូម្បីស្តេចចក្រពត្តិ ដែលមានចិត្តប្រតិព័ទ្ធក្នុងខ្លួន នៅតែនឹកថា "ខ្លួនដូចជាទាសៈ" ។ ព្រោះដូច្នោះ នាងទើបពោលថា ក្នុងផ្ទះរបស់អ្នកដទៃគេសន្សំ

ឧស ស្ទឹកឈើ និងអំបិលទុក ។ សូមឲ្យអ្នកតម្បាញដែលជាទាសៈនាំចេញពីខាងក្រៅក៏នៅមាន ។ តែខ្ញុំជាស្ត្រីម្នាក់ប៉ុណ្ណោះ ។ សូមឲ្យលោកក៏មិនទាន់ដឹងថា ក្នុងផ្ទះរបស់យើង វត្ថុនេះមាន វត្ថុនេះមិនមាន ។ បើលោកត្រូវការក៏ចូរបរិភោគចុះ ។ បើមិនត្រូវការក៏កុំបរិភោគ ។ នាយកម្មោះនោះនិយាយគំហកថា នាងមិនត្រឹមតែនាំអាហារមកយឺតប៉ុណ្ណោះ នៅតែឌឺដងដាក់យើងដោយពាក្យនិយាយទៀត ក៏ក្រោធ កាលមិនឃើញគ្រឿងប្រទូសរ៉ាយដទៃទើបទាញឈើត្រល់ត្បាញសំពត់នោះ យកបំពង់អំបោះចេញពីត្រល់ ហើយគ្រវែងទៅ ភរិយាឃើញឈើត្រល់ខ្ពោះមក ទើបគេចបន្តិច ក៏ចុងឈើត្រល់មុត ។ កាលនាងគេច ចុងឈើត្រល់ទើបមុតត្រូវត្រង់កន្ទុយភ្នែក ។ នាងប្រញាប់យកដៃទាំងពីរខ្ទប់ភ្នែក ។ ឈាមហូរចេញត្រង់កន្លែងមុត ។ នាយកម្មោះនោះ បានរលឹកដល់ពាក្យរបស់ព្រះឧបជ្ឈាយ៍ក្នុងវេលានោះថា ព្រះឧបជ្ឈាយ៍មុខជាសំដៅដល់ហេតុនេះ ទើបពោលនឹងយើងថា ក្នុងអនាគតអ្នកនឹងត្រូវផឹកទឹកបាយដោយដៃរបស់ស្ត្រីតម្បាញខ្វាក់ភ្នែកម្ខាង ។ ព្រះថេរៈនឹងឃើញហេតុនេះដោយពិត ។ ទើបស្រែកយំដោយសំឡេងខ្លាំងៗ ថា ឱលោកម្ចាស់អ្នកឃើញកាលឆ្ងាយ ។ ពួកជាងតម្បាញដទៃៗ បានពោលចំពោះ

នាយកម្មោះនោះថា ណ្ហើយចុះបា កុំស្រែកយំឡើយ ។ ធម្មតាក្អែកដែលបែកហើយមិនអាចធ្វើឲ្យដូចពីដើមបាន ដោយការយំស្រែកទេ ។ នាយកម្មោះនោះពោលថា យើងមិនបានយំដល់រឿងនោះទេ តែយើងយំសំដៅដល់ហេតុនេះ ដូច្នេះហើយ ទើបប្រាប់រឿងទាំងអស់តាមលំដាប់ ។ សមថៈ និងវិបស្សនាកើតឡើងហើយយ៉ាងនេះ កាលវលត់ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីខូចប្រយោជន៍ ដូច្នេះ ។

នៅមានរឿងដទៃទៀត ៖

ភិក្ខុប្រមាណ ៣០ រូប ថ្វាយបង្គំ ព្រះកល្យាណីមហាចេតិយហើយ ចុះពីផ្លូវធំទៅតាមផ្លូវព្រៃ បានឃើញមនុស្សម្នាក់ធ្វើការងារក្នុងទីកន្លែងភ្លើងឆេះក្នុងចន្លោះផ្លូវដើរមក ។ រាងកាយរបស់មនុស្សនោះ ដូចជាប្រលាក់ដោយម្រែងភ្លើង ។ ក្រឡេកមើលសំពត់សាដកមួយផ្ទាំង ប្រលាក់ដោយម្រែងភ្លើង គ្បៀតត្រង់ក្លៀក ប្រាកដដូចជង្គត់ឈើត្រូវភ្លើងឆេះ ។ មនុស្សនោះធ្វើការងារក្នុងពេលថ្ងៃ លីឧសដែលត្រូវភ្លើងឆេះមួយបាច់ចេញទៅ មានសក់សំពីងសំពោងត្រង់ខ្នងមកខុសផ្លូវ បានឈរចំពោះមុខភិក្ខុទាំងឡាយ ។

ពួកសាមណេរឃើញ ទើបសម្លឹងមើលគ្នានិងគ្នាហើយសើច ពោលថា

អាវុសោ ញោមរបស់លោក អីរបស់លោក ពូរបស់លោក ហើយទើប សួរឈ្មោះថា ឧបាសក លោកឈ្មោះអ្វី ។ បុរសនោះត្រូវសួរដល់ឈ្មោះ ក៏វិប្បដិសារី ទម្លាក់បាច់ឧស រៀបចំស្លៀកសំពត់ថ្វាយបង្គំព្រះមហាថេរៈ ហើយទើបពោលថា លោកម្ចាស់ទាំងឡាយមេត្តាឈប់សិន ។ ព្រះមហាថេរៈ ទាំងឡាយបានឈរ ។ ពួកសាមណេរមកហើយ ធ្វើការចំអកឡកឡឺយសូម្បី ចំពោះមុខព្រះមហាថេរៈទាំងឡាយ ។ ឧបាសកពោលថា លោកម្ចាស់ទាំង ឡាយឃើញខ្ញុំហើយសើចចំអក លោកម្ចាស់កុំយល់ថា ពួកយើងបានសម្រេច ដល់ទីបំផុតដោយហេតុត្រឹមតែប៉ុណ្ណេះ ។ សូម្បីខ្ញុំកាលមុន ក៏ជាសមណៈ ដូចជាពួកលោកម្ចាស់ដែរ តែពួកលោកម្ចាស់មិនមានសូម្បីត្រឹមតែចិត្តដែល មានអារម្មណ៍តែមួយ ខ្ញុំបានជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ក្នុង សាសនានេះ ។ ខ្ញុំធ្វើអាកាសឲ្យជាផែនដីបាន ។ ធ្វើផែនដីឲ្យជាអាកាស បាន ។ ធ្វើទីឆ្ងាយឲ្យជិត ។ ធ្វើទីជិតឲ្យឆ្ងាយបាន ។ ខ្ញុំស្ទុះទៅបានសែន ចក្រវាឡដោយខណៈតែមួយ ។ ពួកលោកចូរមើលដៃរបស់ខ្ញុំ ឥឡូវនេះ ដូចជាដៃស្វា ខ្ញុំអង្គុយក្នុងទីនេះស្ទាបព្រះចន្ទ ព្រះអាទិត្យដោយដៃទាំងពីរ នេះបាន ។ ខ្ញុំធ្វើព្រះចន្ទ និងព្រះអាទិត្យឲ្យជាទីតាំង អង្គុយលាងជើងទាំង

នេះឯង ។ ឫទ្ធិរបស់ខ្ញុំបែបនេះ បានអស់ទៅព្រោះសេចក្ដីប្រមាទ ។ ពួកលោកម្ចាស់ ចូរកុំប្រមាទឡើយ ។ ព្រោះជនទាំងឡាយដល់សេចក្ដីវិនាសបែបនេះ ដោយសេចក្ដីប្រមាទ ។ អ្នកមិនប្រមាទ រមែងធ្វើទីបំផុតនៃជាតិជរា និងមរណៈបាន ។ ព្រោះដូច្នោះ លោកម្ចាស់ទាំងឡាយ ធ្វើខ្ញុំនេះឯងឲ្យជាអារម្មណ៍ ហើយនិយាយដាស់តឿនថា លោកម្ចាស់ទាំងឡាយ ចូរកុំប្រមាទឡើយ ហើយឲ្យឱវាទ កាលបុរសនោះកំពុងពោលទុំះឯង ភិក្ខុ ៣០ រូបទាំងនោះដល់នូវសេចក្ដីសង្វេគ ឃើញប្រាកដច្បាស់ បានសម្រេចព្រះ-អរហត្តក្នុងទីនោះឯង ដោយប្រការដូច្នេះ ។ សមថវិបស្សនា ដែលកើតឡើងហើយសូម្បីយ៉ាងនេះ កាលរលត់ទៅ គប្បីជ្រាបថា រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ។

ម្យ៉ាងទៀត ក្នុងបទថា **អនុប្បន្នានំ បាបកានំ** សេចក្ដីលាមកមិនទាន់កើតឡើង គប្បីជ្រាបដោយន័យដូចពោលហើយក្នុងបទមានជាដើមថា **អនុប្បន្នោ វា កាមាសវោ នឧប្បជ្ជតិ** កាមាសវៈមិនទាន់កើត រមែងមិនកើត ។

ម្យ៉ាងទៀត ក្នុងបទថា **ឧប្បន្នានំ បាបកានំ** សេចក្ដីលាមកកើតឡើងហើយនេះ មានសេចក្ដីដូចតទៅនេះ ៖

សេចក្ដីលាមកកើតឡើង ៤ យ៉ាង គឺ កើតឡើងក្នុងបច្ចុប្បន្ន ១ កើតឡើងព្រោះសោយផលហើយប្រាសទៅ ១ កើតឡើងព្រោះធ្វើឱកាស ១ កើតឡើងព្រោះបានភូមិ ១ ។ ក្នុង ៤ យ៉ាងនោះ កិលេសពួកណាមានព្រម ដែលនឹងកើតជាដើម នេះឈ្មោះថា កើតក្នុងបច្ចុប្បន្ន ។ មួយ៉ាងទៀត កាលកម្មប្រព្រឹត្តទៅសោយរសនៃអារម្មណ៍ហើយរលត់ទៅ ឈ្មោះថា សោយផលហើយប្រាសទៅ ។ កម្មកើតឡើងហើយរលត់ ឈ្មោះថា សោយផលហើយប្រាសទៅ ។ សូម្បីទាំងពីរយ៉ាងនោះ ក៏ឈ្មោះថា កើតឡើងព្រោះសោយផលហើយប្រាសទៅ ។ កុសលកម្ម និងអកុសលកម្មហាមវិបាករបស់កម្មដទៃ ហើយធ្វើឱកាសនៃវិបាករបស់ខ្លួន ។ កាលធ្វើឱកាសយ៉ាងនេះ វិបាកកាលកើតឡើង រមែងឈ្មោះថា កើតឡើងហើយតាំងពីធ្វើឱកាស ។ នេះឈ្មោះថា កើតឡើងព្រោះធ្វើឱកាស ។ មួយ៉ាងទៀត ខន្ធ ៥ ឈ្មោះថា ជាភូមិនៃវិបស្សនា ។ ខន្ធ ៥ ទាំងនោះ រមែងមានប្រភេទជាអតីតជាដើម ។ កិលេសដែលដេកត្រាំក្នុងខន្ធ ៥ ទាំងនោះ មិនគួរពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ។ ព្រោះសូម្បីកិលេសដែលដេកត្រាំក្នុងខន្ធ ដែលជាអតីត ក៏នៅលះមិនបាន ។ សូម្បីកិលេសដែលដេកត្រាំក្នុងខន្ធជាអនាគត ក្នុងខន្ធ

ជាបច្ចុប្បន្ន ក៏នៅលះមិនបាន ។ នេះឈ្មោះថា កើតឡើងព្រោះបានភូមិ ។ ព្រោះហេតុនោះបុរាណាចារ្យ ទើបពោលថា កិលេសដែលមិនទាន់បានលះក្នុងភូមិទាំងនោះ រមែងឈ្មោះថា កើតឡើងព្រោះបានភូមិ ។

កម្មលាមកកើតឡើង ៤ យ៉ាងដទៃទៀត គឺ កើតឡើងព្រោះការប្រព្រឹត្ត ១ កើតឡើងព្រោះប្រកាន់អារម្មណ៍ ១ កើតឡើងព្រោះមិនគ្របសង្កត់ ១ កើតឡើងព្រោះមិនដក ១ ។ ក្នុង ៤ យ៉ាងនោះ កម្មដែលប្រព្រឹត្តទៅហើយ មិនឈ្មោះថា កើតឡើងព្រោះការប្រព្រឹត្ត ។ កាលបើកភ្នែកឡើងតែម្តង ហើយចាប់យកនិមិត្តជាអារម្មណ៍ កិលេសទាំងឡាយក្នុងខណៈដែលរលឹកដល់ មិនគួរពោលថា នឹងមិនកើតឡើង ។ ព្រោះហេតុអ្វី ។ ព្រោះជាប់ជំពាក់ក្នុងអារម្មណ៍ហើយ ។ ដូចអ្វី ។ ដូចជ័រនៃដើមទឹកដោះដែលត្រូវពូថៅហើយ គេមិនគួរពោលថា ទឹកដោះនឹងមិនចេញ យ៉ាងណា ។ នេះក៏ដូច្នោះ ឈ្មោះថា កើតឡើងព្រោះប្រកាន់ក្នុងអារម្មណ៍ ។ កិលេសទាំងឡាយដែលមិនបានគ្របសង្កត់ដោយសមាបត្តិ មិនគួរពោលថា នឹងមិនកើតក្នុងឋានៈនេះ ។ ព្រោះហេតុអ្វី ។ ព្រោះគ្របសង្កត់មិនបាន ។ ដូចអ្វី ដូចជាជនទាំងឡាយ គប្បីនាំដើមទឹកដោះមកដោយពូថៅ មិនគួរពោលថា

ទឹកដោះមិនគប្បីចេញក្នុងទីនេះ យ៉ាងណា នេះក៏យ៉ាងនោះ ឈ្មោះថា កើតឡើងព្រោះមិនគ្របសង្កត់ ។ មយ៉ាងទៀត កិលេសទាំងឡាយដែលនៅមិនទាន់ដកចេញដោយមគ្គ រមែងកើតឡើង សូម្បីដល់អ្នកកើតក្នុងភវគ្គព្រហ្ម គប្បីឲ្យពិស្ដារដោយន័យដូចពោលហើយ ដោយប្រការដូច្នេះឯង ។ នេះឈ្មោះថា កើតឡើងព្រោះដកចេញមិនបាន ។

ក្នុងកម្មលាមកដែលកើតឡើងទាំងនេះ កម្មកើតឡើង ៤ យ៉ាង គឺ កើតឡើងក្នុងបច្ចុប្បន្ន ១ កើតឡើងព្រោះសោយផលហើយប្រាសទៅ ១ កើតឡើងព្រោះធ្វើឱកាស ១ កើតឡើងព្រោះការប្រព្រឹត្ត ១ មិនត្រូវទម្លាយដោយមគ្គ ។ កម្មលាមក ៤ យ៉ាង គឺ កម្មកើតឡើងព្រោះបានភូមិ ១ កើតឡើងព្រោះប្រកាន់អារម្មណ៍ ១ កើតឡើងព្រោះគ្របសង្កត់មិនបាន ១ កើតឡើងព្រោះដកមិនបាន ១ ត្រូវទម្លាយដោយមគ្គ ។ ព្រោះមគ្គ កាលកើត រមែងលះកិលេសទាំងនេះបាន ។ មគ្គនោះ រមែងលះកិលេសពួកណាបាន កិលេសទាំងនោះមិនគួរពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ។ សមដូចដែលលោកពោលទុកថា ប្រសិនបើ មគ្គ រមែងលះកិលេសដែលជាអតីតបានសោត បើដូច្នោះ រមែងធ្វើកិលេសដែលអស់ទៅហើយឲ្យអស់

ទៅបាន រមែងធ្វើកិលេសដែលរលត់ហើយ ឲ្យរលត់ទៅ ដែលប្រាសទៅហើយ ឲ្យប្រាសទៅបាន ដែលមិនតាំងនៅ ឲ្យតាំងនៅមិនបាន កិលេសជាអតីតណាមិនមាន រមែងលះកិលេសដែលជាអតីតនោះបាន ។ ប្រសិនបើមគ្គនោះ រមែងលះកិលេសក្នុងអនាគតបានសោត ។ បើដូច្នោះ មគ្គ ក៏រមែងលះកិលេសដែលនៅមិនទាន់កើតបាន រមែងលះកិលេសដែលមិនទាន់កើត មិនឲ្យកើតបាន ។ កិលេសដែលជាអនាគតណាមិនមាន រមែងលះកិលេសនោះបាន ។ ប្រសិនបើ មគ្គនោះ រមែងលះកិលេសដែលជាបច្ចុប្បន្នបានសោត បើដូច្នោះ អ្នកប្រកបដោយរាគៈ រមែងលះរាគៈបាន ត្រូវទោសៈប្រទូសរ៉ាយ រមែងលះទោសៈបាន ឈ្មក់វង្វេងដោយមោហៈ រមែងលះមោហៈបាន រឹងត្អឹងដោយមានះ រមែងលះមានះបាន អ្នកពាល់ត្រូវដោយទិដ្ឋិ រមែងលះទិដ្ឋិបាន រេវរវាយដោយឧទ្ធច្ចៈ រមែងលះឧទ្ធច្ចៈបាន ដល់ការមិនចុះចិត្តស៊ប់ដោយវិចិកិច្ឆា រមែងលះវិចិកិច្ឆាបាន អ្នកប្រព្រឹត្តទៅដោយកម្លាំងអនុស័យ រមែងលះអនុស័យបាន ។ ធម៌ខ្មៅ ធម៌ស រមែងប្រព្រឹត្តទៅគូគ្នា មគ្គភាវនារមែងសៅហ្មង បើដូច្នោះ មគ្គភាវនារមែងមិនមាន ការធ្វើឲ្យច្បាស់ផលក៏មិនមាន ការលះកិលេសក៏មិនមាន ធម្មាភិ-

សម័យក៏មិនមាន ដូច្នោះឬ ។ មគ្គការនាមាន ។ល។ ធម្មាភិសម័យមាន ។ ដូចអ្វី ? ដូចដើមឈើតូចខ្ចី ។ល។ វត្ថុដែលមិនប្រាកដ រមែងមិនប្រាកដ ។ ដើមឈើមិនទាន់មានផ្លែ មកហើយក្នុងបាលី ។ តែគប្បីសម្តែងដោយដើមឈើដែលមានផ្លែ ។ ដូចដើមស្វាយតូចខ្ចីមានផ្លែ ។ ពួកមនុស្សបរិភោគផ្លែរបស់ដើមស្វាយតូចខ្ចីនោះ ។ ធ្វើផ្លែដែលសល់ឲ្យជ្រុះហើយ ដាក់កញ្ច្រែងដរាបពេញ គ្រានោះ បុរសដទៃយកពូថៅកាត់ដើមស្វាយនោះ ។ ផ្លែរបស់ស្វាយនោះក្នុងអតីតនៅមិនសូន្យទៅ ។ ផ្លែអនាគត បច្ចុប្បន្ន ក៏មិនសូន្យជាការមិនសូន្យទាំងនោះ ។ ព្រោះមនុស្សទាំងឡាយបរិភោគផ្លែក្នុងអតីត ។ ផ្លែក្នុងអនាគតមិនទាន់កើត ទើបមិនអាចធ្វើឲ្យសាបសូន្យបាន ។ តែសម័យណា ដើមស្វាយនោះត្រូវកាត់ ក្នុងពេលនោះផ្លែនុ៎ះឯង រមែងមិនមាន ព្រោះហេតុនោះ សូម្បីផ្លែក្នុងបច្ចុប្បន្នក៏មិនទាន់សូន្យ ។ តែបើដើមឈើមិនគប្បីត្រូវកាត់សោត ផ្លែរបស់ដើមឈើដែលអាស្រ័យរសដី និងរសទឹក គប្បីកើត រមែងមិនសូន្យ ។ ព្រោះផ្លែទាំងនោះ ដែលនៅមិនទាន់កើត ក៏រមែងមិនកើត ដែលនៅមិនទាន់ដុះ ក៏រមែងមិនដុះ ដែលនៅមិនទាន់ប្រាកដ ក៏រមែងមិនប្រាកដ យ៉ាងណា មគ្គក៏ដូច្នោះដែរ សូម្បីលះកិលេសទាំងឡាយ

ដែលផ្សេងដោយអតីតជាដើមមិនបាន សូម្បីមិនទាន់លះ ក៏លះមិនបាន ។ ព្រោះកាលមិនទាន់បានកំណត់ដឹងខន្ធទាំងឡាយ កិលេសពួកណាគប្បីកើតឡើង កិលេសទាំងនោះដែលមិនកើត រមែងមិនកើត ដែលនៅទាន់មិនកើត រមែងមិនកើត ដែលនៅមិនប្រាកដ រមែងមិនប្រាកដ ព្រោះមិនទាន់បានកំណត់ដឹងខន្ធទាំងឡាយដោយមគ្គ គប្បីឲ្យសេចក្ដីនេះជាក់ច្បាស់ ដោយពោលអំពីថ្នាំដែលផឹក ដើម្បីមិនឲ្យស្ត្រីដែលមានកូនខ្ចីសំរាលកូនទៀត និងដើម្បីឲ្យអ្នកជម្ងឺជាអំពីរោគ ។ មគ្គ លះកិលេសពួកណាបានយ៉ាងនេះ កិលេសទាំងនោះ មិនគប្បីពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ម្យ៉ាងទៀត មិនមែនមគ្គ រមែងលះកិលេសមិនបាន ។ មគ្គ រមែងលះកិលេសពួកណាបាន លោកពោលថា **ឧប្បន្នានំ បាបកានំ** ជាដើម សំដៅដល់កិលេសទាំងនោះ ។ មគ្គ មិនមែននឹងលះកិលេសបានតែម្យ៉ាងប៉ុណ្ណោះ តែព្រោះនៅលះកិលេសទាំងឡាយមិនបាន ឧបាទិន្នកខន្ធគប្បីកើតឡើង រមែងលះបានសូម្បីឧបាទិន្នកខន្ធនោះ ។ សមដូចដែលលោកពោលទុកថា នាមនិងរូប គប្បីកើតឡើងក្នុង សង្សារវដ្តដែលមានខាងដើម និងខាងចុង ដែលបុគ្គលដឹងមិនបាន វៀរក្នុងភព ៧ ព្រោះការរលត់នៃអភិសង្ខារ និងវិញ្ញាណ

ដោយសោតាបត្តិមគ្គញ្ញាណ នាម និងរូបទាំងនោះ រមែងរលត់ទៅក្នុងទីនោះ ។

គប្បីជ្រាបសេចក្តីពិស្តារដូចតទៅនេះ ៖

មគ្គ រមែងចេញចាកឧបាទិន្នៈ និងអនុបាទិន្នៈ គឺ វិបាក និងកម្មដោយប្រការដូច្នេះ ។ តែកាលពោលអំពីភព សោតាបត្តិមគ្គ រមែងចេញចាកអបាយភព សកទាគាមិមគ្គ រមែងចេញចាកសុគតិភពដោយចំណែកមួយ ។ អនាគាមិមគ្គ រមែងចេញចាកសុគតិកាមភព ។ អរហត្តមគ្គ រមែងចេញចាករូបភព និងអរូបភព ។ អាចារ្យពួកខ្លះពោលថា អរហត្តមគ្គចេញចាកភពទាំងពួង ។ បើដូច្នោះ ការចម្រើនដើម្បីកើតឡើងនៃកុសលធម៌ ដែលមិនទាន់កើតឡើងក្នុងខណៈនៃមគ្គជាយ៉ាងណា ។ ឬដើម្បីសេចក្តីតាំងមាំនៃកុសលធម៌ ដែលកើតឡើងហើយជាយ៉ាងណា ។ ដើម្បីការប្រព្រឹត្តទៅនៃមគ្គនុ៎ះឯង ។ ព្រោះមគ្គកាលប្រព្រឹត្តទៅហើយ លោកពោលថា មគ្គមិនទាន់កើតហើយ ព្រោះមិនធ្លាប់កើតមកពីមុន ។ ព្រោះអ្នកពោលមកកាន់ឋានៈដែលមិនធ្លាប់មក ឬសោយអារម្មណ៍ដែលមិនធ្លាប់សោយ រមែងពោលថា យើងមកកាន់ឋានៈដែលមិនធ្លាប់មកហើយ ។ ឬថា យើងសោយអារម្មណ៍

ដែលមិនធ្លាប់សោយហើយ ការប្រព្រឹត្តទៅនៃមគ្គនោះឯង ឈ្មោះថា ឋិតិ ព្រោះហេតុនោះ គួរពោលថា **ឋិតិយា ភាវេតិ** ឲ្យមគ្គចម្រើនដើម្បីសេចក្ដីតាំងមាំ ។ សេចក្ដីសង្ខេបក្នុងឥទ្ធិបាទ លោកពោលទុកហើយក្នុងចេតោខិលសូត្រ ។ ឈ្មោះថា **ឧបសមគា** មាន ព្រោះដល់សេចក្ដីស្ងប់រម្ងាប់ ឬដល់ដើម្បីសេចក្ដីស្ងប់កិលេស ។

**[៩៧]** ឈ្មោះថា **សម្ពោធិគាមី** មានព្រោះដល់សេចក្ដីត្រាស់ដឹង ឬដល់ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងមគ្គ ។

**[៩៩]** បទមានជាដើមថា **វិវេកនិស្សិតា** អាស្រ័យវិវេក លោកពោលទុកហើយក្នុងការសន្រ្ទមក្នុងអាសវៈទាំងពួង ។ នេះជាសេចក្ដីសង្ខេបក្នុងបទនេះ ។ ចំណែកពោធិបក្ខិយកថានេះ លោកពោលទុកក្នុងវិសុទ្ធិមគ្គ ដោយពិស្ដារហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិមោក្ខកថា ដូចតទៅនេះ ៖

**[១០១]** បទថា **វិមោក្ខេ** ឈ្មោះថា វិមោក្ខ ព្រោះអត្ថថា យ៉ាងណា ។ ព្រោះអត្ថថា រួចផុតដោយល្អ ក៏វិមោក្ខនេះ គឺអ្វី ។ វិមោក្ខ មានអត្ថថា រួចផុតដោយល្អស្ងប់ស្ងៀមអំពីធម៌ជាសត្រូវឈ្មោះថា **អធិមុច្ចនដ្ឋោ** មានអត្ថថា

រូបផុតដោយល្អ ។ មានអត្ថថា ផុតដោយល្អស្ងប់អំពីអារម្មណ៍ទាំងឡាយ ដោយអំណាចការមិនត្រេកអរ ។ លោកអធិប្បាយទុកថា វិមោក្ខប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់សេចក្ដីញ៉ាំងវេទ្ធត់ចិត្ត ដោយសេចក្ដីមិនត្រូវគ្របសង្កត់ ដូចទារកសណ្ដូកអវយវៈដេកលើភ្លៅបិតា ។ តែសេចក្ដីនេះ មិនមានក្នុងវិមោក្ខចុងបង្អស់ ។ មានក្នុងវិមោក្ខខាងដើមៗ ទាំងអស់ ។ ក្នុងបទថា **រូបី រូបានិ បស្សតិ** អ្នកបានរូបឈាន រមែងឃើញរូបនេះ មានអធិប្បាយដូចតទៅនេះ ៖

រូបឈាន ដែលឲ្យកើតដោយអំណាចនីលកសិណជាដើម ក្នុងបណ្ដាកសិណ មានសក់ក្នុងខាងក្នុងជាដើម ឈ្មោះថា រូប ។ ឈ្មោះថា **រូបី** ព្រោះមានរូបឈាននោះ ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** ឃើញរូបខាងក្រៅ ឬឃើញរូប មាននីលកសិណជាដើម ស្ងប់ខាងក្រៅដោយឈានចក្ខុ ។ ដោយបទនេះ លោកសម្ដែងដល់រូបាវចរឈាន ៤ របស់បុគ្គលមានឈាន ដែលឲ្យកើតហើយក្នុងកសិណទាំងឡាយ ដែលមានវត្ថុខាងក្នុង និងខាងក្រៅ ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** គឺ អ្នកមិនមានរូបសញ្ញាក្នុងខាងក្នុង ។

អធិប្បាយថា មានរូបាវចរឈានដែលមិនទាន់កើតក្នុងកសិណ មាន

សក់ជារបស់ខ្លួន ។ ដោយបទនេះ លោកសម្តែងដល់រូបាវចរឈានរបស់អ្នកមានឈាន ដែលធ្វើបរិកម្មយ៉ាងល្អក្នុងខាងក្រៅ ហើយឲ្យកើតក្នុងខាងក្រៅ ។ ដោយបទថា **សុភន្តេវ អធិមុត្តោ ហោតិ** អ្នកបង្អោនចិត្តជឿថាកសិណជារបស់ល្អតែម្យ៉ាងនេះ លោកសម្តែងដល់ឈានក្នុងវណ្ណកសិណមាននីលកសិណជាដើម ដែលបរិសុទ្ធិ ក្នុងបទនោះ ការតម្កល់ចិត្តថា ល្អមិនមានក្នុងអប្បនាខាងក្នុងក៏ពិត តែដល់ដូច្នោះ ព្រះយោគាវចរណាធ្វើសុភកសិណឲ្យជាអារម្មណ៍បរិសុទ្ធដោយល្អហើយ ។ ព្រោះព្រះយោគាវចរនោះ រមែងដល់ភាពជាអ្នកគួរពោលថា ជាអ្នកបង្អោនចិត្តជឿថា ល្អ ។ ដូច្នោះលោកទើបសម្តែងទុកយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គ លោកពោលទុកថា ឈ្មោះថា វិមោក្ខ ព្រោះជាអ្នកបង្អោនចិត្តជឿថា ល្អ ដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តសហគតៈដោយមេត្តា ផ្សាយទៅកាន់ទិសមួយ ។ ព្រោះជាអ្នកចម្រើនមេត្តា សត្វទាំងឡាយទើបមិនគួរស្អប់ ។ មានចិត្តសហ-គតៈដោយករុណា មុទិតា និងឧបេក្ខា ផ្សាយទៅកាន់ទិសមួយ ។ ព្រោះជាអ្នកចម្រើនករុណា មុទិតា និងឧបេក្ខា សត្វទាំងឡាយទើបមិនគួរស្អប់ ឈ្មោះថា វិមោក្ខ ព្រោះជាអ្នកបង្អោនចិត្តជឿថា ល្អយ៉ាងនេះ ។ ក្នុងបទថា **សព្វ-**

សោ រូបសញ្ញានំ ព្រោះកន្លងរូបសញ្ញាដោយប្រការទាំងពួងជាដើម បទដែលគួរពោលទាំងអស់ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **អយំ អដ្ឋមោ វិមោក្ខោ** នេះ ជាវិមោក្ខប្រការទី ៨ គឺ នេះឈ្មោះថា វិមោក្ខដ៏ខ្ពស់បំផុតប្រការទី ៨ ព្រោះលះបង់ខន្ធ ៤ រួចផុតហើយដោយប្រការទាំងពួង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនកថា ដូចតទៅនេះ ៖

**[១០២]** បទថា **អភិភាយតនានិ** គឺ ហេតុជាគ្រឿងគ្របសង្កត់ ។ គ្របសង្កត់អ្វី ។ គ្របសង្កត់ធម៌ដែលជាសត្រូវខ្លះ អារម្មណ៍ខ្លះ ។ ព្រោះអភិភាយតនៈទាំងនោះ រមែងគ្របសង្កត់ធម៌ជាសត្រូវ ដោយភាពជាសត្រូវ ។ គ្របសង្កត់អារម្មណ៍ ព្រោះភាពនៃបុគ្គលជាអ្នកក្រៃលែងដោយញាណ ។

ម្យ៉ាងទៀត ក្នុងបទមានជាដើមថា **អជ្ឈត្តំ រូបសញ្ញី** អ្នកមានការសម្គាល់ក្នុងរូបខាងក្នុង មានសេចក្តីដូចតទៅនេះ ៖

រមែងឈ្មោះថា រូបសញ្ញី អ្នកមានការសម្គាល់ក្នុងរូបខាងក្នុង ដោយអំណាចបរិកម្មរូបខាងក្នុង ។ ព្រោះកាលធ្វើបរិកម្ម នីលបរិកម្មក្នុងខាងក្នុង រមែងធ្វើត្រង់សក់ដែលល្អ ឬត្រង់គ្រាប់ភ្នែក ។ កាលធ្វើបីតបរិកម្ម រមែង

ធ្វើត្រង់ខ្វាញ់ខាប់ ត្រង់សម្បុរ ត្រង់បាតដៃ ត្រង់បាតជើង ឬត្រង់ទីដែលមានលឿងរបស់គ្រាប់ភ្នែក ។ កាលធ្វើលោហិតបរិកម្ម រមែងធ្វើសាច់ ត្រង់លោហិត ត្រង់អណ្តាត ត្រង់ទីមានពណ៌ក្រហមរបស់គ្រាប់ភ្នែក ។ កាលធ្វើឱទាតបរិកម្ម រមែងធ្វើត្រង់ឆ្អឹង ត្រង់ធ្មេញ ត្រង់ក្រចក ឬទីដែលមានពណ៌សរបស់គ្រាប់ភ្នែក ។ តែកសិណនោះ មិនខៀវល្អ មិនលឿងល្អ មិនក្រហមល្អ មិនសល្អ រមែងជាកសិណមិនបរិសុទ្ធិ ។

បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** បុគ្គលម្នាក់ឃើញរូបខាងក្រៅ សេចក្តីថា និមិត្តខាងក្រៅកើតឡើងខាងក្នុង ព្រោះធ្វើបរិកម្មរបស់បុគ្គលណា បុគ្គលនោះ យើងហៅថា ជាបុគ្គលម្នាក់មានការសម្គាល់រូបខាងក្នុងឃើញរូបខាងក្រៅ ដោយអំណាចនៃបរិកម្មខាងក្នុង និងនៃអប្បនាខាងក្រៅយ៉ាងនេះ ។ បទថា **បរិត្តានិ** រូបខាងក្រៅតូច គឺ មិនធំ ។ បទថា **សុវណ្ណ-ទុព្វណ្ណានិ** គឺ មានពណ៌សម្បុរល្អ ឬមានពណ៌សម្បុរអាក្រក់ ។

គប្បីជ្រាបថា នេះលោកពោលថា ជាអភិភាយតនៈ ដោយអំណាចរូបតូចទុំះឯង ។ បទថា **តានិ អភិភុយ្យ** គ្របសង្កត់រូបទាំងនោះ សេចក្តីថា ដូចអ្នកមានអាហារល្អ បានអាហារត្រឹមតែមួយវែក គិតថា មានអ្វីដែល

គួរបរិភោគក្នុងអាហារនេះ ទើបចាប់យកមកលាយគ្នាជាពាក្យតែមួយ យ៉ាងណា ។ បុគ្គលដែលក្រៃលែងដោយឈាន មានញាណវាងវៃគិតថា មានអ្វីដែលគួរចូលដល់ក្នុងអារម្មណ៍បន្តិចបន្តួចនេះ ។ នេះមិនមែនការៈរបស់យើង ទើបគ្របសង្កត់រូបទាំងនោះចូលដល់សមាបត្តិ ។ អធិប្បាយថា ញុំាងអប្បនាឲ្យដល់ក្នុងរូបនេះ ព្រមទាំងការកើតនៃនិមិត្ត ។ លោកពោលដល់សេចក្តីតម្កល់ចិត្តក្នុងរូបនោះ ដោយបទនេះថា **ជានាមិ បស្សាមិ** យើងដឹងយើងឃើញ ។ បុគ្គលនោះ កាលចេញចាកសមាបត្តិហើយ មិនចូលសមាបត្តិក្នុងខាងក្នុង ។

បទថា **ឯវំ សញ្ញី ហោតិ** មានសេចក្តីសម្គាល់យ៉ាងនេះ គឺ ដោយអាភោគសញ្ញាខ្លះ (សេចក្តីសម្គាល់ដោយការតម្កល់ចិត្ត) ដោយឈានសញ្ញាខ្លះ (សេចក្តីសម្គាល់ដោយឈាន) អភិភវសញ្ញា (សេចក្តីសម្គាល់ដោយការគ្របសង្កត់) រមែងមានដល់អ្នកនោះ សូម្បីក្នុងខាងក្នុងសមាបត្តិ ។ ចំណែកអាភោគសញ្ញា រមែងមានដល់អ្នកចេញចាកសមាបត្តិ ។ បទថា **អប្បមាណានិ** រកប្រមាណមិនបាន គឺ មានសភាពដ៏ធំ ប្រមាណមិនបាន ព្រោះការចម្រើន ។ គប្បីជ្រាបសេចក្តីក្នុងបទថា **អភិភុយ្យ** គ្របសង្កត់

ដូចតទៅនេះ ៖

ដូចបុរសអ្នកស៊ីច្រើន កាលបានអាហារមួយដុំ ក៏គិតថា អាហារសូម្បីដទៃចូរមាន អាហារសូម្បីដទៃចូរមាន អាហារមួយដុំនឹងធ្វើអ្វីដល់យើងបាន ទើបមិនឃើញអាហារនោះច្រើនល្មម យ៉ាងណា ។ បុគ្គលដែលក្រៃលែងដោយញាណ អ្នកមានញាណវាងវៃគិតថា នឹងគប្បីចូលដល់ញាណនេះ បានយ៉ាងណា ។ នេះមានប្រមាណតិច ការៈក្នុងការធ្វើភាពជាអ្នកមានចិត្តក្នុងអារម្មណ៍តែមួយមានដល់យើង ទើបគ្របសង្កត់រូបទាំងនោះ ហើយចូលសមាបត្តិ ។ អធិប្បាយថា ញុំាងអប្បនាឲ្យដល់ចិត្តនេះ ព្រមទាំងឲ្យកើតនិមិត្ត ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** មានការសម្គាល់ក្នុងអរូបខាងក្នុង សេចក្តីថា មិនមានសេចក្តីសម្គាល់ បរិកម្មក្នុងរូបខាងក្នុង ព្រោះមិនបាន ឬព្រោះមិនមានប្រយោជន៍ ។

បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** បុគ្គលម្នាក់ឃើញរូបខាងក្រៅ សេចក្តីថា បរិកម្មក្តី និមិត្តក្តី របស់បុគ្គលណាកើតឡើងក្នុងខាងក្រៅ ។ បុគ្គលនោះ មានសេចក្តីសម្គាល់ក្នុងអរូបខាងក្នុង ដែលកើតឡើងដោយអំណាចបរិកម្ម និងអប្បនាខាងក្រៅយ៉ាងនេះ លោកពោលថា បុគ្គលម្នាក់

*ឃើញរូបខាងក្រៅ ។ បទដ៏សេសក្នុងបទនេះ មានន័យដូចពោលហើយក្នុងអភិភាយតនៈទី ៤ ។ ក៏ក្នុងអភិភាយតនៈ ៤ នេះ អភិភាយតនៈ ប្រមាណតិច មកហើយដោយអំណាចវិតក្កចរិត ។ អភិភាយតនៈរកប្រមាណមិនបានមកហើយដោយអំណាចមោហចរិត ។ រូបមានពណ៌ដូចមាស មកហើយដោយអំណាចទោសចរិត ។ រូបមានសម្បុរអាក្រក់ មកហើយដោយអំណាចរាគចរិត ។ រូបទាំងនេះ ជាទីសប្បាយរបស់បុគ្គលទាំងនោះ ។*

*ម្យ៉ាងទៀត រូបជាទីសប្បាយរបស់បុគ្គលទាំងនោះ លោកពោលទុកក្នុងចរិតនិទ្ទេសក្នុងវិសុទ្ធិមគ្គ ដោយពិស្តារហើយ ។*

***គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនៈទី ៥ ជាដើមដូចតទៅនេះ ៖***

*បទថា **នីលានិ** ពណ៌ខៀវ លោកពោលរួមពណ៌ទាំងអស់ ។ បទថា **នីលវណ្ណានិ** មានវណ្ណៈខៀវ គឺ ខៀវដោយពណ៌ ។ បទថា **នីល-ទស្សនានិ** ខៀវសុទ្ធ លោកអធិប្បាយថា វណ្ណៈមិនមានលាយ មិនមានប្រហោងប្រាកដ ដោយការសម្តែងឲ្យឃើញជាពណ៌ខៀវសុទ្ធ ។ ចំណែកបទថា **នីលនិភាសានិ** មានរស្មីខៀវនេះ លោកពោលដោយអំណាចពន្លឺ ។ អធិប្បាយថា មានពន្លឺខៀវប្រកបដោយរស្មីខៀវ ។ ដោយបទនេះ លោក*

សម្តែងដល់រូបទាំងនោះបរិសុទ្ធិ ។ ពិតណាស់ លោកពោលអភិភាយតនៈទាំង ៤ នេះ ដោយអំណាចវណ្ណៈបរិសុទ្ធិ ។

បទថា **ឧម្មារបុប្ផំ** ផ្កាត្រកៀត ព្រោះផ្កាឈើនេះសូម្បីប្រាកដជាទន់ក៏ខៀវសុទ្ធ ។ តែផ្កាអញ្ចន់ជាដើម ប្រាកដជាផ្កាឈើត្រកូលស ។ ព្រោះដូច្នោះ លោកកាន់យកផ្កាត្រកៀតនេះឯង មិនកាន់យកផ្កាអញ្ចន់ជាដើមទាំងនោះ ។ **ពារាណសេយ្យកំ** សំពត់ដែលកើតក្នុងក្រុងពារាណសី គឺ ធ្វើក្នុងក្រុងពារាណសី ។ បានឮថា ក្នុងក្រុងពារាណសីនោះ សូម្បីកប្បាសក៏ទន់ល្អ សូម្បីអ្នករវៃក៏ឆ្លាត សូម្បីទឹកក៏ស្អាត ត្រជាក់ស្និទ្ធ ព្រោះដូច្នោះ សំពត់ទើបរលោងទាំងពីរខាង ។ ក្នុងពីរខាងប្រាកដរលោង និងទន់ស្និទ្ធ ។

ក្នុងបទមានជាដើមថា **បីតានិ** គប្បីជ្រាបដោយន័យនេះដូចគ្នា ។ កាលកំណត់នីលកសិណ រមែងកាន់យកនិមិត្តក្នុងពណ៌ខៀវ ។

មួយវិញទៀត ក្នុងកសិណនេះ ការធ្វើកសិណ ការបរិកម្ម និងបែបនៃអប្បនា មានជាដើម គឺ ក្នុងផ្កាឈើ ក្នុងសំពត់ ឬក្នុងវណ្ណធាតុទាំងអស់ លោកពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **អភិញ្ញាវោសានបារមិប្បត្តា** សម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា គឺ សាវកទាំងឡាយ ចម្រើន

ធម៌ទាំងនោះក្នុងសតិប្បដ្ឋានជាដើម ក្នុងកាលមុនអំពីនេះ ហើយសម្រេចព្រះអរហត្ត ឈ្មោះថា ជាអ្នកសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ។

ម្យ៉ាងទៀត សាវកទាំងឡាយក៏ឈ្មោះថា ជាអ្នកសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ព្រោះជាអ្នកមានភាពជំនាញដែលសន្សំមកហើយក្នុងអភិភាយតនៈ ៨ ទាំងនេះ ។

**គប្បីជ្រាបវិនិច្ឆ័យក្នុងកសិណកថា** ដូចតទៅនេះ ៖

**[១០៣]** ឈ្មោះថា កសិណ ព្រោះអត្ថថា ទាំងអស់ ។ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាខេត្ត ឬជាទីតាំងមាំនៃធម៌ទាំងឡាយ មានកសិណនោះជាអារម្មណ៍ ។ បទថា **ឧទ្ធំ** ខាងលើ គឺ បែរមុខឆ្ពោះទៅកាន់អាកាសខាងលើ ។ បទថា **អធោ** ខាងក្រោម គឺ បែរមុខឆ្ពោះទៅកាន់ផែនដីខាងក្រោម ។ បទថា **តិរិយំ** ខាងទទឹង គឺ កំណត់ដោយជុំវិញ ដូចបរិវេណរបស់ផ្ទៃដី ។ បុគ្គលខ្លះចម្រើនកសិណខាងលើប៉ុណ្ណោះ ។ បុគ្គលខ្លះចម្រើនកសិណខាងក្រោម ។ បុគ្គលខ្លះចម្រើនកសិណដោយជុំវិញៗ ដោយហេតុនោះឯង បុគ្គលប្រាថ្នានឹងឃើញរូប ដូចជាពន្លឺដែលភ្លឺថ្លាផូរផង់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់បទមានជាដើមថា **បឋវីកសិណ-**

*មេកោ សញ្ជានាតិ ឧទ្ធំ អធោតិរិយំ* បុគ្គលម្នាក់រមែងដឹងច្បាស់នូវបឋវីកសិណ ទាំងខាងលើ ខាងក្រោម ខាងទទឹង ។

បទថា **អទ្វយំ** គឺ ក្នុងទិសតូចធំ ។ ក៏បទនេះ លោកពោលដល់សេចក្តីមិនមានអ្វីដទៃនៃទិសមួយ ដូចអ្នកចូលទៅកាន់ទន្លេ ប៉ុណ្ណោះ រមែងមានក្នុងទិសទាំងអស់ មិនមែនយ៉ាងដទៃ យ៉ាងណា ។ បឋវីកសិណ ក៏ដូច្នោះដែរ រមែងជាបឋវីកសិណប៉ុណ្ណោះ ។ កសិណនោះ មិនមានកសិណដទៃប្រឡូកប្រឡំឡាយឡើ ។ ក្នុងកសិណទាំងអស់ ក៏មានន័យនេះឯង ។ បទថា **អប្បមាណំ** នេះ លោកពោលដោយអំណាចកសិណនោះផ្សាយទៅមិនមានប្រមាណ ។ ព្រោះកសិណនោះ ផ្សាយទៅដោយចិត្ត រមែងផ្សាយទៅរហូតដល់អស់ដួងកសិណប៉ុណ្ណោះ ។ រមែងកាន់យកប្រមាណថា នេះជាខាងដើមរបស់កសិណនោះ នេះជាកណ្តាល ។

ម្យ៉ាងទៀត ក្នុងបទថា **វិញ្ញាណកសិណំ** នេះ មានសេចក្តីដូចតទៅនេះ វិញ្ញាណដែលប្រព្រឹត្តទៅហើយ ក្នុងអាកាសដែលបើកកសិណចេញ ។ ក្នុងបទថា **វិញ្ញាណកសិណំ** នោះ គប្បីជ្រាបសេចក្តីដែលកសិណនោះ ទាំងខាងលើ ខាងក្រោម និងខាងទទឹង ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅហើយនោះ

ដោយអំណាចអាកាសដែលបើកកសិណហើយ ក្នុងអាកាសដែលបើកកសិណ ដោយអំណាចនៃកសិណ ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។ ចំណែក បឋវីកសិណជាដើមទាំងនេះ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ដោយ ពិស្តារតាមន័យនៃការចម្រើនកម្មដ្ឋាន សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា សាវក ទាំងឡាយ ជាអ្នកសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ដោយភាពជា អ្នកមានសេចក្តីជំនាញសន្សំទុកហើយ ។

**[១០៨]** ក្នុងឈាន ៤ ដែលជាលំដាប់តពីនេះ ក៏ន័យនេះដូចគ្នា ។ ចំណែកបទដែលគួរពោលក្នុងទីនេះ បានពោលទុកហើយក្នុងមហាអស្សបុរសូត្រ ។ តែក្នុងវិបស្សនាញាណ លោកពោលសេចក្តីនៃបទមានជាដើមថា **រូបី** បុគ្គលបានរូបឈានហើយ ។

បទថា **ឯត្ថ សិតំ ឯត្ថ បដិពទ្ធំ** គឺ វិញ្ញាណអាស្រ័យក្នុងកាយ គឺ មហាភូតរូប ៤ នេះ ។ បទថា **សុភោ** គឺ ល្អ ។ បទថា **ជាតិមា** គឺ តាំង នៅក្នុងអាការដែលបរិសុទ្ធិ ។ បទថា **សុបរិកម្មកតោ** ធ្វើបរិកម្មយ៉ាងល្អ គឺ ជាងច្នៃល្អហើយ មិនមានថ្មនិងគ្រួស ។ បទថា **អច្ឆោ** ថ្លា គឺ ថ្លាក្នុងខ្លួន ផូរផង់ក្នុងខ្លួន ។ បទថា **វិប្បសន្នោ** គឺ ភ្លឺថ្លាល្អ ។ បទថា **សព្វាការស-**

ម្បន្នោ សមដោយចំណែកគ្រប់យ៉ាង គឺ សម្បូរណ៍ដោយអាការទាំងពួង មានការខាត់ និងបោះជាដើម ។ លោកសម្តែងដល់សម្បត្តិរបស់ពណ៌ ដោយបទមានជាដើមថា នីលំ ។ ព្រោះកែវមណីដែលដោតក្រងដោយអំបោះ ក៏ប្រាកដច្បាស់ ដូច្នោះ ។ ក្នុងបទថា ឯវមេវ នេះ គប្បីជ្រាបការប្រៀបធៀបយ៉ាងនោះ ។ ព្រោះករជកាយ ដូចកែវមណី ។ វិបស្សនាញាណដូចអំបោះដែលដោតក្រង ។ ភិក្ខុដែលបានវិបស្សនា ដូចបុរសមានចក្ខុ ។ កាលដែលដឹងច្បាស់កាយដែលមានមហាភូតរូប ៤ របស់ភិក្ខុដែលអង្គុយកំណត់វិបស្សនាញាណ ដូចកាលដែលដឹងច្បាស់កែវមណី របស់អ្នកដាក់កែវមណីទុកលើដៃ ហើយពិចារណាមើលថា នេះឯងកែវមណី ដូច្នោះ ។ កាលដឹងច្បាស់អារម្មណ៍ មានផស្សៈជាគម្រប់ ៥ ក្តី ចិត្ត ចេតសិកទាំងពួងក្តី វិបស្សនាញាណក្តី របស់ភិក្ខុអ្នកអង្គុយកំណត់វិបស្សនាញាណ ដូចកាលដឹងច្បាស់ក្នុងអំបោះថា អំបោះនេះដោតនៅក្នុងកែវមណី ដូច្នោះ ។ ក៏ការដឹងច្បាស់នៃញាណ ដូចម្តេច ។ ព្រោះការដឹងច្បាស់នៃញាណនោះ ជាការដឹងច្បាស់នៃបុគ្គលទុំះឯង ។ មយ៉ាងទៀត វិបស្សនាញាណនេះ ជាលំដាប់របស់មគ្គ ។ បើដូច្នោះ ព្រោះកាលប្រារព្ធវារៈនៃអភិញ្ញា ទើបមិនមានវារៈ

ក្នុងចន្លោះនៃវិបស្សនាញាណនោះ ។ ដូច្នោះ លោកទើបសម្តែងទុកក្នុងទីនេះឯង ។ មយ៉ាងទៀត ព្រោះសេចក្តីតក់ស្លុតចំពោះភ័យ រមែងកើតដល់អ្នកមិនពិចារណាដោយអំណាចសេចក្តីមិនទៀងជាដើម អ្នកបានឮសំឡេងគួរខ្លាចដោយត្រចៀកទិព្វ អ្នករលឹកដល់ខន្ធគួរខ្លាចដោយការរលឹកជាតិបាន អ្នកឃើញរូបគួរខ្លាចដោយភ្នែកទិព្វ ។ ដូច្នោះ លោកទើបមិនសម្តែងបទនោះទុកក្នុងទីនេះ សូម្បីដើម្បីត្រៀមហេតុបន្ទោបង់សេចក្តីខ្លាច របស់អ្នកមិនបានធ្វើការពិចារណាដោយអំណាចសេចក្តីមិនទៀងជាដើម អ្នកសម្រេចអភិញ្ញានោះ ។ សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា សាវកទាំងឡាយសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ដោយព្រះអរហត្ត ។

**[១០៩]** គប្បីជ្រាប ព្រោះជាអ្នកមានសេចក្តីជំនាញក្នុងមនោមយិទ្ធិ ដូចតទៅនេះ ៖

ក្នុងបទទាំងនោះ បទថា **មនោមយំ** គឺ កើតពីចិត្ត ។ បទថា **សព្វង្គបច្ចង្គី** មានអវយវៈតូចធំគ្រប់សព្វ គឺ ប្រកបដោយអង្គទាំងអស់ និងដោយអង្គ ៥ ។

បទថា **អហីនិន្ទ្រិយំ** មានឥន្ទ្រិយមិនខ្វះខាត គឺ មានឥន្ទ្រិយមិនវិកល

ដោយសណ្ឋាន ។ ព្រោះរូបនិមិត្តរបស់អ្នកមានឫទ្ធិ ដូចគ្នានឹងរូបនោះ ដោយអាការគ្រប់យ៉ាង យ៉ាងនេះគឺ បើអ្នកមានឫទ្ធិស សូម្បីរូបនិមិត្តនោះក៏ស ។ បើអ្នកមានឫទ្ធិមានត្រចៀកមិនបានចោះ សូម្បីរូបនោះក៏មានត្រចៀកមិនបានចោះ ។ សូម្បីឧបមា ៣ ប្រការ មានជាដើមថា **មុញ្ជម្ហា ឥសិកំ** គប្បីដកបណ្ដូលស្មៅយាប្លងចេញពីស្មៅយាប្លង លោកពោលដើម្បីសម្ដែងសេចក្ដីដូចគ្នា ។ ព្រោះបណ្ដូលស្មៅយាប្លងខាងក្នុងនោះ ក៏ដូចនឹងស្មៅយាប្លងនុ៎ះឯង ។ កាលនាំដាវចេញពីស្រោមដាក់ដាវ កាលនាំសស្ត្រាចេញពីស្រោមដាក់សស្ត្រា ដាវ និងសស្ត្រា ក៏ដូចនឹងស្រោមនុ៎ះឯង ។

សូម្បីបទថា **ករណ្ឌា** នេះ ជាឈ្មោះរបស់សំណាកពស់ មិនមែនជាឈ្មោះរបស់ហិបឫស្សី ។ ព្រោះសំណាកពស់ក៏ដូចនឹងពស់ ។ ក្នុងបទនោះលោកសម្ដែងដូចនាំដោយដៃថា បុរសគប្បីនាំពស់ចេញពីសំណាក ដែលពិតគប្បីជ្រាបថា នាំដោយចិត្តរបស់បុរសនោះឯង ។ ព្រោះធម្មតា ពស់នេះរមែងសកសំណាកដោយខ្លួនឯង ដោយហេតុ ៤ ទាំងនេះ គឺ តាំងនៅក្នុងកំណើតរបស់ខ្លួន ១ អាស្រ័យចន្លោះឈើ ឬចន្លោះដើមឈើ ១ ព្យាយាមដកខ្លួនចេញពីសំណាក ១ រង្កៀសសំណាកចាស់ ១ មិនអាចនឹងសកសំណាក

ដោយវិធីដទៃអំពីនោះបាន ។ ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលបទនេះ សំដៅដល់ការនាំដោយចិត្ត ។ ប្រការប្រៀបធៀបក្នុងបទនេះ មានដូច្នេះថា សរីរៈរបស់ភិក្ខុនេះ ដូចនឹងស្មៅយាប្លងជាដើម ។ រូបនិមិត្តដូចនឹងបណ្ដូលស្មៅយាប្លងជាដើម ។ ក៏ក្នុងទីនេះ នឹងពោលដល់វិធីនិមិត្ត ព្រោះថា ការពោលដល់អភិញ្ញា ៥ មានឥទ្ធិវិធៈជាដើម លោកពោលទុកពិស្ដារហើយក្នុងវិសុទ្ធិមគ្គគ្រប់ប្រការ ។ គប្បីជ្រាបតាមន័យដូចពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ ព្រោះក្នុងទីនេះ លោកពោលបន្ថែមត្រឹមតែឧបមាប៉ុណ្ណោះ ។ គប្បីឃើញភិក្ខុដែលបានញាណ គឺ ឥទ្ធិវិធៈ ដូចជាងឆ្នាំងអ្នកឆ្លាត ដូច្នោះ ។ គប្បីឃើញឥទ្ធិវិធញ្ញាណ ដូចដីស្អិតដែលជាងឆ្នាំងតាក់តែងយ៉ាងល្អ ដូច្នោះ ។ គប្បីឃើញការសម្ដែងឫទ្ធិរបស់ភិក្ខុនោះ ដូចការធ្វើជាភាជនៈប្រភេទផ្សេងៗ តាមដែលខ្លួនត្រូវការហើយៗ ។ សូម្បីក្នុងទីនេះក៏គប្បីជ្រាបថា ព្រះសាវកទាំងឡាយសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ដោយអំណាចជាអ្នកមានសេចក្ដីជំនាញដែលសន្សំទុកហើយនុ៎ះឯង ។ ក្នុងអភិញ្ញា ៤ ដទៃអំពីនេះ ក៏ដូចគ្នានោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមានៃទិព្វសោតធាតុ ដូចតទៅនេះ ៖

**[១១១]** បទថា ***សទ្ទធមោ*** គឺ បុរសផ្លុំស័ង្ខ ។ បទថា ***អប្បកសិ-រេនេវ*** គឺ ដោយមិនលំបាកទុំះឯង ។

បទថា ***វិញ្ញាបេយ្យ*** គឺ ឲ្យដឹង ។ គប្បីឃើញថា កាលដែលព្រះ-យោគី ដឹងច្បាស់នូវសំឡេងរបស់មនុស្សទាំងជិត និងឆ្ងាយ និងនិព្វាន ដូច កាលដែលបុរសផ្លុំស័ង្ខឲ្យដឹងច្បាស់ទៅក្នុងទិសទាំង ៤ នេះ សំឡេងស័ង្ខ នោះ ក៏ប្រាកដច្បាស់ដល់សត្វទាំងឡាយអ្នកកំណត់ថា នេះជាសំឡេងស័ង្ខ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមានៃចេតោបរិយញ្ញាណ ដូចតទៅនេះ ៖

**[១១២]** បទថា ***ទហរោ*** គឺ កម្លោះ ។ បទថា ***យុវា*** គឺ ប្រកបដោយ ភាពជាកម្លោះ ។ បទថា ***មណ្ឌនកជាតិកោ*** ចូលចិត្តតែងខ្លួន គឺ កំលោះ ក្រមុំ ក៏មិនខ្ជិលប្រអូសស្លូម្បីនិងមានសំពត់ និងរាងកាយសៅហ្មង ក៏នៅ ចូលចិត្តតែងខ្លួន ។ អធិប្បាយថា ងូតទឹកមួយថ្ងៃ ២-៣ ដង ហើយស្លៀក ដណ្តប់សំពត់ស្អាត និងតែងខ្លួន ។ បទថា ***សកណិកំ*** មុខមានប្រជ្រុយ គឺ មុខមានទោស ដោយទោសយ៉ាងណាមួយ មានអុជខ្មៅ ពកមូល មុខវៀច ជាដើម ។ ក្នុងបទនោះគប្បីជ្រាបថា កាលបុរសនោះឆ្លុះមើលស្រមោលមុខ

ទោសរបស់ផ្លែមុខរមែងប្រាកដ យ៉ាងណា កាលភិក្ខុអង្គុយកំណត់ចិត្តដោយចេតោបរិយញ្ញាណ ក៏ដូច្នោះ ចិត្ត ១៦ យ៉ាង របស់អ្នកដទៃរមែងប្រាកដ ។ បទដែលគួរពោលក្នុងឧបមានៃបុព្វេនិវាសញ្ញាណជាដើមទាំងអស់ លោកពោលទុកហើយក្នុងមហាអស្សបុរសូត្រ ។

[១១៦] បទថា *អយំ ខោ ឧទាយិ បញ្ចមោ ធម្មោ* ម្នាលឧទាយី នេះជាធម៌ប្រការទី ៥ គឺ លោកពោលធម៌ប្រការទី ៥ ធ្វើ ១៩ បទៈ ឲ្យជាធម៌ប្រការតែមួយដោយវត្តបដិបត្តិ ។ ដូចសេចក្តីថា លោកធ្វើ ១១ បទៈ ក្នុងអដ្ឋកនាគរសូត្រ ឲ្យជាធម៌ប្រការតែមួយ ដោយអំណាចជាពាក្យសួរ យ៉ាងណា គប្បីជ្រាបថា ១៩ បទៈក្នុងទីនេះ លោកធ្វើឲ្យជាធម៌ប្រការតែមួយដោយអំណាចការបដិបត្តិ យ៉ាងនោះ ។

គប្បីជ្រាបសាវកទាំងឡាយសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ក្នុងចំណែកទាំងឡាយ ៨ តាមលំដាប់ ក្នុងបណ្តាធម៌ ១៩ បទៈទាំងនេះ ក្នុងវិបស្សនាញាណ និងអាសវក្ខយញ្ញាណ ដោយអំណាចនៃព្រះអរហត្ត ។ ក្នុងបទដ៏សេសទាំងឡាយ គប្បីជ្រាបដោយអំណាចជាអ្នកមានភាពជំនាញដែលសន្សំមកហើយ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង

*ដោយប្រការដូច្នេះ ។*

" ចប់អដ្ឋកថា មហាត្រសុកុលុទាយិសូត្រទី ៧ "

# អ ដ្ឋ ក ថា

## សមណមុណ្ឌិកសូត្រទី ៨

[១១៧] *សមណមុណ្ឌិកសូត្រ មានបទចាប់ផ្ដើមថា ឯវំមេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា **ឧគ្គាហមានោ** បរិព្វាជកឈ្មោះថា ឧគ្គាហមានៈ ឈ្មោះពីដើមរបស់បរិព្វាជកនោះថា សុមនៈ តែព្រោះអាចរៀនវិទ្យាច្រើនយ៉ាង ជនទាំងឡាយទើបតាំងឈ្មោះថា ឧគ្គាហមានៈ ។ ឈ្មោះថា **សមយប្បវាទកេ** ព្រោះជាទីប្រជុំសម្ដែងលទ្ធិ ។ ន័យថា ក្នុងទីនោះ ពួកព្រាហ្មណ៍ផ្ដើមដោយបកិតារុក្ខព្រាហ្មណ៍ និងបោក្ខរសាតិព្រាហ្មណ៍ និគ្រន្ថ និងពួកបព្វជិត មានអចេល និងបរិព្វាជកជាដើម ប្រជុំ ប្រកាស សន្ទនាសម្ដែងលទ្ធិរបស់ខ្លួនៗ ព្រោះដូច្នោះ អារាមនោះទើបហៅថា សមយប្បវាទកៈ ទីប្រជុំសម្ដែងលទ្ធិ ។ សាលាឈ្មោះថា តិណ្ឌុកាចីរៈ ព្រោះហោមព័ទ្ធដោយជួរដើមទន្លាប់ ។ ក៏ព្រោះក្នុងទីនេះ មុនមានសាលាមួយខ្នង ។ ខាងក្រោយទើបសាងទុកច្រើនខ្នង ព្រោះអាស្រ័យបោដ្ឋបាទបរិព្វាជក អ្នក*

មានបុណ្យច្រើន ។ ដូច្នោះ ទើបហៅថា ឯកសាលកៈ ដោយបានឈ្មោះ តាមការសំដៅដល់សាលាមួយខ្នងនុ៎ះឯង ។ ឯកសាលកៈនោះ ជាសួនរបស់ព្រះរាជទេវីនៃព្រះបាទបសេនទិកោសល ព្រះនាមថា មល្លិកា ដេរដាស់ដោយផ្កាឈើ និងផ្លែឈើ ព្រោះធ្វើជាអារាម ទើបហៅថា អារាមរបស់ព្រះនាងមល្លិកា ។ ឧគ្គាហមានបរិព្វាជក អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាក្នុងតំបន់តិណ្ឌុកាចីរៈ ដែលជាទីប្រជុំសម្ដែងលទ្ធិនោះ នៅយ៉ាងសប្បាយ ។ បទថា **ទិវាទិវស្ស** ទាំងថ្ងៃ គឺ វេលាថ្ងៃត្រង់ ។ អធិប្បាយថា ឧគ្គាហមានបរិព្វាជក ចេញទៅក្នុងវេលាថ្ងៃត្រង់ ជាថ្ងៃរបស់ថ្ងៃនោះ ។ បទថា **បដិសល្លីនោ** ព្រះមានព្រះភាគទ្រង់ពួនសម្ងំនៅ គឺ ទ្រង់សង្រួមចិត្តពីអារម្មណ៍មានរូបជាដើមនោះៗ ពួនសម្ងំនៅតែមួយព្រះអង្គឯង ដោយទ្រង់ត្រេកអរក្នុងឈាន ។ បទថា **មនោភាវនីយានំ** គឺ អ្នកចម្រើនផ្លូវចិត្ត ។ សេចក្ដីប្រាសចាកនីវរណៈត្រឹមតែការគិត រមែងមានដល់ភិក្ខុដែលពិចារណា និងភិក្ខុអ្នកធ្វើមនសិការ ។ ចិត្តរមែងខ្ពស់ឡើង គឺ រមែងចម្រើន ។

[១១៨] បទថា **យាវតា** ប្រមាណប៉ុនណា ។

បទថា **អយំ តេសំ អញ្ញតរោ** ជាងឈើនេះជាសាវកម្នាក់ក្នុងបណ្ដា

សាវកទាំងនោះ គឺ ជាសាវកម្នាក់ក្នុងចំណោមសាវកទាំងនោះ ។ បទថា **អប្បេវ នាម** គឺ ឧគ្គាហមានបរិព្វាជក ត្រូវការឲ្យជាងឈើចូលទៅជិត ទើបពោល ។ ហេតុដែលត្រូវការនោះ លោកពោលទុកហើយក្នុងសន្ទកសូត្រ ។

**[១១៩]** បទថា **ឯតទវោច** ឧគ្គាហមានបរិព្វាជកបានពោលនឹងជាងឈើនោះ ។ ឧគ្គាហមានបរិព្វាជកសម្គាល់ថា គហបតីនេះ មានបញ្ញាទន់ខ្សោយ យើងនឹងសង្គ្រោះគេដោយធម្មកថា ហើយនឹងធ្វើឲ្យជាសាវករបស់ខ្លួន ទើបបានពោលពាក្យមានជាដើមថា **ចតូហិ ខោ** ដូច្នេះ ។

ក្នុងបទទាំងនោះបទថា **បញ្ញាបេមិ** យើងបញ្ញត្តិ គឺ យើងសម្តែងតាំងឡើង ។

បទថា **សម្បន្នកុសលំ** គឺ មានកុសលបរិបូណ៌ ។ បទថា **បរមកុសលំ** មានកុសលដ៏ខ្ពង់ខ្ពស់ គឺ មានកុសលឧត្តម ។ បទថា **អយោជ្ឈំ** មិនមានអ្នកណាច្បាំងបាន គឺ មិនមានអ្នកណាអាចច្បាំងដោយវាទៈឲ្យញាប់ញ័របាន ជាអ្នកមិនញាប់ញ័រ មិនកម្រើក រឹងមាំ ។ បទថា **ន ករោតិ** គឺ រមែងពោលត្រឹមតែមិនធ្វើប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងបទនេះ ឧគ្គាហមានបរិព្វាជក មិនពោលដល់ការលះដោយការសង្រួម ឬការពិចារណា ។

សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **នេវ អភិនន្ទតិ** មិនត្រេកអរ គឺ ជាងឈើសម្គាល់ថា ធម្មតាពួកតិរ្ច្ឆានទាំងឡាយ ដឹងខ្លះ មិនដឹងខ្លះ ទើបមិនត្រេកអរ ។

បទថា **នប្បដិក្កោសិ** មិនជំទាស់ គឺ ជាងឈើសម្គាល់ថា ឧគ្គាហមានបរិព្វាជក ពោលដូចបណ្តាយតាមសាសនា ហើយនាយជាងឈើធ្វើដូចជាអ្នកជ្រះថ្លាក្នុងសាសនា ទើបមិនជំទាស់ ។

បទថា **យថា ឧគ្គាហមានស្ស** ដូចជាពាក្យរបស់ឧគ្គាហមានបរិព្វាជក ។ ព្រះមានព្រះភាគសម្តែងថា តថាគតមិនពោលដូចពាក្យរបស់ឧគ្គាហមានបរិព្វាជកនោះ បើដូច្នោះ ក្មេងតូចដែលនៅដេកផ្ងារនឹងជាសមណៈដែលអ្នកណាច្បាំងមិនបាន នឹងជាសមណៈរឹងមាំ ។

[១២០] បទថា **កាយោតិបិ ន ហោតិ** សូម្បីត្រឹមតែដឹងថា កាយដូច្នេះ ក៏មិនទាន់មាន គឺ មិនមានសេចក្តីដឹងវិសេសថា កាយរបស់ខ្លួន ឬកាយរបស់អ្នកដទៃ ។ បទថា **អញ្ញត្រ ផន្ទិតមត្តា** វៀរលែងតែការបម្រះប៉ុណ្ណោះ គឺ រមែងមានត្រឹមតែកាយ ក្តៅក្រហាយដោយសម្ផស្ស រលើលើទីដេក ឬត្រូវសង្កើចខាំ ក្រៅអំពីនោះហើយ ក៏មិនមានការធ្វើតាមផ្លូវកាយ

យ៉ាងដទៃ ។ម្យ៉ាងទៀត កម្មនោះនឹងមានក៏ដោយចិត្តប្រកបដោយកិលេស ប៉ុណ្ណោះ ។ បទថា **វាចាតិបិ ន ហោតិ** សូម្បីដឹងថា វាចាដូច្នេះ ក៏មិនទាន់មាន គឺ នឹងដឹងសេចក្ដីផ្សេងគ្នាថា មិច្ឆាវាចា សម្មាវាចា ក៏មិនមាន ។ បទថា **រោទិតមត្តា** ក្រៅអំពីនេះ នឹងមានត្រឹមតែការស្រែកយំ គឺ នឹងមានត្រឹមតែការស្រែកយំរបស់ក្មេងតូចដែលស្រែកឃ្លាន និងក្ដៅក្រហាយ សូម្បីកម្មនោះនឹងមាន ក៏ព្រោះចិត្តប្រកបដោយកិលេសប៉ុណ្ណោះ ។ បទថា **សង្កប្បោ** គឺ នឹងដឹងសេចក្ដីផ្សេងថា មិច្ឆាសង្កប្បៈ សម្មាសង្កប្បៈ ក៏មិនមាន ។ បទថា **វិកុជិតមត្តា** ក្រៅពីដឹងត្រឹមតែការស្រែកយំ និងសើច គឺ ចិត្តរបស់ក្មេងតូច មានអារម្មណ៍ក្នុងអតីតប្រព្រឹត្តទៅ ។ ក្មេងតូចមកពីនរក រលឹកដល់ទុក្ខក្នុងនរក រមែងស្រែកយំ ។ មកពីទេវលោក រលឹកដល់សម្បត្តិក្នុងទេវលោក រមែងសើច ។ កម្មសូម្បីនោះ រមែងមានព្រោះចិត្តប្រកបដោយកិលេសប៉ុណ្ណោះ ។ បទថា **អាជីវោ** នឹងដឹងសេចក្ដីផ្សេងថា មិច្ឆាជីវៈ សម្មាជីវៈ ក៏មិនមាន ។

បទថា **អញ្ញត្រ មាតុំ** ក្រៅអំពីទឹកដោះរបស់មាតា ។ ក្មេងតូចទាំងនោះឈ្មោះថា នៅជាទារក កាលមាតាឲ្យផឹកទឹកដោះ ក៏មិនផឹក ក្នុង

វេលាដែលមាតាចាត់ចែងការងារដទៃ ខាងក្រោយមកនឹងផឹកទឹកដោះ ។ មិច្ឆាជីវៈយ៉ាងដទៃ ផុតពីនេះទៅក៏មិនមាន ។ លោកសម្តែងថា មិច្ឆាជីវៈនេះ រមែងមានព្រោះចិត្តប្រកបដោយកិលេសប៉ុណ្ណោះ ។

**[១២០]** ព្រះមានព្រះភាគ គ្រាទ្រង់បដិសេធវាទៈរបស់បរិព្វាជកយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ដាក់មាតិកាក្នុងសេក្ខភូមិដោយព្រះអង្គឯង ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **ចតូហិ ខោ អហំ** តថាគតបញ្ញត្តិបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការ ។ ក្នុងបទទាំងនោះ បទថា **សម-ធិគយ្ហ តិដ្ឋតិ** គឺ តាំងទុកដោយល្អ ។ ក្នុងបទមានជាដើមថា **ន កាយេន បាបំ** មិនធ្វើកម្មអាក្រក់ដោយកាយ គឺ មិនត្រឹមតែថា មិនធ្វើតែម្យ៉ាងប៉ុណ្ណោះ ។ តែព្រះមានព្រះភាគ ទ្រង់បញ្ញត្តិការលះដោយការសង្រួម និងការពិចារណាទុកក្នុងបទនេះផង ។ ទ្រង់សំដៅដល់ប្រការនោះ ទើបបានត្រាស់ទុក ។ ចំណែកបទមានជាដើមថា **ន ចេវ សម្បន្នកុសលំ** មិនមែនអ្នកមានកុសលសម្បូរណ៍ ត្រាស់សំដៅដល់ព្រះខីណាស្រព ។

**[១២២]** ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់មាតិកាក្នុងអសេក្ខភូមិ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **ទសហិ ខោ អហំ** តថាគត

បញ្ញត្តិបុគ្គលដែលប្រកបដោយធម៌ ១០ ប្រការ ។ ក្នុងបទនោះ អាស្រ័យ ៣ បទ ទ្រង់ត្រាស់ចតុក្កៈ ១ ទុក ២ បទ ។ អាស្រ័យបទ ១ ទ្រង់ត្រាស់ចតុក្កៈបុងក្រោយបង្អស់ទុក ២ បទ ។ នេះគឺ មាតិកាក្នុងអសេក្ខភូមិ ។

**[១២២]** ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ចែកមាតិកានោះ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **កតមេ ច ថបតិ អកុសលា សីលា** ម្នាលជាងឈើ ក៏សីលជាអកុសលនោះ ដូចម្តេច ? ។ ក្នុងបទទាំងនោះ បទថា **សរាគំ** មានរាគៈ គឺ ចិត្តប្រកបដោយលោភៈ ៨ យ៉ាង ។ បទថា **សទោសំ** មានទោសៈ គឺ ចិត្ត ២ ដួង សម្បយុត្តដោយបដិឃៈ ។

បទថា **សមោហំ** មានមោហៈ គឺ សូម្បីចិត្ត ២ ដួង ប្រកបដោយវិចិកិច្ឆា និងឧទ្ធច្ចៈក៏គួរ សូម្បីចិត្តដែលជាអកុសលទាំងអស់ក៏គួរ ។ ព្រោះលោកពោលទុកថា មោហៈ រមែងកើតក្នុងអកុសលទាំងពួង ។ បទថា **ឥតោសមុដ្ឋានា** ឈ្មោះថា ឥតោសមុដ្ឋាន ព្រោះមានសមុដ្ឋានកើតពីចិត្តមានរាគៈជាដើមនេះ ។ បទថា **កុហឹ** គឺ សីលដែលជាអកុសលរលត់មិននៅសល់ ព្រោះសម្រេចបាន:ណា ។ បទថា **ឯត្ថតេ** ក្នុងការលះទុច្ចរិតនេះ គឺ តាំងនៅក្នុងសោតាបត្តិផល ។ ពិតណាស់ បាតិមោក្ខសំវរសីល

រមែងបរិបូណ៌ក្នុងសោតាបត្តិផល ។ ដល់ឋានៈនោះ ហើយសីលជាអកុសល រលត់មិនមានសល់ ។ មយ៉ាងទៀត បទថា **អកុសលសីលំ** នេះ គប្បីជ្រាបថា ជាឈ្មោះរបស់បុគ្គលទ្រុស្តសីលខ្លះ ជាឈ្មោះរបស់ធម៌ដែលជាអកុ-សលខ្លះ ។ បទថា **និរោធាយប្បដិបន្នោ** បដិបត្តិដើម្បីសេចក្តីរលត់ គឺ បដិបត្តិដើម្បីសេចក្តីរលត់តាំងពីសោតាបត្តិមគ្គ ។ តែសីលដែលជាអកុសល ទាំងនោះ ឈ្មោះថា រមែងរលត់ដោយការសម្រេចព្រះអរហត្ត ។

**[១២៤]** ដោយបទ មានជាដើមថា **វីតរាគំ** ជាដើម លោកពោលដល់កាមាវចរកុសលចិត្ត ៨ យ៉ាង ។ ដោយបទនេះ សីលដែលជាកុសល រមែងតាំងឡើង ។ បទថា **សីលវា ហោតិ** ជាអ្នកមានសីល គឺ ជាអ្នកសម្បូរណ៍ដោយសីល និងសម្បូរណ៍ដោយគុណ ។ បទថា **សីលមយោ** សម្រេចដោយសីល គឺ មិនសម្រេចដោយសីលយ៉ាងនេះថា ត្រឹមតែប៉ុណ្ណេះក៏ល្មម ។ មិនមានវត្ថុណាៗ ដែលគួរនឹងធ្វើក្រៃលែងទៅជាងនេះ ។ បទថា **យត្ថស្ស តេ** ដែលជាទីរលត់អស់នៃសីលជាកុសលទាំងនោះ របស់ភិក្ខុនោះ គឺ តាំងនៅក្នុងអរហត្តផល ។ ព្រោះសីលដែលជាអកុសល រលត់មិនមានសល់ ព្រោះសម្រេចព្រះអរហត្តផល ។ បទថា **និរោធាយ បដិបន្នោ**

បដិបត្តិដើម្បីរលត់ គឺ ឈ្មោះថា បដិបត្តិដើម្បីរលត់តាំងពីអរហត្តមគ្គ ។ សីលដែលជាកុសលទាំងនោះ ឈ្មោះថា ជាការរលត់ ព្រោះការសម្រេចផល ។

**[១២៥]** ក្នុងកាមសញ្ញាជាដើម មានសេចក្តីដូចតទៅនេះ ៖

បទថា **កាមសញ្ញា** សញ្ញាក្នុងកាម គឺ សញ្ញាក្រៅពីនេះកើតរួមនឹងចិត្តដែលប្រកបដោយលោភៈ ៨ ដួង សញ្ញាដែលកើតរួមនឹងចិត្តប្រកបដោយទោមនស្ស ២ ដួង ។ បទថា **បឋមំ ឈានំ** បឋមជ្ឈាន គឺ បឋមជ្ឈានដែលជាអនាគាមិផល ។ បទថា **ឯត្ថេតេ** សេចក្តីត្រិះរិះជាអកុសលទាំងនេះ រលត់អស់ទៅក្នុងបឋមជ្ឈាន គឺ តាំងនៅក្នុងអនាគាមិផល ។ ព្រោះសេចក្តីត្រិះរិះជាអកុសល រមែងមិនមានសល់ ព្រោះការសម្រេចអនាគាមិផល ។ បទថា **និរោធាយ បដិបន្នោ** បដិបត្តិដើម្បីសេចក្តីរលត់ គឺ ឈ្មោះថា ជាអ្នកបដិបត្តិដើម្បីសេចក្តីរលត់តាំងពីអនាគាមិមគ្គ ។ តែសេចក្តីត្រិះរិះដែលជាអកុសលទាំងនោះ ឈ្មោះថា ជាការរលត់ដោយការសម្រេចផល ។ សញ្ញាសូម្បី ៣ មាននេក្ខម្មសញ្ញាជាដើម ជាសញ្ញាកើតរួមនឹងកាមាវចរកុសល ៨ ។

**[១២៦]** បទថា **ឯត្ថេតេ** សេចក្តីត្រិះរិះដែលជាកុសលទាំងនេះ រលត់មិនមានសល់ក្នុងទុតិយជ្ឈាននេះ គឺ ក្នុងអរហត្តផល ព្រោះថា សេចក្តីត្រិះរិះដែលជាកុសល រមែងរលត់មិនមានសល់ ព្រោះការសម្រេចអរហត្តផលដែលប្រកបដោយទុតិយជ្ឈាន ។ បទថា **និរោធាយ បដិបន្នោ** បដិបត្តិដើម្បីសេចក្តីរលត់ គឺ ឈ្មោះថា ជាអ្នកបដិបត្តិដើម្បីសេចក្តីរលត់ដរាបដល់អរហត្តមគ្គ ។ តែសេចក្តីត្រិះរិះដែលជាកុសលទាំងនោះ ឈ្មោះថា ជាការរលត់ដោយការសម្រេចផល ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងនោះឯង ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា សមណមុណ្ឌិកសូត្រទី ៨ "

# ៩. អ ដ្ឋ ក ថា

## ចូឡសកុលុទាយិសូត្រទី ៩

[១២៨] ចូឡសកុលុទាយិសូត្រ មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។

[១៣០] ក្នុងបណ្ដាបទទាំងនោះ បទថា យទា បន ភន្តេ ភគវា គឺ បរិព្វាជកប្រាថ្នានឹងស្ដាប់ធម្មកថានេះ កាលនឹងសម្ដែងសេចក្ដីអាល័យក្នុងព្រះធម៌ទេសនា ទើបពោលពាក្យនេះ ។ បទថា តំយេវេត្ថ បដិភាតុ បញ្ហាចូរប្រាកដដល់អ្នក សេចក្ដីថា បើអ្នកប្រាថ្នានឹងស្ដាប់ធម៌ បញ្ហាប្រការមួយ ហេតុមួយ ចូរប្រាកដដល់អ្នក ។

បទថា យថា មំ បដិភាសេយ្យ គឺ ជាហេតុដែលនឹងឲ្យធម៌ទេសនាប្រាកដដល់យើង ។ លោកសម្ដែងថា កាលកថាតាំងឡើងដោយហេតុនោះ ដើម្បីនឹងស្ដាប់ធម៌បានដោយសប្បាយ ។

[១៣១] បទថា តស្ស មយ្ហំ ភន្តេ ខ្ញុំព្រះអង្គកើតសតិ ប្រារព្ធព្រះមានព្រះភាគ សេចក្ដីថា ន័យថា សកុលុទាយិបរិព្វាជកនោះ ឃើញព្រះ

មានព្រះភាគ គិតថា បើព្រះមានព្រះភាគប្រថាប់នៅក្នុងទីនេះ សេចក្ដីនៃកាសិតនេះនឹងប្រាកដ ទើបរលឹកដល់ព្រះទសពលថា ព្រះទសពលទ្រង់នឹងធ្វើសេចក្ដីឲ្យប្រាកដ ដូចឲ្យប្រទីបពាន់ភ្លឺ ដូច្នោះ ។ ព្រោះដូច្នោះ សកុលុ-ទាយិបរិព្វាជក ទើបបានពោលពាក្យមានជាដើមថា **តស្ស មយ្ហំ ភន្តេ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អហោ នូន** ទាំងពីរបទ ជានិបាតចុះក្នុងសេចក្ដីថា ជាទីរលឹកដល់ ។ ដោយហេតុនោះ កាលសកុលុទាយិបរិព្វា-ជករលឹកដល់ ព្រះមានព្រះភាគ ទើបបានមានសេចក្ដីរលឹកថា **អហោ នូន ភគវា អហោ នូន សុគតោ** ឱមានតែព្រះមានព្រះភាគដោយពិត ឱមានតែព្រះសុគតដោយពិត ។

បទថា **យោ ឥមេសំ** សេចក្ដីថា ព្រះមានព្រះភាគព្រះអង្គណា ជាអ្នកឆ្លាត ឆ្លាតដោយល្អ ជំនាញ វាងវៃក្នុងធម៌ទាំងនេះ ព្រះមានព្រះភាគព្រះអង្គនោះ គប្បីទ្រង់ពោលដោយពិត ។ ព្រះសុគតព្រះអង្គនោះ គប្បីទ្រង់ពោលដោយពិត ។ ព្រោះកិលេស ជាហេតុនាំឲ្យកើតក្នុងភពទាំងឡាយតែម្យ៉ាងសែនកោដិនៃកប្បមិនតិច ប្រាកដដល់បុព្វេនិវាសញ្ញាណរបស់ព្រះមានព្រះភាគព្រះអង្គនោះ នេះជាអធិប្បាយក្នុងបទនេះ ដោយប្រការដូច្នេះ ។

**[១៣២]** *បទថា* ***តំ វាហំ បុព្វន្តំ អារព្ភ*** *ឬយើងគប្បីប្រារព្ធចំណែក អតីត សេចក្ដីថា ពិតណាស់ បុគ្គលណាជាអ្នកមានលាភ បុគ្គលនោះ កាល គេពោលថា កាលមុនលោកបានជាក្សត្រិយ៍ បានជាព្រាហ្មណ៍ កាលដឹងហើយ នឹងស្ដាប់ដោយគោរព ។ ចំណែកអ្នកមិនមានលាភ នឹងជាយ៉ាងនេះ នឹង ជាយ៉ាងនេះ ដូច្នេះខ្វះ គេរមែងសម្ដែងត្រឹមតែកម្មប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះថា តថាគតនឹងគប្បីញុំាងចិត្តរបស់អ្នក នោះឲ្យត្រេកអរបាន ដោយការព្យាករណ៍បញ្ហា ប្រារព្ធដល់ខន្ធចំណែកអតីត ដូច្នេះ ។*

*បទថា* ***សោ វា មំ អបរន្តំ*** *បុគ្គលនោះ គប្បីសួរបញ្ហាប្រារព្ធខន្ធ ចំណែកអនាគតចំពោះតថាគត គឺ ព្រោះអនាគតង្សញ្ញាណ រមែងសម្រេច ដល់អ្នកបានទិព្វចក្ខុ ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។ បទ ក្រៅពីនេះ មានន័យដូចបានពោលហើយក្នុងពេលមុន ។*

*បទថា* ***ធម្មំ វោ ទេសិស្សាមិ*** *តថាគតនឹងសម្ដែងធម៌ដល់អ្នកទាំង ឡាយ សេចក្ដីថា បានឮថា សកុលុទាយិបរិព្វាជកនេះ សូម្បីកាលសម្ដែង ដល់ខន្ធក្នុងអតីត ក៏មិនដឹង សូម្បីកាលសម្ដែងដល់ខន្ធក្នុងអនាគត ក៏មិនដឹង ។*

បើដូច្នោះ ព្រះមានព្រះភាគមានបំណងនឹងទ្រង់ សម្តែងដល់បច្ចយាការដែលល្អិតល្អន់ ទើបត្រាស់យ៉ាងនោះ ។ ក៏សកុលុទាយិនោះ នឹងដឹងខ្លួននោះបានឬ នឹងនៅមិនដឹងខ្លួននោះក្នុងពេលក្លាមនោះ តែនឹងជាបច្ច័យនៃវាសនារបស់គេក្នុងអនាគត ព្រះមានព្រះភាគទ្រង់ឃើញដូច្នេះ ទើបត្រាស់យ៉ាងនោះ ។ បទថា **បំសុបីសាចកំ** បីសាចធូលី គឺ បីសាចដែលកើតក្នុងទីមិនស្អាត ។

ព្រោះថា បីសាចនោះ កាន់យកឫសឈើមួយហើយ មិនប្រាកដកាយ ។ មានរឿងដំណាលថា យក្ខិណីម្នាក់ ឲ្យទារក ២ នាក់ អង្គុយត្រង់ទ្វារវត្តបុព្វារាម ហើយចូលទៅក្នុងក្រុងដើម្បីស្វែងរកអាហារ ។ ពួកក្មេងឃើញព្រះថេរៈកំពុងចេញបិណ្ឌបាតមួយរូប ទើបពោលថា លោកម្ចាស់ មាតារបស់ពួកយើង ចូលទៅខាងក្នុងព្រះនគរ បើលោកម្ចាស់ឃើញ ជួយប្រាប់ដល់មាតានោះ គាត់បានវត្ថុណា ចូរកាន់យកវត្ថុដែលបានហើយ ប្រញាប់ត្រឡប់ចេញមក ។ ពួកក្មេងទាំងនោះមិនអាចនៅរង់ចាំបាន ព្រោះសេចក្តីស្រេកឃ្លាន ។ ព្រះថេរៈសួរថា យើងនឹងឃើញមាតារបស់អ្នកឯងនោះបានយ៉ាងណា ។ ពួកក្មេងទើបពោលថា លោកម្ចាស់ ចូរកាន់យកឫសឈើ

នេះចុះ ហើយបានថ្វាយឫសឈើមួយចំណិត ។ យក្ខច្រើនពាន់បានប្រាកដដល់ព្រះថេរៈៗ បានឃើញយក្ខិណីនោះ ដោយសញ្ញាណដែលពួកក្មេងឲ្យទុក ។ ព្រះថេរៈឃើញយក្ខិណីមានរូបរាងគួរខ្ពើម គួរខ្លាច ប្រាថ្នារកតែរបស់ស្មោកគ្រោកត្រង់ថ្ពាល់តែម្យ៉ាង ទើបពោលសេចក្តីនេះ កាលយក្ខិណីសួរថា លោកឃើញខ្ញុំព្រះករុណាបានយ៉ាងណា ព្រះថេរៈទើបសម្តែងចំណិតឫសឈើឲ្យមើល ។ យក្ខិណីដណ្តើមឫសឈើកាន់យកទៅ ។ បិសាចធូលីទាំងឡាយ កាន់ឫសឈើមួយហើយ មិនប្រាកដកាយដោយប្រការដូច្នេះ ។ សកុលុទាយិបរិព្វាជកនោះពោលថា សូម្បីបិសាច ខ្ញុំព្រះអង្គមិនទាន់ឃើញឡើយ សំដៅដល់យក្ខិណីនោះ ។ បទថា **ន បក្ខាយតិ** គឺ មិនឃើញប្រាកដ ។

**[១៣៤]** បទថា **ទីឃាបិ ខោ តេ ឯសា** សេចក្តីថា ម្នាលឧទាយី វាចារបស់អ្នកនោះផ្សាយទៅឆ្ងាយពេកណាស់ ។

អធិប្បាយថា កាលពោលយ៉ាងនោះ គប្បីប្រព្រឹត្តទៅមួយរយឆ្នាំខ្លះ ពាន់ឆ្នាំខ្លះ និងវាចានោះ ក៏មិនគប្បីសម្តែងដើម្បីបានប្រយោជន៍ឡើយ ។ បទថា **អប្បាដិហិរីកតំ** ជាពាក្យប្រើមិនបាន សេចក្តីថា ពាក្យនោះដល់សេចក្តី

ជាពាក្យមិននាំសត្វចេញទៅ មិនមានតម្លៃ មិនមានប្រយោជន៍ ។ ឥឡូវនេះ កាលសកុលុទាយិបរិព្វាជកនឹងសម្តែងដល់វណ្ណៈនោះ ទើបពោលពាក្យមានជាដើមថា **សេយ្យថាបិ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបប្រដូចកែវពិទូរ្យ ។ ក្នុងបទទាំងនោះ បទថា **បណ្ឌុកម្ពលេនិក្ខិត្តោ** កែវពិទូរ្យគេដាក់ទុកលើសំពត់កម្ពលពណ៌ក្រហម គឺ ដាក់ទុកត្រង់សំពត់កម្ពលពណ៌ក្រហម ដែលមានពណ៌មិនស្មើគ្នា ។ បទថា **ឯវំ វណ្ណោ អត្តា ហោតិ** ខ្លួនក៏មានវណ្ណៈដូច្នោះ សកុលុទាយិពោលពាក្យនេះថា អត្តភាពនោះ ក្នុងវេលាយើងស្លាប់ រមែងរុងរឿងដូចខ្លួនក្នុងសុភកិណ្ហទេវលោក លោកសំដៅដល់ខ្លួនដែលកើតក្នុងសុភកិណ្ហទេវលោក ។

**[១៣៥]** បទថា **អយំ ឥមេសំ ឧភិន្នំ** បណ្តាពន្លឺទាំងពីរនេះ អំពិល-អំពែកក្នុងវេលាខែងងឹត ក្នុងរាត្រីល្អជាង ប្រណីតជាង សេចក្តីថា រស្មីរបស់កែវមណីមិនផ្សាយចេញខាងក្រៅ ពន្លឺរបស់អំពិលអំពែកមានខ្លួនតូចផ្សាយចេញទៅត្រឹមតែ ១ ធ្នាប់ ២ ធ្នាប់ និង ៤ ធ្នាប់ ចំណែកពន្លឺរបស់អំពិលអំពែកមានខ្លួនធំ ផ្សាយចេញទៅសូម្បីប្រមាណប៉ុនបរិវេណរបស់លានបញ្ជាន់ស្រូវ ព្រោះដូច្នោះ សកុលុទាយិ ទើបពោលយ៉ាងនោះ ។

**[១៣៩]** បទថា **វិទ្ធេ** គឺ ភ្លឺច្បាស់ អធិប្បាយថា នៅឆ្ងាយ ដោយប្រាសចាកពពក ។ បទថា **វិគតវលាហកេ** គឺ ប្រាសចាកពពក ។

បទថា **ទេវេ** គឺ ភ្លៀង ។ បទថា **ឱសធិតារកា** គឺ ផ្កាយព្រឹក ។ ពិតហើយ ព្រោះអាចារ្យពួកខ្លះប្រាប់ពោលថា ជនទាំងឡាយកាន់យកឱសថដោយសញ្ញាណនោះ តាំងពីផ្កាយព្រឹករះឡើង ដូច្នោះ ផ្កាយនោះលោកទើបហៅថា **ឱសធិតារកា** ។ បទថា **អភិទោអឌ្ឍរត្តសមយំ** គឺ ព្រះចន្ទក្នុងវេលាកណ្តាលយប់ ។ ដោយបទនេះ លោកសម្តែងដល់ព្រះចន្ទ ដែលតាំងនៅក្នុងសម័យ គឺ ត្រង់កណ្តាលផ្ទៃអាកាស ។

**[១៤០]** សូម្បីក្នុងបទថា **អភិទោ មជ្ឈន្តិកេ** ព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ ក៏មានន័យនេះដូចគ្នា ។ បទថា **តតោ ភេវា** គឺ ទេវតាទាំងនោះមានច្រើនជាងនោះ ។ អធិប្បាយថា មានច្រើន និងមានច្រើនជាង ។ បទថា **អាភានានុភោន្តិ** គឺ ស៊ូនឹងពន្លឺព្រះចន្ទព្រះអាទិត្យមិនបាន ។ ពន្លឺព្រះចន្ទនិងព្រះអាទិត្យ រមែងក្លឺស្វាងទៅដោយពន្លឺក្នុងខ្លួននៃខ្លួនឯង ។

**[១៤១]** ឥឡូវនេះ ព្រោះសកុលុទាយិ គិតថា យើងនឹងសួរដល់លោកមានសេចក្តីសុខដោយចំណែកមួយ ទើបអង្គុយស្ងៀម ភ្លេចពាក្យសួរ ។

ដូច្នោះ ព្រះមានព្រះភាគ កាលទឹងទ្រង់ឲ្យសកុលុទាយិរលឹកដល់ពាក្យសួរបាន ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **កឹ បន ឧទាយិ អត្ថិ ឯកន្ត-សុខោ លោកោ** ម្នាលឧទាយី លោកមានសេចក្តីសុខដោយចំណែកមួយមែនឬ ។ ក្នុងបទទាំងនោះ បទថា **អាការវតី** គឺ មានហេតុ ។ បទថា **អញ្ញតរំ វា បន តបោគុណំ** គុណា គឺ តបៈណាមួយ ព្រះមានព្រះភាគត្រាស់សំដៅដល់លទ្ធិរបស់អចេលកៈ គឺ វៀរការផឹកសុរា ។ ព្រោះហេតុអ្វីសកុលុទាយិ ទើបសួរថា បពិត្រព្រះអង្គដ៏ចម្រើន លោកមានសេចក្តីសុខដោយចំណែកតែមួយមែនឬ ។ ន័យថា សកុលុទាយិនោះ បានគិតថាសូម្បីយើងក៏ពោលថា ខ្លួនមានសេចក្តីសុខដោយចំណែកតែមួយ ។

ម្យ៉ាងទៀត យើងពោលការបដិបត្តិជាសុខវេលាខ្លះ ជាទុក្ខវេលាខ្លះ ។ សូម្បីបដិបទារបស់ខ្លួន អ្នកមានសេចក្តីសុខដោយចំណែកមួយ ក៏គប្បីមានសេចក្តីសុខដោយចំណែកមួយ ។ កថារបស់ពួកយើងជាកថាមិននាំសត្វចេញទៅ ។ ចំណែកកថារបស់ព្រះសាស្តា ជាកថានាំសត្វចេញទៅព្រោះហេតុនោះ ឥឡូវនេះ យើងនឹងសួរព្រះសាស្តា ទើបនឹងដឹង ព្រោះដូច្នោះ ព្រះថេរៈទើបសួរ ។

**[១៨៤]** បទថា **ឯត្ថ មយំ អនស្សាម** គឺ ពួកយើងមិនត្រេកអរក្នុងហេតុនេះ ព្រោះហេតុអ្វី បរិស័ទរបស់សកុលុទាយិបរិព្វាជក ទើបបានពោលយ៉ាងនោះ ។ ន័យថា បរិស័ទរបស់សកុលុទាយិបរិព្វាជកទាំងនោះ ដឹងថាកាលមុនពួកខ្លួនតាំងនៅក្នុងធម៌ ៥ ប្រការ ធ្វើកសិណបរិកម្ម ញ៉ាំងតតិយជ្ឈានឲ្យកើត លុះឈានមិនទាន់វិនាស ធ្វើកាលៈហើយទៅកើតក្នុងជាន់សុភកិណ្ហៈ តែកាលកាលកន្លងទៅៗ សូម្បីកសិណបរិកម្មក៏មិនដឹង ។ សូម្បីតតិយជ្ឈានក៏មិនអាចឲ្យកើតបាន ។ មួយ៉ាងទៀត ពួកគេរៀនធម៌ ដែលជាចំណែកខាងដើម ៥ ថា បដិបទាមានហេតុ ។ ហើយរៀនតតិយជ្ឈានថាលោកមានសុខដោយចំណែកមួយ ។ ព្រោះដូច្នោះ ពួកគេទើបពោលយ៉ាងនោះ ។ បទថា **ឧត្តរិតរំ** គឺ វត្ថុដ៏ក្រៃលែងជាងធម៌ ៥ នេះ ។ លោកអធិប្បាយថា ពួកយើងមិនដឹងបដិបទា ឬលោកដែលជាសុខដោយចំណែកមួយក្រៃលែងជាងតតិយជ្ឈាន ។ បទថា **អប្បសទ្ទេ កត្វា** គឺ ហាមបរិព្វាជកទាំងនោះ ដែលផ្តើមនឹងធ្វើសំឡេងខ្លាំងមិនឲ្យមាន ដោយការជាស់តឿនតែមួយដងប៉ុណ្ណោះ ។

**[១៨៥]** ក្នុងបទថា **សច្ឆិកិរិយាហេតុ** ព្រោះហេតុធ្វើឲ្យច្បាស់នេះ ។

សច្ចិកិរិយាមាន ២ យ៉ាងគឺ បដិលាភសច្ចិកិរិយា (ការធ្វើឲ្យច្បាស់ការបាន) ១ បច្ចក្ខសច្ចិកិរិយា (ការធ្វើឲ្យជាក់ច្បាស់) ១ ។ ក្នុងសច្ចិកិរិយា ២ យ៉ាងនោះ អ្នកញុំាងតតិយជ្ឈានឲ្យកើតហើយ តតិយជ្ឈានមិនទាន់វិនាសធ្វើកាលៈទៅកើតជាអ្នកមានអាយុ និងវណ្ណស្មើទេវតាទាំងនោះ ក្នុងសុភកិណ្ហលោក នេះឈ្មោះថា **បដិលាភសច្ចិកិរិយា** ។ អ្នកញុំាងចតុត្ថជ្ឈានឲ្យកើត ទៅកាន់សុភកិណ្ហលោក ដោយការសម្តែងឫទ្ធិហើយតាំងនៅ សន្ទនាប្រាស្រ័យនឹងទេវតាទាំងនោះ នេះឈ្មោះថា **បច្ចក្ខសច្ចិកិរិយា** តតិយជ្ឈានរបស់សច្ចិកិរិយាសូម្បីទាំងពីរនោះ ឈ្មោះថា **អាការវតីបដិបទា** បដិបទាមានហេតុ មិនញុំាងតតិយជ្ឈានឲ្យកើត ក៏មិនអាចកើតក្នុងសុភកិណ្ហលោកបាន (និង) មិនអាចញុំាងចតុត្ថជ្ឈានឲ្យកើតបាន ។ សកុលុទាយិសំដៅដល់សច្ចិកិរិយាទាំងពីរនេះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុធ្វើឲ្យច្បាស់លោកមានសុខដោយចំណែកតែមួយនោះពិតប្រាកដ ។

**[១៤៥]** បទថា **ឧទកមណិកោ** គឺ ថ្លាំងទឹក ។ បទថា **វន្តរាយម-កាសិ** បរិស័ទរបស់សកុលុទាយិបានធ្វើអន្តរាយ គឺ បានធ្វើអន្តរាយដោយដល់សកុលុទាយិបរិព្វាជកមិនបានបព្វជ្ជា ព្រោះឧបនិស្សយវិបត្តិ ។

បានឮថា សកុលុទាយិបរិព្វាជកនេះ បានបួសក្នុងសាសនារបស់ព្រះពុទ្ធកស្សប បានបំពេញសមណធម៌ ។ គ្រានោះភិក្ខុសម្លាញ់របស់គេម្នាក់ពោលថា អាវុសោ ខ្ញុំធុញក្នុងព្រះសាសនាបានសឹកចេញ ។ ភិក្ខុនោះកើតសេចក្ដីលោភក្នុងបាត្រ និងចីវររបស់ភិក្ខុដែលជាសម្លាញ់នោះ ទើបបានពោលដល់គុណរបស់ការនៅជាគ្រហស្ថ ។ ភិក្ខុសម្លាញ់ទើបឲ្យបាត្រនិងចីវរដល់ភិក្ខុនោះ ហើយក៏សឹក ។ ដោយកម្មរបស់ភិក្ខុនោះ ឥឡូវនេះទើបកើតអន្តរាយចំពោះការបព្វជ្ជាចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ។ សូត្រមុនរបស់ព្រះមានព្រះភាគ ត្រឹមតែជាកាណវារៈដែលលើស ។ សូត្រនេះជាភាណវារៈគោល ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់ធម៌ដោយបែបផែនត្រឹមតែប៉ុណ្ណេះ ។ ការសម្រេចមគ្គផលមិនកើតសូម្បីដោយទេសនាតែម្ដង ។ តែនឹងជាបច្ច័យដល់ភិក្ខុនោះក្នុងអនាគត ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់ទើបសម្ដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ឃើញធម៌នោះនឹងជាបច្ច័យក្នុងអនាគតកាលនៅមានព្រះជន្ម ទើបទ្រង់មិនតែងតាំងភិក្ខុសូម្បីមួយរូប ទុកក្នុងឯតទគ្គៈក្នុងមេត្តាវិហារី (មានធម៌ជាគ្រឿងនៅ គឺ មេត្តា) ។

ព្រះមានព្រះភាគទ្រង់ឃើញថា ក្នុងអនាគតភិក្ខុនេះ នឹងបួសក្នុងសាសនារបស់យើង ហើយនឹងជាអ្នកប្រសើរជាងភិក្ខុខាងមេត្តាវិហារី ។ ភិក្ខុនោះ កាលព្រះមានព្រះភាគបរិនិព្វានហើយ កើតក្នុងក្រុងបាតលីបុត្តក្នុងសម័យរបស់ព្រះបាទធម្មាសោករាជ ហើយបួស លុះបួសហើយ បានសម្រេចព្រះអរហត្ត មានឈ្មោះថា ព្រះអស្សគុត្តត្ថេរបានជាអ្នកកំពូលលើសភិក្ខុខាងជាមេត្តាវិហារី ។ ដោយអានុភាពនៃមេត្តារបស់ព្រះថេរៈ សូម្បីសត្វតិរច្ឆានទាំងឡាយ ក៏បានទទួលមេត្តាចិត្ត ។ ព្រះថេរៈជាអាចារ្យប្រៀនប្រដៅភិក្ខុសង្ឃក្នុងសកលជម្ពូទ្វីប អាស្រ័យនៅត្រង់ វត្ត និងសេនាសនៈ ។ ព្រៃប្រមាណ ៣០ យោជន៍ បានជាផ្ទះសម្រាប់ធ្វើសចក្តីព្យាយាមតែម្យ៉ាង ។ ព្រះថេរៈ ក្រាលផ្ទាំងស្បែកទុកលើអាកាសហើយ អង្គុយលើផ្ទាំងស្បែកនោះ ប្រាប់កម្មដ្ឋាន ។ កាលកន្លងទៅ ព្រះថេរៈមិនទៅបិណ្ឌបាត អង្គុយប្រាប់កម្មដ្ឋាននៅក្នុងវិហារ ។ មនុស្សទាំងឡាយទៅកាន់វិហារ បានថ្វាយទាន ។ ព្រះបាទធម្មាសោករាជ បានស្តាប់គុណរបស់ព្រះថេរៈ មានបំណងនឹងឃើញ ទ្រង់បានបញ្ជូនមនុស្សឲ្យទៅនិមន្តរហូត ៣ ដង ។ ព្រះថេរៈគិតថា យើងនឹងឲ្យឱវាទដល់ភិក្ខុសង្ឃ ដូច្នេះហើយទើបមិនបានទៅ សូម្បីតែ

ម្តង ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា ចូឡសកុលុទាយិសូត្រទី ៩ "

# អ ដ្ឋ ក ថា

## វេខណសសូត្រទី ១០

**[១៥០]** *វេខណសសូត្រ* មានបទចាប់ផ្តើមថា *ឯវមេ្វ សុតំ* ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះ បទថា *វេខណសោ* បានឮថា វេខណសបរិព្វាជកនេះ ជាអាចារ្យរបស់សកុលុទាយិបរិព្វាជក ។ វេខណសបរិព្វាជកនោះ បានឮថា សកុលុទាយិបរិព្វាជក បរាជ័យបញ្ហាមានវណ្ណយ៉ាងក្រៃលែង ទើបគិតថា សកុលុទាយិនោះ យើងឲ្យរៀនយ៉ាងល្អហើយ សូម្បីសកុលុទាយិក៏រៀនបានល្អ គេបរាជ័យបានយ៉ាងណាហ្ន៎ ណ្ហើយចុះ យើងនឹងទៅដោយខ្លួនឯង ទូលសួរបញ្ហាមានវណ្ណក្រៃលែងចំពោះព្រះសមណគោតម ទើបដឹងបាន ។ ទើបទៅកាន់ក្រុងសាវត្ថី ប្រមាណ ៤៥ យោជន៍អំពីក្រុងរាជគ្រឹះ ហើយចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ឈរបន្ទឹឧទានក្នុងសម្នាក់ព្រះមានព្រះភាគ ។

**[១៥១]** ក្នុងបទនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ដូចនឹង

សូត្រមុនទុំះឯង ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់ទើប ផ្ដើមថា **បញ្ច ខោ ឥមេ** កាមគុណ ៥ ទាំងនេះ ។ បុគ្គលខ្លះសូម្បីនៅគ្រប់គ្រងផ្ទះ ក៏ជាអ្នកជូន់ក្នុងកាម បង្អោនទៅក្នុងកាម ។ បុគ្គលខ្លះជាអ្នកជូន់ក្នុងនេក្ខម្មៈ បង្អោនទៅក្នុងនេក្ខម្មៈ ម្យ៉ាងទៀត បុគ្គលខ្លះជាបព្វជិត ជាអ្នកជូន់ក្នុងកាម បង្អោនទៅក្នុងកាម ។ បុគ្គលខ្លះជាអ្នកជូន់ក្នុងនេក្ខម្មៈ បង្អោនទៅក្នុងនេក្ខម្មៈ ។ បុគ្គលនេះឈ្មោះថា ជាអ្នកជូន់ក្នុងកាម បុគ្គលនោះកាលគេពោលកថានេះ នឹងកំណត់សេចក្ដីដែលខ្លួនបង្អោនទៅក្នុងកាម ទេសនានេះ នឹងជាទីសប្បាយនៃបុគ្គលនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ផ្ដើមទេសនានេះ ។ បទថា **កាមគ្គសុខំ** សុខជាទីបំផុតរបស់កាម លោកបំណងយកនិព្វាន ។

**[១៦១]** បទថា **បាបិតោ ភវិស្សតិ** នឹងឲ្យព្រះសមណគោតម បានទទួលសេចក្ដីវិនាស គឺ នឹងឲ្យដល់ភាពវង្វេង ។ បទថា **លាមកំយេវ សម្បជ្ជតិ** ដល់សភាពជាធម៌ថ្នាក់ទាប គឺ ដល់ភាពជាធម៌ត្រឹមតែពាក្យនិយាយដែលគ្មានប្រយោជន៍ទុំះឯង ។

**[១៦២]** បទថា **តិដ្ឋតុ បុព្វន្តោ តិដ្ឋតុ អបរន្តោ** ចំណុចខាងដើមចូរលើកទុកចុះ ចំណុចខាងចុងចូរលើកទុកចុះ ។ ព្រោះបុព្វេនិវាសញ្ញាណ

ដែលសមគួរដល់កថាក្នុងអតីតរបស់លោកមិនមាន ។ ទិព្វចក្ខុញ្ញាណ ដែលសមគួរដល់កថាក្នុងអនាគតក៏មិនមាន ។ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា សូម្បីទាំងពីរយ៉ាងនោះក៏ចូរលើកទុកចុះ ។ បទថា **សុត្តពន្ធនេហិ** គឺដោយគ្រឿងចងធ្វើដោយអំបោះ គឺ គេចងអំបោះទុកត្រង់ដៃជើង និងត្រង់កដើម្បីថែរក្សាទារកនោះ ។ គ្រឿងចងនេះ លោកសំដៅដល់អំបោះនោះ ។ តែកាលធំឡើង គ្រឿងចងទាំងនោះពុកផុយនឹងរបូតទៅឯង ឬកាត់ចេញទៅ ។ ព្រះមានព្រះភាគទ្រង់សម្តែងបទនេះ ដោយបទថា **ឯវមេវ ខោ** ដូច្នេះ ។ ការមិនដឹងទីបំផុតខាងដើមនៃអវិជ្ជា ដូចកាលនៅជាក្មេងតូច មិនដឹងគ្រឿងចងធ្វើដោយអំបោះ ដូច្នោះ ។ ព្រោះមិនអាចដឹងទីបំផុតនៃអវិជ្ជាបាន ។ តែការដឹងថា ការរួចផុតពីគ្រឿងចង គឺ អវិជ្ជា ដោយអរហត្តមគ្គ ដូចជាការដឹងក្នុងវេលារួចផុត ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងនោះឯង ដោយប្រការដូច្នេះ ។

“ ចប់អដ្ឋកថា វេខណសសូត្រទី ១០ ”

## ចប់បរិព្វាជកវគ្គទី ៣

## រួមក្នុងវគ្គនេះ មាន ១០ សូត្រ គឺ៖

១-ចូឡវច្ឆគោត្តសូត្រ
២-អគ្គិវច្ឆគោត្តសូត្រ
៣-មហាវច្ឆគោត្តសូត្រ
៤-ទីឃនខសូត្រ
៥-មាគណ្ឌិយសូត្រ
៦-សន្ទកសូត្រ
៧-មហាសកុលុទាយិសូត្រ
៨-សមណមុណ្ឌិកសូត្រ
៩-ចូឡសកុលុទាយិសូត្រ
១០-វេខណសសូត្រ

# រាជវគ្គ

## អ ដ្ឋ ក ថា

## ឃដិការសូត្រទី ១

[១៦៤] ឃដិការសូត្រ មានពាក្យផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឃដិការសូត្រនោះ ដូចតទៅនេះ ៖

បទថា **សិតំ បាត្វាកាសិ** ទ្រង់ធ្វើការញញឹមឲ្យប្រាកដ សេចក្តីថា ព្រះមានព្រះភាគទ្រង់ដំណើរទៅដោយមហាមគ្គា ទ្រង់ក្រឡេកមើលប្រទេសមួយកន្លែង ហើយទ្រង់រំពឹងថា កាលយើងប្រព្រឹត្តចរិយា ធ្លាប់នៅក្នុងទីនេះខ្លះឬទេហ្ន៎ ដូច្នេះ ទ្រង់ឃើញថា កាលសាសនារបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ ទីនេះជានិគមឈ្មោះថា វេកលិ្គៈ[១] ក្នុងកាលនោះ យើងជាមាណពឈ្មោះ ជោតិបាល តថាគតមានសម្លាញ់ជាអ្នកស្នូនឆ្នាំងឈ្មោះ ឃដិការ តថាគតនឹងនាយឃដិការនោះ បានធ្វើហេតុដ៏ល្អទុកមួយយ៉ាងក្នុងទីនេះ សេចក្តីល្អ

---

១-កូមា.វេគលិន្គៈ ស្យាម.វេហលិន្គៈ

នោះនៅបិទបាំង នៅមិនទាន់ប្រាកដដល់ភិក្ខុសង្ឃ ណ្ហើយចុះ តថាគតនឹងធ្វើរឿងនោះឲ្យប្រាកដដល់ភិក្ខុសង្ឃ ទ្រង់ត្រិះរិះដូច្នេះហើយ ទ្រង់ចេញចាកផ្លូវ ប្រថាប់ឈរនៅក្នុងប្រទេសមួយ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនញញឹមសប្បាយ ដូចពួកមនុស្សអ្នកលោកិយ៍រមែងទះពោះសើចថា ទីណា ទីណា ដូច្នេះ ។ ចំណែកការញញឹមរបស់ព្រះពុទ្ធទាំងឡាយ ប្រាកដត្រឹមតែអាការដោយសោមនស្សញ្ញាណ ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការសើចនោះ មានដោយចិត្តដែលកើតព្រមដោយសោមនស្ស ១៣ ដួង ។ ក្នុងបណ្ដាចិត្តទាំងនោះ បុថុជ្ជនរមែងសើចដោយចិត្ត ៨ ដួង គឺ ដោយអកុសលចិត្ត ៤ ដួង ដោយកាមាវចរកុសលចិត្ត ៤ ដួង ។ ព្រះសេក្ខបុគ្គលរមែងសើចដោយចិត្ត ៦ ដួង វៀរចិត្តដែលសម្បយុត្តដោយទិដ្ឋិចំណែកអកុសល ២ ដួងចេញ ។ ព្រះខីណាស្រព រមែងញញឹមដោយចិត្ត ៥ ដួង គឺ ដោយកិរិយាចិត្តដែលជាសហេតុកៈ ៤ ដួង ដោយកិរិយាចិត្តដែលជាអហេតុកៈ ១ ដួង ។ សូម្បីក្នុងចិត្តទាំងនោះ កាលអារម្មណ៍មានកម្លាំងមកប្រាកដ រមែងញញឹមដោយចិត្តដែលសម្បយុត្តដោយញាណ ២ ដួង ។ កាលអារម្មណ៍ទុព្វលមកប្រាកដ រមែងញញឹមរីករាយដោយចិត្ត ៣

ដួង គឺ ដោយទុហេតុកៈ ២ ដួង ដោយអហេតុកៈ ១ ដួង ។ តែក្នុងទីនេះ ចិត្តដែលកើតព្រមដោយសោមនស្ស ដែលជាមនោវិញ្ញាណធាតុ ជាចំណែក កិរិយាអហេតុកចិត្ត ធ្វើឲ្យការញញឹម ដែលជាអាការត្រេកអរកើតពីភវង្គ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការញញឹមនោះ សូម្បីមានប្រមាណតិចតួចយ៉ាងនេះ ក៏បានប្រាកដដល់ព្រះថេរៈ ។ សួរថា ប្រាកដយ៉ាងណា ។ ឆ្លើយថា ធម្មតា ក្នុងកាលនោះ រស្មីមានប្រមាណប៉ុនដើមត្នោតដ៏ធំវិលជុំវិញ រុងរឿង ចេញ ពន្លឺដូចផ្ទេកបន្ទោរ ១០០ អំពីព្រះឱស្ឋ ដូចជាមហាមេឃដែលនឹងញុំាងភ្លៀង ឲ្យធ្លាក់ក្នុងទ្វីបទាំង ៤ តាំងឡើងអំពីព្រះចង្កូមកែវទាំង ៤ ធ្វើប្រទក្សិណ ព្រះសិរសាដ៏ប្រសើរ ៣ ជុំវិញ ហើយក៏អន្តរធានបាត់ទៅត្រង់ចុងព្រះចង្កូម កែវនុ៎ះឯង ។ ព្រោះហេតុនោះ ព្រះអានន្ទសូម្បីនឹងដើរតាមក្រោយព្រះ-មានព្រះភាគ ក៏ជ្រាបដល់ការញញឹម ដោយសញ្ញានោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ភគវន្តំ ឯតទវោច** នេះ ដូចតទៅ នេះ ៖

ន័យថា ព្រះអានន្ទ គិតថា ព្រះមានព្រះភាគព្រះនាមថា កស្សបៈ

ទ្រង់រមែងឲ្យឱវាទភិក្ខុសង្ឃ ទ្រង់ធ្វើការប្រកាសសច្ចធម៌ទាំង ៤ យើងនឹងឲ្យព្រះមានព្រះភាគពេញព្រះទ័យប្រថាប់អង្គុយក្នុងទីនេះ ភូមិភាគនេះ នឹងមានព្រះពុទ្ធដល់ពីរព្រះអង្គទ្រង់ប្រើប្រាស់ មហាជននឹងបូជា ដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម និងធ្វើចេតិយស្ថានដើម្បីបម្រើរក្សា ក៏នឹងមានសួគ៌ជាទីទៅក្នុងខាងមុខ ដូច្នេះហើយ ទើបបានក្រាបទូលពាក្យថា បើយ៉ាងនោះ សូមព្រះមានព្រះភាគ ដូច្នេះជាដើម ។

**[១៦៥]** បទថា **មុណ្ឌកេន សមណកេន** សេចក្តីថា នឹងហៅមនុស្សក្បាលត្រងោលថា មនុស្សត្រងោល ឬហៅសមណៈថា សមណៈ រមែងសមគួរ ។ ក៏ឯជោតិបាលនេះ ធុញទ្រាន់ដោយវោហារដែលខ្លួនរៀនហើយក្នុងព្រាហ្មណត្រកូល ព្រោះមានញាណមិនទាន់ចាស់ក្លា ទើបពោលដូច្នោះ ។ បទថា **សោត្តិសិនានំ** បានដល់ មេ្សាលម្អិតធ្វើទុកសម្រាប់ងូតទឹក ។ ដែលយកលម្អិតថ្មពណ៌ដូចត្បូងក្រហម និងអំបោះធ្វើហើយ លោកហៅថា គ្រឿងលម្អិត ។ ដែលលោកសំដៅយក ពោលទុកថា **តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កុរុវិន្ទិយសុត្តិកាយ នហាយន្តិ** ក៏គ្រានោះឯង ភិក្ខុឆព្វគ្គិយងូតទឹកដោយដុំលម្អិតថ្ម ។ សម្ភារៈទាំងពីរនោះ កាន់យកដុំលម្អិតថ្មក្រហម

សម្រាប់ជុសខ្លួននោះ ទៅជុសខ្លួន ។ បទថា **ឯវំ សម្ម** សេចក្ដីថា សូម្បី ក្នុងបច្ចុប្បន្ននេះ ពួកមនុស្ស មានអ្នកណាបបួលថា ពួកយើងទៅសំពះព្រះ ចេតិយ ទៅស្ដាប់ធម៌ជាមួយគ្នាចុះ នឹងមិនធ្វើសេចក្ដីឧស្សាហ៍ តែបើអ្នក ណាៗ បបួលថា ពួកយើងទៅមើលការរាំច្រៀងជាដើមជាមួយគ្នា ដូច្នេះ នឹងទទួលពាក្យដោយការបបួលត្រឹមតែម្ដង យ៉ាងណា ជោតិបាលក៏ដូច្នោះ ដែរ កាលយជិការបបួលថា ទៅងូតទឹកជាមួយគ្នា ក៏ទទួលពាក្យដោយការ បបួលតែម្ដង ទើបធ្វើយទៅដូច្នោះ ។

**[១៦៨]** បទថា **ជោតិបាលំ មាណវំ អាមន្តេសិ** សេចក្ដីថា យជិការ អ្នកខ្លាំង ងូតទឹកដោយការបរិហារយ៉ាងល្អត្រង់ម្ខាង ហើយឡើងមុន ឈរ រង់ចាំកាលជោតិបាលងូតហើយ ដោយការរក្សាដូចអ្នកមានឥស្សរិយយស ដែលធំរហូតងូតទឹករួច ហៅជោតិបាល ស្លៀកដណ្ដប់ហើយ កំពុងធ្វើសក់ ឲ្យស្ងួត ។ យជិការកាលនឹងណែនាំ ទើបពោលថា **អយំ** ព្រោះជោតិ- បាលមាណពនៅជិត ។

**[១៧០]** បទថា **ឱវដ្ដិកំ វិនិវេឋេត្វា** សេចក្ដីថា ព្រះពោធិសត្វមាន កម្លាំងដូចដំរីសារ ឯនទៅបន្តិច ពោលថា ថយទៅសម្លាញ់ ឲ្យយជិការអ្នក

ស្នូទផ្ទាំងព្រៃលែងការចាប់ត្រង់ទីដែលចាប់ទុកហើយ ។ បទថា **កេសេសុ បរាមសិត្វា ឯតទវោច** សេចក្តីថា បានឮថា ឃដិការនោះ ត្រិះរិះថា ជោតិបាលមាណពនេះ ជាអ្នកមានបញ្ញា កាលបានឃើញព្រះតថាគតតែម្តង នឹងជ្រះថ្លាផង នឹងជ្រះថ្លាក្នុងធម្មកថាផង ធម្មតាអ្នកដែលជ្រះថ្លាហើយ នឹងអាចធ្វើអាការដែលបានជ្រះថ្លា ឈ្មោះថា មិត្ត រមែងមានគុណប្រយោជន៍យ៉ាងនេះ យើងនឹងធ្វើអ្វីមួយ ចាប់សម្លាញ់ស្មោះស្មើចិត្ត ទៅកាន់សម្នាក់ព្រះទសពលឲ្យបាន ដូច្នោះ ទើបចាប់ជោតិបាលមាណពនោះត្រង់សក់ ហើយបានពោលពាក្យនោះ ។ បទថា **ឥតរជច្ចោ** សេចក្តីថា ឃដិការ មានជាតិដទៃ គឺ មានជាតិមិនស្មើគ្នានឹងយើង សំដៅសេចក្តីថា មានជាតិថោកទាប ។ បទថា **ន វតិទំ** នេះ បានដល់ សេចក្តីយល់ព្រមក្នុងការចាប់ទុំះឯងថា ការចាប់យើងនេះ នឹងមិនជាការចាប់ដ៏អាក្រក់ គឺ មិនមែនការចាប់ដែលតិចតួច នឹងជាការចាប់ដ៏ធំ គឺ ឃដិការស្នូទផ្ទាំងនេះ មិនជាការចាប់ដោយកម្លាំងរបស់ខ្លួន ចាប់ដោយកម្លាំងរបស់ព្រះសាស្តា ដូច្នេះ ។ ទ អក្សរ ហិ អក្សរ និង បិ អក្សរ ក្នុងពាក្យថា **យាវតទោហិបិ** នេះ ជានិបាត សេចក្តីថា ប៉ុណ្ណោះជាយ៉ាងក្រៃលែង ។ ពាក្យនេះ មានអធិប្បាយថា ហៅដោយ

វាចា និងចាប់ត្រង់ថ្នក់សំពត់ រហូតដល់ចាប់សក់ គួរធ្វើប្រយោគដើម្បីការចាប់ក្នុងសេចក្តីនោះ ។

**[១៧២]** បទថា **ធម្មិយា កថាយ** បានដល់ គប្បីជ្រាបធម្មីកថាដែលបដិសំយុត្តដោយបុព្វេនិវាសញ្ញាណ ដើម្បីបានចំពោះនូវសតិក្នុងទីនេះ ។

ក៏ព្រះមានព្រះភាគ ត្រាស់ធម្មកថា ដើម្បីឲ្យជោតិបាលនោះ ត្រឡប់បានសតិ ដោយន័យនេះថា ម្នាលជោតិបាល ខ្លួនអ្នកមិនមែនសត្វអ្នកឈានចុះកាន់ឋានៈដ៏អាក្រក់ តែអ្នកប្រាថ្នាសព្វញ្ញុតញ្ញាណ ឈានចុះក្នុងមហាពោធិបល្ល័ង្ក ធម្មតាបុគ្គលដូចអ្នក មិនគួរនៅដោយសេចក្តីប្រមាទ ដូច្នេះ ។ ចំណែកព្រះថេរៈអ្នកនៅត្រើយសមុទ្រឯណោះ ពោលថា ព្រះមានព្រះភាគត្រាស់ធម្មីកថាថា ជោតិបាល តថាគតបំពេញបារមី ១០ ប្រការ ត្រាស់ដឹងសព្វញ្ញុតញ្ញាណ មានភិក្ខុពីរម៉ឺនហែហម ត្រាច់ទៅក្នុងលោកដោយប្រការណា សូម្បីអ្នកក៏ចូរបំពេញបារមី ១០ ប្រការ ចាក់ធ្លុះសព្វញ្ញុតញ្ញាណមានពួកសមណៈជាបរិវារ ត្រាច់ទៅក្នុងលោកដោយប្រការតែម្យ៉ាង ដូច្នេះ មិនសមគួរនឹងប្រមាទ ដូច្នេះ ចិត្តរបស់ជោតិបាលនោះ រមែងបង្អោនទៅក្នុងបព្វជ្ជាដោយប្រការណា ក៏ទ្រង់ប្រៀនប្រដៅដល់ទោសក្នុងកាមទាំងឡាយ

និងអានិសង្សក្នុងការចេញបួស ដោយប្រការនោះ ។

**[១៧៤]** បទថា **អលត្ថ ខោ អានន្ទ ។បេ។ បព្វជ្ជំ អលត្ថ ឧបសម្បទំ** សេចក្តីថា ជោតិបាលមាណពបួសហើយ បានធ្វើយ៉ាងណា ដែលជាព្រះពោធិសត្វនឹងគប្បីធ្វើ ។ ធម្មតាព្រះពោធិសត្វ រមែងបព្វជ្ជាក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំងឡាយ ។ កាលបួសហើយ រមែងមិនជាអ្នកមានជើងដែលធ្លាក់ចុះដូចសត្វក្រៅពីនេះ តាំងនៅក្នុងចតុប្បារិសុទ្ធិសីល ហើយរៀនសូត្រព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក សមាទានធុតង្គ ១៣ ចូលព្រៃ បំពេញគតវត្ត និងបច្ចាគតវត្ត ធ្វើសមណធម៌ចម្រើនវិបស្សនា រហូតទល់អនុលោមញ្ញាណទើបឈប់ មិនធ្វើសេចក្តីព្យាយាមដើម្បីមគ្គផលតទៅ សូម្បីជោតិបាលមាណព ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ បទថា **អឌ្ឍមាសូបសម្បន្នេ** សេចក្តីថា គ្រាព្រះមានព្រះភាគ ទ្រង់ញ៉ាំងទារកនៃត្រកូលឲ្យបួសហើយ មិនប្រថាប់នៅមួយខែ ស្តេចទៅហើយ សេចក្តីស្រឡាញ់របស់មាតាបិតាមិនស្ងប់ ។ គេមិនទាន់ដឹងការកាន់បាត្រ និងចីវរ សេចក្តីស្និទស្នាលជាមួយនឹងភិក្ខុកម្លោះ និងសាមណេរទាំងឡាយមិនទាន់កើត សេចក្តីស្រឡាញ់មួយអន្លើដោយព្រះថេរៈទាំងឡាយមិនទាន់រឹងមាំ មិនទាន់កើតសេចក្តីត្រេក-

អរ ក្នុងទីដែលទៅហើយ តែកាលនៅរហូតដល់អស់វេលា មានប្រមាណប៉ុណ្ណេះ មាតាបិតា ក៏រមែងបានឃើញ ដោយហេតុនោះ សេចក្តីសោករបស់មាតានិងបិតានោះ រមែងថយចុះ រមែងដឹងការកាន់បាត្រ និងចីវរ រមែងកើតសេចក្តីស្និទស្នាលជាមួយនឹងសាមណេរ និងភិក្ខុកម្លោះទាំងឡាយ សេចក្តីស្រឡាញ់ មួយអន្លើដោយព្រះថេរៈទាំងឡាយរមែងតាំងមាំ ក្នុងទីដែលទៅហើយ រមែងមានសេចក្តីត្រេកអរក្រៃលែង រមែងមិនអផ្សុក ព្រោះដូច្នោះទើបគួរនៅរហូតដល់អស់កាលមានប្រមាណត្រឹមនេះ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគព្រះនាមថា កស្សបៈ ទ្រង់ប្រថាប់នៅអស់កន្លះខែ ទើបទ្រង់ចៀសចេញទៅ ។

**[១៧៦]** បទថា **បណ្ឌុមុទិកស្ស សាលិនោ** បានដល់ ស្រូវសាលីពណ៌លឿង ដែលធ្វើឲ្យទន់ស្ងួតហើយ ។ បានឮថា ស្រូវសាលីនោះ តាំងពីសាបព្រោះទៅ មានការរក្សា ដូច្នេះ ភ្លឺស្រែ ត្រូវធ្វើបរិកម្មយ៉ាងល្អ ហើយយកពូជដាក់ក្នុងទីនោះ ស្រោចដោយទឹកក្រអូប ។ ក្នុងវេលាសាបព្រោះចងបាំងដោយសំពត់នៅខាងលើ ធ្វើដូចពិតាន វេលាទុំ ក៏ប្រុតធ្វើជាកណ្តាប់ចងខ្សែព្យួរហាលឲ្យស្ងួត ក្រោលរបស់ក្រអូបម៉ត់ពេញជង្រុករក្សាទុក បិទ

ទ្វារគ្រប់បីឆ្នាំ ។ ស្រូវសាលីពណ៌លឿងក្លិនក្រអូប ដែលរក្សាទុកអស់បីឆ្នាំយ៉ាងនេះ ជាបាយសារបរិសុទ្ធិល្អ មិនមានគ្រាប់ខ្មៅ នឹងធ្វើជារបស់ទំពារប្រភេទផ្សេងៗ ក៏បាន ជាបាយស្អាតក៏បាន ។ លោកសំដៅយកពាក្យនោះទើបពោលថា **បណីតញ្ច ខាទនីយំ ភោជនីយំ ។បេ។ កាលំ អារោចាបេសិ** ប្រែថា គាត់តែងខាទនិយៈភោជនីយៈដ៏ប្រណីត ។ល។ ហើយឲ្យរាជបុរសក្រាបទូលកត្តកាល ដូច្នេះ ។

**[១៧៧]** ពីរបទថា **អធិវុដ្ឋោ មេ** សេចក្ដីថា ព្រះមានព្រះភាគព្រះនាមថា កស្សបៈ ត្រាស់សំដៅដល់យ៉ាងណា ? ត្រាស់សំដៅដល់ថាក្នុងវេលាព្រះអង្គស្ដេចចេញអំពីវេភល្លិគៈ ឃដិការបានកាន់យកបដិញ្ញាដើម្បីឲ្យស្ដេចប្រថាប់នៅចាំវស្សាក្នុងសម្នាក់របស់ខ្លួននោះ ។ ត្រាស់សំដៅដល់ការចាំវស្សានោះ ។ បទថា **អហុទេវអញ្ញថត្តំ អហុ ទោមនស្សំ** សេចក្ដីថាព្រះបាទកិកិកាសិរាជ ទ្រង់ប្រារព្ធដល់ការមិនមានលាភ មានការខូចព្រះទ័យមានចិត្តទោមនស្សថា យើងមិនបានថ្វាយទានរហូតអស់ត្រៃមាស និងមិនបានស្ដាប់ព្រះធម៌ និងមិនបានបដិបត្តិព្រះភិក្ខុ ២ ម៉ឺនរូប ដោយទំនងនេះ ។ ទ្រង់មិនប្រារព្ធព្រះតថាគត ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះព្រះអង្គជាព្រះសោតាបន្ន ។

បានឮមកថា ពីមុនព្រះបាទកិកិកាសិរាជនោះ ទ្រង់រាប់អានព្រាហ្មណ៍ ។ តមកសម័យមួយ កាលជាយដែនកម្រើកឡើង ទ្រង់ស្ដេចទៅរម្ងាប់ ទើបត្រាស់បង្គាប់ធីតាព្រះនាមថា **ឧរច្ឆទា** ថា កូនសម្លាញ់ ចូរអ្នកកុំប្រមាទក្នុងទេវតារបស់យើង ។ ពួកព្រាហ្មណ៍ទាំងឡាយ ឃើញរាជធីតានោះហើយក៏បាត់បង់ស្មារតី ។ រាជបុរសទាំងឡាយ កាលព្រះនាងសួរថា អ្នកទាំងនេះគឺ នរណា ក៏ឆ្លើយថា ជាទេវតា[១] របស់ព្រះអង្គ ។ ព្រះរាជធីតាត្រាស់សួរថា ឈ្មោះថា កុម្មទេវតា មានរូបយ៉ាងនេះឯង ហើយស្ដេចក៏ឡើងកាន់ប្រាសាទ ។ ថ្ងៃមួយ ព្រះនាងទ្រង់ឈរទតថ្នល់ហ្លួង ទ្រង់ឃើញព្រះអគ្គសាវករបស់ព្រះមានព្រះភាគព្រះនាមថា កស្សបៈ ទ្រង់បញ្ជាឲ្យនិមន្តមកហើយថ្វាយបិណ្ឌបាត ទ្រង់ស្ដាប់អនុមោទនាហើយនោះឯង បានសម្រេចព្រះសោតាបន្ន ទើបត្រាស់សួរថា ភិក្ខុរូបដទៃៗ នៅមានទៀតខ្លះទេ ទ្រង់បានស្ដាប់ថា ព្រះសាស្ដាព្រមដោយភិក្ខុសង្ឃពីរម៉ឺនរូប ស្ដេចប្រថាប់នៅ

---

១-ដីកាថា តេសំ សមញ្ញា សម័យនោះហៅព្រាហ្មណ៍ទាំងនោះថា កុម្មទេវតា ។

ក្នុងព្រៃឥសិបតនៈ ទើបទ្រង់ឲ្យទៅនិមន្តមក ហើយទ្រង់ថ្វាយទាន ។ ព្រះរាជាទ្រង់ញ៉ាំងព្រះរាជាណាខេត្តឲ្យស្ងប់ហើយ ស្តេចត្រឡប់មក ។ ពេលនោះ ពួកព្រាហ្មណ៍ទាំងឡាយមកគាល់ព្រះរាជាមុននោះឯង ពោលទោសព្រះធីតា ហើយបែកគ្នា ។ តែព្រះរាជា ទ្រង់បានប្រទានពរទុកក្នុងវេលាព្រះរាជធីតាប្រសូតិ ។ ព្រះញាតិទាំងឡាយសូមពរថ្វាយព្រះនាងថា សូមឲ្យគ្រងរាជ្យ ៧ ថ្ងៃ ។ គ្រានោះ ព្រះរាជាទើបទ្រង់ប្រគល់រាជសម្បត្តិឲ្យព្រះរាជធីតាអស់ ៧ ថ្ងៃ ។ ព្រះរាជធីតាទ្រង់ញ៉ាំងព្រះសាស្តាឲ្យសោយហើយ ត្រាស់បង្គាប់ឲ្យព្រះរាជាស្តេចប្រថាប់អង្គុយក្នុងខាងក្រៅវាំងនន ។ ពេលព្រះរាជាទ្រង់បានស្តាប់ការអនុមោទនារបស់ព្រះសាស្តា ក៏បានជាព្រះសោតាបន្ន ។ ក៏ធម្មតាព្រះសោតាបន្ន ទ្រង់មិនមានអាឃាត ប្រារព្ធព្រះតថាគត ។ ព្រោះដូច្នោះលោកទើបពោលថា **ន តថាគតំ អរព្ភ** ប្រែថា សេចក្តីទាស់ចិត្ត សេចក្តីទោមនស្ស មិនបានប្រារព្ធព្រះតថាគត ។

**[១៧៨]** បទថា **យំ ឥច្ឆតិ តំ ហរតុ** សេចក្តីថា បានឮថា យជិការស្មូនឆ្នាំង ធ្វើភាជន៍ទាំងឡាយទុក មិនធ្វើការទិញ និងការលក់ ។ គ្រាពោលយ៉ាងនេះហើយ ទើបទៅកាន់ព្រៃ ដើម្បីរកឧសខ្លះ ដើម្បីរកដីខ្លះ

ដើម្បីរកស្លឹកឈើខ្លះ ។ មហាជនបានឮថា ឃដិការស្មូនឆ្នាំងធ្វើភាជន៍ស្រេច ហើយ ទើបកាន់យកអង្ករ អំបិល ទឹកដោះជូរ ប្រេង និងទឹកអំពៅ ដែលល្អៗ ជាដើមមក ។ បើភាជន៍មានតម្លៃច្រើន តម្លៃមានតិច ។ នឹងត្រូវឲ្យវត្ថុសមគួរ ទើបកាន់យកទៅ ដូច្នោះ មហាជនទើបមិនទាន់យកភាជន៍នោះទៅ ។ នឹងត្រូវទៅនាំយកតម្លៃមកបន្ថែម ដោយគិតថា ឃដិការស្មូនឆ្នាំង ជាឈ្មួញប្រកបដោយធម៌ បដិបត្តិទំនុកបម្រុងមាតាបិតា ទំនុកបម្រុងព្រះសម្មាសម្ពុទ្ធ អកុសលនឹងមានដល់យើងជាច្រើន ដូច្នេះ ។ តែបើភាជន៍មានតម្លៃតិច តម្លៃដែលគេនាំមកមានច្រើន នឹងជួយរក្សាទុកដាក់តម្លៃដែលនាំមកឲ្យល្អ ដូចជាម្ចាស់ផ្ទះហើយទើបទៅ ដោយគិតថា ឃដិការស្មូនឆ្នាំង ជាឈ្មួញដែលប្រកបដោយធម៌ នឹងជាបុណ្យរបស់ពួកយើង ដូច្នេះ ។ ព្រះមានព្រះភាគព្រះនាមថាកស្សបៈ កាលទ្រង់បញ្ឈប់ព្រះតម្រាស់របស់ព្រះរាជាថា ឃដិការស្មូនឆ្នាំងមានគុណសម្បត្តិយ៉ាងនេះ ហេតុអ្វីទើបមិនទាន់បួស ទើបត្រាស់ថា ឃដិការស្មូនឆ្នាំង ចិញ្ចឹមមាតាបិតាដែលភ្នែកខ្វាក់ និងចាស់ជរា ដូច្នេះ ។

**[១៧៩]** បទថា *កោ នុ ខោ* សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ឃដិការស្មូនឆ្នាំងទៅណាហើយ ។ បទថា **កុម្ភិយា** ប្រែថា អំពីឆ្នាំង

បាយ ។ បទថា **បរយោគា** ប្រែថា អំពីឆ្នាំងសម្ល ។ បទថា **បរិភុញ្ជ** ប្រែថា ចូរបរិភោគចុះ ។ សួរថា ក៏មាតាបិតារបស់ឃដិការ ពោលយ៉ាងនោះ ព្រោះហេតុអ្វី ។ ឆ្លើយថា បានឮថា ឃដិការស្ទូនឆ្នាំងដាំបាយ និងសម្លហើយ ឲ្យមាតាបិតាបរិភោគ ខ្លួនឯងទើបបរិភោគ ហើយតាំងទុកបាយនិងសម្លសម្រាប់ថ្វាយព្រះមានព្រះភាគ ក្រាលអាសនៈទុក នាំអាហារមកទុកទីជិត តាំងទឹកទុក ឲ្យសញ្ញាដល់មាតាបិតាហើយ ទើបទៅកាន់ព្រៃ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ បទថា **អភិវិស្សដ្ឋោ** ប្រែថា ទ្រង់ស្និទស្នាលយ៉ាងក្រៃលែង ។ បទថា **បីតិសុខំ ន វិជហិ** សេចក្តីថា ឃដិការស្ទូនឆ្នាំងមិនលះបង់បីតិសុខរហូតទៅ ដោយពិត ឃដិការស្ទូនឆ្នាំងរលឹករឿយៗ មិនថាខណៈណាៗ ជាពេលយប់ក៏ដោយ ពេលថ្ងៃក៏ដោយ ទាំងក្នុងស្រុក ទាំងក្នុងព្រៃថា ព្រះមានព្រះភាគជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ទ្រង់ចូលមកក្នុងផ្ទះយើង កាន់យកអាមិសទៅបរិភោគ នេះជាលាភរបស់យើងហ្ន៎ បីតិ ៥ យ៉ាង រមែងកើតឡើងគ្រប់ខណៈៗ ។ លោកពោលពាក្យនោះ សំដៅដល់រឿងនេះ ។

[១៨០] បទថា **កឡោបិយា** ប្រែថា អំពីកឡោ ។ សួរថា ក៏ព្រះ-

មានព្រះភាគ ទ្រង់ធ្វើយ៉ាងនេះបានឬ ។ ឆ្លើយថា ជាហេតុដែលប្រកបដោយធម៌ ដូចគ្នានឹងបាយក្នុងបាត្ររបស់ភិក្ខុទាំងឡាយ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ទើបធ្វើយ៉ាងនោះ ។ មួយវិញទៀត ការបញ្ញត្តិសិក្ខាបទ រមែងមានដល់ព្រះសាវកទាំងឡាយប៉ុណ្ណោះ ឈ្មោះថា ព្រំដែននៃសិក្ខាបទ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ដូចផ្កាឈើ និងផ្លែឈើដែលមាននៅក្នុងព្រះរាជឧទ្យាន បុគ្គលដទៃបេះផ្កាឈើ និងផ្លែឈើទាំងនោះទៅ រមែងមានទោស ចំណែកព្រះរាជាទ្រង់បរិភោគបានតាមព្រះរាជអធ្យាស្រ័យ សេចក្តីនេះ ក៏មានឧបមេយ្យដូច្នោះ ។ ចំណែកព្រះថេរៈអ្នកនៅត្រើយម្ខាងសមុទ្រឯណោះ ពោលថា បានឮថា ពួកទេវតាទាំងឡាយចាត់ចែងថ្វាយហើយដូច្នេះ ។

**[១៨១]** បទថា *ហរថ ភន្តេ ហរថ ភទ្រមុខា* សេចក្តីថា កូនរបស់យើង កាលសួរថា នឹងទៅណា ។ ក៏ឆ្លើយថា ទៅសម្នាក់ព្រះទសពល ។ រវល់តែទៅទីណាទេដឹងហ្ន៎ ទើបមិនដឹងថា ទីប្រថាប់របស់ព្រះសាស្តាលេចភ្លៀង ជាអ្នកមានចិត្តត្រេកអរល្អហើយក្នុងការកាន់យក មានសេចក្តីសម្គាល់ថា មិនមានកំហុស ទើបពោលយ៉ាងនោះ ។ បទថា **តេមាសំ អាកាស-**

ចតុទ្ទសំ អដ្ឋាសិ សេចក្តីថា បានឮថា ព្រះមានព្រះភាគទ្រង់ប្រថាប់កន្លងទៅអស់មួយខែ ក្នុងរដូវភ្លៀង ៤ ខែ ទើបទ្រង់ឲ្យភិក្ខុទៅនាំគ្រឿងប្រក់មក ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។ មយ៉ាងទៀត សេចក្តីចំពោះបទក្នុងរឿងនេះដូចតទៅនេះ ៖

ឈ្មោះថា មានអាកាសជាគ្រឿងប្រក់ ព្រោះអត្ថថា អាកាសជាគ្រឿងប្រក់របស់ផ្ទះនោះ ។ បទថា **ន ចាតិវស្សិ** សេចក្តីថា មិនមែនត្រឹមតែភ្លៀងមិនលេចនោះទេ តាមធម្មតា ទឹកសូម្បីត្រឹមតែមួយតំណក់ ក៏មិនបានលេចដល់ក្នុងខាងក្នុងទីទឹកធ្លាក់នៃសំយាបផ្ទះ យជិការស្មូនឆ្នាំងនេះ យ៉ាងណា សូម្បីខ្យល់ និងកំដៅថ្ងៃ ក៏មិនធ្វើសេចក្តីបៀតបៀនដូចខាងក្នុងផ្ទះដែលមានគ្រឿងប្រក់ដ៏ក្រាស់ ដូច្នោះ ។ ការប្រែប្រួលនៃរដូវ ក៏បានមានតាមធម្មតាទុំះឯង ។ ក្នុងខាងក្រោយ កាលនិគមនោះសូម្បីទៅហើយ ទីត្រង់នោះ ភ្លៀងក៏មិនធ្លាក់ស្រោចនោះឯង ។ ពួកមនុស្ស កាលធ្វើការងារក្នុងពេលភ្លៀង ក៏នឹងរក្សាសំពត់ សាដកទុកត្រង់ទីនោះ ហើយធ្វើការងារ ។ ទីត្រង់នោះនឹងរក្សាដូច្នោះ រឿយៗ ទៅ រហូតមួយកប្ប ។ ក៏អាការដូច្នោះទុំះឯង មិនមែនដោយឥទ្ធានុភាពរបស់ព្រះតថាគត តែដោយគុណសម្បត្តិ

នៃមាតាបិតារបស់ឃដិការស្មូនឆ្នាំងនោះឯង ។ ពិតណាស់ មាតាបិតារបស់ឃដិការស្មូនឆ្នាំងនោះ មិនបានកើតទោមនស្ស ព្រោះសេចក្តីនោះជាបច្ច័យថា ព្រះសម្មាសម្ពុទ្ធមិនគប្បីបានក្នុងទីណា ទើបទ្រង់ឲ្យធ្វើការរើដំបូលផ្ទះរបស់យើង ដែលជាមនុស្សក្មេកខ្វាក់ទាំងពីរនាក់ ។ តែបានកើតសេចក្តីសោមនស្សយ៉ាងខ្លាំងដល់គេថា ព្រះមានព្រះភាគ ជាអគ្គបុគ្គលក្នុងលោកព្រមទាំងទេវលោក ឲ្យមកនាំស្មៅអំពីផ្ទះរបស់យើង ទៅប្រក់ព្រះគន្ធកុដិដូច្នេះ ។ បណ្ឌិតគប្បីជ្រាបថា បាដិហារ្យនេះ កើតឡើងដោយគុណសម្បត្តិរបស់មាតាបិតាឃដិការស្មូនឆ្នាំងនោះឯង ដោយប្រការដូច្នេះ ។

**[១៨២]** ក្នុងពាក្យថា ***តណ្ឌុលវាហសតានិ*** នេះ គប្បីជ្រាបថា ពីរយេរទេះ ជាវាហៈមួយ ។ ពាក្យថា គ្រឿងសម្ល ដែលសមគួរដល់បាយនោះ សេចក្តីថា វត្ថុ មានប្រេង ទឹកអំពៅជាដើម ដែលសមគួរដល់បាយនោះ ដើម្បីស្លបៈ បានឮថា ព្រះរាជាទ្រង់បញ្ជូនរបស់មានប្រមាណប៉ុណ្ណេះទៅផង ទ្រង់សម្គាល់ថា ភត្តនឹងមានដល់ភិក្ខុមួយពាន់រូប ដើម្បីប្រយោជន៍ត្រៃមាស ។ ពាក្យថា កុំជារបស់ខ្ញុំឡើយ ចូរជារបស់ព្រះរាជាចុះ ឃដិការស្មូនឆ្នាំង បដិសេធហើយ ព្រោះហេតុអ្វី ។ ព្រោះជាអ្នកសម្រេចសេចក្តី

ប្រាជ្ញាតិច ។ បានឮថា ឃដិការស្មូនឆ្នាំងនោះ មានសេចក្ដីគិតយ៉ាងនេះថា ព្រះរាជាទ្រង់មិនធ្លាប់ឃើញយើង បញ្ជូនមកដើម្បីអ្វី ។ បន្ទាប់ពីនោះ ទើបគិតថា ព្រះសាស្ដាស្ដេចទៅកាន់ព្រះនគរពារាណសី ព្រះអង្គកាលត្រូវព្រះរាជាទូលអង្វរឲ្យនៅចាំវស្សា ក៏ត្រាស់ប្រាប់ថា ទ្រង់ទទួលបេ្តជ្ញារបស់យើងទុកហើយ នឹងត្រាស់ប្រាប់គុណកថារបស់យើងដោយពិត ក៏អ្នកដែលមានលាភនៃគុណកថាដែលបានពោលហើយ រមែងដូចជាលាភ ដែលអ្នករបាំរាំហើយទើបបាន និងដូចលាភដែលអ្នកដេញពិណហើយ ទើបបាន ប្រយោជន៍អ្វីដោយវត្ថុនេះដល់យើង យើងអាចធ្វើការទំនុកបម្រុងទាំងមាតា និងបិតាទាំងព្រះសម្មាសម្ពុទ្ធ ដោយលាភដែលយើងធ្វើការងារហើយ កើតឡើងដូច្នេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។

" ចប់អដ្ឋកថា ឃដិការសូត្រទី ១ "

# អ ដ្ឋ ក ថា

## រដ្ឋបាលសូត្រទី ២

[១៨៤] រដ្ឋបាលសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់ចាំមកយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរដ្ឋបាលសូត្រនោះ ដូចតទៅនេះ

បទថា ថុល្លកោដ្ឋិតំ បានដល់ ជង្រុកស្រូវ គឺ ពេញជង្រុក ។ បានឮថា ជនបទនោះមានស្រូវជានិច្ច គឺ គ្រាប់ស្រូវចេញចូលលានគ្រប់កាល ។ ដោយហេតុនោះ ក្នុងនិគមនោះ ជង្រុកស្រូវទាំងឡាយទើបពេញជានិច្ច ព្រោះដូច្នោះ ជនបទនោះ ទើបរាប់បានថា ថុល្លកោដ្ឋិតៈ ប្រែថា មានស្រូវពេញជង្រុកតែម្យ៉ាង ។ ហេតុអ្វី ព្រះរដ្ឋបាល ទើបមានឈ្មោះថា រដ្ឋបាល ។

ដែលឈ្មោះថា រដ្ឋបាល ព្រោះជាអ្នកអាចរក្សារដ្ឋ ដែលបែងចែកបាន ។ សួរថា ឈ្មោះរបស់ព្រះរដ្ឋបាលនោះ កើតឡើងក្នុងកាលណា ។

ឆ្លើយថា កាលព្រះសម្មាសម្ពុទ្ធ ព្រះនាមថា បទុមុត្តរៈ ។ ពិតណាស់ ១០០,០០០ កប្បមុនអំពីកប្បនេះ មនុស្សមានអាយុ ១០០,០០០ ឆ្នាំ ព្រះសាស្តាព្រះនាមថា បទុមុត្តរៈ ឧប្បត្តិឡើង មានភិក្ខុ ១០០,០០០ រូប ជាបរិវារ ស្តេចចារិកដើម្បីប្រោសសត្វលោក ដែលលោកសំដៅយក ពោលទុកថា ព្រះសាស្តាព្រះនាមថា បទុមុត្តរៈ មានព្រះជនកព្រះនាមថា ព្រះបាទអានន្ទ ព្រះជននីព្រះនាមថា ព្រះនាងសុជាតា ក្នុងនគរហង្សវតី ។

គ្រាព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់មិនទាន់ឧប្បត្តិ ។ កុដុម្ពីពីរនាក់នៃក្រុងហង្សវតី មានសទ្ធាជ្រះថ្លា តាំងរោងទានសម្រាប់អ្នកក្រខ្សត់ អ្នកធ្វើដំណើរនិងយាចកជាដើម ។ គ្រានោះ តាបស ៥០០ នាក់ ដែលនៅក្នុងភ្នំ មកដល់ក្រុងហង្សវតី ។ អ្នកទាំងពីរនោះ ក៏បែងចែកតាបសម្នាក់ពាក់កណ្តាល ហើយទំនុកបម្រុង ។ តាបសទាំងឡាយនៅអស់វេលាបន្តិច ក៏ត្រឡប់ទៅកាន់ភ្នំ ។ តាបសជាថេរៈ ក៏បែកគ្នាជាពីរ ។ គ្រានោះ កុដុម្ពីទាំងពីរនាក់នោះ ក៏ធ្វើការទំនុកបម្រុងតាបសទាំងនោះ រហូតដល់អស់ជីវិត ។ កាលពួកតាបសបរិភោគហើយ អនុមោទនា មួយរូបពោលពណ៌នាគុណរបស់ភពស្តេចសក្កៈ ។ មួយរូបពោលពណ៌នាគុណរបស់ភពនាគរាជ ស្តេចផែន

ដី ។ បណ្តាកុដុម្ពីទាំងពីរ ម្នាក់ប្រាថ្នាភពស្តេចសក្កៈ ក៏កើតជាស្តេចសក្កៈ ។ ម្នាក់ប្រាថ្នាភពនាគ ក៏ជានាគរាជឈ្មោះ បាលិតៈ ។ ស្តេចសក្កៈឃើញនាគនោះមកកាន់ទីទំនុកបម្រុងរបស់ខ្លួន ទើបសួរថា អ្នកនៅតែត្រេកអរក្រៃលែងក្នុងកំណើតនាគឬ ។ បាលិតៈនាគរាជនោះឆ្លើយថា យើងមិនត្រេកអរទេ ។ ស្តេចសក្កៈប្រាប់ថា បើដូច្នោះ អ្នកចូរថ្វាយទានចំពោះព្រះមានព្រះភាគបទុមុត្តរៈចុះ ហើយធ្វើសេចក្តីប្រាថ្នានៅក្នុងទីនេះ យើងទាំងពីរនឹងនៅជាសុខ ។ នាគរាជនិមន្តព្រះសាស្តា មកថ្វាយមហាទាន ៧ ថ្ងៃ ដល់ព្រះមានព្រះភាគដែលមាន ភិក្ខុ ១០០,០០០ រូប ជាបរិវារ ឃើញសាមណេរឱរសរបស់ព្រះបទុមុត្តរទសពល ឈ្មោះឧបរេវតៈ ក្នុងថ្ងៃទី ៧ ថ្វាយសំពត់ទិព្វចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទើបប្រាថ្នាតំណែងរបស់សាមណេរ ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាមើលអនាគតកាល ទ្រង់ឃើញថា គេនឹងបានជារាហុលកុមារ ឱរសរបស់ព្រះពុទ្ធព្រះនាមថា គោតមៈ ក្នុងអនាគតកាល ទើបត្រាស់ថា សេចក្តីប្រាថ្នារបស់អ្នកនឹងសម្រេច ។ នាគរាជក៏ប្រាប់សេចក្តីនោះដល់ស្តេចសក្កៈ ។ ស្តេចសក្កៈស្តាប់ហើយ ក៏ថ្វាយទាន ៧ ថ្ងៃដូចគ្នា ឃើញកុលបុត្រឈ្មោះ រដ្ឋបាល ជាអ្នករក្សារដ្ឋ ចេញបួស

ដោយសទ្ធា ទើបតាំងសេចក្ដីប្រាថ្នាថា ក្នុងអនាគតកាល កាលបើមានព្រះពុទ្ធដូចជាព្រះអង្គឧប្បត្តិក្នុងលោក សូម្បីខ្ញុំព្រះអង្គក៏កើតក្នុងត្រកូលដែលអាចរក្សារដ្ឋ គប្បីមានឈ្មោះថា រដ្ឋបាលអ្នកបួសដោយសទ្ធា ដូចជាកុលបុត្រនេះ ។ ព្រះសាស្ដាទ្រង់ជ្រាបថា សេចក្ដីប្រាថ្នាសម្រេច ទើបទ្រង់ត្រាស់ព្រះគាថា នេះថា

ត្រកូលណា ឈ្មោះត្រកូលរដ្ឋបាល ហើយអាចដើម្បីចិញ្ចឹម
ត្រកូលបួនវណ្ណៈ ព្រមទាំងព្រះរាជា កុលបុត្រនេះ នឹងកើត
ក្នុងត្រកូលនោះ ។

គប្បីជ្រាបថា ឈ្មោះនេះ របស់ព្រះរដ្ឋបាលនោះ កើតឡើងតាំងពីព្រះសម្មាសម្ពុទ្ធព្រះនាមថា បទុមុត្តរៈ ដោយប្រការដូច្នេះ ។

**[១៨៦]** បទថា ***ឯតទហោសិ*** សេចក្ដីថា ការគិតអ្វីៗ ថា ***យថា យថា ខោ*** ជាដើម មានហើយ ។ សេចក្ដីសង្ខេបក្នុងពាក្យនោះ មានដូច្នេះ ។ យើងដឹងនូវទោជល់ធម៌ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយហេតុណាៗ ក៏ជាការយើងពិចារណាហើយ ដោយហេតុនោះៗ យ៉ាងនេះថា ព្រហ្មចរិយៈ គឺ សិក្ខា ៣ នោះ យើងគប្បីប្រព្រឹត្តឲ្យបរិបូណ៌ ដោយចំណែកមួយ

ព្រោះធ្វើមិនឲ្យដាច់សូម្បីមួយថ្ងៃ ឲ្យដល់ចរិមកចិត្ត និងគប្បីប្រព្រឹត្តឲ្យបរិសុទ្ធិដោយចំណែកមួយ ដូចស័ង្ខខាត់ហើយ ដូចស័ង្ខដែលខាត់ពណ៌ហើយ បានដល់ ដូចស័ង្ខដែលជម្រះហើយ ព្រោះធ្វើមិនឲ្យមានមន្ទិល ដោយមន្ទិល គឺ កិលេសសូម្បីក្នុងមួយថ្ងៃ ហើយឲ្យដល់ចរិមកចិត្ត ។ បទថា **ឥទំ ន សុករំ អគារំ អជ្ឈាវសតា** សេចក្តីថា ព្រហ្មចរិយៈនោះ ដែលបុគ្គលនៅគ្រប់គ្រងផ្ទះប្រព្រឹត្តឲ្យបរិបូណ៌ដោយចំណែកមួយ ។ល។ ធ្វើមិនបានងាយឡើយ បើដូច្នោះ យើងគប្បីកោរសក់ និងពុកមាត់ ដណ្តប់សំពត់ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ដែលឈ្មោះថា កាសាយៈ ព្រោះជ្រលក់ដោយទឹកអម្ចត់ ចេញចាកផ្ទះបួសមិនមានផ្ទះ ។ បទថា **អចិរបក្កន្តេសុ ថុល្លកោដ្ឋិតកេសុ ព្រាហ្មណគហបតិកេសុ យេន ភគវា តេនុបសង្កមិ** សេចក្តីថា ក្នុងកាលព្រាហ្មណ៍ និងគហបតីទាំងនោះ មិនទាន់ក្រោកទៅ រដ្ឋបាលកុលបុត្រ ក៏មិនទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ ។ ព្រោះហេតុអ្វី ។ ព្រោះញាតិសាលោហិតមិត្តទាំងឡាយ របស់គេក្នុងទីនោះ ជាចំនួនច្រើន ក៏ប្រាថ្នាថា អ្នកទាំងនោះពោលថា លោកជាកូនតែម្នាក់របស់មាតាបិតា លោកមិនគួរបួស ហើយគប្បីចាប់គេត្រង់ដើមដៃទាញមក បន្ទាប់

ពីនោះ បព្វជ្ជាក៏នឹងអន្តរាយ ។ គេក្រោកឡើងព្រមនឹងបរិស័ទ ដើរទៅបន្តិច ហើយក៏ត្រឡប់ធ្វើលេសថា មានកិច្ចជាប់ដោយសរីរៈណាមួយ ហើយចូលគាល់ព្រះមានព្រះភាគ ទូលសូមបព្វជ្ជា ។ ដោយហេតុនោះ លោកទើបពោលថា **អថខោ រដ្ឋបាលោ កុលបុត្តោ អចិរវុដ្ឋិតាយ បរិសាយ** ។បេ។ **បព្វាជេតុ មំ ភគវា** ។ ក៏ព្រោះរាប់ចាប់តាំងពីរាហុលកុមារបួសហើយ ព្រះមានព្រះភាគទ្រង់មិនបំបួសកុលបុត្រ ដែលមាតាបិតាមិនអនុញ្ញាត ដូច្នោះទើបត្រាស់សួរគេថា **អនុញ្ញាតោសិ បន ត្វំ រដ្ឋបាល មាតាបិតូហិ** ។បេ។ **បព្វជ្ជាយ** ។

**[១៨៦]** ក្នុងពាក្យថា **អម្ម តាត** នេះ រដ្ឋបាល ហៅមាតាថា **អម្ម** ហៅបិតាថា **តាត** ។

**[១៨៨]** បទថា **ឯកបុត្តកោ** ប្រែថា បុត្រប៉ុណ្ណោះ បុត្រណាៗ ដទៃមិនថា បង ឬប្អូនមិនមាន ។ ក៏ក្នុងពាក្យនេះ កាលគួរនឹងពោលថា **ឯកបុត្តោ** ក៏ពោលថា **ឯកបុត្តកោ** ដោយអំណាចសេចក្តីអាណិត ។ បទថា **បិយោ** ប្រែថា កើតបីតិ ។ បទថា **មនាបោ** ប្រែថា ចម្រើនចិត្ត ។ បទថា **សុខេ ឋិតោ** ប្រែថា តាំងនៅក្នុងសេចក្តីសុខទុំះឯង អធិប្បាយថា ចម្រើន

សេចក្ដីសុខ ។ បទថា **សុខបរិហដោ** ប្រែថា បរិហារដោយសេចក្ដីសុខ ។ តាំងពីវេលាកើតមក គេមានមេដោះដោយពរមិនដាក់ដៃ លេងដោយគ្រឿងលេងរបស់ក្មេង មានរថសេះតូចៗ ជាដើម ឲ្យបរិភោគតែភោជនដែលមានរសល្អ ឈ្មោះថា បរិហារដោយសេចក្ដីសុខ ។ បទថា **ន ត្វំ តាត រដ្ឋបាល កស្សចិ ទុក្ខស្សជានាសិ** សេចក្ដីថា នែ៎ រដ្ឋបាលកូន បាឯងមិនដែលស្គាល់ទុក្ខ សូម្បីប្រមាណតិចតួច ។ បទថា **មរណេនបិ តេ មយំ អកាមកា វិនាភវិស្សាម** សេចក្ដីថា សូម្បីបានឹងគប្បីស្លាប់ កាលពួកយើងនៅរស់ សូម្បីព្រោះសេចក្ដីស្លាប់របស់បា ពួកយើងមិនត្រូវការ មិនប្រាថ្នា មិនពេញចិត្ត ក៏នឹងត្រូវការព្រាត់ប្រាស ឬនឹងដល់នូវសេចក្ដីព្រាត់ប្រាសចាកបា ដូចម្ដេចបាន ។ បទថា **កឹ បន មយំ តំ** សេចក្ដីថា បើដូច្នោះ ហេតុដែលយើងនឹងអនុញ្ញាតឲ្យបារស់នៅ ចេញចាកផ្ទះទៅបួស ដូចម្ដេចបាន ។ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងពាក្យថា **កឹ បន មយន្តំ** យ៉ាងនេះថា ដោយហេតុណា ពួកយើងទើបនឹងអនុញ្ញាតឲ្យបាមានជីវិត ដូច្នេះ ។

**[១៨៩]** បទថា **តត្ថេវ** សេចក្ដីថា ក្នុងទីដែលមាតាបិតាមិនអនុញ្ញាតលោក ត្រង់កន្លែងនោះឯង ។ បទថា **អនន្តរហិតាយ** សេចក្ដីថា ព្រោះមិន

ត្រូវការដោយគ្រឿងក្រាលអ្វីៗ ។

**[១៩០]** បទថា **បរិចារេហិ** សេចក្ដីថា ទំនុកបម្រុងតន្ត្រី របាំ និងអ្នករបាំជាដើម បម្រើខ្លួនតាមសេចក្ដីសុខ ព្រមទាំងពួកសម្លាញ់ក្នុងទីនោះ អធិប្បាយថា នាំទៅកាន់ទីឯណោះ ។ ម្យ៉ាងទៀត បទថា **បរិចារេហិ** លោកអធិប្បាយថា ទំនុកបម្រុងតន្ត្រី របាំ និងអ្នករបាំជាដើម រីករាយត្រេកអរលេងជាមួយពួកសម្លាញ់ ។ បទថា **កាមេ បរិភុញ្ជន្តោ** សេចក្ដីថា បរិភោគភោគៈជាមួយបុត្រភរិយារបស់ខ្លួន ។ បទថា **បុញ្ញានិ ករោន្តោ** សេចក្ដីថា ប្រារព្ធព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ធ្វើកុសលកម្ម ជម្រះផ្លូវទៅកាន់សុគតិ មានការថ្វាយទានជាដើម ។ បទថា **តុណ្ហី អហោសិ** បានដល់មិននិយាយកាត់ពាក្យនិយាយតទៅ ។ គ្រានោះ មាតាបិតារបស់គេនិយាយ ៣ ដង មិនបានសូម្បីពាក្យតប ទើបឲ្យហៅសម្លាញ់មកនិយាយថា សម្លាញ់របស់អ្នកឯងនោះប្រាថ្នានឹងបួស ហាមគេផងចុះ ។ សូម្បីសម្លាញ់ទាំងនោះចូលទៅរកគេ ហើយនិយាយ ៣ ដង ។

**[១៩១]** សូម្បីសម្លាញ់ទាំងនោះ គេក៏ស្ងៀម ។ ដោយហេតុនោះលោកទើបពោលថា **អថខោរដ្ឋបាលស្ស កុលបុត្តស្ស សហាយកា ។បេ។**

តុណ្ហី អហោសិ ។ គ្រានោះ ពួកសម្លាញ់របស់គេ ក៏គិតយ៉ាងនេះថា បើសម្លាញ់នេះមិនបានបួស ក៏នឹងស្លាប់ យើងក៏នឹងមិនបានគុណអ្វីៗ តែគេបួសហើយ ទាំងមាតាបិតាក៏នឹងឃើញដោយគ្រាខ្លះ ទាំងយើងក៏នឹងឃើញក៏ធម្មតា ការបព្វជ្ជានេះជារបស់ធ្ងន់ គេក៏ត្រូវកាន់បាត្រដើរទៅត្រាច់បិណ្ឌបាតរាល់ៗ ថ្ងៃ ព្រហ្មចរិយៈដែលមានការដេកតែមួយពេល ឆាន់តែមួយពេលលំបាកយ៉ាងក្រៃលែង ក៏សម្លាញ់របស់យើងនេះជាអ្នកក្រុង ជាសុខុមាល-ជាតិ គេកាលមិនអាចប្រព្រឹត្តព្រហ្មចរិយៈនោះបាន ក៏នឹងមកក្នុងទីនេះវិញដោយពិត ណ្ហើយចុះ យើងនឹងឲ្យមាតាបិតារបស់គេអនុញ្ញាត ។ សម្លាញ់ទាំងនោះបានធ្វើយ៉ាងនោះ ។

**[១៩២]** សូម្បីមាតាបិតា ធ្វើកតិកាសញ្ញានេះថា ក៏បាបួសហើយគប្បីឲ្យមាតាបិតាបានឃើញផង ទើបអនុញ្ញាតបា ។ ដោយហេតុនោះ លោកទើបពោលថា **អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយា យេន រដ្ឋ-បាលស្ស កុលបុត្តស្ស មាតាបិតរោ ។បេ។ អនុញ្ញាតោសិ មាតាបិតូហិ ។បេ។ ឧទ្ទិសិតព្វោ** ។ បណ្តាបទទាំងនោះ បទថា **ឧទ្ទិសិតព្វោ** សេចក្តីថាគប្បីមកសម្តែងខ្លួនឲ្យមាតាបិតាបានឃើញគ្រាខ្លះ ។

[១៩៣] បទថា **ពលំ គហេត្វា** សេចក្ដីថា បរិភោគភោជនជាទីសប្បាយ តាក់តែងកាយដោយការខាត់ស្បែកជាដើម មានកម្លាំងកាយហើយថ្វាយបង្គំមាតាបិតា លាសាច់ញាតិ ដែលមានទឹកភ្នែកជោកមុខ ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា ។លៗ សូមព្រះមានព្រះភាគ មេត្តាបំបួសខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុមួយរូប ដែលឈរក្នុងទីជិត ត្រាស់ថា ភិក្ខុ បើដូច្នោះ អ្នកចូរឲ្យរដ្ឋបាលបព្វជ្ជា និងឧបសម្បទា ។ ភិក្ខុនោះទទួលព្រះពុទ្ធតម្រាស់ថា ព្រះករុណា ព្រះអង្គ បានកុលបុត្រឈ្មោះរដ្ឋបាល ដែលព្រះជិនស្រីប្រទានជាសទ្ធិវិហារិក ឲ្យបព្វជ្ជា និងឧបសម្បទា ។ ដោយហេតុនោះ លោកទើបពោលថា **អលត្ថ ខោ រដ្ឋបាលោ កុលបុត្តោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ** ។

[១៩៤] បទថា **បហិតត្តោ វិហរន្តោ** សេចក្ដីថា នៅយ៉ាងនេះ ១២ ឆ្នាំ ។ ពិតណាស់ រដ្ឋបាលភិក្ខុនេះ ជានេយ្យបុគ្គល មានបុណ្យសូម្បីព្រមដោយបុណ្យចាស់ ក៏នឹងត្រូវបំពេញសមណធម៌ផង សេចក្ដីប្រាថ្នាមាំថា ព្រះអរហត្តថ្ងៃនេះ ព្រះអរហត្តថ្ងៃនេះ ឆ្នាំទី ១២ ទើបសម្រេចព្រះអរហត្ត ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្ដីថា ព្រះថេរៈគិតថា មាតាបិតា

របស់យើងអនុញ្ញាតឲ្យបួស ពោលថា បាឯងត្រូវមកជួបយើងក្នុងគ្រាខ្លះ ហើយទើបអនុញ្ញាត មាតាបិតាជាអ្នកធ្វើកិច្ចដែលធ្វើបានលំបាក ក៏យើងបួសដោយអធ្យាស្រ័យណា អធ្យាស្រ័យរបស់យើងនោះ ដល់ហើយនូវទីបំផុត ឥឡូវនេះ យើងនឹងទូលលាព្រះមានព្រះភាគ សម្តែងខ្លួនដល់មាតាបិតា ហើយប្រាថ្នានឹងទូលលា ទើបចូលគាល់ ។ បទថា **មនសាកាសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ធ្វើទុកក្នុងព្រះទ័យថា កាលព្រះរដ្ឋបាលទៅហើយ នឹងមានឧបសគ្គណាៗទេហ្ន៎ ។ ទ្រង់ជ្រាបថា នឹងមានពិត ទ្រង់ពិចារណាមើលថា ព្រះរដ្ឋបាលនឹងអាចញាំញីឧបសគ្គនោះបានឬទេ ទ្រង់ឃើញថា ព្រះរដ្ឋបាលនោះសម្រេចព្រះអរហត្ត ក៏ទ្រង់ជ្រាបថា នឹងអាចទើបទ្រង់អនុញ្ញាត ។ ដោយហេតុនោះ ទើបពោលថា **យថា ភគវា អញ្ញាសិ ។បេ។ កាលំ មញ្ញសិ** ដូច្នេះ ។

**[១៩៦]** បទថា **មិគាចិរេ** បានដល់ ព្រះឧទ្យានមានឈ្មោះយ៉ាងនេះ ។ ក៏ព្រះរាជឧទ្យាននោះ ព្រះរាជាព្រះរាជទានដល់ពួកបព្វជិតដែលមកដល់ក្នុងវេលាហួសកាល ដែលទ្រង់អនុញ្ញាតយ៉ាងនេះថា ចូរប្រើប្រាស់ឧទ្យាននេះតាមសេចក្តីសប្បាយចុះ ។ ព្រោះដូច្នោះ ព្រះថេរមិនកើតសូម្បីការគិត

ថា យើងនឹងប្រាប់បិតាមាតាថា យើងមកហើយ មាតាបិតានោះចាត់ចែង ទឹកលាងជើង ប្រេងលាបជើងជាដើម ដល់យើង ហើយចូលទៅកាន់ព្រះរាជឧទ្យាននោះឯង ។ បទថា **បិណ្ឌាយ បាវិសិ** បានដល់ ចូលទៅបិណ្ឌបាតក្នុងថ្ងៃទី ២ ។ បទថា **មជ្ឈិមាយ** បានដល់ ខ្លោងទ្វារកណ្ដាលរបស់ផ្ទះមាន ៧ ខ្លោងទ្វារ ។ បទថា **ឧល្លិក្ខាបេតិ** បានដល់ ឲ្យជាងកាត់សក់ ។ បទថា **ឯតទវោច** បានដល់ បិតាគិតថា សមណៈទាំងនេះឲ្យបុត្រជាទីស្រឡាញ់តែមួយរបស់យើងបួស យើងមិនឃើញសូម្បីតែមួយថ្ងៃ ដូចប្រគល់ទុកក្នុងដៃចោរ សមណៈទាំងនេះធ្វើការគ្រោតគ្រាតយ៉ាងនេះ នៅតែយល់ថា ទីនេះគួរនឹងចូលមកទៀត គួរនឹងទាញចេញទៅពីទីនេះ ទើបពោលពាក្យថា **ឯតំ ឥមេហិ មុណ្ឌកេហិ** ។

**[១៩៧]** បទថា **ញាតិទាសី** បានដល់ ទាសីរបស់ពួកញាតិ ។ បទថា **អាភិទោសិកំ** បានដល់ នំដែលសល់ទុកមួយយប់ គឺ នំដែលកន្លងមួយយប់ទៅហើយ ជារបស់ផ្អូម ។ ក្នុងពាក្យនោះ មានសេចក្ដីរបស់បទដូច្នេះ ។ ឈ្មោះថា **អាភិទោស** ព្រោះត្រូវទោស គឺ សេចក្ដីផ្អូមគ្របសង្កត់ហើយ ។ អភិទោសនោះឯង ក៏គឺ **អាភិទោសិក** ។ នេះជាឈ្មោះរបស់នំដែលកន្លង

ហួសមួយយប់ទៅហើយ គឺ ទំដែលសល់ទុកមួយយប់ យ៉ាងនោះ ។ បទថា **កុម្មាសំ** បានដល់ នំដែលធ្វើដោយស្រូវដំណើប ។

បទថា **ឆឌ្ឌេតុកាមា ហោតិ** សេចក្តីថា ព្រោះដោយទីបំផុត សូម្បីតែទាសកម្មករ ទាំងគោ ក៏មិនគួរបរិភោគ ដូច្នោះ ទាសីប្រាថ្នានឹងចោលនំនោះទៅខាងក្រៅដូចសម្រាម ។ បទថា **សចេតំ** កាត់បទថា **សចេ ឯតំ** ។ ព្រះថេរៈ ហៅទាសីរបស់ខ្លួននោះ ដោយអរិយវោហារថា **ភគិនិ** ។ បទថា **ឆឌ្ឌនីយធម្មំ** សេចក្តីថា ប្រាថ្នានឹងចោលទៅជាសភាវៈ ។ លោកអធិប្បាយទុកថា ម្នាលប្អូនស្រី បើវត្ថុនេះប្រាថ្នានឹងចោលទៅខាងក្រៅជាធម្មតា មិនហួងហែងទុក ចូរនាងចាក់ក្នុងបាត្ររបស់អាត្មានេះចុះ ។

សួរថា ហេតុដូចម្តេច ព្រះថេរៈទើបពោលយ៉ាងនេះ មិនជាការសូមឬ និយាយដូចសូមឬ ។ ឆ្លើយថា មិនមែន ។ ព្រោះហេតុអ្វី ។ ព្រោះគេលះបង់ការហួងហែងហើយ ។ ពិតហើយ វត្ថុណាដែលប្រាថ្នានឹងចោលទៅជាធម្មតា គេលះបង់ការហួងហែងហើយ ម្ចាស់របស់មិនហួងហែងក្នុងវត្ថុណា គួរនឹងពោលថា ចូរនាំរបស់នោះមកទាំងអស់ ចូរចាក់ក្នុងបាត្រនេះចុះ ។ ដោយហេតុនោះឯង ព្រះរដ្ឋបាលនេះ ជាអ្នកតាំងនៅក្នុងអរិយវង្សដ៏

ប្រសើរ ទើបពោលយ៉ាងនេះ ។ បទថា **ហត្ថានំ** បានដល់ ដៃទាំងពីរ តាំងពីកដៃរបស់ព្រះថេរៈ ដែលបង្អោនបាត្រដើម្បីទទួលភិក្ខារ ។ បទថា **បាទានំ** បានដល់ ជើងសូម្បីទាំងពីរតាំងពីជាយសំពត់ស្លៀក ។ បទថា **សរស្ស** បានដល់ សំឡេងដែលពោលថា ម្នាលប្អូនស្រី បើរបស់នោះជាដើម ។ បទថា **និមិត្តំ អគ្គហេសិ** សេចក្តីថា នាងទាសី កាលពិចារណាមើលខ្នងដៃជាដើម ក៏ចាំបាន កំណត់អាការដែលធ្លាប់កំណត់ក្នុងវេលាដែលលោកនៅជាគ្រហស្ថថា ខ្នងដៃ និងជើងទាំងនេះ ដូចជាខ្នងអណ្តើកមាស ម្រាមដៃមូលល្អ ដូចថ្មហរិតាលមូលមានពណ៌លឿង សំឡេងពីរោះដូចរបស់រដ្ឋបាលបុត្ររបស់យើង ។ កាលព្រះរដ្ឋបាលនោះ នៅព្រៃដល់ ១២ ឆ្នាំ និងបរិភោគភោជន គឺ ដុំបាយ ពណ៌សម្បុររបស់រាយកាយ ទើបឃើញជាអ្នកដទៃទៅ ។ ដោយហេតុនោះ ទាសីរបស់ញាតិឃើញព្រះថេរៈនោះ ទើបចាំមិនបាន តែកាន់យកនិមិត្តបាន ។ បទថា **រដ្ឋបាលស្ស មាតរំ ឯតទវោច** សេចក្តីថា សូម្បីពួកនាងមេដាះ អ្នកថ្នាក់ថ្នមអវយវៈតូចធំរបស់ព្រះថេរៈឲ្យផឹកទឹកដោះ ចិញ្ចឹមមកដរាបធំធាត់ ក៏មិនអាចនិយាយនឹងបុត្រដែលបួសហើយ ដល់ភាពជាព្រះមហាខីណាស្រពជាដើមថា លោកម្ចាស់ លោកឬហ្ន៎

គឺ វដ្ដបាលបុត្ររបស់យើង ទើបប្រញាប់ចូលផ្ទះ ពោលពាក្យនេះចំពោះមាតារបស់វដ្ដបាល ។ ស័ព្ទថា **យគ្ឃេ** ជានិបាតចុះក្នុងអត្ថថា ពោលប្រាប់ ។ ស័ព្ទថា **ជេ** ក្នុងពាក្យថា **សចេ ជេ សច្ចំ** នេះ ជានិបាតក្នុងអត្ថថា ស្រែកហៅ ។ ពិតណាស់ មនុស្សទាំងឡាយ រមែងស្រែកហៅអ្នកដែលជាទាសៈទាសីក្នុងជនបទនោះ ។ ព្រោះហេតុនោះឯង គប្បីឃើញសេចក្ដីក្នុងបទនេះយ៉ាងនេះថា នាងទាសីដ៏ចម្រើន បើអ្នកឯងនិយាយពិត ។ បទថា **ឧបសង្កមិ** សេចក្ដីថា ហេតុអ្វីទើបចូលទៅ ។ នាងគិតថា ស្ត្រីទាំងឡាយក្នុងត្រកូលដ៏ធំ កាលចេញទៅខាងក្រៅ រមែងបានទទួលការតិះដៀល នេះជាកិច្ចប្រញាប់ ចាំយើងនឹងប្រាប់កិច្ចនោះដល់សេដ្ឋី ព្រោះដូច្នោះ នាងទើបចូលទៅ ។

**[១៩៨]** បទថា **អញ្ញតរំ កុឌ្ឌមូលំ** សេចក្ដីថា បានឮថា ក្នុងទីនោះមានសាលានៅជិតផ្ទះរបស់ទានបតី ។ ត្រង់សាលានោះ គេចាត់អាសនៈទុកទឹក និងបាយគេក៏ចាត់តាំងទុកក្នុងសាលានោះ បព្វជិតទាំងឡាយ ដែលត្រាច់បិណ្ឌបាត ហើយអង្គុយឆាន់ ។ បើថា បព្វជិតទាំងឡាយប្រាថ្នា ក៏នឹងកាន់យកវត្ថុសូម្បីរបស់ទានបតីទាំងឡាយ ព្រោះដូច្នោះ សូម្បីទីនោះក៏គប្បី

ជ្រាបថា ជិតជញ្ជាំងមួយកន្លែងនៃសាលា ដូច្នេះ របស់ត្រកូលមួយ ។ ពិតណាស់ បព្វជិតទាំងឡាយមិនអង្គុយចាន់ក្នុងទីដែលមិនសមគួរ ដូចមនុស្សក្រទេ ។ សព្ទថា **អត្ថិ** ក្នុងពាក្យថា **អត្ថិ នាម តាត** នេះ ចុះក្នុងអត្ថថា មានហើយ ។ សព្ទថា **នាម** ជានិបាតចុះក្នុងអត្ថថា សួរ ឬសម្គាល់ ។ លោកអធិប្បាយថា បិតាគប្បីពោលថា នែ៎ រដ្ឋបាលកូននឹងមកដល់ក្នុងទីដូច្នេះ បរិភោគនំសល់មួយយប់ រដ្ឋបាលកូន ពួកយើងនោះមានទ្រព្យ មិនមែនមិនមានទ្រព្យ ។ បិតាគប្បីពោលថា ម្យ៉ាងទៀត រដ្ឋបាលកូល អ្នកគប្បីអង្គុយក្នុងទីដូច្នេះ បរិភោគនំដែលសល់មួយយប់របស់ពួកយើងណា ពួកយើងនោះ នៅមានជីវិត មិនមែនស្លាប់ទៅហើយ ។ ម្យ៉ាងទៀត បាឯងសូម្បីត្រូវចិញ្ចឹមឲ្យធំធាត់មកដោយរសភោជនដ៏ល្អ មិនពិការ និងបរិភោគនំសល់មួយយប់គួរខ្ពើមយ៉ាងនេះណា ដូចបរិភោគអម្រឹត បារដ្ឋបាល សមណគុណជាគ្រឿងអាស្រ័យនូវព្រះសាសនា តម្កល់មាំខាងក្នុងរបស់បាឯងនិងមានហើយ ។

ក៏គហបតីនោះ មិនអាចពោលសេចក្ដីនេះឲ្យបរិបូណ៌បាន ព្រោះត្រូវទុក្ខបៀតបៀន ហើយពោលបានត្រឹមតែប៉ុណ្ណេះថា បារដ្ឋបាល មែនឬ

ដែលបាបានបរិភោគទំសល់មួយយប់ ។

ក៏ក្នុងសេចក្តីនេះ អ្នកគិតអក្សរពោលលក្ខណៈនេះទុក ។ លោកធ្វើពាក្យអនាគតកាលថា **បរិភុញ្ជិស្សសិ** ជិតបទក្នុងស័ព្ទថា **អត្ថិ** នេះ ដោយអត្ថដែលមិនបរិបូណ៌ តាមការកំណត់របស់ខ្លួន ។ ពាក្យនោះមានសេចក្តីដូច្នេះថា មានហើយឬ បារដ្ឋបាល ដែលបានឹងឆាន់នំកុម្មាសផ្អូមសូម្បីយើងឃើញនឹងភ្នែកក៏មិនជឿ ទ្រាំមិនបាន ។ គហបតីឈរចាប់ត្រង់កណ្តាប់មាត់បាត្ររបស់ព្រះថេរៈ ពោលពាក្យមានប្រមាណប៉ុណ្ណេះ កាលបិតាឈរចាប់ត្រង់កណ្តាប់មាត់បាត្រនោះឯង សូម្បីព្រះថេរៈ ក៏ឆាន់នំផ្អូមនោះ ដែលបញ្ចេញក្លិនផ្អូមក្នុងកន្លែងដែលបែកដូចពងមាន់ស្អុយ ដូចជាកម្ពូតសុនខ ។ ឮថា បុថុជ្ជនក៏មិនអាចស៊ីនំដូច្នោះបាន ។ តែព្រះថេរៈ តាំងនៅក្នុងអរិយឫទ្ធិ ឆាន់ដូចគ្នានឹងឆាន់អម្រឹតមានរសទិព្វ ទទួលទឹកដោយធម្ម-ក្រក លាងបាត្រ មាត់ និងដៃជើង ពោលពាក្យជាដើមថា **កុតោ នោ គហបតិ** ។

ក្នុងបទទាំងនោះ បទថា **កុតោ នោ** ប្រែថា ពីទីណាហ្ន៎ ។ បទថា **គេហំ ទានំ** សេចក្តីថា មិនបានទានដោយទេយ្យធម៌ឡើយ ។ បទថា ន

បច្ចក្ខានំ សេចក្ដីថា មិនបាន សូម្បីពាក្យហៅដោយបដិសណ្ឋារៈយ៉ាងនេះថា បាវជ្ជបាល បាលួមអត់ធន់បានខ្លះឬ មកដោយសេចក្ដីលំបាកបន្តិចបន្តួចខ្លះឬ បាមិនបាន់អាហារក្នុងផ្ទះមុនឬ ។

ក៏ព្រោះហេតុអ្វី ព្រះថេរៈទើបពោលយ៉ាងនេះ ។ ព្រោះអនុគ្រោះបិតា ។

បានឮថា ព្រះថេរៈគិតយ៉ាងនេះថា បិតានេះ និយាយចំពោះយើងយ៉ាងណា នឹងនិយាយចំពោះបព្វជិតសូម្បីដទៃដូច្នោះ ក៏ក្នុងព្រះពុទ្ធសាសនាខាងក្នុងរបស់ពួកភិក្ខុដែលមិនបាំងគុណដូចយើង ដូចជាផ្កាបទុមក្នុងចន្លោះស្លឹក ដូចភ្លើងត្រូវផេះមិនបាំង ដូចខ្លឹមចន្ទន៍ដែលស្រោយមិនបាំង ដូចកែវមុក្តាដែលដីមិនបាំង ដូចព្រះចន្ទដែលពពកមិនបាំង រមែងមិនមានពាក្យបែបនេះ នឹងប្រព្រឹត្តទៅក្នុងភិក្ខុទាំងនោះ បិតាក៏នឹងតាំងនៅក្នុងសេចក្ដីប្រយ័ត្នប្រយែង ព្រោះហេតុនោះ ព្រះថេរៈទើបពោលយ៉ាងនេះ ដោយសេចក្ដីអនុគ្រោះ ។

បទថា **ឯហិ តាត** សេចក្ដីថា គហបតីនិយាយថា បាកុំជាអ្នកមិនមានផ្ទះ មកយើងនឹងទៅផ្ទះ ។ បទថា **អលំ** បានដល់ ព្រះថេរៈកាលបដិសេធ

ទើបពោលយ៉ាងនេះ ព្រោះជាអ្នកកាន់ឯកាសនិកង្គធុតង្គយ៉ាងឧក្រិដ្ឋ ។ បទថា **អធិវាសេសិ** សេចក្ដីថា តែព្រះថេរៈ ដោយប្រក្រតីជាអ្នកកាន់សបទានចារិកង្គធុតង្គយ៉ាងឧក្រិដ្ឋ ទើបមិនទទួលភិក្ខា ដើម្បីឆាន់ក្នុងថ្ងៃស្អែក តែទទួលដោយសេចក្ដីអនុគ្រោះមាតា ។ បានឮថា មាតារបស់ព្រះថេរៈរលឹកហើយរលឹកទៀតដល់ព្រះថេរៈ ក៏កើតសេចក្ដីសោកយ៉ាងធំ ស្រែកទួញយំ មានមុខជោកទៅដោយទឹកភ្នែក ។ ព្រោះដូច្នោះ ព្រះថេរៈគិតថា បើយើងមិនទៅសួរសុខទុក្ខមាតានោះ បេះដូងរបស់មាតានឹងគប្បីបែក ទើបទទួលដោយសេចក្ដីអនុគ្រោះ ។

**[១៩៩]** បទថា **ទ្វេ បុញ្ជេ** សេចក្ដីថា ឲ្យធ្វើជា ២ គំនរ គឺ ប្រាក់មួយគំនរ មាសមួយគំនរ ។

សួរថា ក៏គំនរទ្រព្យធំយ៉ាងណា ។ ឆ្លើយថា ធំដូចជាបុរសឈរខាងនេះ មើលមិនឃើញមជ្ឈិមបុរសដែលឈរខាងឯណោះ ។ បិតាកាលសម្ដែងគំនរកហាបណៈ និងគំនរមាស ទើបពោលថា **ឥទំ តេ** ។ បទថា **មត្តិកំ** ប្រែថា ទ្រព្យខាងមាតា អធិប្បាយថា ទ្រព្យនេះជារបស់យាយកាលមាតាមកផ្ទះនេះ មាតាក៏ឲ្យទ្រព្យដើម្បីប្រយោជន៍ដល់របស់ក្រអូប និង

ផ្កាឈើជាដើម ។ បទថា **អញ្ញំ បិត្តិកំ អញ្ញំ បិតាមហំ** សេចក្ដីថា ទ្រព្យណាជារបស់បិតា និងជីតារបស់កូន ទ្រព្យនោះដែលរក្សាទុក និងដែលប្រើប្រាស់យ៉ាងដទៃ មាននៅសល់ច្រើន ។ ក៏ក្នុងពាក្យនោះ ពាក្យថា **បិតាមហំ** នេះ គប្បីជ្រាបថា លុបតទ្ធិត ។ បាឋៈថា **បេតាមហំ** ក៏មាន ។ បទថា **សក្កា តាត** វដ្ឋបាល សេចក្ដីថា វដ្ឋបាលកូន មិនមែនបព្វជិតតែម្យ៉ាងដែលអាចធ្វើបុណ្យបាន សូម្បីអ្នកគ្រប់គ្រងផ្ទះបរិភោគភោគៈ ក៏អាចតាំងនៅក្នុងសរណៈ ៣ សមាទានសិក្ខាបទ ៥ ធ្វើបុណ្យ មានទានជាដើមឲ្យក្រៃលែងឡើងបាន មកចុះបា កូនគប្បី ។ល។ ចូរធ្វើបុណ្យ ។ ព្រះថេរៈពោលយ៉ាងនេះថា **តតោនិទានំ** សំដៅដល់ សេចក្ដីសោកជាដើម ដែលកើតដល់អ្នករក្សាទ្រព្យនោះៗ និងដល់អ្នកវិនាសទ្រព្យ ដោយអំណាចរាជភ័យជាដើម ព្រោះទ្រព្យជាហេតុ ព្រោះទ្រព្យជាបច្ច័យ ។ គ្រាព្រះថេរៈពោលយ៉ាងនោះ សេដ្ឋីគហបតីគិតថា យើងនាំទ្រព្យនេះមកដោយបំណងនឹងឲ្យបុត្រនេះសឹក ឥឡូវនេះ បុត្រនោះ ត្រឡប់ផ្ដើមទូន្មានធម៌ដល់យើងណ្ហើយចុះ គេនឹងមិនធ្វើតាមពាក្យរបស់យើងពិត ហើយក៏ក្រោកឡើងទៅឲ្យបើកទ្វារបន្ទប់របស់នាងជាបុត្រនោះ បញ្ជូនមនុស្សទៅប្រាប់ថា នេះ

ជាស្វាមី ពួកនាងចូរទៅ ធ្វើយ៉ាងណា ព្យាយាមចាប់មកឲ្យបាន ។ នាងរបាំទាំងឡាយនៅក្នុងវ័យស្រស់ស្អាត ទៅលោមព័ទ្ធព្រះថេរៈ ។ លោកពោលពាក្យថា **បុរាណទុតិយិកា** ជាដើម សំដៅដល់ស្ត្រីជាប្រធាន ២ នាក់ ក្នុងបណ្ដានាងរបាំទាំងនោះ ។ បទថា **បច្ចេកំ បាទេសុ គហេត្វា** បានដល់ ចាប់ព្រះថេរៈនោះត្រង់ជើងម្ខាងម្នាក់ ។ បទថា **កីទិសា នាម តាត អយ្យបុត្ត អច្ឆរាយោ** បពិត្រអយ្យបុត្ត លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុស្រីអប្សរណា ពួកស្រីអប្សរនោះ ល្អដូចម្ដេចទៅ ។ ព្រោះហេតុអ្វី នាងរបាំទាំងនោះ ទើបពោលយ៉ាងនេះ ។ បានឮថា គ្រានោះមនុស្សទាំងឡាយឃើញស្ដេចកម្លោះខ្លះ ព្រាហ្មណ៍កម្លោះខ្លះ កូនសេដ្ឋីខ្លះ ជាច្រើន លះបង់សម្បត្តិដ៏ធំទាំងគ្នាបួស មិនដឹងគុណរបស់បព្វជ្ជា ទើបតាំងពាក្យសួរថា ហេតុអ្វី អ្នកទាំងនេះទើបបួស ។ ពេលនោះ មនុស្សពួកដទៃទើបពោលថា ព្រោះហេតុនៃទេពអប្សរ ទេវនាដកៈ ។ ពាក្យនោះបានផ្សាយទៅយ៉ាងធំទូលាយ ។ នាងរបាំទាំងអស់នោះ ចាំពាក្យនោះបានហើយ ទើបពោលយ៉ាងនេះ ។ ព្រះថេរៈកាលនឹងបដិសេធ ទើបពោលថា **ន ខោ មយំ** ភគិនី ប្អូនស្រី យើងមិនមែនប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុនៃនាងអប្សរ ។ បទ

ថា *សមុទាចរតិ* ប្រែថា រមែងហៅ រមែងពោល ។ បទថា **តត្ថ មុច្ចិតា** **បបតីសុ** សេចក្តីថា នាងរបាំទាំងឡាយ ឃើញព្រះថេរៈហៅដោយវាទៈថា ម្នាលប្អូនស្រី ទើបគិតថា ពួកយើងមិនបានចេញទៅខាងក្រៅដល់ ១២ ឆ្នាំ ដោយគិតថា ថ្ងៃនេះអ្នកនឹងមក ពួកយើងគប្បីរស់នៅដោយអំណាចនៃទារក ពួកណា យើងអាស្រ័យលោកក៏មិនបានទារកពួកនោះ យើងជាអ្នកសាប-សូន្យទាំងខាងឯណោះទាំងខាងដទៃ ឈ្មោះថា លោកនេះជារបស់យើងឬ ព្រោះដូច្នោះ ពួកនាងរបាំសូម្បីទាំងនោះ កាលគិតដើម្បីខ្លួនថា ឥឡូវនេះ យើងមិនមានទីពឹងហើយ ក៏កើតសេចក្តីសោកយ៉ាងខ្លាំងថា ឥឡូវនេះ លោក មិនត្រូវការពួកយើង និងពួកយើងក៏នៅជាករិយារបស់គេ គង់នឹងសម្គាល់ ដូចក្មេងស្រី ដេកនៅក្នុងផ្ទៃរបស់មាតាជាមួយគ្នា ទើបដួលសន្លប់ក្នុងទីនោះ ឯង អធិប្បាយថា ដួលទៅ ។ បទថា **មា នោ វិហេឋេថ** សេចក្តីថា កុំ សម្តែងទ្រព្យ និងបញ្ជូនមាតុគ្រាមមកបៀតបៀនអាត្មាឡើយ ។

សួរថា ព្រះថេរៈពោលយ៉ាងនោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះ អនុគ្រោះមាតាបិតា ។ បានឮមកថា សេដ្ឋីនោះសម្គាល់ថា ដែលឈ្មោះថា ភេទបព្វជិតសៅហ្មង យើងនឹងឲ្យដោះភេទបព្វជិតចេញ ឲ្យងូតទឹក បរិភោគ

រួមគ្នាបីនាក់ ទើបមិនថ្វាយកិច្ចាដល់ព្រះថេរៈ ។ ព្រះថេរៈគិតថា មាតាបិតាទាំងនេះ ធ្វើអន្តរាយក្នុងអាហារដល់ព្រះខីណាស្រពដូចយើង នឹងគប្បីប្រសព្វវត្ថុដែលមិនមែនបុណ្យយ៉ាងច្រើន ទើបពោលយ៉ាងនេះ ដោយការអនុគ្រោះមាតាបិតានោះ ។

[២០០] បទថា **គាថា អភាសិ** ប្រែថា បានពោលគាថាទាំងឡាយ ។ បណ្ដាបទទាំងនោះ ដោយបទថា **បស្ស** ព្រះថេរៈពោលសំដៅដល់មនុស្សដែលនៅជិត ។ បទថា **ចិត្តំ** ប្រែថា ដែលចិត្តវិចិត្រហើយ ។

បទថា **ពិម្ពំ** ប្រែថា អត្តភាព ។ បទថា **អរុកាយំ** បានដល់ ប្រជុំនៃដំបៅគឺ ដំបៅទាំង ៩ ។ បទថា **សមុស្សិតំ** បានដល់ ដែលចងឆ្អឹង ៣០០ កំណាត់នឹងសរសៃ ៩០០ បូកដោយដុំសាច់ ៩០០ លើកឡើងដោយជុំវិញ ។ បទថា **អាតុរំ** បានដល់ ដុតរោលជានិច្ច ព្រោះដុតរោលដោយជរា ដុតរោលដោយរោគ និងដុតរោលដោយកិលេស ។ បទថា **ពហុសង្កប្បំ** សេចក្ដីថា មានសេចក្ដីត្រិះរិះច្រើន ដោយសេចក្ដីត្រិះរិះ គឺ សេចក្ដីប្រាថ្នាដែលកើតឡើងដល់សាកសពពួកជនទៃ ។ ពិតហើយ ពួកបុរសរមែងកើតសេចក្ដីត្រិះរិះក្នុងរាងកាយរបស់ស្ត្រី ពួកស្ត្រីក៏រមែងកើតសេចក្ដីត្រិះរិះ

ក្នុងរាងកាយរបស់បុរសទាំងនោះ ។ម្យ៉ាងទៀត ពួកក្អែក និងសុនខជាដើម រមែងប្រាថ្នារាងកាយនោះ សូម្បីជាសាកសពដែលគេចោលក្នុងព្រៃស្មសាន ព្រោះដូច្នោះ ទើបឈ្មោះថា មានសេចក្តីត្រិះរិះច្រើន ។ បទថា **យស្ស នត្ថិ ធុវំ ឋិតិ** សេចក្តីថា កាយណា មិនមានសេចក្តីតាំងមាំដោយចំណែកមួយ ដូចជាថ្ងៃបណ្តើរកូន និងដូចជាដុំពពុះទឹកជាដើម សេចក្តីដែលរាងកាយនោះ មានការបែកធ្លាយទៅជាធម្មតា ជារបស់ពិត ។ បទថា **តចេន ឱនទ្ធំ** បានដល់ ជណ្តប់ដោយស្បែកមនុស្សស្រស់ ។ បទថា **សហ វត្ថេភិ សោភតិ** សេចក្តីថា សូម្បីរូបដែលតាក់តែងឲ្យល្អស្អាតដោយរបស់ក្រអូបជាដើម ដោយកុណ្ឌលមណី រមែងល្អស្អាតព្រមដោយសំពត់ ដែលតាក់តែងរូប វៀរសំពត់ចេញ ក៏គួរខ្ពើម មិនគួរសម្លឹងមើល ។ បទថា **អល្លត្តកកតា** បានដល់ ស្រោចដោយទឹកល័ក្តស្រស់ ។ បទថា **ចុណ្ណកមក្ខិតំ** បានដល់ យកគ្រាប់ស្ពៃដែលបៀតបៀនត្រង់ផ្ទៃមុខជាដើមចេញ យកដីប្រៃដែលកម្ចាត់នូវឈាម យកម្សៅល្ងធ្វើលោហិតឲ្យថ្លា យករមៀតលាបស្បែក យកម្សៅលាបមុខ ។ ដោយហេតុនោះ រាងកាយនោះ ទើបល្អស្អាតយ៉ាងក្រៃលែង ។ លោកពោលពាក្យនោះ សំដៅយកកាយនោះ ។ បទថា **អដ្ឋបទកតា** សេចក្តីថា ធ្វើដោយ

ទឹកផ្សេងៗ ទាញទៅធ្វើឲ្យជាវង់មូល ជុំវិញថ្ងាស់ឲ្យជា ៨ ផ្នត់ ។ បទថា **អញ្ជនី** បានដល់ បំពង់បន្តក់ភ្នែក ។ បទថា **ឱទហិ** ប្រែថា តាំងទុក ។ បទថា **បាសំ** បានដល់ សំណាញ់ដែលធ្វើដោយព្រោល ។ បទថា **នាសទា** បានដល់ មិនជាប់ ។ បទថា **និវាបំ** បានដល់ អាហារដូចជាចំណី និងស្មៅ ដែលពោលទុកក្នុងនិវាបសូត្រ ។ បទថា **កន្ទន្តេ** ប្រែថា កន្ទក់កន្ទេញ ។

ក៏ព្រះថេរៈ សម្តែងមាតាបិតាឲ្យដូចជាព្រានបាញ់ម្រឹគ ដោយគាថានេះ ។ សម្តែងពួកញាតិក្រៅពីនោះ ដូចជាបរិវាររបស់ព្រានបាញ់ម្រឹគ ប្រាក់ និងមាស ដូចសំណាញ់ព្រោល ភោជនដែលខ្លួនបរិភោគ ដូចចំណី និងស្មៅ ខ្លួនឯងដូចម្រឹគធំ ។ ប្រៀបដូចម្រឹគធំស៊ីចំណី និងស្មៅជាអាហារ តាមត្រូវការ ផឹកទឹក អើតកត្រួតមើលបរិវារ គិតថា យើងទៅកាន់ទីនេះ នឹងរួចផុតភ័យ លោតឡើងមិនជាប់អន្ទាក់របស់ពួកនាយព្រានម្រឹគ ដែលកំពុងកន្ទក់កន្ទេញចូលព្រៃទៅ ត្រូវខ្យល់ល្ហើយៗ បក់តិចនៅខាងក្រោមគុម្ពឈើ ដូចឆត្រមានម្ជប់ក្រាស់ ឈរពិចារណាផ្លូវដែលមក យ៉ាងណា ព្រះថេរៈក៏ដូច្នោះដែរ លុះពោលគាថាទាំងនេះហើយ ក៏ហោះទៅប្រាកដត្រង់ព្រះរាជឧទ្យានឈ្មោះ មិគាចិរៈ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះថេរៈទើបហោះចេញទៅ ។

ឆ្លើយថា បានឮថា សេដ្ឋីបិតារបស់ព្រះថេរៈនោះ ឲ្យធ្វើកូនវនុក ទុកត្រង់ខ្លោងទ្វារទាំង ៧ បង្គាប់អ្នកប្រដាល់ថា បើព្រះថេរៈនឹងចេញទៅ ចូរចាប់ដៃជើងព្រះថេរៈ ដោះសំពត់កាសាយចេញឲ្យកាន់ភេទគ្រហស្ថ ។ ព្រោះដូច្នោះ ព្រះថេរៈទើបគិតថា មាតាបិតានោះ ចាប់ដៃជើងព្រះមហាខី-ណាស្រេពដូចយើង នឹងគប្បីប្រសព្វវត្ថុមិនមែនបុណ្យ ប្រការនោះកុំបាន មានដល់មាតាបិតាឡើយ ទើបបានហោះទៅ ។

ព្រះថេរៈបរសមុទ្ទវាសិត ឈរពោលគាថាទាំងនេះហើយ

ហោះទៅប្រាកដត្រង់ព្រះរាជឧទ្យាន មិគាចិរៈរបស់ព្រះបាទ

កោរព្យៈ ។ ប្រាកដដោយពាក្យមានដូច្នេះ ។

**[២០១]** ពាក្យថា ***មិគ្គវោ*** ជាឈ្មោះរបស់អ្នករក្សាព្រះឧទ្យាននោះ ។ បទថា ***សោ ធេន្តោ*** បានដល់ ធ្វើផ្លូវទៅព្រះរាជឧទ្យានឲ្យស្មើ ឲ្យជម្រះស្ថានទីដែលគួរនឹងជម្រះ ឲ្យបោសស្ថានទីដែលគួរបោស និងធ្វើការពង្រាយខ្សាច់ រោយផ្កាឈើ តាំងធ្នាំងទឹកពេញដោយទឹក តាំងដើមចេកជាដើម ទុកខាងក្នុងព្រះរាជឧទ្យាន ។ បទថា ***យេន រាជា កោរព្យោ តេនុបសង្កមិ***

សេចក្ដីថា អ្នករក្សាសួន គិតថា ព្រះរាជារបស់យើង ត្រាស់សរសើរកុល-បុត្រនេះគ្រប់កាល ទ្រង់មានបំណងនឹងជួប តែទ្រង់មិនជ្រាបថា កុលបុត្រនោះមកហើយ ព្រោះដូច្នោះ បណ្ណាការនេះជារបស់ធំក្រៃលែង យើងនឹងទៅក្រាបទូលព្រះរាជ ទើបចូលទៅគាល់ព្រះបាទកោរព្យៈ ។

បទថា **កិត្តយមានោ អហោសិ** សេចក្ដីថា បានឮថា ព្រះរាជានោះ រលឹកហើយរលឹកទៀតដល់ព្រះថេរៈ ត្រាស់អំពីគុណថា កុលបុត្តអ្នកលះបង់សម្បត្តិដ៏ធំបែបនោះបួសហើយ ត្រឡប់មកវិញហើយក៏មិនព្រេកអរទាំងក្នុងកណ្ដាលពួកពល ទាំងកណ្ដាលនាងរបាំ ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាក ។ ព្រះបាទកោរព្យៈនេះ ទ្រង់កាន់យកគុណប្រការនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **វិសជ្ជេថាតិ វត្វា** សេចក្ដីថា វត្ថុណាសមគួរដល់បុគ្គលណាក្នុងពួកអ្នកជិតស្និទ្ធ មហាអាមាត្រ និងពលជាដើម ក៏ឲ្យព្រះរាជទានវត្ថុនោះ ដល់អ្នកនោះ ។ បទថា **ឧស្សាដាយ** សេចក្ដីថា ដែលកុះករ និងកុះករហើយ ។ ទ្រង់នាំបរិស័ទដ៏ច្រើនកុះករដោយមហាមាត្រដែលជាធំជាដើម ចូលទៅហើយ ។ ព្រះរាជាទ្រង់សំគាល់ថា កម្រាលឈើនៅខ្វះ ទើបទ្រង់ធ្វើឲ្យថ្នាក់ផ្កាឈើជាដើមក្រាស់ កំណត់ទទឹងទុក មិនពោល

ហើយអង្គុយក្នុងទីនោះ មិនគួរ ទើបពោលយ៉ាងនេះ ថា **ឥធ ករំ វឌ្ឍបា-លោកជត្តរេ និសីទតូ** ព្រះវឌ្ឍបាលដ៏ចម្រើន មេត្តាអង្គុយលើកម្រាលឈើក្នុងទីនេះ ។

**[២០២]** បទថា **បារិជុញ្ញានិ** សេចក្តីថា ការៈ គឺ សេចក្តីវិនាសបានដល់ ការអស់ទៅ ។ បទថា **ជិណ្ណោ** បានដល់ ចាស់ គ្រោះជរា ។ បទថា **វិឌ្ឍោ** គឺ ចម្រើនដោយវ័យ ។

បទថា **មហល្លកោ** គឺ ចាស់ដោយជាតិ ។ បទថា **អទ្ធគតោ** គឺ កន្លងកាល កន្លងវ័យ ។

បទថា **វយោអនុប្បត្តោ** គឺ ដល់បច្ឆិមវ័យហើយ ។ បទថា **បព្វជតិ** បានដល់ ទៅវិហារជិតៗ ថ្វាយបង្គំភិក្ខុ ឲ្យលោកករុណា អង្វរថា កាលខ្ញុំនៅជាកម្លោះ ធ្វើកុសលទុកច្រើន ឥឡូវនេះ ជាមនុស្សចាស់ ឈ្មោះថាការបព្វជ្ជានេះជារបស់មនុស្សចាស់ ខ្ញុំនឹងបោសលានព្រះចេតិយ ធ្វើការបោសសម្អាតទីនៅ មេត្តាឲ្យខ្ញុំបួសចុះ លោកម្ចាស់ ។ ព្រះថេរៈក៏ឲ្យបួសដោយសេចក្តីករុណា ។ លោកពោលពាក្យនេះ សំដៅដល់ការបួសកាលចាស់នោះ ។ សូម្បីក្នុងវារៈទីពីរ ក៏ន័យនេះដូចគ្នា ។

**[២០៤]** បទថា **អប្បាពាធោ** បានដល់ មិនមានរោគ ។ បទថា **អប្បតង្កោ** បានដល់ មិនមានទុក្ខ ។ បទថា **សមវេបាកិនិយា** បានដល់ ប្រកបដោយភ្លើងធាតុដែលរំលាយអាហារស្មើល្អ ។ បទថា **គហណិយា** បានដល់ តេជោធាតុដែលកើតពីកម្ម ។ អាហាររបស់បុគ្គលណា ដែលបរិភោគល្មមហើយ រមែងជ្រួតជ្រាប ក៏ឬថា របស់បុគ្គលណា រមែងតាំងនៅយ៉ាងនោះ ដូចអាហារដែលនៅជាកញ្ចប់ ប្រកបដោយភ្លើងធាតុ ដែលរំលាយស្មើគ្នាទាំងពីរនោះ ។

ចំណែកបុគ្គលណាវេលាបរិភោគហើយ ក៏កើតសេចក្តីត្រូវការអាហារ បុគ្គលនេះ ឈ្មោះថា ប្រកបដោយភ្លើងធាតុដែលរំលាយស្មើល្អ ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** បានដល់ មិនត្រជាក់ពេកមិនក្តៅពេក ដោយហេតុនោះឯង ។

**[២០៥]** បទថា **អនុបុព្វេន** សេចក្តីថា តាមលំដាប់ ជាដើមថា ព្រះរាជាទ្រង់ពិចារណា ។ ក្នុងវារៈទីពីរ ក៏គប្បីជ្រាបដោយលំដាប់ មានរាជភ័យ ចោរភ័យ និងឆាតកភ័យ គឺ ភ័យកើតពីសេចក្តីស្រេកឃ្លានជាដើម ។

**[២០៧]** បទថា **ធម្មុទ្ទេសា ឧទ្ទិដ្ឋា** បានដល់ លើកធម្មនិទ្ទេសឡើង

សម្តែង ។

បទថា **ឧបនីយតិ** បានដល់ ទៅជិតជរាមរណៈ ឬត្រូវនាំទៅក្នុងជរាមរណៈនោះ ដោយការអស់អាយុ ។

បទថា **អទ្ធុវោ** គឺ វៀរចាកការតាំងនៅយឺនយូរ ។ បទថា **អតាណោ** បានដល់ វៀរចាកសមត្ថភាពដែលនឹងតតាំង ។ បទថា **អនភិស្សរោ** បានដល់ មិនមានសរណៈ គឺ វៀរចាកសមត្ថភាពដែលនឹងមានសរណៈឲ្យក្រៃលែងហើយបានធូរចិត្ត ។ បទថា **អស្សកោ** គឺ មិនមានអ្វីជារបស់ខ្លួន វៀរចាករបស់ដែលជារបស់ខ្លួន ។ បទថា **សព្វំ បហាយ គមនីយំ** បានដល់ លោកចាំបាច់ត្រូវលះបង់វត្ថុទាំងពួង ដែលកំណត់ថា ជារបស់ខ្លួនហើយទៅ ។ បទថា **តណ្ហាទាសោ** ប្រែថា ជាទាសនៃតណ្ហា ។

[២០៨] បទថា **ហត្ថិស្មឹ** ប្រែថា ក្នុងសិល្បៈដំរី ។

បទថា **កតាវី** បានដល់ ធ្វើកិច្ចសម្រេចហើយ សិក្សាសម្រេចហើយ អធិប្បាយថា មានសិល្បៈស្ទាត់ជំនាញហើយ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **ឧរុពលី** បានដល់ បរិបូរណ៍ដោយកម្លាំងភ្លៅ ។

ពិតហើយ បុគ្គលណាមានកម្លាំងដែលចាប់ខែល និងអាវុធចូលទៅ

កាន់កងទ័ពរបស់សត្រូវ ទម្លាយវត្ថុដែលមិនទាន់បានទម្លាយ ថែរក្សាវត្ថុដែលទម្លាយបានហើយ នាំរាជសម្បត្តិដែលនៅក្នុងដៃរបស់សត្រូវមកបាន បុគ្គលនេះឈ្មោះថា មានកម្លាំងក្លៅ ។ បទថា **ពាហុពលី** បានដល់ បរិបូរដោយកម្លាំងដើមដៃ ។ ពាក្យដ៏សេសក៏ដូចនឹងន័យមុនទុំះឯង ។ បទថា **អលមត្ថោ** ប្រែថា មានអត្តភាពអង់អាច ។ បទថា **បរិយោធាយ វត្តិស្សន្តិ** បានដល់ កំណត់យកថា នឹងគ្របសង្កត់អន្តរាយដែលកើតឡើងប្រព្រឹត្តទៅ ។ បទថា **សំវិជ្ជតិ ខោ ភោ រដ្ឋបាល ឥមស្មឹ រាជកុលេ បហូតំ ហិរញ្ញ-សុវណ្ណំ** ព្រះរាជានោះ ទ្រង់នាំហេតុនៃធម្មុទ្ទេសក្នុងចំណែកខ្ពស់មកពោលថា បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ប្រាក់មាសជាច្រើនក្នុងរាជកុលនេះមាន ។

**[២១២]** បទថា **អថាបរំ ឯតទវោច** សេចក្តីថា ព្រះថេរៈបានពោលលំដាប់ធម្មុទ្ទេស ៤ ដោយន័យជាដើមថា **បស្សាមិ លោកេ** ។ ក្នុងបទទាំងនោះ បទថា **ភិយ្យោ ច កាមេ អភិបត្ថយន្តិ** សេចក្តីថា ប្រាថ្នាវត្ថុ-កាម និងកិលេសកាមក្រៃលែងៗ ឡើង យ៉ាងនេះថា បានមួយចង់បានពីរ បានពីរចង់បានបួន ។ បទថា **បសយ្ហ** បានដល់ គ្របគ្រងសម្បត្តិ ។ បទថា **សសាគរន្តំ** បានដល់ ព្រមដោយសាគរជាទីបំផុត ។ បទថា **ឱរំ សមុទ្ទស្ស**

សេចក្តីថា មិនឆ្អែតដោយរដ្ឋរបស់ខ្លួន មានសមុទ្រជាដែន ។ បទថា **ន ហត្ថិ** កាត់បទថា **ន ហិ អត្ថិ** ប្រែថា មិនមានឡើយ ។ បទថា **អហោ វតានោ** កាត់បទថា **អហោ វត នុ** ។ មយ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **អមរាតិចាហុ** កាត់បទថា **អមរំ ឥតិ ច អហុ** ។ លោកអធិប្បាយថា ពួកញាតិលោមព័ទ្ធញាតិដែលស្លាប់ទួញយំ ជនទាំងឡាយពោលពាក្យជាដើមថា ឱ ហ្ន៎ បងរបស់យើងស្លាប់ បុត្ររបស់យើងស្លាប់ ។

បទថា **ផុសន្តិ ផស្សំ** គឺ ត្រឹមត្រូវមរណផស្សៈ បទថា **តថេវ ផុដ្ឋោ** សេចក្តីថា បុគ្គលល្ងង់យ៉ាងណា សូម្បីអ្នកប្រាជ្ញក៏ដូច្នោះដែរ មរណផស្សៈពាល់ត្រូវហើយ ឈ្មោះថា បុគ្គលដែលមរណផស្សៈមិនពាល់ត្រូវមិនមាន ។ សេចក្តីប្លែកគ្នាមានដូច្នេះ ។ បទថា **ពាលោ ហិពាល្យា វិធិតោវ សេតិ** សេចក្តីថា បុគ្គលល្ងង់អាស្រ័យមរណផស្សៈ ចាក់ដោតហើយដេកនៅ ព្រោះជនពាលត្រូវមរណផស្សៈ ប៉ះខ្ទប់ហើយដេកនៅ រមែងញាប់ញ័រ រមែងប្រែប្រួលដោយវិប្បដិសារជាដើមថា យើងមិនបានធ្វើសេចក្តីល្អទុកហ្ន៎ ។ បទថា **ធីរោ ចន វេធតិ** សេចក្តីថា អ្នកប្រាជ្ញឃើញសុគតិនិមិត្ត ក៏មិនញាប់ញ័រ មិនរន្ធត់ ។ បទថា **យាយ រោសានំ ឥធាធិគច្ឆតិ** សេចក្តីថា សម្រេច

ព្រះអរហត្តទីបំផុតនៃកិច្ចទាំងពួងក្នុងលោកនេះដោយបញ្ញា យ៉ាងណា ក៏បញ្ញានោះប្រសើរខ្ពង់ខ្ពស់ជាងទ្រព្យ ។ បទថា **អព្យោសិតត្តា** សេចក្តីថា ព្រោះនៅមិនទាន់ចប់ព្រហ្មចរិយៈ អធិប្បាយថា ព្រោះមិនទាន់បានសម្រេចអរហត្ត ។ បទថា **ភវាភវេសុ** បានដល់ ក្នុងហីនភព និងប្រណីតភព ។ បទថា **ឧបេតិគព្ភញ្ច បរញ្ច លោកំ** សេចក្តីថា កាលបុគ្គលទាំងនោះធ្វើបាបហើយ សត្វណាមួយត្រូវប្រសព្វសង្សារវដ្តបន្តៗ ទៅ រមែងចូលដល់គភ៌ និងលោកដទៃ ។ បទថា **តស្សប្បបញ្ញោ** សេចក្តីថា បុគ្គលមិនមានបញ្ញា ក៏ជឿតាមបុគ្គលមិនមានបញ្ញានោះ ដូច្នោះ ។

បទថា **សកម្មុនា ហញ្ញតិ** សេចក្តីថា រមែងក្តៅក្រហាយដោយកម្មមានវាយដោយផ្តៅជាដើម ដោយអំណាចកម្មដែលខ្លួនឯងធ្វើទុក ។ បទថា **បេច្ច បរម្ហិ លោកេ** សេចក្តីថា ទៅអំពីលោកនេះហើយ ក្តៅក្រហាយក្នុងលោកដទៃ គឺ អបាយ ។ បទថា **វិរូបរូបេន** មានរូបផ្សេងៗ អធិប្បាយថា មានសភាពផ្សេងៗ ។ បទថា **កាមគុណេសុ** បានដល់ ឃើញទោសក្នុងកាមគុណទាំងពួង ទាំងក្នុងបច្ចុប្បន្ន និងខាងមុខ ។ បទថា **ទហរា** ប្រែថា ខ្សោយ ដោយទីបំផុតត្រឹមតែជាកលលៈ ។ បទថា **វុឌ្ឍា** គឺ កើតមួយរយ

ឆ្នាំ ។ បទថា **អបណ្ណកំសាមញ្ញំ សេយ្យោ** សេចក្តីថា មហារាជ អាត្មាភាពបួស ព្រោះពិចារណាហើយថា សាមញ្ញផលប៉ុណ្ណោះមិនខុស មិនបែកជាពីរ នាំសត្វចេញចាកទុក្ខដោយចំណែកតែមួយ ជាធម៌ដ៏ក្រៃលែងផងប្រណីតផង ព្រោះដូច្នោះ មហារាជទ្រង់ឃើញ ទ្រង់ស្តាប់យ៉ាងណា ទើបត្រាស់ប្រការណា ចូរចាំអាត្មាភាពថា អាត្មាភាពឃើញ និងស្តាប់សេចក្តីនេះទើបចេញបួស ហើយក៏បញ្ចប់ទេសនានោះឯង ។

" ចប់អដ្ឋកថា រដ្ឋបាលសូត្រទី ២ "

# អ ដ្ឋ ក ថា

## មឃទេវម្ពសូត្រទី ៣[១]

[២១៣] មឃទេវម្ពសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកយ៉ាងនេះ ៖

ក្នុងបណ្តាទាំងនោះ បទថា **មឃទេវម្ពវនេ** សេចក្តីថា ក្នុងកាលមុនព្រះរាជាព្រះនាមថា មឃទេវៈ ត្រាស់បង្គាប់ឲ្យដាំស្វនស្វាយកន្លែងនោះទុក ។ កាលដើមឈើទាំងនោះវិនាសអស់ទៅ តមកព្រះរាជាទាំងឡាយអន្ទដទៃៗ ក៏បានត្រាស់បង្គាប់ឲ្យដាំទុកទៀត ។ ក៏សួនទនោះ ដល់ការរាប់ថា មឃទេវម្ពវ័ន ព្រោះការហៅតៗ គ្នាមកពីដើម ។

បទថា **សិតំ បាត្វាកាសិ** សេចក្តីថា ក្នុងវេលាល្ងាច ព្រះមានព្រះភាគស្តេចចារិកទៅក្នុងវិហារ ទ្រង់ឃើញភូមិភាគដែលគួររីករាយចិត្ត ទើបទ្រង់រំពឹងថា តថាគតធ្លាប់នៅក្នុងទីនេះមកឬទេហ្ន៎ ទើបទ្រង់ឃើញថា កាលមុនតថាគតជាព្រះរាជា នាមថា មឃទេវៈ បានដាំសួនស្វាយនេះ ។

---

១-បាលីថា មាឃទេវសូត្រ ។

តថាគតបួសក្នុងទីនេះឯង ចម្រើនព្រហ្មវិហារ ៤ ទៅកើតក្នុងព្រហ្មលោក ក៏ហេតុនេះទុំះឯង មិនទាន់ប្រាកដដល់ភិក្ខុសង្ឃ តថាគតនឹងធ្វើឲ្យប្រាកដ កាលនឹងទ្រង់សម្តែង ព្រះឱស្ឋដ៏ប្រសើររបស់ព្រះអង្គ ក៏ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។

[២១៤] ឈ្មោះថា **ធម្មិកោ** អ្នកមានធម៌ ព្រោះអត្ថថា ទ្រង់មានធម៌ ។ ឈ្មោះថា ធម្មរាជា ព្រោះអត្ថថា ទ្រង់ជាព្រះរាជាប្រកបដោយធម៌ ។ ពាក្យថា **ទ្រង់តាំងនៅក្នុងធម៌** គឺ ទ្រង់តាំងនៅក្នុងធម៌ គឺ កុសលកម្មបថ ១០ ប្រការ ។ ពាក្យថា **ទ្រង់ប្រព្រឹត្តធម៌** គឺ ទ្រង់ប្រព្រឹត្តរាជធម៌ ។ ក្នុងបទទាំងនោះ បទថា **ព្រាហ្មណគហបតិកេសុ** សេចក្តីថា ព្រះអង្គទ្រង់ជាទីស្រឡាញ់ ទ្រង់រក្សាប្រពៃណីដែលព្រះរាជាអង្គមុនៗ ឲ្យហើយដល់ពួកព្រាហ្មណ៍ ទ្រង់មិនញុំាងកិច្ចនោះឲ្យវិនាសសាបសូន្យទេ ទ្រង់ធ្វើដោយប្រក្រតី ជានិយាមរហូតតមក ។ ពួកគហបតីទាំងឡាយ ក៏ទ្រង់បដិបត្តិដូចគ្នា ។ ពាក្យដែលលោកពោលសំដៅដល់រឿងនេះ ។ ដោយបទថា **បក្ខស្ស** លោករួមសូម្បីបាដិហារិកបក្ខចូលផង ។ គឺ បណ្ឌិតគប្បីជ្រាបថា ថ្ងៃទាំងនេះ ឈ្មោះថា បាដិហារិកបក្ខ គឺ ថ្ងៃ ៧ កេច , ថ្ងៃ ៩ កេច , ដោយអំណាចនៃថ្ងៃទទួល

ដល់ថ្ងៃឧបោសថក្នុងតិថី ៨ កើត ; ថ្ងៃ ១៣ កើត និងថ្ងៃបាដិបទ ដោយអំណាចនៃថ្ងៃទទួលដល់ថ្ងៃឧបោសថទី ១៤ កើត , ទី ១៥ កើត , ព្រះអង្គទ្រង់ចូលទៅគង់ប្រថាប់នៅជាប្រចាំក្នុងថ្ងៃឧបោសថនោះ ។

បទថា **ទេវទូតា** សេចក្តីថា មច្ចុ សេចក្តីស្លាប់ ឈ្មោះថា ទេវៈ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ជាទូតនៃសេចក្តីស្លាប់នោះ ។ គឺ បុគ្គលកាលសក់ស្កូវប្រាកដហើយ លោកទើបពោលថា ជាទូតរបស់មច្ចុរាជ ។ ព្រោះដូច្នោះ សក់ដែលស្កូវហើយ លោកទើបពោលថា ជាទូតរបស់មច្ចុទេវៈ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ទូតដូចទេវតាទាំងឡាយក៏មាន ។ ឧបមាដូចកាលទេវតាអ្នកប្រដាប់ហើយ តាក់តែងហើយ មកឈរក្នុងអាកាសស្រែកប្រាប់ថា ក្នុងថ្ងៃឯណោះ លោកនឹងស្លាប់ ដូច្នេះ ទេវទូតនោះក៏ដូច្នោះ កាលសក់ស្កូវហើយ ប្រាកដហើយ ក៏ដូចគ្នានឹងទេវតាព្យាករណ៍ឲ្យដូច្នោះដែរ ។ ព្រោះដូច្នោះ សក់ដែលស្កូវហើយ លោកទើបហៅថា **ទូត** ដូចគ្នានឹងទេវៈដូច្នេះ ។ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ជាទូតនៃវិសុទ្ធិទេពក៏បាន ។ ពិតហើយ ព្រះពោធិសត្វគ្រប់ៗ ព្រះអង្គ ទ្រង់ឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិតជាមុន ទ្រង់សង្វេគ ទើបទ្រង់ចេញបួស ។

ដូចដែលត្រាស់ទុកថា ៖

សូមថ្វាយព្រះពរ យើងឃើញមនុស្សចាស់ មនុស្សមាន
ទុក្ខ មនុស្សឈឺ និងឃើញមនុស្សស្លាប់ អស់អាយុខ័យ
និងបានឃើញអ្នកបួស អ្នកស្លៀកដណ្តប់សំពត់កាសាយៈ
ហេតុនោះ យើងទើបចេញបួស ដូច្នេះ ។

ដោយបរិយាយនេះ សក់ដែលស្កូវហើយ លោកទើបហៅថា **ទេវទូត** ព្រោះជាទូតនៃវិសុទ្ធិទេព ។ បទថា **កប្បកស្ស គាមវរំ ទត្វា** ទ្រង់ព្រះរាជ-ទានស្រុកសួយដល់ជាងកោរកាត់ សេចក្តីថា ទ្រង់ព្រះរាជទានស្រុកដែលចម្រើនបំផុត មានសួយកើតឡើងដល់មួយសែន ។ ទ្រង់ព្រះរាជទាន ព្រោះហេតុអ្វី ។ ព្រោះទ្រង់ស្លុតព្រះទ័យ ។

ពិតហើយ ព្រះអង្គទ្រង់កើតសេចក្តីស្លុតព្រះទ័យ ព្រោះទ្រង់ឃើញសក់ស្កូវដែលនៅត្រង់ម្រាមព្រះហស្ត នឹងទ្រង់មានព្រះជន្មដល់ ៨៤,០០០ ឆ្នាំទៀត ។ សូម្បីដូច្នោះ ក៏ទ្រង់សម្គាល់ព្រះអង្គដូចជាឈរក្នុងសម្នាក់នៃស្តេចមច្ចុរាជ ទើបទ្រង់ស្លុតព្រះទ័យ ទ្រង់ពេញព្រះទ័យក្នុងបព្វជ្ជា ។ ព្រោះដូច្នោះ លោកទើបពោលថា ៖

ព្រះបាទមឃទេវ ទ្រង់ជាអធិបតីក្នុងទិស ទ្រង់ជាអ្នកប្រាជ្ញ

ទ្រង់ឃើញសក់ស្កូវលើព្រះសិរសា ទ្រង់ស្លុតព្រះទ័យ ទ្រង់

ត្រេកអរក្នុងបព្វជ្ជា ។

ហើយពោលទុកតទៅទៀតថា ៖

សក់ស្កូវដុះឡើងលើសិរសារបស់យើង ក៏នាំយកនូវកាព

កម្ចោះចេញទៅ ទេវទូតប្រាកដហើយ ជាសម័យដែលយើង

គួរចេញបួស ។

បទថា **បុរិសយុគេ** កាលយុគបុរសប្រព្រឹត្តទៅហើយ គឺ កាលយុគបុរសដែលសម្ភពក្នុងវង្ស ។

**[២១៥]** ពាក្យថា **កេសមស្សុំ ឱហារេត្វា** ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ សេចក្តីថា ក៏សូម្បីកាលនឹងបួសជាតាបស ក៏ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ។ តអំពីនោះ ក៏ទ្រង់ព័ន្ធព្រះកេសាដែលវែងឡើងមកទុកត្រង់ជដាត្រាច់ទៅ ។ សូម្បីព្រះពោធិសត្វក៏ទ្រង់បួសជាតាបស ។ កាលបួសហើយ ទ្រង់មិនប្រកបរឿយៗ នូវអនេសនា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភិក្ខាដែលនាំមកពីព្រះរាជវាំង ទ្រង់ចម្រើនព្រហ្មវិហារធម៌ ។ ព្រោះ

ដូច្នោះ លោកទើបបានពោលថា ព្រះអង្គ ទ្រង់មានព្រះទ័យប្រកបដោយមេត្តា ដូច្នេះជាដើម ។

**[២១៨]** បទថា **កុមារកីឡិកំ កីឡិ** ព្រះរាជឱរសទាំងអម្បាលនោះនៅលេងល្បែងក្មេង សេចក្តីថា ដែលម្ចាស់បងចិញ្ចឹមពដោយចង្កេះ ទ្រង់នៅលេង ។ ក៏ព្រះម្ចាស់បងទាំងឡាយ លើកព្រះកុមារនោះដូចកាន់បាច់ផ្កាឈើត្រាច់ទៅ ។ បទថា **រញ្ញោ មឃទេវស្ស បុត្តោ ។បេ។ បព្វជិ** ព្រះរាជឱរសរបស់ព្រះបាទមឃទេវៈ ស្តេចចេញទ្រង់ព្រះផ្នួស សេចក្តីថា ក្នុងថ្ងៃដែលព្រះរាជឱរសនេះទ្រង់ព្រះផ្នួស បានកើតមង្គលដល់ ៥ ប្រការ គឺ ធ្វើមតកភត្តថ្វាយព្រះបាទមឃទេវៈ ១ , មង្គល គឺ ព្រះឱរសរបស់ព្រះបាទមឃទេវៈចេញបួស ១ , មង្គល គឺ ព្រះរាជបុត្ររបស់ព្រះរាជាលើកស្វេត-ឆត្រឡើងគ្រងរាជ្យ ១ , មង្គល គឺ ព្រះរាជបុត្ររបស់ព្រះរាជា ដែលលើកស្វេតឆត្រឡើងគ្រងរាជ្យ ជាឧបរាជ្យ ១ , មង្គល គឺ តាំងព្រះនាមព្រះរាជឱរសរបស់ព្រះរាជា អ្នកលើកស្វេតឆត្រ ១ ។ មហាជនបានធ្វើមង្គល ៥ ប្រការរួមគ្នាក្នុងគ្រាតែមួយ ។ ក្នុងផែនដីជម្ពូទ្វីប បានលើកនង្គ័លឡើង គឺ មិនត្រូវការធ្វើស្រែចំការ ។

បទថា **បុត្តបបុត្តកា** សេចក្ដីថា សេចក្ដីបន្តគ្នាមករបស់ព្រះរាជ-បុត្ររបស់ព្រះបាទមឃទេវនោះ ប្រព្រឹត្តទៅហើយយ៉ាងនេះ គឺ ព្រះរាជ-បុត្រ និងព្រះរាជាបន្ទាប់តៗ គ្នាមក ។ បទថា **បច្ឆិមកោ អហោសិ** (ព្រះបាទនិមិជាអង្គចុងក្រោយបង្អស់) សេចក្ដីថា ក្សត្រិយ៍អង្គចុងបង្អស់ដែលទ្រង់បានបព្វជ្ជាហើយ ។ បានឮថា ព្រះពោធិសត្វទ្រង់កើតក្នុងព្រហ្មលោកហើយទ្រង់រំពឹងថា កល្យាណវត្តដែលយើងតាំងទុកក្នុងមនុស្សលោកនោះនៅប្រព្រឹត្តទៅឬហ្ន៎ ដូច្នេះ ក៏ទ្រង់ឃើញថា នៅប្រព្រឹត្តទៅរហូតដល់អស់កាលយូរមានប្រមាណប៉ុណ្ណោះ តែឥឡូវនេះ នឹងមិនប្រព្រឹត្តទៅ ព្រះអង្គទ្រង់ត្រិះរិះថា ក៏យើងនឹងមិនឲ្យវង្សរបស់យើងដាច់ឡើយ ដូច្នេះ ទ្រង់ក៏កាន់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះរាជា ដែលកើតក្នុងវង្សរបស់ខ្លួន ទ្រង់កើតដើម្បីបន្តវង្សរបស់ខ្លួន ។ ព្រោះហេតុនោះឯង ព្រះរាជកុមារនោះ ទើបទ្រង់មានព្រះនាមថា **និមិ** ។

ដោយប្រការដូច្នេះ ព្រះរាជានោះទើបជាព្រះរាជាអង្គចុងក្រោយបង្អស់របស់ព្រះរាជាដែលចេញបួសហើយ ព្រះរាជាដែលចេញបួសក្រោយបង្អស់ទើបមាន ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត កាលពោលអំពីគុណ ក៏មានគុណយ៉ាងច្រើនណាស់ ។ តែគុណដ៏ធំក្រៃលែងជាងព្រះរាជាគ្រប់ព្រះអង្គ របស់ព្រះបាទនិមិរាជនោះ មានគុណ ២ ប្រការ គឺ ព្រះអង្គទ្រង់លះបង់ទ្រព្យក្នុងទ្វារទាំង ៤ ក្នុងទ្វារនីមួយៗ មួយសែនរាល់ៗ ថ្ងៃ និងទ្រង់ហាមអ្នកមិនបានរក្សាឧបោសថចូលគាល់ ។ គឺ កាលអ្នកដែលមិនបានរក្សាឧបោសថ តាំងចិត្តថា នឹងចូលគាល់ព្រះរាជាទើបទៅហើយ នាយទ្វារនឹងសួរថា លោករក្សាឧបោសថឬមិនបានរក្សា ។ អ្នកណាមិនបានរក្សាឧបោសថ ក៏នឹងហាមអ្នកនោះថា ព្រះរាជាទ្រង់មិនឲ្យអ្នកដែលមិនបានរក្សាឧបោសថចូលគាល់ ។ ក្នុងបុគ្គលទាំងនោះ មិនមានឱកាសដែលនិងនិយាយថា ពួកខ្ញុំទាំងឡាយជាអ្នកជនបទនឹងបានភោជនក្នុងកាលត្រង់ណា ដូច្នេះខ្វះ ។ ពិតណាស់ អ្នកចាត់ចែងកត្ត ត្រៀមភោជន៍កត្តទុកច្រើនពាន់ត្រង់ទ្វារទាំង ៤ និងត្រង់ព្រះលានហ្លួង ។ ព្រោះដូច្នោះ មហាជននឹងគោរពុកមាត់ ងូតទឹកផ្លាស់ប្តូរសំពត់ បរិភោគភោជនបានតាមពេញចិត្តក្នុងទីដែលប្រាថ្នាហើយៗ អធិដ្ឋានអង្គឧបោសថទៅកាន់ទ្វារព្រះរាជវាំង ។ កាលនាយទ្វារសួរហើយថា លោករក្សាឧបោសថឬ ក៏ឆ្លើយថា ចាំរក្សា ដោយហេតុនោះឯង នាយទ្វារទើបនិយាយថា

មកបានហើយ ទើបនាំចូលទៅកាន់ទ្វារព្រះរាជវាំង ។ ព្រះបាទនិមិរាជ ទ្រង់មានព្រះគុណដ៏ក្រៃលែង ដោយគុណ ២ ប្រការទាំងនេះ ដោយប្រការដូចពោលមកនេះ ។

[២១៩] បទថា **ទេវានំ តាវតឹសានំ** សេចក្តីថា ពួកទេវតាដែលកើតក្នុងភពជាន់តាវត្តឹង្ស ។ បានឮថា ទេវតាទាំងនោះតាំងនៅក្នុងឱវាទរបស់ព្រះរាជាអ្នកសោយរាជក្នុងព្រះនគរមិថិលាក្នុងវិទេហរដ្ឋ រក្សាបញ្ច-សីល ធ្វើឧបោសថកម្ម ទើបទៅកើតក្នុងទីនោះ បានសរសើរគុណរបស់ព្រះរាជា ។ ពាក្យថា **ពួកទេវតាជាន់តាវត្តឹង្ស** លោកពោលសំដៅយកទេវតាទាំងនោះ ។

[២២០] បទថា **និសិន្នោ ហោតិ** សេចក្តីថា ព្រះរាជាស្តេចឡើងកាន់ប្រាសាទដ៏ប្រសើរជាន់លើ ប្រថាប់អង្គុយពិចារណាទាន និងសីលហើយ ។ បានឮថា បានទ្រង់មានព្រះតម្រិះយ៉ាងនេះថា ទានធំជាងសីល ឬសីលធំជាងទាន បើទានធំជាង យើងក៏នឹងឲ្យតែទានតែម្យ៉ាង ប្រសិនបើសីលធំជាង ក៏នឹងបំពេញតែសីលតែម្យ៉ាង ។ កាលព្រះអង្គមិនអាចសម្រេចព្រះទ័យបានថា យ៉ាងនេះធំ វត្ថុនេះធំ ស្តេចសក្កៈ ទើបស្តេចមកប្រាកដចំពោះ

ព្រះភ័ក្ត្រ ។

ព្រោះហេតុនោះ លោកទើបពោលទុកថា **អថ ខោ អានន្ទ ។បេ។ សម្មុខេ បាតុរហោសិ** ។ បានឮថា ព្រះអង្គទ្រង់ត្រិះរិះយ៉ាងនេះថា ព្រះរាជាកើតសេចក្តីសង្ស័យ ដើម្បីនឹងកាត់សេចក្តីសង្ស័យរបស់ព្រះអង្គ ខ្ញុំព្រះអង្គនឹងដោះបញ្ហា នឹងកាន់យកបដិញ្ញាដើម្បីស្តេចមកក្នុងទីនេះ ។ ព្រោះដូច្នោះទើបមកប្រាកដចំពោះព្រះភ័ក្ត្រ ។ ព្រះរាជាទ្រង់ឃើញរូបដែលមិនធ្លាប់ឃើញក៏ទ្រង់កើតសេចក្តីខ្លាច ព្រះលោមាបះឡើង ។ ទីនោះ ស្តេចសក្កៈត្រាស់ចំពោះព្រះរាជានោះថា ទ្រង់កុំខ្លាចឡើយ មហារាជ សួរមកចុះ យើងនឹងវិសជ្ជនាថ្វាយ នឹងបន្ទោបង់សេចក្តីសង្ស័យរបស់ព្រះអង្គបាន ដូច្នេះ ។ ព្រះរាជាត្រាស់សួរបញ្ហាថា ៖

បពិត្រមហារាជអ្នកជាធំជាងសព្វសត្វ ខ្ញុំព្រះអង្គសូមសួរ
ព្រះអង្គ ទាន ១ ព្រហ្មចរិយៈ ១ (សីល) ប្រការណានឹង
មានផលច្រើនជាងគ្នា ។

ស្តេចសក្កៈត្រាស់ថា ឈ្មោះថា ទាននឹងធំយ៉ាងណា
សីលប៉ុណ្ណោះធំ ព្រោះជាគុណដ៏ប្រសើរបំផុត បពិត្រមហា

រាជ សូម្បីខ្ញុំព្រះអង្គបានឲ្យទានដល់ជដិលទាំងម៉ឺននាក់ ច្រើន ម៉ឺនឆ្នាំ តែកាលមុនមិនទាន់ផុតពីបេត្តវិស័យ តែលោកអ្នក មានសីល បរិភោគទានរបស់ខ្ញុំ បានទៅកើតក្នុងព្រហ្ម- លោក ដូច្នេះ ។

ហើយត្រាស់គាថា ដូចតទៅនេះថា ៖

បុគ្គលនឹងចូលដល់ភាពជាក្សត្រិយ៍ ដោយព្រហ្មចរិយៈ ថ្នាក់ទាប នឹងចូលដល់ភាពជាទេវៈដោយព្រហ្មចរិយៈថ្នាក់ កណ្តាល នឹងបរិសុទ្ធិបាន ដោយព្រហ្មចរិយៈយ៉ាងខ្ពស់ ព្រោះអ្នកមិនមានផ្ទះបំពេញតបៈទាំងឡាយ រមែងចូលដល់ កាយពួកណា កាយពួកនោះ ដែលបុគ្គលណាៗ បំពេញ ព្យាយាម ដោយការអង្វរបានដោយងាយ មិនបាន ។

ស្តេចសក្កៈ ទ្រង់បន្ទោបង់សេចក្តីសង្ស័យរបស់ព្រះរាជាយ៉ាងនេះ ហើយ ដើម្បីនឹងឲ្យកាន់យកបដិញ្ញាក្នុងកាលស្តេចទៅកាន់ទេវលោក ទើប ត្រាស់ថា **លាភា វត មហារាជ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អវិកម្បមានោ** សេចក្តីថា ទ្រង់មិនខ្វាចក្រែង ។

[២២១] បទថា **អធិវាសេតំ** សេចក្ដីថា ព្រះរាជាទ្រង់ទទួលអញ្ជើញហើយ ដោយព្រះតម្រាស់ថា ខ្ញុំព្រះអង្គបបួលមហាជនឲ្យបំពេញកុសលដែលខ្ញុំព្រះអង្គបានមកឃើញទី ជាទីនៅរបស់លោកអ្នកមានបុណ្យទាំងឡាយហើយ រមែងអាចពោលប្រាប់បានសប្បាយក្នុងអាវាសនៃមនុស្ស ដូច្នេះ ។ បទថា **ឯវំ ភទ្ទន្តវា** សេចក្ដីថា មាតលីទេវបុត្រទូលថា ព្រះតម្រាស់របស់ព្រះអង្គ ចូរជាយ៉ាងនោះ ។ បទថា **យោជេត្វា** សេចក្ដីថា ទឹមរថ ដោយសេះអាជានេយ្យមួយពាន់ក្នុងយុគមួយនោះដោយពិត ។ តែកិច្ចដែលគប្បីប្រកបចំពោះចំណែកមួយរបស់រថទាំងនោះ មិនបានមាន រមែងអាស្រ័យចិត្តប្រកបហើយនោះដោយពិត ។ ក៏ទិព្វរថនោះ ធំវែងដល់ ២៥០ យោជន៍ ។ ចាបពីខ្សែដល់រថ ៥០ យោជន៍ ។ ដែលជាប់នឹងភ្លៅ ៥០ យោជន៍ ។ ចំណែកខាងក្រោយចាប់ផ្ដើមតាំងពីដែលជាប់នឹងភ្លៅ ៥០ យោជន៍ ទាំងដងសុទ្ធតែប្រកបដោយរតនៈមានវណ្ណៈ៧ ។ ខ្ពស់ស្មើទេវលោក ។ ខាងក្រោមត្រឹមមនុស្សលោក ព្រោះដូច្នោះ មិនគប្បីកំណត់ថា បញ្ជូនរថទៅបែរមុខទៅខាងក្រោម ។ ដូចជា បញ្ជូនទៅកាន់ផ្លូវដើរតាមប្រក្រតី យ៉ាងណា លុះមពួកមនុស្សទទួលទានបាយក្នុងវេលាល្ងាចឆ្អែតស្រេចហើយ ទើប

បញ្ជូនទៅធ្វើឲ្យជាគូនឹងព្រះចន្ទដូច្នោះឯង ។ បានដូចជាព្រះចន្ទតាំងឡើងជាគូគ្នា ដូច្នោះ ។ មហាជនឃើញហើយ នាំគ្នានិយាយផ្សេងៗ គ្នាថា ព្រះចន្ទរះឡើងជាគូគ្នា ។ កាលចូលមកជិត ទើបដឹងថា មិនមែនព្រះចន្ទជាគូគ្នា ជាវិមានមួយ មិនមែនវិមានមួយ តែជារថមួយ ។ សូម្បីរថនោះចូលមកជិតហើយៗ ក៏ជារថតាមធម្មតានុ៎ះឯង សូម្បីសេះក៏មានប្រមាណប៉ុន និងសេះតាមធម្មតានោះឯង ។ គ្រានាំរថមក ដោយអាការយ៉ាងនេះហើយ ធ្វើប្រទក្សិណប្រាសាទរបស់ព្រះរាជា ហើយត្រឡប់រថទៅត្រង់សីហ-បញ្ជរផ្នែកទិសខាងលិច ធ្វើឲ្យបែរមុខទៅទិសដែលមក ចតរថត្រង់សីហ-បញ្ជរ ត្រៀមឲ្យស្តេចឡើងថា បពិត្រមហារាជ សូមព្រះអង្គស្តេចឡើងប្រថាប់ចុះ ។

ព្រះរាជាទ្រង់ត្រិះរិះថា ទិព្វយានយើងបានហើយ ទើបស្តេចមិនទាន់ឡើងពេលភ្លាមនោះ ។ តែទ្រង់ប្រទានឱវាទដល់អ្នកព្រះនគរថា ចូរមើលចុះ បាទាំងឡាយ កាលស្តេចសក្កៈទេវរាជទ្រង់បញ្ជូនរថមកទទួលយើងនេះព្រះអង្គមិនបាន បញ្ជូនមកព្រោះអាស្រ័យជាតិ និងគោត្រ ឬត្រកូល និងប្រទេស តែព្រោះទ្រង់ជ្រះថ្លាក្នុងគុណ គឺ សីលាចារវត្តរបស់យើង ទើប

បញ្ជូនមក ប្រសិនបើ ពួកអ្នកទាំងឡាយនឹងរក្សាសីល ក៏គង់នឹងបញ្ជូនមកដល់អ្នកទាំងឡាយ ឈ្មោះថា សីលនោះសមគួរហើយដើម្បីរក្សា យើងមិនបានទៅកាន់ទេវលោក សូមអ្នកទាំងឡាយជាអ្នកមិនប្រមាទចុះ ។ ទ្រង់ទូន្មានមហាជនឲ្យតាំងនៅក្នុងសីល ៥ ហើយ ទើបស្ដេចឡើងរថ ។ តពីនោះ មាតលីសារថីសម្ដែងផ្លូវជា ២ ផ្លូវក្នុងអាកាសគិតថា សូម្បីយើងក៏ធ្វើសេចក្ដីដែលសមគួរដល់មហារាជ ទើបពោលពាក្យមានជាដើមថា **អបិច មហារាជ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កតមេន** សេចក្ដីថា បពិត្រមហារាជ ក្នុងបណ្ដាផ្លូវទាំងនេះ ផ្លូវមួយទៅនរក ផ្លូវមួយទៅសួគ៌ ខ្ញុំព្រះបាទនឹងនាំព្រះអង្គទៅផ្លូវណាក្នុងផ្លូវទាំងនោះ ។ បទថា **យេន** សេចក្ដីថា ទៅហើយដោយផ្លូវណា សត្វទាំងឡាយធ្វើកម្មដ៏លាមក រមែងសោយផលនៃកម្មដ៏លាមកក្នុងទីណា ខ្ញុំព្រះអង្គរមែងអាចដើម្បីឃើញនូវទីនោះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូច្នេះ ។ សូម្បីសេចក្ដីនៃគាថាក្នុងជាតកថា

បពិត្រព្រះរាជាជាអ្នកប្រសើរ ទ្រង់ជាធំក្រៃលែងគ្រប់ទិស
ខ្ញុំនឹងនាំព្រះអង្គទៅផ្លូវណា ពួកសត្វដែលធ្វើកម្មអាក្រក់

ទៅផ្លូវមួយ ពួកសត្វអ្នកធ្វើកម្មល្អ ទៅផ្លូវមួយ ដូច្នេះ ។

ព្រោះហេតុនោះ ព្រះបាទនិមិរាជទើបត្រាស់ថា ៖

យើងនឹងឃើញនរក ដែលជាទីនៅនៃអ្នកធ្វើកម្មអាក្រក់ ជាមុន ដែលជាស្ថានទីរបស់អ្នកមានកម្មអាក្រក់ និងជាផ្លូវទៅរបស់អ្នកទ្រុស្តសីល ។

បទថា **ឧភយេនេវ មំ** សេចក្ដីថា ម្នាលមាតលី លោកចូរនាំយើងទៅដោយផ្លូវទាំងពីរ យើងបំណងនឹងឃើញនរក សូម្បីទេវលោក ក៏ចង់ឃើញ ។ ខ្ញុំនឹងនាំព្រះអង្គទៅផ្លូវណាមុន ។ ចូរនាំទៅដោយផ្លូវនរកមុន ។ លំដាប់នោះ មាតលីទើបសម្ដែងមហានរក ១៥ រណ្ដៅ ដល់ព្រះរាជា ដោយអានុភាពរបស់ខ្លួន ។ ក្នុងសេចក្ដីនេះមានពាក្យពោលដោយពិស្ដារ គប្បីជ្រាបតាមន័យដែលពោលទុកក្នុងជាតកថា ៖

មាតលីទេវបុត្រសម្ដែងវេតរណីនទីនរក ដែលធ្ងន់បានសែនលំបាក ពុះខ្ជួលប្រកបដោយទឹកក្រុតក្ដៅហើយ ប្រៀបដូចអណ្ដាតភ្លើង ដល់ព្រះរាជា ។

មាតលីសារថីសម្ដែងនរកហើយ ក៏ត្រឡប់រថបែរមុខទៅកាន់ទេវ-

លោក កាលសម្តែងវិមានទាំងឡាយរបស់នាងទេពធីតា នាមថា **ករណី** និងរបស់គណៈទេវបុត្រ មានទេវបុត្រនាមថា **សោណទិន្នៈ** ជាប្រធាន ទើបនាំទៅកាន់ទេវលោក ។ សូម្បីក្នុងសេចក្តីនោះ ក៏គប្បីជ្រាបពាក្យយ៉ាងពិស្តារដោយន័យដែលពោលទុកក្នុងជាតកទុំះឯងថា ៖

ក៏នាងទេពធីតាដែលព្រះអង្គសំដៅដល់នោះ ឈ្មោះករណី កាលមានជីវិតនៅក្នុងលោក (មនុស្ស) ជាទាសីកើតពីទាសី ក្នុងផ្ទះរបស់ព្រាហ្មណ៍ម្នាក់ នាងដឹងច្បាស់នូវភ្ញៀវ មានកាលដែលដល់ហើយ (ឲ្យអង្គុយលើអាសនៈ អង្គាសដោយស្លាកភត្តដែលធ្វើផ្ទាល់ខ្លួនដោយគោរព ត្រេកអរចំពោះភិក្ខុនោះជានិច្ច) ដូចមាតាត្រេកអរចំពោះបុត្រដែលបែកគ្នាយូរ មកដល់ក្នុងពេលនោះ ដូច្នោះ ជាអ្នកសង្រួម (មានសីល) ជាអ្នកចែកទាន (មានចាគៈ) ទើបបានមកកើតក្នុងវិមាននោះ ហើយក៏រីករាយ ។

កាលព្រះពោធិសត្វស្តេចទៅយ៉ាងនេះ លុះមកដល់រថប៉ះខ្ទប់ផែនដីត្រង់ខ្លោងទ្វារចិត្តកូដទេវនគរ ក៏មានកោលាហល ។ ពួកទេវនាំគ្នាលះចោល

សក្កទេវរាជ ទុកឲ្យនៅតែមួយព្រះអង្គឯង ទៅធ្វើការទទួលព្រះមហាសត្វ ។ ស្តេចសក្កៈទ្រង់ឃើញព្រះមហាសត្វនោះ មកជិតទេវតាទាំងឡាយហើយ កាលទ្រង់មិនអាចតាំងព្រះទ័យបាន ទើបត្រាស់ថា ម្នាលមហារាជ សូមព្រះអង្គទ្រង់អភិរម្យក្នុងទេវលោកទាំងឡាយ ដោយទេវានុភាពចុះ ។

បានឮថា ស្តេចសក្កៈនោះ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ព្រះរាជានេះ ស្តេចមកក្នុងថ្ងៃនេះ ហើយទ្រង់ធ្វើពួកទេវៈឲ្យនៅព្រមខាងមុខនៃខ្លួនត្រឹមតែមួយថ្ងៃប៉ុណ្ណោះ បើនឹងប្រថាប់នៅអស់មួយថ្ងៃពីរថ្ងៃ ពួកទេវៈក៏នឹងមិនថែរក្សាយើង ដូច្នេះ ។ ស្តេចសក្កៈនោះ ទ្រង់ឫស្យា ទើបត្រាស់យ៉ាងនោះ ដោយបំណងយ៉ាងនេះថា ម្នាលមហារាជ ការដែលព្រះអង្គប្រថាប់នៅក្នុងទេវលោកនេះ នឹងមិនមានបុណ្យ សូមព្រះអង្គចូរប្រថាប់នៅដោយបុណ្យរបស់ពួកអ្នកដទៃចុះ ។ ព្រះពោធិសត្វ កាលទ្រង់បដិសេធថា បពិត្រសក្កៈ ខ្ញុំព្រះអង្គមិនអាចនឹងស្ថិតនៅបាន ព្រោះអាស្រ័យអ្នកដទៃ ដូចជាកណ្ឌៈដែលបានមកព្រោះសូមគេបានមក ដូច្នោះ ទើបត្រាស់ថា ណ្ហើយចុះ អ្នកនិរទុក្ខ ដូច្នេះជាដើម ។ សូម្បីក្នុងជាតកលោក ក៏ពោលទុកថា ៖

វត្ថុយ៉ាងណាបានមកព្រោះអ្នកដទៃឲ្យ វត្ថុនោះមានឧបមា
ប្រៀបដូចជាយានដែលសូមគេមក ឬទ្រព្យដែលសូមគេមក

ខ្ញុំព្រះអង្គមិនប្រាថ្នា វត្ថុដែលអ្នកជទែឲ្យ ។

បណ្ឌិតគប្បីពោលតាមន័យក្នុងព្រះជាតក ដូច្នេះ ។

សួរថា កាលព្រះពោធិសត្វ ស្ដេចទៅកាន់ទេវលោកដោយអត្តភាពជាមនុស្សប៉ុន្មានដង ។

ឆ្លើយថា បួនដង គឺ កាលសោយព្រះជាតិជាព្រះបាទមន្ធាតុរាជ ១ ដង កាលសោយព្រះជាតិជាព្រះបាទសាធិនៈ ១ ដង កាលសោយព្រះជាតិជាគុត្តិលវីណាវាទកព្រាហ្មណ៍ ១ ដង កាលសោយព្រះជាតិជាព្រះបាទនិមិ ១ ដង ។ កាលកាលជាព្រះបាទមន្ធាតុ ព្រះអង្គប្រថាប់នៅក្នុងទេវលោកអស់វេលាមួយអសង្ខេយ្យ ។ ក៏កាលព្រះអង្គប្រថាប់នៅក្នុងទេវលោកនោះ ស្ដេចសក្កៈចុតិអស់ ៣៦ ព្រះអង្គ ។ កាលជាព្រះបាទសាធិនរាជ ប្រថាប់នៅមួយសប្ដាហ៍ ។ បើរាប់ដោយឆ្នាំមនុស្សក៏ជា ៧០០ ឆ្នាំ ។ កាលជាគុត្តិលវីណាវាទកៈ និងកាលជាព្រះបាទនិមិរាជ ទ្រង់ប្រថាប់នៅត្រឹមតែមួយភ្លែត ។ ដោយការរាប់ជាថ្ងៃមនុស្សជា ៧ ថ្ងៃ ។ ពាក្យថា **តត្ថេវមំ មិថិលំ បជិនេតុ** សេចក្ដីថា មាតលីសារថី បាននាំត្រឡប់មកប្រតិស្ឋានទុកក្នុងទីកន្លែងដែលមានសិរីដូចដើមនោះឯង (ក្រឡាបន្ទំ) ។

[២២៨] ពាក្យថា **កឡារជនកោ** ជាព្រះនាមរបស់ព្រះរាជបុត្រនោះ ។

ម្យ៉ាងទៀត ជនទាំងឡាយពោលថា កឡារជនកៈ ព្រោះមានអុជខ្មៅក្រហម កើតឡើង ។ ពាក្យថា **ព្រះរាជកុមារនោះ** ស្តេចមិនបានចេញចាកព្រះរាជ-និវេសន៍ ទ្រង់ព្រះផ្នួស សេចក្តីថា ព្រះអង្គបានត្រាស់ពាក្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។ ពាក្យដ៏សេសទាំងអស់ បានប្រាកដដូចដើមនោះឯង ។ ក្នុងពាក្យថា **សមុច្ឆេទោ ហោតិ** នេះ គប្បីជ្រាបវិភាគដូច្នេះ បុគ្គលណាកាត់កល្យាណវត្តដាច់សូន្យទៅ ព្រោះអ្វី បុគ្គលណាឲ្យប្រព្រឹត្តទៅ រមែងឈ្មោះថា ដែលបុគ្គលណាឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងសេចក្តីនោះ ភិក្ខុដែលមានសីល កាលមិនធ្វើសេចក្តីព្យាយាម ដោយគិតថា យើងមិនអាចបានព្រះអរហត្ត ឈ្មោះថា រមែងកាត់ ។ កល្យាណវត្ត រមែងឈ្មោះថា ដែលអ្នកទ្រុស្តសីលកាត់ហើយ ។ ព្រះសេក្ខបុគ្គលទាំង ៧ រមែងឲ្យប្រព្រឹត្តទៅ ។ រមែងឈ្មោះថា ដែលព្រះខីណាស្រពឲ្យប្រព្រឹត្តទៅហើយ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងងាយយល់ទាំងអស់ ។

" ចប់អដ្ឋកថា មយទេវម្ពសូត្រទី ៣ "

# អ ដ្ឋ ក ថា

## មធុរសូត្រទី ៤

[២២៥] មធុរសូត្រ មានពាក្យជាដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងព្រះសូត្រនោះ បទថា **មហាកច្ចានៈ** គឺ បុត្ររបស់បុរោហិត នៃព្រះចៅឧជ្ជេនី ក្នុងកាលជាគ្រហស្ថ មានរូបល្អ គួរមើល នាំមកនូវសេចក្តីជ្រះថ្លា និងមានសម្បុរដូចមាស ។ បទថា **មធុរាយំ** គឺ ក្នុងព្រះនគរមានឈ្មោះយ៉ាងនោះ ។ បទថា **គុន្ទាវនេ** គឺ ក្នុងព្រះរាជឧទ្យាន ឈ្មោះកណ្ហកគុន្ទាវ័ន ។ បទថា **អវន្តិបុត្តោ** បានដល់ ជាបុត្ររបស់ធីតានៃព្រះ-រាជាក្នុងអវន្តិរដ្ឋ ។ ពាក្យថា **វុឌ្ឍោ ចេវ អរហា ច** សេចក្តីថា ទាំងកម្លោះ ទាំងសមគួរ គឺ មិនបានលើកតម្កើងដូចជាមនុស្សចាស់ ដូច្នោះ ។ ចំណែកព្រះថេរៈជាអ្នកចម្រើនផង ជាព្រះអរហន្តផង ។ ពាក្យថា **ព្រាហ្ម-ណោ ភោ កច្ចានៈ** សេចក្តីថា បានឮថា ព្រះរាជានោះកាន់លទ្ធិព្រាហ្មណ៍ ដូច្នោះ ទើបពោលយ៉ាងនោះ ។

ក្នុងពាក្យជាដើមថា **ព្រាហ្មណាវ សេដ្ឋា វណ្ណា** លោកសម្តែងថា ព្រាហ្មណ៍ប៉ុណ្ណោះជាអ្នកប្រសើរបំផុត ក្នុងឋានៈដែលប្រាកដនៃជាតិ និងគោត្រជាដើម ។

[២២៦] បទថា **ហីនោអញ្ញោ វណ្ណោ** វណ្ណៈដទៃទាប សេចក្តីថា លោកពោលថា វណ្ណៈបីពីក្រៅនេះ ជាវណ្ណៈទាប ។ បទថា **សុក្កោ** ប្រែថា ស ។ បទថា **កណ្ហោ** ប្រែថា ខ្មៅ ។ បទថា **សុជ្ឈន្តិ** សេចក្តីថា បរិសុទ្ធិ ក្នុងឋានៈដែលប្រាកដនៃជាតិ និងគោត្តជាដើម ។

បទថា **ព្រហ្មុនោ បុត្តា** បានដល់ បុត្ររបស់មហាព្រហ្ម ។ បទថា **ឱរសាមុខតោ ជាតា** សេចក្តីថា នៅក្នុងទ្រូង ចេញមកពីមាត់ ឈ្មោះថា ឱរស ព្រោះអត្ថថា ធ្វើទុកត្រង់ទ្រូងឲ្យចម្រើនល្អហើយ ។ បទថា **ព្រហ្មជា** ប្រែថា កើតអំពីព្រះព្រហ្ម ។ បទថា **ព្រហ្មនិម្មិតា** បានដល់ ព្រះព្រហ្មនិមិត្តហើយ ។ បទថា **ព្រហ្មទាយាទា** គឺ ជាទាយាទនៃព្រះព្រហ្ម ។ បទថា **ឃោសោយេវ ឯសោ** នោះ ត្រឹមតែជាវោហារ ។ បទថា **ឥជ្ឈេយ្យ** ប្រែថា គប្បីសម្រេច ។ សំដៅសេចក្តីថា ប្រាថ្នាទ្រព្យជាដើម មានប្រមាណប៉ុនណា មនោរថរបស់គេក៏គប្បីពេញដោយទ្រព្យជាដើម មានប្រមាណត្រឹម

នោះ ។ បទថា **ខត្តិយោបិស្ស** កាត់បទថា **ខត្តិយោ អបិ អស្ស** គឺ ជាអ្នកក្រោកឡើងមុនសម្រាប់អ្នកដល់កាលជាធំ ។

**[២៣៣]** បទថា **ន តេសំ ឯត្ថ កិញ្ចិ**(១) សេចក្ដីថា ក្នុងវណ្ណៈ ៤ ទាំងនេះ ខ្ញុំមិនឃើញថាផ្សេងគ្នាអ្វី ។

**[២៤០]** បទថា **អាសនេន វា និមន្តេយ្យាម** សេចក្ដីថា គប្បីក្រាលអាសនៈដែលសម្រាប់គង់ ហើយនិមន្តថា សូមគង់ក្នុងទីនេះ ។ បទថា **អភិនិមន្តេយ្យាម វា តំ** សេចក្ដីថា នាំអាសនៈនោះមកហើយ គោរពនិមន្ត ។ ក្នុងការនិមន្តនោះ អភិនិហារ (សេចក្ដីគោរព) មាន ២ យ៉ាង គឺ ដោយផ្លូវវាចា ដោយផ្លូវកាយ ។ គឺ កាលនិយាយថា លោកមានសេចក្ដីត្រូវការដោយចីវរជាដើម យ៉ាងណា ក៏សូមប្រាប់មកចុះក្នុងខណៈដែលលោកម្ចាស់ត្រូវការហើយ ដូច្នេះ ឈ្មោះថា គោរពនិមន្តដោយផ្លូវវាចា ។ តែកាលកំណត់ឃើញសេចក្ដីនៃចីវរហែកជាដើម ពោលថា លោកម្ចាស់ចូរយកផ្ទាំងសំពត់នេះទៅចុះ ថ្វាយចីវរទាំងនោះ ឈ្មោះថា គោរពបូជា គោរពនិមន្តផ្លូវកាយ ។ លោកពោលថា **អភិនិមន្តេយ្យាម វា តំ** ដូច្នេះ សំដៅយកការគោរពនិមន្ត សូម្បីទាំងពីរនោះ ។ បទថា **រក្ខាវរណគុត្តិ** បានដល់

ការឃុំគ្រង ពោលគឺ ការរក្សា ពោលគឺ ការការពារ ។ ក៏ការរក្សាដែលគេចាត់តាំង បុគ្គលឲ្យកាន់អាវុធ មិនឈ្មោះថា ការចាត់ចែងប្រកបដោយធម៌ ។ ចំណែកការចាត់ចែងហាមមិនឲ្យអ្នករកឧស និងអ្នករកស្លឹកឈើជាដើម ចូលទៅក្នុងវេលាដែលមិនគួរ ហាមព្រានម្រឹគជាដើម មិនឲ្យចាប់ម្រឹគ ឬត្រី ខាងក្នុងទីវិហារ ក៏ឈ្មោះថា ការចាត់ចែងដែលប្រកបដោយធម៌ ។ លោកពោលថា **ធម្មិកំ** ព្រោះសំដៅយកការហាមយ៉ាងនោះ ។

**[២៤២]** បទថា **ឯវំ សន្តេ** សេចក្តីថា កាលបព្វជិតទាំង ៤ វណ្ណៈស្មើគ្នា សក្ការៈថា ជាអ្នកបួសមានហើយ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងងាយយល់ទាំងអស់នោះឯង ។

" ចប់អដ្ឋកថា មធុរសូត្រ ទី ៤ "

# អ ដ្ឋ ក ថា

## ពោធិរាជកុមារសូត្រទី ៥

**[២៤៧]** *ពោធិរាជកុមារសូត្រ មានបទផ្ដើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបាន ស្ដាប់ចាំមកយ៉ាងនេះ ៖*

*ក្នុងសូត្រនោះ បទថា* ***កោកនទោ*** *សេចក្ដីថា ផ្កាបទុម លោកហៅ ថា* ***កោកនទ*** *ៗ ក៏ប្រាសាទដែលជាមង្គលនោះ លោកសាងសម្ដែងឲ្យដូច ផ្កាបទុមដែលក្រឡេកមើលឃើញ ព្រោះដូច្នោះ ទើបដល់ការរាប់ថា* ***កោ-កនទប្រាសាទ*** *ៗ*

**[២៤៨]** *តាំងជណ្ដើរឡើងដំបូង លោកហៅថា ជណ្ដើរជាន់ខាងក្រោម ក្នុងពាក្យថា* ***យាវបច្ឆិមសោ បាណកឡេវរា*** *នេះ ៗ*

**[២៤៩]** *បទថា* ***អទ្ទសា ខោ*** *សេចក្ដីថា អ្នកដែលឈរត្រង់ខ្លោងទ្វារ នោះឯង ដើម្បីត្រូវការមើល ក៏ឃើញ ៗ បទថា* ***ភគវា តុណ្ហី អហោសិ*** *សេចក្ដីថា ព្រះមានព្រះភាគទ្រង់ពិចារណាថា ព្រះរាជកុមារទ្រង់ធ្វើសក្ការៈ ធំនេះ ដើម្បីប្រាថ្នាអ្វីហ្ន៎ ទើបទ្រង់ជ្រាបថា ទ្រង់ធ្វើព្រោះប្រាថ្នាព្រះឱរស ៗ*

ក៏ព្រះរាជកុមារនោះមិនមានឱរស ទ្រង់ប្រាថ្នាព្រះឱរស បានឮថា ជនទាំងឡាយធ្វើអធិការ ការធ្វើដ៏ធំក្រៃលែងចំពោះព្រះពុទ្ធទាំងឡាយ ទើបនឹងបានវត្ថុដូចដែលខ្លួនប្រាថ្នា ដូច្នេះ ។ ព្រះអង្គទ្រង់ធ្វើសេចក្តីប្រាថ្នាថា បើយើងនឹងបានបុត្រ ព្រះសម្មាសម្ពុទ្ធ នឹងទ្រង់ជាន់ផ្ទាំងសំពត់របស់យើង បើយើងមិនបាន ទ្រង់ក៏នឹងមិនជាន់ ទើបត្រាស់បង្គាប់ឲ្យក្រាលសំពត់ទុក ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ពិចារណាថា បុត្ររបស់ព្រះរាជានេះនឹងមានឬទេហ្ន៎ ហើយទ្រង់ឃើញថា នឹងមិនមាន ។

ព្រះមានព្រះភាគទ្រង់ជ្រាបថា បានឮថា ក្នុងកាលមុន ព្រះរាជានោះទ្រង់នៅក្នុងកោះមួយកន្លែង ទ្រង់សោយកូនសត្វ ដោយមានឆន្ទៈស្មើគ្នា ។ ប្រសិនបើមាតុគ្រាមរបស់ព្រះអង្គ នឹងគប្បីមានចិត្តជាយ៉ាងដទៃទេ ក៏នឹងបានបុត្រ តែអ្នកទាំងពីរមានឆន្ទៈស្មើគ្នា ធ្វើបាបកម្មទុក ដូច្នោះ បុត្ររបស់គេ ទើបមិនមាន ដូច្នេះ ។ តែកាលតថាគតជាន់សំពត់ ព្រះរាជកុមារក៏នឹងយល់ខុសបានថា ដំណឹងលេចឮតគ្នាក្នុងលោកថា បុគ្គលធ្វើអធិការចំពោះព្រះពុទ្ធទាំងឡាយហើយ រមែងនឹងបានវត្ថុដែលខ្លួនប្រាថ្នាហើយៗ យើងបានធ្វើអភិនិហារច្រើនណាស់ តែយើងក៏មិនបានបុត្រ ដំណឹងនេះមិនពិត ។

*សូម្បីពួកតិរ្ថិយទាំងឡាយ ក៏នឹងតិះដៀលថា ឈ្មោះថា វត្ថុដែលមិនគួរធ្វើ របស់សមណៈទាំងឡាយ មិនមាន ពួកសមណៈជាន់សំពត់បន្តិចហើយ ត្រាច់ទៅ ដូច្នេះ ។ កាលនឹងជាន់ ក្នុងកាលឥឡូវនេះ ភិក្ខុជាច្រើនជាអ្នកដឹងចិត្តរបស់អ្នកដទៃ ភិក្ខុទាំងនោះជ្រាបថា គួរនឹងជាន់ និងជ្រាបថា មិនគួរនឹងជាន់ ក៏ក្នុងអនាគត (មនុស្សទាំងនោះ) នឹងមានឧបនិស្ស័យបន្តិចបន្តួច តែជនទាំងឡាយនោះមិនដឹងអនាគត ។ កាលភិក្ខុទាំងនោះជាន់ វត្ថុដែលគេប្រាថ្នាសម្រេច ប្រការនោះក៏នឹងការល្អ បើមិនសម្រេច ព្រះមានព្រះភាគទ្រង់មិនប្រាថ្នានឹងជាន់ ទើបទ្រង់នៅស្ងៀម ដោយហេតុទាំងនេះ គឺ ពួកមនុស្សនឹងមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយថា ពីមុនបុគ្គលធ្វើអភិនិហារដល់ភិក្ខុសង្ឃ រមែងបានវត្ថុដែលប្រាថ្នាហើយៗ ការធ្វើនោះឥឡូវនេះមិនបានទេ ភិក្ខុទាំងឡាយដែលបដិបត្តិបរិបូណ៌ ដឹងថាពួកភិក្ខុទាំងនោះ ភិក្ខុទាំងនេះ រមែងមិនអាចបដិបត្តិឲ្យសម្បូរណ៍ ដូច្នេះ ។*

*ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីជាន់ផ្ទាំងសំពត់ទេ ។ តែកាលភិក្ខុទាំងឡាយ មិនឈានកន្ទងបទបញ្ញត្តិ ដើម្បីភាពជាមង្គល ព្រះមានព្រះភាគ ទើបទ្រង់ដាក់អនុប្បញ្ញត្តិ*

ដើម្បីឲ្យជាន់បានថា ម្នាលភិក្ខុទាំងឡាយ គ្រហស្ថត្រូវការមង្គល តថាគត អនុញ្ញាតដើម្បីសេចក្តីជាមង្គល ដល់គ្រហស្ថទាំងឡាយ ដូច្នេះ ។ បទថា **បច្ឆិមំ ជនតំ តថាគតោ អបលោកេតិ** សេចក្តីថា ព្រះថេរៈពោលសំដៅ យកហេតុទី ៣ ក្នុងបណ្តាហេតុដែលពោលហើយ ។ លោកពោលពាក្យថា **នខោ សុខេន្តិ សុខំ** ព្រោះហេតុអ្វី ។ លោកសម្គាល់ថា ប្រហែលជាព្រះ សម្មាសម្ពុទ្ធ នៅមានសេចក្តីសម្គាល់ក្នុងកាមសុខល្លិកានុយោគ ទើបទ្រង់ មិនជាន់ ព្រោះដូច្នោះ សូម្បីយើងក៏នឹងមានធុរៈស្មើដោយព្រះសាស្តា ដូច្នេះ ទើបពោលយ៉ាងនោះ ។

**[២៥០]** បទថា **សោ ខោ អហំ** ជាដើម បណ្ឌិតគប្បីជ្រាបដោយ ន័យដែលពោលហើយក្នុងមហាសច្ចកៈ រហូតដល់ **យាវ រត្តិយា បច្ឆិមេ យាមេ** ។ តពីនោះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបាសរាសិសូត្រ តាំងពី **បញ្ចវគ្គិយានំ អាសវក្ខយា** ។

បទថា **អង្គ សគណ្ហេ សិប្បេ** បានដល់ សិល្បៈរបស់អ្នកសូម ។ បទថា **កុសលោ អហំ** សេចក្តីថា យើងជាអ្នកឆ្លាត ។ ក៏កុមារនេះ រៀន សិល្បៈក្នុងសម្នាក់របស់អ្នកណា ។ បិតារៀនក្នុងសម្នាក់របស់ជីតា កុមារ

នេះក៏រៀនក្នុងសម្នាក់បិតា ។

បានឮមកថា ក្នុងព្រះនគរកោសម្ពី ព្រះរាជាព្រះនាមថា **បរន្តប** ទ្រង់គ្រងរាជ្យ ។ ព្រះរាជមហេសីមានព្រះគភ៌ ទ្រង់អន្ទ្រយដណ្តប់សំពត់កម្ពលមានពណ៌ក្រហម មានសម្ព័ន្ធទន់នៅជាមួយនឹងព្រះរាជា ត្រង់ចុងព្រះដំណាក់ ។ មានសត្វហត្ថីលិង្គមួយ សម្គាល់ថាជាដុំសាច់ ក៏ហើរមកចាប់យក (ព្រះនាង) ទៅកាន់អាកាស ។ ព្រះនាងគិតថា សត្វនឹងទម្លាក់ព្រះអង្គចុះ ទើបទ្រង់នៅស្ងៀម ។ សត្វនោះ នាំព្រះនាងទៅចុះត្រង់បង្គាបឈើនាជើងភ្នំមួយកន្លែង ។ ព្រះនាងទើបទះព្រះហស្ថ ធ្វើសំឡេងខ្លាំងឡើង ។ សត្វនោះក៏ភ័យគេចចៀសទៅ ព្រះនាងក៏ប្រសូតព្រះឱរសលើបង្គាបឈើនោះឯង ។ កាលភ្លៀងធ្លាក់ចុះមកក្នុងពេលយប់ ។ វេលាយាមបី ព្រះនាងទើបយកសំពត់កម្ពលដណ្តប់ប្រថាប់អន្ទ្រយ ។ និងក្នុងទីមិនឆ្ងាយពីជើងភ្នំនោះ មានតាបសមួយរូបអាស្រ័យនៅ ។ ដោយសំឡេងស្រែករបស់ព្រះនាងនោះ តាបសទើបមកកាន់គល់ឈើកាលរុណោះឡើង សួរព្រះនាងដល់ជាតិ ហើយនាំជណ្តើរឲ្យនាងចុះមក នាំទៅកាន់ទីនៅរបស់ខ្លួន ឲ្យសោយបបរ និងបាយ ។ ព្រោះទារកកាន់យករដូវនៃពពក និងរដូវនៃភ្នំកើត

ហើយ ទើបតាំងឈ្មោះថា **ឧទេន** ។ ព្រះតាបសរកផ្លែឈើមកចិញ្ចឹមជន ទាំង ២ ។ ថ្ងៃមួយព្រះនាងធ្វើការទទួលក្នុងវេលាតាបសត្រឡប់ សម្ដែង មាយារបស់ស្ត្រីធ្វើតាបសឲ្យដាច់សីលភេទហើយ ។ កាលអ្នកទាំងនោះនៅ រួមគ្នា កាលវេលាក៏កន្លងទៅ ព្រះបាទបរន្តបៈសោយទីវង្គត់ហើយ ។ តាបស ងើយមើលនក្សត្រក្នុងវេលារាត្រីក៏ដឹងថា ព្រះរាជាសោយទីវង្គត់ ទើបសួរ ថា ព្រះរាជារបស់នាងសោយទីវង្គត់ហើយ នាងត្រូវការនឹងឲ្យបុត្ររបស់ នាងនៅក្នុងទីនេះឬ ឬនឹងឲ្យលើកស្វេត្រឆត្រក្នុងរាជសម្បត្តិរបស់ព្រះបិតា ។ ព្រះនាង ទើបពោលសេចក្ដីទាំងអស់តាំងពីដើមមក ឲ្យព្រះឱរសជ្រាបថា ព្រះឱរសត្រូវការនឹងលើកស្វេត្រឆត្ររបស់ព្រះបិតា ទើបប្រាប់ដល់តាបស ។ ឯតាបសចេះវិជ្ជាចាប់ដំរី ។ សួរថា វិជ្ជានោះតាបសបានមកពីណា ។ ឆ្លើយ ថា បានមកពីសម្នាក់ស្ដេចសក្កៈ ។ បានឮថា ក្នុងកាលមុន ស្ដេចសក្កៈ មកទំនុកបម្រុងតាបសនោះ បានសួរថា លោកម្ចាស់លំបាកដោយរឿងអ្វី ខ្លះ ។ ព្រះតាបសទើបទូលថា មានអន្តរាយដាប់ទាក់ទងនឹងដំរី ។ ស្ដេច សក្កៈទើបប្រទានវិជ្ជាចាប់ដំរី និងពិណដល់តាបសនោះ ត្រាស់ទូន្មានថា កាលត្រូវការនឹងឲ្យដំរីគេចចេញ ចូរដេញពិណនេះហើយ រាយមន្តនេះ កាល

មានសេចក្តីប្រាថ្នានឹងឲ្យដំរីមក ក៏ចូររាយមន្តនេះ ដូច្នេះ ។ តាបសទើប ទូន្មានសិល្បៈនោះដល់កុមារ ។ ព្រះកុមារនោះ ឡើងដើមជ្រៃមួយដើម កាលដំរីទាំងឡាយមកហើយ ក៏ដេញពិណរាយមន្ត ។ ដំរីទាំងឡាយ ខ្លាច គេចចៀសទៅហើយ ។ ព្រះកុមារជ្រាបអានុភាពរបស់សិល្បៈ ថ្ងៃស្អែក ទើបប្រកបសិល្បៈហៅដំរី ។ ដំរីដែលជាមេហ្វូងក៏មក ឱន.កចូលទៅជិត ។ ព្រះកុមារឡើងកដំរី ហើយជ្រើសរើសដំរីកម្លោះៗ ដែលល្មមនឹងប្រកបបាន ហើយកាន់យកសំពត់កម្ពល និងព្រះទម្រង់ទៅថ្វាយបង្គំមាតាបិតា ចេញទៅ ដោយលំដាប់ ចូលទៅកាន់ស្រុកនោះៗ រួបរួមមនុស្ស ប្រាប់ថា យើងជា ឱរសព្រះរាជា ត្រូវការសម្បត្តិទើបមក ទៅឡោមព័ទ្ធព្រះនគរ ហើយពោល ថា យើងជាឱរសរបស់ព្រះរាជា សូមអ្នកទាំងឡាយចូរប្រគល់ឆ័ត្រដល់យើង កាលពួកគេមិនជឿ ក៏សម្តែងសំពត់កម្ពល និងព្រះទម្រង់ឲ្យមើល ហើយ ក៏បានលើកឆ័ត្រឡើងគ្រងរាជ្យ ។ ព្រះរាជានោះ មានព្រះទ័យទុកដាក់ចំពោះ តែដំរី កាលគេទូលថា ត្រង់ទីឯណោះមានដំរីល្អ ក៏ទ្រង់ស្តេចទៅចាប់ ។ ព្រះបាទចណ្ឌបជ្ជោត ទ្រង់ត្រិះរិះថា យើងនឹងរៀនសិល្បៈក្នុងសម្នាក់របស់ ព្រះបាទឧទេននោះ ទើបត្រាស់បង្គាប់ឲ្យចាត់ចែងដំរីឈើឡើង ចាត់ឲ្យទាហាន

អន្តោយខាងក្នុងដំរីឈើនោះ ពេលព្រះរាជានោះស្តេចមកដើម្បីទ្រង់ចាប់ដំរី ក៏ត្រូវចាប់បាន បញ្ជូនព្រះធីតាទៅដើម្បីរៀនសិល្បៈចាប់ដំរី ក្នុងសម្នាក់របស់ព្រះរាជា ។ ព្រះអង្គបានសម្រេចសំវាសរួមគ្នានឹងព្រះធីតានោះ ហើយនាំគ្នាគេចចេញទៅកាន់ព្រះនគររបស់ព្រះអង្គ ។ ព្រះពោធិរាជកុមារនេះ ទ្រង់កើតក្នុងព្រះគភ៌របស់ព្រះធីតានោះ ទើបបានរៀនសិល្បៈ (មន្ត) ក្នុងសម្នាក់របស់ព្រះជនករបស់ព្រះអង្គ ។

**[២៧៩]** បទថា **បធានិយង្គានិ** សេចក្តីថា សេចក្តីផ្តើម លោកហៅថា **បធានៈ** (សេចក្តីព្យាយាម) ។ សេចក្តីព្យាយាមរបស់ភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **បធានិយៈ** អ្នកមានសេចក្តីព្យាយាម ។ អង្គនៃភិក្ខុដែលមានសេចក្តីព្យាយាម ហេតុនោះ ឈ្មោះថា **បធានិយង្គៈ** ។

បទថា **សទ្ធោ** បានដល់ អ្នកប្រកបដោយសទ្ធា ។ ក៏សទ្ធានោះមាន ៤ ប្រការ គឺ អាគមនសទ្ធា ១ អធិគមនសទ្ធា ១ ឱកប្បនសទ្ធា ១ បសាទសទ្ធា ១ ។

ក្នុងបណ្តាសទ្ធា ៤ យ៉ាងនោះ សេចក្តីជឿចំពោះព្រះសព្វញ្ញុពោធិសត្វ ឈ្មោះថា **អាគមនសទ្ធា** ព្រោះមកហើយចាប់ផ្តើមតាំងពីតាំងសេចក្តី

ប្រាថ្នា ។ ឈ្មោះថា **អធិគមនសទ្ធា** ព្រោះសម្រេចហើយដោយការចាក់ធ្លុះនៃព្រះអរិយសាវកទាំងឡាយ ។ សេចក្តីដាក់ចិត្តជឿដោយសេចក្តីមិនញាប់ញ័រ កាលគេពោលថា **ពុទ្ធោ ធម្មោ សង្ឃោ** ឈ្មោះថា **ឱកប្បនសទ្ធា** ។ ការកើតឡើងនៃសេចក្តីជ្រះថ្លា ឈ្មោះថា **បសាទសទ្ធា** ។

ក្នុងទីនេះបំណងយក **ឱកប្បនសទ្ធា** ។ បទថា **ពោធិ** បានដល់ មគ្គញ្ញាណ ៤ ។ បុគ្គលរមែងជឿថា ព្រះតថាគតទ្រង់ចាក់ធ្លុះមគ្គញ្ញាណ ៤ នោះល្អហើយ ។ម្យ៉ាងទៀត ពាក្យនេះជាកំពូលនៃទេសនាតែម្តង ។ ក៏សេចក្តីជឿក្នុងព្រះរតនៈទាំង ៣ លោកបំណងយកហើយដោយអង្គនេះ ។ គឺ អ្នកណាមានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាដើម យ៉ាងខ្លាំងក្លា **បធានវីរិយ** របស់អ្នកនោះ រមែងសម្រេច ។ បទថា **អប្បាពាធោ** បានដល់ ការមិនមានរោគ ។

បទថា **អប្បាតង្កោ** បានដល់ សេចក្តីមិនមានទុក្ខ ។ បទថា **សមវេបាកិនិយា** សេចក្តីថា មានវិបាកស្មើគ្នា ។ បទថា **គហណិយា** បានដល់ តេជោធាតុដែលកើតពីកម្ម ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** សេចក្តីថា អ្នកមានធាតុដែលត្រជាក់កម្មាត់ ក៏ខ្លាចត្រជាក់ អ្នកមានធាតុក្តៅកម្មាត់ ក៏

ខ្វាចក្តៅ ។ សេចក្តីព្យាយាមរបស់អ្នកទាំងនោះនឹងមិនសម្រេច ។ នឹងសម្រេចដល់អ្នកមានធាតុជាកណ្តាលៗ ។ ព្រោះដូច្នោះ លោកទើបពោលថា **មជ្ឈិមាយបធានក្ខមាយ** ។ បទថា **យថាភូតំ អត្តានំ អាវិកត្តា** សេចក្តីថា ប្រកាសទោសរបស់ខ្លួន តាមសេចក្តីពិត ។ បទថា **ឧទយត្ថគាមិនិយា** សេចក្តីថា អាចនឹងដល់ គឺ នឹងកំណត់ដល់ការកើត និងការរលត់ ។ ដោយពាក្យនេះលោកពោលដល់ឧទយព្វយញ្ញាណ ដែលកំណត់លក្ខណៈ ៥០ ។ បទថា **អរិយាយ** បានដល់ បរិសុទ្ធិ ។ បទថា **និព្វេធិកាយ** សេចក្តីថា អាចកំណត់កងលោភៈជាដើមបានក្នុងកាលមុន ។ បទថា **សម្មាទុក្ខក្ខយគាមិនិយា** សេចក្តីថា ឲ្យដល់ការអស់ទៅនៃទុក្ខដែលនឹងត្រូវធ្វើឲ្យអស់នោះ ព្រោះលះកិលេសទាំងឡាយចេញបានដោយទង្គប្បហាន ។ ដោយបទទាំងអស់នោះត្រាស់វិបស្សនាបញ្ញាតែម្យ៉ាង ដោយប្រការដូច្នេះ ។ ពិតណាស់ សេចក្តីព្យាយាម រមែងមិនសម្រេចដល់អ្នកមានបញ្ញាទន់ខ្សោយ ។

ម្យ៉ាងទៀត ដោយពាក្យនេះគប្បីជ្រាបថា អង្គនៃភិក្ខុដែលមានសេចក្តីព្យាយាមទាំងប្រាំជាលោកិយៈ ប៉ុណ្ណោះ ។

បទថា **សាយមនុសិដ្ឋោ បាតោ វិសេសមធិគច្ឆតិ** ទូន្មានពេលល្ងាច

សម្រេចគុណវិសេសក្នុងពេលព្រឹក សេចក្ដីថា កាលព្រះអាទិត្យអស្តង្គត ក៏ទូន្មាន ពេលអរុណរះឡើងក៏សម្រេចគុណវិសេស ។ ពាក្យថា **បាតម-នុសិដ្ឋោ សាយំ** សេចក្ដីថា ពេលអរុណរះ ក៏ទូន្មាន ក្នុងពេលព្រះអាទិត្យអស្តង្គត ក៏សម្រេចគុណវិសេស ។ ព្រះទេសនានេះ លោកពោលដោយអំណាចនៃនេយ្យបុគ្គល ។ ពិតហើយ នេយ្យបុគ្គលសូម្បីមានបញ្ញាទន់ខ្សោយ ក៏សម្រេចអរហត្តបានដោយ ៧ ថ្ងៃ ។ អ្នកមានបញ្ញាចាស់ក្លា តែមួយថ្ងៃ ។ គប្បីជ្រាបពាក្យដ៏សេស ដោយអំណាចនៃបញ្ញាជាកណ្ដាលៗ ។ បទថា **អហោ ពុទ្ធោ អហោ ធម្មោអហោ ធម្មស្ស ស្វាក្ខាតតា** សេចក្ដីថា ព្រោះភិក្ខុ ឲ្យអាចារ្យប្រាប់កម្មដ្ឋានក្នុងវេលាព្រឹក ក្នុងវេលាល្ងាចសម្រេចអរហត្ត ព្រោះធម៌របស់ព្រះពុទ្ធទាំងឡាយមានគុណដ៏ក្រៃលែង និងព្រោះព្រះធម៌ដែលព្រះពុទ្ធត្រាស់ល្អហើយ ដូច្នោះ កាលនឹងសរសើរ ទើបពោលយ៉ាងនោះ ។ បទថា **យត្រ ហិ នាម** ជានិបាតប្រើក្នុងអត្ថថាគួរអស្ចារ្យ ។

**[២៨១]** បទថា **កុច្ឆិមតិ** បានដល់ សត្វដែលជិតចុតិ ។ បទថា **យោ មេ អយំ ភន្តេ កុច្ឆិគតោ** សេចក្ដីថា ក៏សរណៈ រមែងជាការកាន់យកហើយដោយអាការយ៉ាងនេះឬ ។ មិនទាន់ជាការកាន់យកហើយ ។ ធម្មតា

ការដល់សរណៈដោយអចិត្តកៈ រមែងមិនមាន ។ ចំណែកការរក្សា រមែងប្រាកដចំពោះហើយ ។ ខាងក្រោយមកមាតាបិតា បានដាស់តឿនកុមារនោះឲ្យរលឹកបានថា ម្នាលកូន កាលនៅក្នុងគភ៌ក៏ឲ្យកាន់យកសរណៈនោះ ដូច្នេះ កាលវេលាដល់ ព្រះរាជកុមារនោះ ក៏កំណត់បានហើយ ញុំាងសតិឲ្យកើតឡើងថា យើងជាឧបាសកដល់សរណៈហើយ ដូច្នេះ ក្នុងកាលណា ។ ក្នុងកាលនោះ រមែងឈ្មោះថា កាន់យកសរណៈហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់នោះឯង ។

" ចប់អដ្ឋកថា ពោធិរាជកុមារសូត្រទី ៥ "

# អ ដ្ឋ ក ថា

## អង្គុលិមាលសូត្រទី ៦

**[២៨២]** *អង្គុលិមាលសូត្រ មានពាក្យចាប់ផ្តើមថា ខ្ញុំបានស្តាប់មក យ៉ាងនេះ ៖*

*សួរថា ក្នុងព្រះសូត្រនោះ ពាក្យថា ទ្រទ្រង់កម្រងនៃម្រាមដៃ ទ្រទ្រង់ទុក ព្រោះហេតុអ្វី ។ ឆ្លើយថា ទ្រទ្រង់ទុកតាមពាក្យរបស់អាចារ្យ ។ ក្នុងសេចក្តីនោះ មានអនុបុព្វិកថា ដូចតទៅនេះ ៖*

*បានឮថា ព្រះអង្គុលិមាលនេះ បានបដិសន្ធិក្នុងគភ៌នៃនាងព្រាហ្មណ៍ឈ្មោះ* **មន្តានី** *នៃបុរោហិតរបស់ព្រះបាទកោសល ។ នាងព្រាហ្មណីបានប្រសូតបុត្រក្នុងវេលាពេលយប់ ។ ក្នុងវេលាដែលអង្គុលិមាលនោះប្រសូតចាកគភ៌មាតា អាវុធទាំងឡាយក្នុងនគរទាំងអស់ក៏រន្ទាលឡើង ។ សូម្បីពន្លឺដែលជាមង្គលរបស់ព្រះរាជា សូម្បីទាំងស្រោមដាវដែលនៅក្នុងក្រឡាបន្ទំដ៏សិរីក៏រុងរឿង ។ ព្រាហ្មណ៍ទើបក្រោកចេញមក ហើយមើលផ្កាយនក្សត្រ ក៏ដឹងថា បុត្រកើតដោយនក្សត្រចោរ ទើបចូលគាល់ព្រះរាជា ទូល*

សួរដល់ការផ្ទុំជាសុខ ។

ព្រះរាជាត្រាស់ថា លោកអាចារ្យ យើងនឹងដេកជាសុខនៅបានពីណា បើអាវុធដែលជាមង្គលរបស់យើងភ្លឺរុងរឿង យើញថានឹងមានអន្តរាយដល់រដ្ឋ ឬដល់ជីវិត ។ បុរោហិតទូលថា បពិត្រមហារាជ ទ្រង់កុំខ្លាចឡើយ កុមារកើតហើយក្នុងផ្ទះរបស់ទូលបង្គំ អាវុធទាំងឡាយ មិនមែននឹងរុងរឿងដោយអានុភាពរបស់កុមារនោះ ។ នឹងមានហេតុអ្វី លោកអាចារ្យ ។ បពិត្រព្រះមហារាជ គេនឹងជាចោរ ។ គេនឹងជាចោរម្នាក់ ឬថា នឹងជាចោរប្រទូស-រ៉ាយដល់រាជសម្បត្តិ ។ គេនឹងជាចោរធម្មតាម្នាក់នឹងធ្វើអ្វីបាន ។ ឯបុរោ-ហិតកាលក្រាបទូលយ៉ាងនោះហើយ ដើម្បីនឹងយកព្រះទ័យរបស់ព្រះរាជាទើបទូលថា ចូរសម្លាប់វាចុះព្រះអង្គ ។ ព្រះរាជា ។ ជាចោរធម្មតានឹងធ្វើអ្វីបាន ។ ដូចស្រូវសាលីតែមួយគុម្ពក្នុងស្រែទាំងពាន់ករីសៈ ចូរទំនុកបម្រុងគេទុកចុះ ។ កាលនឹងតាំងឈ្មោះកុមារនោះ វត្ថុទាំងនេះ គឺ ស្រោមដាវដែលជាមង្គលដែលដាក់ទុកក្នុងទីក្រឡាបន្ទំ កូនសរដែលដាក់ទុកក្នុងបំពង់កូនកាំបិតសម្រាប់កាត់ទងត្នោតដែលទុកក្នុងសំឡីកប្បាស ឆេះឡើងបញ្ចេញពន្លឺតែមិនបៀតបៀន ដូច្នោះ ទើបតាំងឈ្មោះថា **អហិង្សកៈ** ។ ល្មមវេលា

នឹងឲ្យរៀនសិល្បៈ ក៏បញ្ជូនគេទៅកាន់ក្រុងតក្កសិលា ។ អហិង្សកកុមារនោះ ជាធម្មន្តេវាសិក ផ្តើមរៀនសិល្បៈហើយ ។ ជាអ្នកដល់ព្រមដោយវត្ត តាំងចិត្តបម្រើប្រព្រឹត្តជាទីពេញចិត្ត និយាយចរចាពីរោះ ។ ចំណែកអន្តេវាសិកដ៏សេស ជាអន្តេវាសិកខាងក្រៅ ។ អន្តេវាសិកទាំងនោះ អង្គុយប្រឹក្សាគ្នាថា ចាប់តាំងពីវេលាដែលអហិង្សកមាណពមក ពួកយើងមិនប្រាកដឡើយ យើងនឹងទម្លាយគេបានយ៉ាងណា នឹងនិយាយថា ជាអ្នកល្ងង់ក៏និយាយមិនបាន ព្រោះមានបញ្ញាក្រៃលែងជាងពួកយើង និងថា មានវត្តមិនល្អ ក៏មិនអាចនិយាយ ព្រោះជាអ្នកសម្បូរណ៍ដោយវត្ត និងថា មានជាតិថោកទាប ក៏និយាយមិនបាន ព្រោះសម្បូរណ៍ដោយជាតិ ពួកយើងនឹងធ្វើយ៉ាងណា ខណៈនោះ ប្រឹក្សានឹងអ្នកមានឆ្លាតវាងវៃម្នាក់ថា យើងនឹងធ្វើចន្លោះរបស់អាចារ្យទម្លាយគេចេញ បែងចែកជាបីពួក ពួកដំបូងចូលទៅរកអាចារ្យ សំពះហើយឈរ ។ អាចារ្យសួរថា អ្វីបា ។ ក៏ប្រាប់ថា ពួកខ្ញុំបានស្តាប់រឿងមួយក្នុងផ្ទះនេះ ។ កាលអាចារ្យសួរថា អ្វីបា ។ ក៏ពោលថា ពួកយើងជ្រាបថា អហិង្សកមាណពនឹងប្រទូសរ៉ាយជាមួយលោកអាចារ្យ ។ អាចារ្យទើបគំហកដេញចេញថា ចេញទៅ អ្នកឯងថោកទាប អ្នកឯងកុំទម្លាយបុត្ររបស់យើង

ក្នុងពីយើងចេញឡើយ ។ បន្ទាប់ពីនោះ ក៏ទៅមួយពួកទៀត តអំពីនោះ ក៏ទៅមួយពួកទៀត ទាំងបីពួក បានពោលទំនងតែមួយដូចគ្នា ហើយក៏ពោលថា បើអាចារ្យមិនជឿពួកខ្ញុំ ក៏ចូរដឹងដោយខ្លួនឯងចុះ ដូច្នេះ ។ លោកអាចារ្យឃើញសិស្សទាំងឡាយ ពោលដោយសេចក្តីហួងហែង ទើបសម្រេចចិត្តថា នឹងមានសេចក្តីពិត ទើបគិតថា យើងនឹងសម្លាប់វា ។

តទៅទើបគិតទៀតថា បើយើងសម្លាប់វា នរណាៗ ដែលគិតថា លោកអាចារ្យទិសាបាមោក្ខ ញ៉ាំងទោសឲ្យកើតឡើងក្នុងមាណពអ្នកមករៀនសិល្បៈក្នុងសម្នាក់របស់ខ្លួន ហើយផ្តាច់ជីវិតចេញ ដូច្នេះ ក៏មិនមកដើម្បីរៀនសូត្រសិល្បៈទៀត ដោយអាការយ៉ាងនេះ យើងក៏នឹងសាបសូន្យលាភ កុំដូច្នោះឡើយ យើងនឹងប្រាប់វាថា នៅមានសិល្បៈវិជ្ជាថ្នាក់ចុងក្រោយបង្អស់ ហើយពោលថា អ្នកឯងត្រូវសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ ក្នុងរឿងនេះ ឯងនឹងជាបុគ្គលម្នាក់លេចធ្លោឡើង សម្លាប់មនុស្សឲ្យបានគ្រប់មួយពាន់ ។ ពេលនោះ អាចារ្យទើបពោលចំពោះអហិង្សកកុមារថា មកចុះបា អ្នកចូរសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ កាលធ្វើបានដូច្នេះ ក៏នឹងជាការធ្វើឧបចារៈដល់សិល្បៈ ការបូជាគ្រូ ដូច្នេះ ។ អហិង្សកកុមារ ទើបពោលថា បពិត្រ

លោកអាចារ្យ ខ្ញុំកើតក្នុងត្រកូលដែលមិនបៀតបៀន ខ្ញុំមិនអាចធ្វើដូច្នោះ ។ សិល្បៈដែលមិនបានតម្លៃបូជាគ្រូ ក៏នឹងមិនឲ្យផលនោះទេ ។ អហិង្សកកុមារ ទើបកាន់យកអាវុធ ៥ ប្រការ សំពះអាចារ្យចូលកាន់ព្រៃ ឈរក្នុងទីដែលមនុស្សនឹងចូលទៅកាន់ព្រៃខ្លះ ត្រង់កណ្តាលព្រៃខ្លះ ត្រង់ទីដែលអ្នកចេញពីព្រៃខ្លះ សម្លាប់មនុស្សអស់ជាច្រើន ។ ក៏មិនកាន់យកសំពត់ ឬសំពត់ជូតសីសៈ ធ្វើត្រឹមតែកំណត់ថា ១ ឬ២ ដូច្នេះ ដើរទៅ សូម្បីការរាប់ ក៏កំណត់មិនបាន ។ តែដោយធម្មតា អហិង្សកកុមារនេះ ជាអ្នកមានបញ្ញា តែចិត្តមិនតាំងមាំបាន ព្រោះបាណាតិបាត ។ ដូច្នោះ ទើបកំណត់សូម្បីការរាប់មិនបានតាមលំដាប់ ។ គេកាត់ម្រាមដៃបានមួយៗ ក៏រក្សាទុក ។ ក្នុងទីដែលរក្សាទុក ម្រាមដៃក៏វិនាសអស់ទៅ ។ តអំពីនោះ ទើបក្រងធ្វើជាកម្រងម្រាមដៃបង់ក ។ ដោយហេតុនោះឯង គេទើបប្រាកដឈ្មោះថា **អង្គុលិមាល** ។ អង្គុលិមាលនោះ ត្រាច់ទៅកាន់ព្រៃទាំងអស់ ដរាបមិនមានអ្នកណាអាចទៅព្រៃដើម្បីរកឧសជាដើម ។ ក្នុងពេលយប់ក៏ចូលមកកាន់ខាងក្នុងស្រុក យកជើងធាក់ទ្វារ ។ តពីនោះ ក៏សម្លាប់មនុស្សដែលដេកនោះឯង កំណត់ថា ១ , ១ ដើរទៅ ។ ស្រុកក៏បង្ខិតថយទៅតាំងក្នុងនិគម ។ និគមក៏បង្ខិត

ថយទៅតាំងនៅក្នុងក្រុង ។ ពួកមនុស្សលះបង់ស្រុក នាំកូនធ្វើដំណើរមក លោមព័ទ្ធព្រះនគរសាវត្ថី អស់រយៈផ្លូវដល់បីយោជន៍ តាំងបន្ទាយសម្រាក ប្រជុំគ្នាត្រង់រាជវាំង មនុស្សជាច្រើនពោលរៀបរាប់ផ្សេងៗ គ្នាថា បពិត្រ សម្មតិទេព ក្នុងព្រំដែនរបស់ព្រះអង្គ មានចោរឈ្មោះអង្គុលិមាលជាដើម ។ ក្នុងលំដាប់នោះ ព្រាហ្មណ៍ក៏ដឹងថា ចោរអង្គុលិមារនោះ គឺជាបុត្ររបស់ ខ្លួន ទើបពោលនឹងនាងព្រាហ្មណីថា នែ៎នាងដ៏ចម្រើន កើតចោរឈ្មោះអង្គុ- លិមាលឡើងហើយ ចោរនោះមិនមែនអ្នកដទៃណា គឺ អហិង្សកកុមារជា កូនរបស់នាង ឥឡូវនេះ ព្រះរាជាស្តេចនឹងចេញទៅចាប់គេ យើងគួរនឹង ធ្វើយ៉ាងណា ។ នាងព្រាហ្មណីនិយាយថា លោកទៅចុះ ចូរទៅនាំកូនរបស់ យើងមក ។ ព្រាហ្មណ៍និយាយថា នែ៎នាងដ៏ចម្រើន ខ្ញុំមិនអាចទៅ ព្រោះ មិនទុកចិត្តដល់បុគ្គល ៤ ពួក គឺ ចោរដែលជាសម្លាញ់ចាស់របស់យើង មិនគួរធ្វើទុកក្នុងចិត្តដល់សម្លាញ់ដែលធ្លាប់មានសន្ថវមេត្រីនិងគ្នាមកពីមុន ព្រះរាជាក៏មិនគួរទុកចិត្តថា នឹងរាប់អានយើង ។ ស្ត្រីក៏មិនគួរទុកចិត្តថា រាប់នៅក្នុងសាច់ញាតិរបស់យើង តែចិត្តរបស់ម្តាយ មានចិត្តទន់ ដូច្នោះ នាងព្រាហ្មណីទើបពោលថា ខ្ញុំនឹងទៅនាំកូនរបស់ខ្ញុំមក ដូច្នេះ ទើបចេញ

ទៅ ។ និងក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាបច្ចូសម័យជិតភ្លឺ ទ្រង់ឃើញអង្គុលិមាល ទើបទ្រង់ព្រះតម្រិះថា កាលតថាគតទៅ នឹងជាសេចក្ដីសួស្ដីដល់គេ អ្នកដែលនៅក្នុងព្រៃ ដែលរកស្រុកមិនបាន កាលបានស្ដាប់គាថាដែលប្រកបដោយបទ ៤ បទ ចេញបួសក្នុងសម្នាក់របស់តថាគតហើយ នឹងធ្វើឲ្យច្បាស់នូវអភិញ្ញា ៦ បើតថាគតមិនទៅ គេនឹងធ្វើខុសក្នុងមាតា នឹងជាអ្នកដែលនរណាៗ លើកឡើងមិនបាន តថាគតនឹងធ្វើការសង្គ្រោះគេ ដូច្នេះ ហើយទ្រង់ស្លៀកដណ្ដប់ក្នុងវេលាព្រឹក ចូលទៅដើម្បីបិណ្ឌបាត ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ បំណងនឹងសង្គ្រោះគេ ទើបស្ដេចចេញចាកពីវិហារ ។ ដើម្បីនឹងសម្ដែងសេចក្ដីនេះ លោកទើបពោលថា **អថ ខោ ភគវា** ដូច្នេះជាដើម ។ ពាក្យថា **សង្គរិត្វា សង្គរិត្វា** សេចក្ដីថា ជាពួកៗ ច្ចាប់សង្កេត ។ បទថា **ហត្ថត្ថំ គច្ឆន្តិ** សេចក្ដីថា ដល់ការតាំងនៅមិនបានក្នុងដៃ គឺ វិនាសទៅ ។ សួរថា ក៏អ្នកទាំងនោះចាំព្រះមានព្រះភាគបាន ដូចម្ដេចពោលយ៉ាងនេះថា ចាំមិនបានឬ ? ឆ្លើយថា ចាំមិនបាន ។ ព្រោះព្រះមានព្រះភាគក្លែងភេទ ស្ដេចទៅត្រឹមតែមួយព្រះអង្គ

ក្នុងសម័យនោះ សូម្បីចោរក៏សោប់សោល់ក្នុងចិត្ត ព្រោះបរិភោគមិនគ្រប់គ្រាន់ និងដេកជាទុក្ខអស់វេលាយូរ ។ ម្យ៉ាងទៀត ពួកមនុស្សត្រូវចោរអង្គុលិមាលសម្លាប់អស់ប៉ុន្មាន ។ ត្រូវសម្លាប់អស់ ៩៩៩ នាក់ហើយ ។ ក៏ចោរនោះមានសេចក្តីសម្គាល់ថា ឥឡូវនេះ បើបានម្នាក់ទៀតក៏នឹងគ្រប់មួយពាន់ ទើបតាំងចិត្តថា ឃើញអ្នកណាមុនក៏នឹងសម្លាប់អ្នកនោះឲ្យគ្រប់ចំនួន ដើម្បីធ្វើឧបចារៈដល់សិល្បៈ (បូជាគ្រូ) កោរសក់ និងពុកមាត់ ហើយងូតទឹកផ្លាស់ប្តូរសំពត់នឹងទៅជួបមាតាបិតា ដូច្នេះ ទើបចេញពីកណ្តាលព្រៃមកកាន់មាត់ព្រៃ ឈរក្នុងទីម្ខាង បានឃើញព្រះមានព្រះភាគហើយ ។ ដើម្បីនឹងសម្តែងសេចក្តីនេះ លោកទើបពោលថា **អទ្ទសា ខោ** ដូច្នេះជាដើម ។

**[២៨៥]** បទថា ***ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ*** សេចក្តីថា ទ្រង់បណ្តាលឲ្យដូចជាផែនដីធំមានរលកតាំងឡើង ហើយទ្រង់ជាន់នៅក្នុងចំណែកខាងនាយ វិលក្នុងចំណែកខាងអាយចេញទៅ ។ អង្គុលិមាល ចោលកូនសរចេញ ហើយដើរទៅ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទីទួលធំនៅខាងមុខហើយព្រះអង្គនៅត្រង់កណ្តាល ចោរនៅត្រង់ចុងបំផុត ។ អង្គុលិមាលនោះ

គិតថា យើងនឹងដេញទាន់ ចាប់បានក្នុងកាលឥឡូវនេះ ទើបប្រញាប់ស្ទុះទៅដោយកម្លាំង ។

ព្រះមានព្រះភាគ ស្ដេចនៅត្រង់ទីខាងចុងនៃទួល ចោរនៅត្រង់កណ្ដាល គេប្រញាប់ស្ទុះមកដោយរហ័ស គិតថា ដេញទាន់នឹងចាប់បានត្រង់នេះ ។ ព្រះមានព្រះភាគ ក៏ទ្រង់បណ្ដាលអណ្ដូង ឬផែនដីទុកខាងមុខគេ ។ ដោយទំនងនេះ រហូតអស់ផ្លូវដល់បីយោជន៍ ។ ចោរហត់នឿយ ទឹកមាត់ក្នុងមាត់ស្ងួត ញើសហូរចេញអំពីក្លៀក ។ គ្រានេះ មានសេចក្ដីគិតដូច្នេះដល់គេថា គួរអស្ចារ្យណាស់ហ្ន៎ លោកដ៏ចម្រើន ។

បទថា **មិគំបិ** សេចក្ដីថា ម្រឹគដូចម្ដេច នឹងបានបាន ? ។ ក្នុងពេលដែលអស់កម្លាំង ក៏ចាប់យកមកជាអាហារបាន ។ បានឮថា ចោរនោះគោះគុម្ពឈើមួយកន្លែង ឲ្យម្រឹគក្រោកឡើងគេចចេញទៅ ។ បន្ទាប់ពីនោះក៏នឹងជាប់តាមម្រឹគ បានដូចចិត្តប្រាថ្នាហើយអាំងស៊ី ។

**[២៨៦]** បទថា **បុច្ឆេយ្យំ** សេចក្ដីថា សមណៈនេះកំពុងដើរទៅពិតមែន (ក៏ថា) ឈប់ហើយ ចំណែកខ្លួនយើងឈប់ហើយ ក៏ថា មិនឈប់ដោយហេតុណា ធ្វើដូចម្ដេច ? ហ្ន៎ យើងនឹងគប្បីសួរហេតុនោះៗ ចំពោះ

សមណៈនេះ ។ បទថា **និធាយ** សេចក្តីថា សូម្បីអាជ្ញាណាដែលបុគ្គល
គប្បីឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ ដើម្បីបៀតបៀន យើងដាក់អាជ្ញានោះ
គឺ នាំចេញ ពិចារណាដោយមេត្តា ខន្តិ ប្រព្រឹត្តទៅក្នុងសារាណីយធម៌ទាំង
ឡាយដោយអវិហិង្សា ។ បទថា **តុវមដ្ឋិតោសិ** សេចក្តីថា កាលអ្នកសម្លាប់
សត្វ មានប្រមាណមួយពាន់នេះ ព្រោះមិនមានសេចក្តីសង្រួមក្នុងសត្វមាន
ជីវិតទាំងឡាយ មេត្តាក្តី ខន្តិក្តី បដិសង្ខាក្តី អវិហិង្សាក្តី សារាណីយធម៌ក្តី
របស់អ្នកទើបមិនមាន ដូច្នោះ អ្នកទើបឈ្មោះថា មិនទាន់ឈប់ ។ មាន
ពាក្យអធិប្បាយថា សូម្បីឈប់ហើយដោយឥរិយាបថក្នុងខណៈនេះ អ្នកក៏
នឹងទៅកាន់ក្នុងនរក គឺ នឹងត្រាច់ទៅក្នុងកំណើតតិរច្ឆាន ក្នុងប្រេតវិស័យ
ឬក្នុងអសុរកាយ ។ ក្នុងលំដាប់នោះ ចោរគិតថា ការបន្លឺសីហនាទនេះធំ
ការបន្លឺដ៏ធំនេះ នឹងជារបស់អ្នកដទៃមិនបាន ការបន្លឺនេះប្រាកដជារបស់ព្រះ-
សមណៈព្រះនាមថា សិទ្ធត្ថៈ ជាឱរសនៃព្រះនាងមហាមាយា យើងឃើញ
នេះប្រាកដជាព្រះសម្មាសម្ពុទ្ធដែលមានព្រះចក្ខុមុតក្លា ទ្រង់ឃើញហើយហ្ន៎
ព្រះមានព្រះភាគស្តេចមកដើម្បីធ្វើការសង្គ្រោះដល់យើង ដូច្នេះ ទើបពោល
ថា **ចិរស្សំ វត មេ** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងនោះ បទថា **មហិតោ** សេចក្ដីថា ដែលទេវតានិងមនុស្សជាដើមបូជាហើយ ដោយការបូជាដោយបច្ច័យ ៤ ។ បទថា **បច្ចុបាទិ** សេចក្ដីថា ទ្រង់ដំណើរមកកាន់ព្រៃធំនេះដើម្បីនឹងសង្គ្រោះយើងដោយកន្លងកាលយូរណាស់ ។ ពាក្យថា **បជហិស្សំ បាបំ** សេចក្ដីថា ខ្ញុំព្រះអង្គនឹងលះបាប ។ បទថា **ឥច្ចេវ** ប្រែថា ពោលយ៉ាងនេះហើយ ដោយពិត ។ បទថា **អាវុធំ** បានដល់ អាវុធ ៥ ប្រការ ។ បទថា **សោព្ភេ** គឺដែលដាច់ទៅតែម្ខាង ។ បទថា **បបាតេ** បានដល់ ដាច់ម្ខាង ។ បទថា **នរកេ** គឺ ទីដែលបែកក្រហែង ។ ម្យ៉ាងទៀត ក្នុងទីនេះលោកពោលដល់ព្រៃប៉ុណ្ណោះ ដោយបទទាំងបីនេះ ។ បទថា **អវកិរិ** បានដល់ បោះទៅ គឺចោលទៅហើយ ។ បទថា **តមេហិ ភិក្ខូតិ តទា អហោច** សេចក្ដីថា ព្រះមានព្រះភាគ កាលនឹងញ៉ាំងអង្គុលីមាលនេះឲ្យបួស ក៏មិនមានកិច្ចក្នុងការស្វែងរកថា នឹងបានកូនកាំបិតពីទីណា នឹងបានបាត្រចីវរពីទីណា ដូច្នេះ ។

ម្យ៉ាងទៀត ទ្រង់ពិចារណាមើលកម្ម ។ ពេលនោះទ្រង់ជ្រាបថា អង្គុលិមាលនោះ ធ្លាប់បានថ្វាយភណ្ឌៈ គឺ បរិក្ខារ ៨ ដល់លោកអ្នកមានសីលក្នុងកាលមុន ទើបទ្រង់លាព្រះហស្ដខាងស្ដាំ ត្រាស់ថា **ឯហិ ភិក្ខុ ស្វាក្ខាតោ**

ធម្មោ ចរ ព្រហ្មចរិយំ សម្មាទុក្ខស្ស អន្តកិរិយាយ អ្នកចូរជាភិក្ខុចុះ ធម៌តថាគតពោលទុកល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ដូច្នេះ ។ អង្គុលីមាលនោះ បានចំពោះនូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ស្មើគ្នានឹងព្រះតម្រាស់នោះឯង ។ ក្នុងពេលក្លាមនោះ ភេទគ្រហស្ថរបស់លោកអន្តរធានទៅ សមណភេទប្រាកដហើយ ។

បរិក្ខារ ៨ ដូចដែលពោលទុកយ៉ាងនេះថា ត្រៃចីវរ បាត្រ

កាំបិត ម្ជុល វត្ថពន្ធចង្កេះ រួមជា ៨ នឹងសំពត់តម្រងទឹក

សមគួរដល់ភិក្ខុដែលប្រកបសេចក្តីព្យាយាមហើយ ដូច្នេះ

ជារបស់ចាំបាច់សម្រាប់ខ្លួន កើតឡើងហើយ ។

ពាក្យថា **ឯសោវ តស្ស អហុ ភិក្ខុភាវោ** សេចក្តីថា ភាពជាឯហិភិក្ខុនេះ បានជាភិក្ខុភាវៈដែលចូលដល់ព្រមដល់ព្រះអង្គុលិមាលនោះ ។ គឺថាការឧបសម្បទផ្សេងដទៃអំពីឯហិភិក្ខុមិនមាន ក៏មិនមែន ។

បទថា **បច្ឆាសមណេន** បានដល់ បច្ឆាសមណៈអ្នកកាន់ភណ្ឌៈ ។ សេចក្តីថា ព្រះមានព្រះភាគឲ្យព្រះអង្គុលិមាលកាន់បាត្រ និងចីវររបស់ខ្លួនហើយទ្រង់ធ្វើព្រះអង្គុលីមាលនោះឲ្យជាបច្ឆាសមណៈ ស្តេចទៅហើយ ឯ

ចំណែកមាតារបស់អង្គុលិមាលនោះ មិនដឹង ព្រោះនៅឆ្ងាយគ្នាប្រមាណ ៨ អសុកៈ ដើរស្រែកហៅថា អហិង្សកៈ កូនឈរនៅទីណា កូនអង្គុយនៅទីណា កូនទៅណា ហេតុដូចម្តេចមិននិយាយនឹងម៉ែ ដូច្នេះ កាលមិនឃើញ ទើបមកដល់ទីនេះឯង ។

**[២៨៧]** បទថា **បញ្ចមត្តេហិ អស្សសតេហិ** សេចក្តីថា បើចោរនឹងបរាជ័យ យើងនឹងជាប់តាមទៅចាប់ចោរនោះ បើយើងបរាជ័យ យើងនឹងប្រញាប់គេចចេញទៅ ដូច្នោះ ទើបចេញទៅដោយកម្លាំងសេះដ៏លឿន ។ បទថា **យេន អារាមោ** សេចក្តីថា មកកាន់ព្រះអារាមព្រោះហេតុអ្វី ។ បានឮថា ព្រះរាជានោះទ្រង់ខ្លាចចោរ មិនបានប្រាថ្នានឹងទៅ ទ្រង់ចេញទៅព្រោះក្រែងចំពោះពាក្យរិះគន់ ។ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ត្រិះរិះថា យើងនឹងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយអង្គុយ ព្រះសាស្តានឹងត្រាស់សួរថា ព្រះអង្គនាំពលចេញមកព្រោះហេតុអ្វី ដូច្នេះ ពេលនោះយើងនឹងទូលថា ក៏ព្រះមានព្រះភាគមិនបានសង្គ្រោះខ្ញុំព្រះអង្គ ដោយប្រយោជន៍ក្នុងសម្ប-រាយិកភពតែម្យ៉ាងប៉ុណ្ណោះ សូម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ក៏ទ្រង់សង្គ្រោះផង ព្រះមានព្រះភាគនឹងគិតថា បើយើងមានជ័យជំនះ ទ្រង់ក៏នឹងព្រងើយ

បើយើងបរាជ័យ ក៏នឹងត្រាស់ថា មហាបពិត្រ ប្រយោជន៍អ្វីស្ដេចមកប្រាវព្ធចោរមួយនាក់ តពីនោះ មនុស្សក៏នឹងយល់ដល់យើងយ៉ាងនេះថា ព្រះរាជាស្ដេចចេញចាប់ចោរ តែព្រះសម្មាសម្ពុទ្ធទ្រង់ហាមហើយ ដូច្នេះ សម្ដីងយើញថា នឹងផុតពីពាក្យរិះគន់ដោយប្រការដូច្នេះ ទើបស្ដេចទៅហើយ ។

សួរថា ព្រះរាជាត្រាស់ថា ក៏អង្គុលិមាលចោរនោះ មកពីណា ព្រោះហេតុអ្វី ។

ឆ្លើយថា ត្រាស់ដើម្បីទ្រង់ជ្រាបពីព្រះមានព្រះភាគថា ព្រះមានព្រះ-ភាគ ទ្រង់ពិចារណាមើលឧបនិស្ស័យរបស់អង្គុលិមាលចោរនោះហើយ ទ្រង់គប្បីនាំគេមកឲ្យបួស ។ បទថា **រញ្ញោ** សេចក្ដីថា ព្រះរាជាប៉ុណ្ណោះ ទ្រង់ខ្លាចតែមួយព្រះអង្គឯង ក៏មិនមែន ។ មហាជនសូម្បីដ៏សេសក៏ខ្លាច ចោលខែល និងអាវុធ គេចចេញពីទីប្រឈមមុខនោះឯង ចូលក្រុងបិទទ្វារ ឡើងកាន់ប៉ម ឈរក្រឡេកមើល និងពោលយ៉ាងនេះថា អង្គុលិមាលដឹងថា ព្រះរាជាស្ដេចមកកាន់សម្នាក់របស់យើង ដូច្នេះ ហើយមកអង្គុយចាំនៅព្រះជេតពនមុន ព្រះរាជាត្រូវអង្គុលិមាលចោរនោះចាប់ទៅហើយ តែពួកយើងគេចចេញផុតហើយ ។

**[២៨៩]** បទថា **នត្ថិ តេ ឥតោ ភយំ** សេចក្ដីថា ក៏ឥឡូវនេះ អង្គុលិមាលនេះ មិនសម្លាប់សូម្បីស្រមោចក្រហម ភ័យអំពីសម្នាក់របស់អង្គុលិមាលនេះ រមែងមិនមានដល់ព្រះអង្គ ។

សួរថា លោកពោលដោយបទថា **កថំ គោតោ** ដូច្នេះ ព្រោះហេតុអ្វី ។ ឆ្លើយថា លោកសម្គាល់ថា ការកាន់យកឈ្មោះដែលកើតឡើងព្រោះកម្មដែលគ្រោតគ្រាតហើយ ហៅបព្វជិតមិនសមគួរ យើងនឹងស្រែកហៅលោកដោយអំណាចនៃគោត្ររបស់បិតាមាតា ដូច្នេះ ទើបសួរ ។ បទថា **បរិក្ខារានំ** សេចក្ដីថា យើងនឹងធ្វើការខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់បរិក្ខារទាំងនោះ និងព្រះអង្គកំពុងពោលហើយនោះឯង ក៏ទ្រង់ដោះសំពត់សាដកដាក់ទុកក្នុងទីជិតជើងរបស់ព្រះថេរៈហើយ ។ ធុតង្គ ៤ ប្រការ មានការនៅក្នុងព្រៃជាវត្តជាដើម មកហើយក្នុងព្រះបាលី ។ តែព្រះថេរៈបានសមាទានធុតង្គទាំង ១៣ ប្រការតែម្ដង ព្រោះដូច្នោះ លោកទើបពោលថា **អលំ** កុំឡើយ ដូច្នេះ ។ សួរថា លោកសំដៅដល់អ្វីទើបពោលថា **យញ្ហិ មយំ ភន្តេ** ដូច្នេះ ។

ឆ្លើយថា លោកចាប់ដំរីជាដើមដែលព្រះរាជាបញ្ជូនមកហើយក្នុងទី

ដែលមកហើយថា យើងតាមចាប់បានសូម្បីដំរីដែលរត់ យ៉ាងនេះ ។

សូម្បីព្រះរាជាក៏ទ្រង់បញ្ជូនដំរីជាដើម ជាច្រើនទៅច្រើនដង យ៉ាងនេះថា ចូរយកដំរីទៅព័ទ្ធគេ ហើយចាប់មក ចូរយកសេះទៅព័ទ្ធ ចូរយករថទៅព័ទ្ធ ហើយចាប់មក ។ កាលអ្នកទាំងនោះទៅហើយយ៉ាងនេះ កាលអង្គុលីមាល ក្រោកឡើងបញ្ចេញសំឡេងថា វើយ! យើងជាអង្គុលិមាល សូម្បីតែម្នាក់ក៏មិនអាចលើកអាវុធបាន ។ នឹងប្រហារមនុស្សទាំងអស់នោះសម្លាប់ចេញហើយ ។ ដំរីក៏ជាដំរីព្រៃ សេះក៏ជាសេះព្រៃ រថក៏បាក់បែកខ្ចាត់ខ្ចាយត្រង់ទីនោះឯង ព្រះរាជាសំដៅយករឿងដូចពោលមកនេះ ទើបត្រាស់យ៉ាងនោះ ។

**[២៩០]** បទថា **បិណ្ឌាយ បាវិសិ** នេះ មិនមែនព្រះអង្គុលិមាលនេះចូលទៅលើកដំបូង ក៏ពាក្យនេះ លោកពោលសំដៅយកថ្ងៃដែលឃើញស្ត្រី ។ ឯព្រះអង្គុលិមាលនេះចូលទៅបិណ្ឌបាត សូម្បីរាល់ថ្ងៃ ដូចគ្នា ។ តែពួកមនុស្សឃើញលោកហើយ រមែងតក់ស្លុតខ្លះ រមែងរត់គេចទៅព្រៃទៅខ្លះ រមែងបិទទ្វារខ្លះ ។ ពួកខ្លះពេលបានឮថា អង្គុលិមាល ក៏រត់គេចចូលព្រៃខ្លះ ចូលផ្ទះបិទទ្វារខ្លះ ។ កាលមិនអាច ក៏ឈរបែរខ្នងដាក់ខ្លះ ។

ព្រះថេរៈមិនបានសូម្បីបាយយាគូត្រឹមតែមួយវែក សូម្បីភត្តត្រឹមតែមួយវែក រមែងលំបាកដោយបិណ្ឌបាត ។ កាលមិនបានក្នុងខាងក្រៅ ក៏ចូលទៅកាន់ព្រះនគរ ដោយគិតថា ក្រុងទូទៅដល់មនុស្សគ្រប់គ្នា ។ ពេលចូលទៅផ្លូវនោះ ក៏មានហេតុដែលជាសំឡេងស្រែកចេញមកជាពាន់ៗ មានសំឡេងថា អង្គុលិមាលមកហើយៗ ។ បទថា **ឯតទហោសិ** សេចក្តីថា បានមានហើយព្រោះការកើតឡើងនៃករុណា ។ កាលអង្គុលិមាលសម្លាប់មនុស្សដល់ពាន់នាក់ខ្វះមួយ (៩៩៩) ក៏មិនបាន មានសេចក្តីករុណាត្រឹមតែម្នាក់ សូម្បីក្នុងថ្ងៃមួយ ត្រឹមតែឃើញស្ត្រីមានគភ៌វង្វេងស្មារតីហើយ សេចក្តីករុណាកើតឡើងបានយ៉ាងណា កើតឡើងបានដោយកម្លាំងនៃបព្វជ្ជា ។ ពិតណាស់ សេចក្តីករុណានោះ ជាកម្លាំងនៃបព្វជ្ជា ។

**[២៩២]** បទថា **តេនហិ** សេចក្តីថា ព្រោះហេតុដែលលោកកើតសេចក្តីករុណានោះ ។ បទថា **អរិយាយ ជាតិយា** សេចក្តីថា ម្នាលអង្គុ-លិមាល អ្នកកុំកាន់យកហេតុនោះឡើយ នោះមិនមែនជាតិរបស់អ្នក នោះជាវេលាកាលនៅជាគ្រហស្ថ ធម្មតាគ្រហស្ថរមែងសម្លាប់សត្វ ។ ខ្លះរមែងធ្វើអទិន្នាទានជាដើមខ្លះ ។ តែឥឡូវនេះ ជាតិរបស់លោកឈ្មោះថា អរិយ-

ជាតិ ។ ព្រោះដូច្នោះ អ្នកកុំវង្វៀស នឹងនិយាយយ៉ាងនេះថា **យតោ អហំ ភគិនិ ជាតោ** ព្រោះហេតុនោះឯង ទើបទ្រង់បញ្ជូនទៅ ដោយព្រះតម្រាស់ថា អ្នកចូរពោលឲ្យផ្សេងទៅយ៉ាងនេះថា **អរិយាយ ជាតិយា** ដូច្នេះ ។

ពាក្យថា **តំ ឥត្ថី ឯតទវោច** សេចក្តីថា ធម្មតាការប្រសូតបុត្ររបស់ស្ត្រីទាំងឡាយ មនុស្សប្រុសមិនគួរនឹងចូលទៅ ព្រះថេរៈធ្វើអ្វី ទើបប្រាប់ថា ព្រះអង្គុលិមាលត្ថេរមកធ្វើសច្ចកិរិយាដើម្បីប្រសូតដោយសួស្តី ។ តពីនោះ ជនទាំងនោះទើបបិទបាំងវាំងនន តម្កល់តាំងទុកខាងក្រៅវាំងននសម្រាប់ព្រះថេរៈ ។ ព្រះថេរៈគង់លើតាំងនោះ ធ្វើសច្ចកិរិយាថា **យតោ អហំ ភគិនិ សព្វញ្ញុពុទ្ធស្ស អរិយាយ ជាតិយា ជាតោ** ម្នាលប្អូនស្រី ចាប់តាំងពីយើងកើតដោយអរិយជាតិនៃព្រះសព្វញ្ញុពុទ្ធ ។ ទារកក៏ប្រសូតិមក ដូចទឹកហូរអំពីធម្មក្រក ព្រមជាមួយនឹងពាក្យសត្យៈនោះឯង ។ ទាំងមាតាទាំងបុត្រ មានសេចក្តីសួស្តីហើយ ។ ក៏ឯព្រះបរិត្តនេះ លោកពោលទុកថា នេះឈ្មោះថា **មហាបរិត្ត** នឹងមិនមានអន្តរាយណាៗ មកទម្លាយបាន ។ ជនទាំងឡាយបានធ្វើតាំងតម្កល់ទុកត្រង់កន្លែងដែលព្រះថេរៈអង្គុយធ្វើសច្ចកិរិយា ។ ជនទាំងឡាយរមែងនាំស្ដ្រីសត្វតិរច្ឆានញីដែលមានគភ៌

ចាស់មកឲ្យដេកត្រង់តាំងនោះ ។ ក្នុងវេលានោះឯង ក៏ប្រសូតចេញបាន ដោយងាយ ។ សត្វណាទ្រូលនាំមកមិនបាន ក៏យកទឹកលាងតាំងនោះទៅ ស្រោចសីសៈ ក៏ប្រសូតចេញបានក្នុងខណៈនោះឯង ។ សូម្បីរោគយ៉ាង ដទៃក៏ស្ងប់ទៅ ។ បានឮថា ព្រះមហាបរិត្តនេះ មានបាដិហារិយ៍តាំងនៅ រហូតដល់អស់កប្ប ។ សួរថា ក៏ព្រះមានព្រះភាគ រមែងឲ្យព្រះថេរៈធ្វើ វេជ្ជកម្មឬ ។ ឆ្លើយថា ព្រះអង្គមិនបានឲ្យធ្វើ ។ ព្រោះពួកមនុស្សពេល ឃើញព្រះថេរៈក៏ខ្លាច ហើយគេចចេញទៅ ។ ព្រះថេរៈ រមែងលំបាកដោយ កិច្ចាហារ រមែងមិនអាចធ្វើសមណៈធម៌បាន ។ ទ្រង់ឲ្យធ្វើសច្ចកិរិយា ព្រោះ ដើម្បីសង្គ្រោះព្រះថេរៈនោះ ។ ដូចបានស្តាប់មកថា ព្រះមានព្រះភាគនោះ បានមានបរិវិតក្កយ៉ាងនេះថា ឥឡូវនេះព្រះអង្គុលិមាលត្ថេរ ត្រឡប់បានមេត្តា ចិត្ត ធ្វើសេចក្តីសួស្តីឲ្យដល់ពួកមនុស្សដោយសច្ចកិរិយា ដូច្នោះ ពួកមនុស្ស រមែងសម្គាល់ថា គួរចូលទៅរកព្រះថេរៈ តពីនោះ នឹងមិនលំបាកដោយ កិច្ចាហារ អាចធ្វើសមណធម៌បាន ទើបឲ្យធ្វើសច្ចកិរិយា ព្រោះទ្រង់អនុគ្រោះ ដោយប្រការដូច្នេះ ។ សច្ចកិរិយា មិនមែនជាវេជកម្ម ។

ម្យ៉ាងទៀត កាលព្រះថេរៈរៀនមូលកម្មដ្ឋានដោយតាំងចិត្តថា នឹងធ្វើ

សមណធម៌ ហើយទៅអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ចិត្តក៏នឹងមិនដំណើរឆ្ពោះទៅកាន់ព្រះកម្មដ្ឋាន ។ រមែងប្រាកដចំពោះតែកន្លែងដែលលោកឈរត្រង់ព្រៃ ហើយសម្លាប់ពួកមនុស្សប៉ុណ្ណោះ ។ អាការនៃពាក្យក្តី ភាពពិការនៃដៃ និងជើងក្តី របស់អ្នកដែលខ្លាចសេចក្តីស្លាប់ថា ខ្ញុំជាអ្នកក្រខ្សត់ ខ្ញុំនៅមានបុត្រតូចៗ សូមមេត្តាឲ្យជីវិតដល់ខ្ញុំ ចុះលោកដូច្នេះ រមែងមកកាន់គន្លងមនោទ្វារវជ្ជនៈ លោកនឹងមានសេចក្តីក្តៅក្រហាយត្រូវក្រោកចេញទៅអំពីទីនោះ ។ ទីនោះ ព្រះមានព្រះភាគឲ្យធ្វើសច្ចកិរិយាដោយអរិយជាតិ ដោយទ្រង់សម្លឹងឃើញថា ព្រះអង្គុលិមាលត្រូវធ្វើជាតិនោះ ឲ្យជាអព្វោហារិក (វាចាដ៏ក្រៃលែង) ជាមុន ហើយចម្រើនវិបស្សនាទើបនឹងសម្រេចព្រះអរហត្តបាន ។

**[២៩៣]** បទថា *ឯកោ វូបកដ្ឋោ* ជាដើម ពោលទុកពិស្តារហើយក្នុងវត្ថសូត្រ ។

**[២៩៤]** បទថា ***អញ្ញេនបិ លេឌ្ឌុខិត្តោ*** សេចក្តីថា ដុំដីជាដើមដែលមនុស្សបោះទៅដោយទិសាភាគណាៗ ក៏ដោយ ក្នុងទីនេះត្រឹមតែលោមព័ទ្ធទុកដោយជុំវិញ ចំពោះសត្វក្អែក សុនខ និងជ្រូកជាដើម ឲ្យត្រឡប់ទៅ

ក៏មកធ្លាក់ចុះត្រង់កាយរបស់ព្រះថេរៈដែរ ។ រស់នៅយ៉ាងនេះ ក្នុងទីមានប្រមាណប៉ុនណា អន្ទាក់ដែលដាក់ហើយ ពេលលោកត្រាច់បិណ្ឌបាតត្រឡប់ហើយ ក៏ជាប់អន្ទាក់ទាល់តែបាន ។

បទថា **ភិន្នេន សីសេន** សេចក្តីថា ទម្លាយស្បែករហូតដល់ឆ្អឹង ។

បទថា **ព្រាហ្មណ** លោកពោលសំដៅដល់ភាពជាព្រះខីណាស្រព ។

បទថា **យស្ស ខោត្តំ កម្មស្ស វិបាកេន** នេះ លោកពោលសំដៅយកទិដ្ឋធម្មវេទនីយកម្មដែលជាសភាគគ្នា ។ ពិតហើយ កម្មដែលលោកធ្វើទុំះឯង រមែងញ៉ាំងចំណែកទាំងបីឲ្យពេញ ក្នុងបណ្តាចិត្ត ៧ ដួង ចេតនាក្នុងជវនចិត្តដួងដំបូងជាកុសល ឬអកុសល ក៏រមែងឈ្មោះថា **ទិដ្ឋធម្មវេ-ទនីយកម្ម** ។ កម្មនោះ រមែងឲ្យវិបាកក្នុងអត្តភាពនេះប៉ុណ្ណោះ ។ កាលមិនអាច រមែងឈ្មោះថាជា **អហោសិកម្ម** ទៅ ដោយពួកបីនេះ គឺ **អហោ-សិកម្ម (នាហោសិ កម្មវិបាកោ)** កម្មវិបាកមិនបានមានហើយ **(ន ភវិស្សតិ កម្មវិបាកោ)** កម្មវិបាកនឹងមិនមាន **(នត្ថិ កម្មវិបាកោ)** មិនមានកម្មវិបាក ។ ជវនចេតនាដួងទី ៧ ដែលឲ្យសម្រេចប្រយោជន៍ ឈ្មោះថា **ឧបបជ្ជវេទ-នីយកម្ម** ។ កម្មនោះ រមែងឲ្យផលក្នុងអត្តភាពបន្ទាប់ទៅ ។ កាលមិនអាច

ដូច្នោះ កម្មនោះ ក៏ឈ្មោះថាជា **អហោសិកម្ម** ដោយន័យដែលពោលហើយនោះឯង ។ ជវនចេតនា ៥ ដួង ក្នុងចន្លោះកម្មទាំងពីរ រមែងឈ្មោះថា **អបរាបរិយវេទនីយកម្ម** ។ កម្មនោះ រមែងបានឱកាសកាលណា រមែងឲ្យផលកាលនោះក្នុងអនាគត ។ កាលមានការវិលវល់នៅក្នុងសង្សារ ឈ្មោះថា អហោសិកម្មរមែងមិនមាន ។ ក៏កម្មទាំង ២ នេះ របស់ព្រះថេរៈ គឺ ឧបបជ្ជវេទនីយកម្ម ១ អបរាបរិយវេទនីយកម្ម ១ ដែលព្រះអរហត្តមគ្គធ្វើកម្មឲ្យអស់ សម្រេចហើយ ។ នៅមានតែទិដ្ឋធម្មវេទនីយកម្ម ។ កម្មនោះសូម្បីលោកដល់ព្រះអរហត្តហើយ ក៏នៅឲ្យផលនោះឯង ។ ព្រះមានព្រះភាគទ្រង់សំដៅដល់កម្មនេះ ទើបត្រាស់ថា **យស្ស ខោ ត្វំ** ជាដើម ។ ព្រោះដូច្នោះ ក្នុងពាក្យថា **យស្ស ខោ** នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា **យាទិសស្ស ខោ ត្វំ ព្រាហ្មណ កម្មស្ស វិបាកេន** ម្នាលព្រាហ្មណ៍ ដោយផលនៃកម្មឯណាប្រាកដដូចអ្នក ។

**[២៩៥]** បទថា **អញ្ញា មុត្តោវ** នេះ ត្រឹមតែថា ជាកំពូលនៃទេសនា ។ ក្នុងទីនេះ លោកបំណាងយកថា ព្រះចន្ទចេញផុតពីគ្រឿងសៅហ្មងទាំងនេះ គឺ ពពក អ័ព្ទទឹកសន្សើម ធូលី រាហូ ។ ភិក្ខុជាអ្នកផុតហើយអំពីកិលេស

គឺ សេចក្ដីប្រមាទ ជាអ្នកមិនប្រមាទហើយ រមែងញ៉ាំងលោក គឺ ខន្ធ ធាតុ អាយតនៈ របស់ខ្លួននេះឲ្យភ្លឺស្វាង ធ្វើងងឹត គឺ កិលេសដែលខ្លួនកម្ចាត់ចេញហើយ ដូចជាព្រះច័ន្ទមិនមានគ្រឿងសៅហ្មង ដូចពោលមកនេះ រមែងញ៉ាំងលោកឲ្យភ្លឺស្វាង ដូច្នោះ ។ បទថា **កុសលេន បិថិយ្យតិ** សេចក្ដីថា រមែងបិទដោយកុសល គឺ មគ្គ បានដល់ ធ្វើមិនឲ្យមានបដិសន្ធិទៀត ។ បទថា **យុញ្ជតិ ពុទ្ធសាសនេ** សេចក្ដីថា ប្រកបហើយ ប្រកបទួទៅហើយដោយកាយ វាចា និងដោយចិត្ត នៅក្នុងព្រះពុទ្ធសាសនា ។ គាថាទាំង ៣ នេះ ហៅថា ឧទានគាថារបស់ព្រះថេរៈ ។ បានឮថា ព្រះថេរៈកាលនឹងធ្វើអាការការពារខ្លួន ទើបពោលពាក្យថា **ទិសា ហិ មេ** នេះ ។ ក្នុងបទទាំងនោះ បទថា **ទិសា ហិ មេ** សេចក្ដីថា ពួកជនដែលជាសត្រូវរបស់យើងរមែងតិះដៀលយើងយ៉ាងនេះ សូម្បីព្រះអង្គុលិមាល ចូរសោយទុក្ខដូចជាពួកយើងទាំងឡាយសោយទុក្ខ ព្រោះអំណាចពួកញាតិត្រូវអង្គុលិមាលសម្លាប់ហើយ ដូច្នោះ សំដៅសេចក្ដីថា ជនទាំងនោះចូរបានឮធម្មកថា គឺ សច្ចៈ ៤ របស់យើងគ្រប់ទិស ។ បទថា **យុញ្ជន្តុ** សេចក្ដីថា អ្នកប្រកបហើយប្រកបទួទៅហើយដោយកាយ វាចា និងចិត្ត ។ បទថា **យេ ធម្មមេវាទប-**

**យន្តិ សន្តោ** សេចក្តីថា បុគ្គលល្អ គឺ សប្បុរសពួកណា រមែងចាប់យកធម៌នោះឯង គឺ សមាទាន គឺ កាន់យក ជនទាំងនោះ (អ្នកកើតពីមនូ) ជាសត្រូវរបស់យើង ចូរសេពគប់ ចូរសេព សំដៅសេចក្តីថា ចូរមានរូបជាទីស្រឡាញ់ចុះ ។ បទថា **អវិរោធបសំសនំ** គឺ មេត្តា លោកហៅថា **អវិរោធ** (សេចក្តីមិនក្រោធ) សំដៅសេចក្តីថា សេចក្តីមេត្តា និងសេចក្តីសរសើរ ។ បទថា **សុនន្តុ ធម្មំ កាលេន** សេចក្តីថា ចូរស្តាប់ខន្តិធម៌ មេត្តាធម៌ បដិសន្ធារធម៌ និងសារាណីយធម៌គ្រប់ៗ ខណៈ ។ បទថា **តញ្ច អនុវិធីយន្តុ** សេចក្តីថា និងចូរធ្វើតាម គឺ បំពេញធម៌នោះឲ្យបរិបូណ៌ ។ បទថា **ន ហ ជាតុ សោ មមំ ហឹសេ** សេចក្តីថា បុគ្គលណាជាអ្នកប្រាថ្នាប្រទូស្តចំពោះយើង សូមបុគ្គលនោះ កុំគប្បីបៀតបៀនយើងដោយចំណែកមួយ ។ បទថា **អញ្ញំ វា បន កិញ្ចិ នំ** សេចក្តីថា ចូរកុំបៀតបៀន ចូរកុំធ្វើឲ្យលំបាកដល់យើងតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីបុគ្គលណាៗ ដទៃក៏កុំបៀតបៀន កុំធ្វើឲ្យលំបាក ។ បទថា **បប្បុយ្យ បរមំ សន្តឹ** បានដល់ ដល់ព្រះនិព្វាន ដែលមានសេចក្តីស្ងប់យ៉ាងក្រៃលែង ។ បទថា **រក្ខេយ្យ តសថាវរេ** សេចក្តីថា អ្នកនៅមានតណ្ហា លោកហៅថា អ្នកមានសេចក្តី

តក់ស្លុត អ្នកមិនមានតណ្ហា លោកហៅថា អ្នករីងមាំ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះ បុគ្គលណាដល់ព្រះនិព្វាន បុគ្គលនោះរមែងជាអ្នកដែលអាចដើម្បីរក្សាសេចក្តីតក់ស្លុត និងសេចក្តីរឹងមាំទាំងអស់បាន ព្រោះដូច្នោះ បុគ្គលដែលប្រាកដដូចជាយើង រមែងដល់ព្រះនិព្វាន ជនទាំងឡាយ រមែងបៀតបៀនយើងដោយចំណែកមួយមិនបានទេ ដូច្នេះ ។ លោកពោលគាថាទាំងបីនេះ ដើម្បីការពារខ្លួន ។

ឥឡូវនេះ កាលនឹងសម្តែងសេចក្តីបដិបត្តិរបស់ខ្លួន ទើបពោលពាក្យមានជាដើមថា **ឧទកញ្ហិ ន យន្តិ នេត្តិកា** ។ បទថា **នេត្តិកា** ក្នុងគាថានោះ សេចក្តីថា ជនពួកណា ស្តារប្រឡាយឲ្យស្អាតហើយទប់ (ទំនប់) ក្នុងទីដែលគួរទប់ ហើយបង្ហូរទឹកចូល ។

បទថា **ឧសុការា ទមយន្តិ** សេចក្តីថា (ជាងសរ) លាបដោយទឹកបាយ ពេលត្រង់រងើកភ្លើង ពត់ត្រង់កន្ទេងកោងធ្វើឲ្យត្រង់ ។ បទថា **តេជនំ** បានដល់ កូនសរ ។ ជាង រមែងពត់កូនសរនោះ និងឲ្យអ្នកដទៃពត់ ដូច្នោះ ទើបហៅថា **តេនជំ** ។ បទថា **អត្តានំ ទមយន្តិ** សេចក្តីថា បណ្ឌិតរមែងទូន្មានខ្លួន គឺ ធ្វើឲ្យត្រង់ គឺ ធ្វើឲ្យអស់អស្មិមានះ ដូចជាអ្នកបញ្ចូលទឹក

រមែងបង្ហូរទឹកទៅដោយផ្លូវត្រង់ ជាងសរក៏ធ្វើសរឲ្យត្រង់ និងជាងចាំងឈើក៏ចាំងឈើឲ្យត្រង់ ដូច្នោះ ។ បទថា **តាទិនា** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនញាប់ញ័រដោយអាការ ៥ ដែលមិនមានកំហុសជាប្រក្រតី ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម គឺ ព្រះសាស្តាទ្រង់ដល់លក្ខណៈនៃការមិនញាប់ញ័រយ៉ាងនេះ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា នឹងធឹងក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា ខ្ជាក់ចេញហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា លះបង់ហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា ឆ្លងបានហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះសម្តែងចេញនូវភាពរឹងមាំនោះ ។ បទថា **ភវនេត្តិ** បានដល់ ខ្សែនៃភព ។ ពាក្យនេះ ជាឈ្មោះនៃតណ្ហា ។ ពិតហើយ សត្វទាំងឡាយត្រូវតណ្ហានោះចងហទយៈទុក នាំទៅកាន់ភពនោះៗ ដូចគោដែលគេលាមទុកដោយខ្សែត្រង់ក ដូច្នោះ ព្រោះដូច្នោះ លោកទើបហៅថា **ភវ-នេត្តិ** (តណ្ហាដែលនាំសត្វទៅកាន់ភព) ។ បទថា **ផុដ្ឋោ កម្មវិបាកេន** សេចក្តីថា បុគ្គលដែលមគ្គចេតនាពាល់ត្រូវហើយ ។ ក៏ព្រោះកម្មដែលមគ្គចេតនាដុត គឺ ដុតផេះ ឲ្យដល់ការអស់ទៅ ដូច្នោះ មគ្គចេតនានោះ លោកទើប

ហៅថា **កម្មវិបាក** ។ ក៏ព្រះអង្គុលិមាលនេះ ដែលកម្មវិបាកនោះពាល់ត្រូវហើយ ។ បទថា **អនណោ** បានដល់ ជាអ្នកមិនមានកិលេស រមែងមិនប្រព្រឹត្តទៅដើម្បីទុក្ខវេទនា ។

ម្យ៉ាងទៀត ក្នុងពាក្យថា **អនណោ ភុញ្ជាមិ** (យើងជាអ្នកមិនជំពាក់បំណុលក្នុងការបរិភោគ) នេះ គប្បីជ្រាបការបរិភោគ ៤ យ៉ាង គឺ ថេយ្យ-បរិភោគ ១ ឥណបរិភោគ ១ ទាយជ្ជបរិភោគ ១ សាមិបរិភោគ ១ ។

ក្នុងបណ្តាបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អ្នកទ្រុស្តសីល ឈ្មោះថា **ថេយ្យបរិភោគ** ។ ក៏អ្នកទ្រុស្តសីលនោះ លួចបច្ច័យ ៤ បរិភោគ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគដុំបាយរបស់អ្នកស្រុកដោយភាពជាចោរ ដូច្នេះ ។ ចំណែកការមិនពិចារណា ហើយបរិភោគរបស់អ្នកមានសីល ឈ្មោះថា **ឥណប-រិភោគ** (បរិភោគដោយការជំពាក់បំណុល) , ការបរិភោគរបស់ព្រះសេក្ខៈ ៧ ពួកឈ្មោះថា **ទាយជ្ជបរិភោគ** (បរិភោគដោយជាទាយាទ) ។ ការបរិ-ភោគរបស់ព្រះខីណាស្រព ឈ្មោះថា **សាមិបរិភោគ** (បរិភោគដោយភាពជាម្ចាស់របស់) ។ បទថា **មិនមានបំណុល** ក្នុងទីនេះ លោកពោលសំដៅ

យកការមិនមានបំណុល គឺ កិលេស ។ បាឋៈថា **អនិណោ** ដូច្នេះ ក៏មាន ។ បទថា **ភុញ្ជាមិ ភោជនំ** (យើងនឹងឆាន់ភោជន) លោកពោលសំដៅយកសាមិបរិភោគ ។ បទថា **កាមរតិសន្ថវំ** សេចក្តីថា អ្នកទាំងឡាយកុំប្រកបរឿយៗ គឺ កុំធ្វើសេចក្តីសរសើរដោយសេចក្តីត្រេកអរ ព្រោះតណ្ហាក្នុងកាមទាំងពីរ ។ បទថា **នយិទំ ទុម្មន្តិតំ មម** សេចក្តីថា ការដែលយើងឃើញព្រះសម្មាសម្ពុទ្ធហើយ គិតថា យើងនឹងបួស យ៉ាងណា ការគិតរបស់យើងនោះ មិនមែនជាការគិតអាក្រក់ឡើយ ។ បទថា **សុវិភត្តេសុ ធម្មេសុ** សេចក្តីថា ក្នុងធម៌ ដែលតថាគតកើតឡើងក្នុងលោកយ៉ាងនេះថា តថាគតជាសាស្តាចែកល្អហើយ ព្រះនិព្វានជាធម៌ប្រសើរបំផុត យ៉ាងណា យើងចូលដល់ហើយ ចូលដល់ព្រមហើយនូវព្រះនិព្វាននោះនោះឯង ព្រោះដូច្នោះការមកដល់របស់យើងនេះ ជាការមកល្អហើយ មិនប្រាសចាកប្រយោជន៍ ។ បទថា **តិស្សោ វិជ្ជា** បានដល់ បុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយបញ្ញា ។ បទថា **កតំពុទ្ធស្ស សាសនំ** សេចក្តីថា កិច្ចដែលគួរធ្វើក្នុងសាសនារបស់ព្រះពុទ្ធយ៉ាងណានៅមាន កិច្ចយ៉ាងទាំងអស់នោះ ខ្ញុំធ្វើហើយ ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យដល់ទីបំផុត ដោយវិជ្ជាបី

*និងលោកុត្តរធម៌ ៩ ដោយប្រការដូច្នេះ ។*

“ ចប់អដ្ឋកថា អង្គុលិមាលសូត្រទី ៦ ”

# អ ដ្ឋ ក ថា

## បិយជាតិកសូត្រទី ៧

**[២៩៦]** *បិយជាតិកសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*ក្នុងបទទាំងនោះ បទថា* ***នេវ កម្មន្តា បដិភន្តិ*** *សេចក្ដីថា ការងាររមែងមិនប្រាកដដោយប្រការទាំងពួង គឺ រមែងមិនប្រាកដដោយ ការកំណត់តាមប្រក្រតី ។*

*សូម្បីក្នុងបទទីពីរ ក៏ន័យនេះឯង ។ ក៏បទថា* ***ន បដិភន្តិ*** *ក្នុងព្រះសូត្រនេះ ប្រែថា មិនត្រូវចិត្ត ។ បទថា* ***អាហាឡនំ*** *ប្រែថា ព្រៃជាទីចោលសាកសព ។*

**[២៩៧]** *បទថា* ***អញ្ញថត្តំ*** *បានដល់ សភាពជាប្រការដទៃ ព្រោះមានវណ្ណៈប្លែកទៅ ។ ធម៌ដែលនឹងគប្បីដឹងច្បាស់ដោយចិត្ត ឈ្មោះថា ឥន្ទ្រិយ ។ តែពាក្យនេះ លោកពោលសំដៅដល់ឱកាសដែលឥន្ទ្រិយតាំងមាំហើយ ។*

**[២៩៨]** *បទថា* ***បិយជាតិកា*** *សេចក្ដីថា រមែងកើតពីការស្រឡាញ់ ។*

បទថា **បិយប្បភូតិកា** សេចក្តីថា មានមកពីរបស់ជាទីស្រឡាញ់ ។ បទថា **សាធុ តំ មហារាជ** សេចក្តីថា សូម្បីកំណត់សេចក្តី សំដៅដល់ព្រះតម្រាស់នោះ ទើបពោលយ៉ាងនោះ ដោយសទ្ធាក្នុងព្រះសាស្តា ។

បទថា **ចរ បិរេ** សេចក្តីថា អ្នកចូរចៀសចេញទៅផ្លូវដទៃសិន សំដៅសេចក្តីថា អ្នកកុំឈរទីនេះ ។ ម្យ៉ាងទៀត បទថា **ចរ បិរេ** គឺ អ្នកចូរទៅផ្លូវដទៃ អធិប្បាយថា កុំឈរក្នុងទីនេះខ្វះ ។

[៣០៣] បទថា **ទ្វិធា ឆេត្វា** សេចក្តីថា កាត់ធ្វើឲ្យជា ២ ចំណែកដោយដាវ ។ បទថា **អត្តានំ ឧប្បាលេសិ** សេចក្តីថា យកដាវទ្ទុះឯង វះពោះរបស់ខ្លួន ។ បើស្ត្រីនោះ មិនជាទីស្រឡាញ់របស់បុរសនោះ ឥឡូវនេះបុរសនោះ មិនគប្បីសម្លាប់ខ្លួន ដោយគិតថា យើងនឹងរកស្ត្រីដទៃ ។ តែព្រោះស្ត្រីនោះ ជាទីស្រឡាញ់របស់បុរសនោះ ដូច្នោះ បុរសនោះប្រាថ្នាការព្រមព្រៀងនឹងស្ត្រីនោះសូម្បីក្នុងបរលោក ទើបបានធ្វើយ៉ាងនោះ ។

[៣០៤] ពាក្យថា ព្រះកុមារីព្រះនាមថា **វជិរី** ជាទីប្រោសប្រាណរបស់ព្រះអង្គឬ សេចក្តីថា បានឮថា ព្រះនាងនោះមានព្រះតម្រិះយ៉ាងនេះព្រះនាងពោលយ៉ាងនោះ ព្រោះគិតថា បើយើងនឹងគប្បីពោលពាក្យជាដើម

ថា បពិត្រមហារាជ រឿងធ្លាប់មានមកហើយ ក្នុងព្រះនគរសាវត្ថីនេះ នៅមានស្ត្រីដទៃទៀត ព្រះអង្គគប្បីបដិសេធនឹងយើងថា អ្នកណាបានធ្វើយ៉ាងនោះដល់នាង ចូរថយទៅ សេចក្តីនោះ រមែងមិនមាន យើងនឹងញុំាងស្ត្រីនោះ ឲ្យយល់ដោយអាការដែលប្រព្រឹត្តទៅនោះឯង ។ ក្នុងបទថា **វិបរិណាមញ្ញថាភាវា** នេះ បណ្ឌិតគប្បីជ្រាបសេចក្តីប្រែប្រួល ព្រោះសេចក្តីស្លាប់ គឺ ដោយប្រការដទៃ ហើយគេចចេញទៅជាមួយអ្នកណាៗ ។

បទថា **វាសភាយ** សេចក្តីថា ព្រះទេវីរបស់ព្រះរាជាមួយអង្គ ព្រះនាមថា វាសភា លោកពោលសំដៅដល់ព្រះនាងនោះ ។

បទថា **បិយា តេ អហំ** លោកពោលក្នុងខាងក្រោយទាំងអស់ ព្រោះហេតុអ្វី ។

បានឮថា សេចក្តីត្រិះរិះយ៉ាងនេះ បានមានហើយដល់ព្រះនាងនោះ ទើបទូលសួរក្នុងខាងក្រោយទាំងអស់ ដើម្បីឲ្យជាទីតាំងនៃពាក្យថា ព្រះរាជានេះ ទ្រង់ក្រោធនឹងយើង បើយើងនឹងគប្បីសួរមុនអ្នកដទៃទាំងអស់ថា ខ្ញុំម្ចាស់ជាទីស្រឡាញ់របស់ព្រះអង្គឬ ព្រះអង្គក៏នឹងគប្បីត្រាស់ថា នាងមិនបានជាទីស្រឡាញ់របស់យើង ចូរចៀសចេញទៅ បើដូច្នេះ ពាក្យក៏នឹងមិន

បានតាំងឡើង ។ បណ្ឌិតគប្បីជ្រាបសេចក្តីប្រែប្រួលដោយភាពជាអ្នកត្រូវបោលទុកក្នុងដែនកាសីកោសល សភាពដោយប្រការដទៃ នៅក្នុងកណ្តាប់ដៃព្រះរាជា អ្នកជាបដិបក្ខទាំងឡាយ (រាជសត្រូវ) ។

បទថា **អាចមេហិ** សេចក្តីថា អ្នកឯងចូរយកទឹកខ្ពុរមាត់មក ។ ព្រះបាទបសេនទិកោសលទ្រង់ខ្ពុរហើយ ទ្រង់លាងព្រះហស្ត និងព្រះបាទហើយ ទ្រង់បិទព្រះឱស្ឋ បំណងនឹងនមស្ការព្រះសាស្តា ទើបត្រាស់យ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងងាយស្រួលយល់ទាំងនោះឯង ។

“ ចប់អដ្ឋកថា បិយជាតិកសូត្រទី ៧ ”

# អ ដ្ឋ ក ថា

## ពាហិតិយសូត្រទី ៨

**[៣១០]** *ពាហិតិយសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់ចាំមក ហើយយ៉ាងនេះ ៖*

**[៣១១]** *ក្នុងព្រះសូត្រនោះ បទថា* ***ឯកបុណ្ឌរិកនាគំ*** *បានដល់ ដំរីដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា លើត្រោងត្អឹងរបស់ស្ដេចដំរីនោះ មានពណ៌សប្រមាណប៉ុនផ្លែត្នោត ព្រោះដូច្នោះ គេទើបតាំងឈ្មោះស្ដេចដំរីនោះថា ឯកបុណ្ឌរិកៈ ។ បទថា* ***សិរិវឌ្ឍំ មហាមត្តំ*** *បានដល់ មហាមាត្រមានឈ្មោះយ៉ាងនោះ ដែលឡើងជិះដំរីមួយផ្សេងទៀតទៅជាមួយ ដើម្បីសន្ទនាតាមសេចក្ដីសប្បាយ ។ បទថា* ***នោ*** *ក្នុងពាក្យថា* ***អាយស្មា នោ*** *នេះ ជានិបាតប្រើក្នុងការសួរ ។ មហាមាត្រកំណត់អាការដែលព្រះថេរៈទ្រទ្រង់សង្ឃាដិ និងបាត្រ ទើបក្រាបទូលថា បពិត្រមហារាជ ។*

**[៣១៣]** *បទថា* ***ឧបារម្ភោ*** *សេចក្ដីថា គួរតិះដៀល គឺ គួរដល់ការលើកទោស ។ ព្រះរាជាត្រាស់សួរថា យើងនឹងសួរយ៉ាងណា ។ ព្រះរាជា*

ត្រាស់សួរថា ព្រះសូត្រនេះកើតឡើងក្នុងរឿងដែលល្អ ព្រោះនឹងសួររឿងនោះ ។

[៣១៤] បទថា **យំ ហិ មយំ ភន្តេ** សេចក្តីថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងទាំងឡាយមិនអាចកាន់យកបទថា ដែលសមណព្រាហ្មណ៍អ្នកដឹងច្បាស់ នេះណា ឲ្យបរិបូរណ៌ដោយបញ្ហាបាន ហេតុយ៉ាងនោះ ព្រះអានន្ទជាអ្នកពោលយ៉ាងនេះ ឲ្យបរិបូណ៌ហើយ ។ បទថា **អកុសលោ** បានដល់ ដែលកើតពីសេចក្តីមិនឆ្លាត ។

បទថា **សាវជ្ជោ** សេចក្តីថា ប្រព្រឹត្តទៅជាមួយនឹងទោស ។ បទថា **សព្យាបជ្ឈោ** សេចក្តីថា ប្រព្រឹត្តទៅជាមួយនឹងទុក្ខ ។ ក្នុងបទថា **ទុក្ខ-វិបាកោ** នេះ លោកពោលដល់វិបាកដែលហូរចេញ ។ បទថា **តស្ស** សេចក្តីថា ដល់កាយសមាចារដែលប្រព្រឹត្តទៅហើយដើម្បីប្រយោជន៍ដល់ការបៀតបៀនខ្លួនឯងជាដើម ដូចដែលពោលហើយនោះ ។ ក្នុងពាក្យថា មហាបពិត្រ ព្រះតថាគតលះអកុសលធម៌បានទាំងអស់ ដោយកុសលធម៌នេះ គឺ ទ្រង់សរសើរការលះអកុសលធម៌ទាំងអស់គ្រប់យ៉ាងនោះឯង កាលលោកពោលថា សូមថ្វាយព្រះពរ រមែងសរសើរ ពាក្យសួររមែងមានដោយប្រការណា ជាការពោលអត្ថដោយប្រការនោះ ម្យ៉ាងទៀត ព្យាករណ៍យ៉ាង

នេះ មិនគប្បីជាការៈ ព្រោះសូម្បីអ្នកដែលនៅលះអកុសលមិនទាន់បាន ក៏គប្បីសរសើរការលះម្យ៉ាងទៀត ដើម្បីសម្តែងថា ព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងណា ក៏មានប្រក្រតីពោលយ៉ាងនោះ ព្រោះទ្រង់លះអកុសលបានហើយ ទើបព្យាករណ៍យ៉ាងនោះ ។ សូម្បីក្នុងចំណែកស ក៏មានន័យនេះដូចគ្នា ។ បទថា **ពាហិតិយា** នេះ ជាឈ្មោះរបស់សំពត់ដែលកើតឡើងក្នុងពាហិតិរដ្ឋ ។ ពាក្យថា **ដោយប្រវែង ១៦ ហត្ថ** សេចក្តីថា គឺ វែងមានប្រមាណ ១៦ ហត្ថគត់ ។ បទថា **ដោយទទឹង ៨ ហត្ថ** សេចក្តីថា គឺដោយទទឹង ៨ ហត្ថគត់ ពាក្យថា **បានទូលថ្វាយ** (សំពត់ពាហិតិកា) ដល់ព្រះមានព្រះភាគ សេចក្តីថា បានថ្វាយចំពោះព្រះមានព្រះភាគ ។

ក៏ឯគ្រាថ្វាយហើយ បានចងធ្វើជាពិតានក្នុងព្រះគន្ធកុដិ ។ តាំងពីនោះ ព្រះគន្ធកុដិក៏ស្រស់ល្អដ៏ក្រៃលែងហួសប្រមាណ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ទាំងនោះឯង ។ ម្យ៉ាងទៀត ទេសនានេះបញ្ចប់ហើយដោយអំណាចនៃនេយ្យបុគ្គលនោះឯង ។

“ ចប់អដ្ឋកថា ពាហិតិយសូត្រទី ៨ ”

# អ ដ្ឋ ក ថា

## ធម្មចេតិយសូត្រទី ៩

[៣២០] *ធម្មចេតិយសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*ក្នុងព្រះសូត្រនោះ ពាក្យថា* **មេទលុំ** *ជាឈ្មោះរបស់និគមនោះ ។ ក៏បានឮថា និគមនោះ មានផ្ទាំងថ្មមានពណ៌ដូចខ្លាញ់ខាប់ កើតឡើងដ៏ក្រាស់ក្នុងទីនោះៗ ព្រោះដូច្នោះ ទើបដល់ការរាប់ថា* **មេទលុបៈ** *ម្យ៉ាងទៀតសេនាសនៈនិគមនោះ ក៏មិនពិតប្រាកដ ដូច្នោះ ទើបមិនបានពោលទុក ។ បទថា* **នគរកំ** *បានដល់ និគមមួយរបស់ស្ដេចសក្យៈមានឈ្មោះយ៉ាងនោះ ។*

*ពាក្យថា ដោយព្រះរាជករណីយ៍យ៉ាងណាមួយ គឺ មិនមែនដោយករណីយ៍យ៉ាងដទៃ តែព្រះបាទបសេនទិកោសលនេះ ត្រាស់បង្គាប់ថា ពួកអ្នកចូរចាប់ពន្ធុលសេនាបតី ព្រមដោយបុត្រ ៣២ នាក់ ឲ្យបាន ក្នុងពេលតែមួយថ្ងៃ ។ ក៏ក្នុងថ្ងៃនោះ នាងមល្លិកាភរិយារបស់ពន្ធុលសេនាបតីនោះទូលនិមន្តព្រះមានព្រះភាគព្រមដោយភិក្ខុ ៥០០ រូប ។ ពេលភិក្ខុសង្ឃ មាន*

ព្រះពុទ្ធជាប្រធាន ស្តេចទៅដល់ផ្ទះ ទ្រង់ប្រថាប់គង់ហើយ អ្នកនាំដំណឹងប្រាប់ថា លោកសេនាបតីដល់អសញ្ញកម្មហើយ មកឲ្យនាងមល្លិកា ។ នាងទទួលសំបុត្រ សួរថា ជាដំណឹងល្អ (ឬអាក្រក់) ។ ក៏ឆ្លើយប្រាប់ថា ព្រះរាជាទ្រង់ឲ្យចាប់សេនាបតីព្រមទាំងបុត្រ ៣២ នាក់ ប្រហារជីវិតព្រមគ្នា ម៉ែម្ចាស់ ។ នាងពោលថា ពួកអ្នកកុំបានធ្វើឲ្យឮសុះសាយដល់មហាជនឡើយ ហើយយកសំបុត្រដាក់ទុកក្នុងថ្នក់សំពត់ អង្គាសព្រះភិក្ខុសង្ឃ ។ ក្នុងពេលនោះ មេចុងភៅលើកថ្នាំងសប្បិមួយថ្នាំង ដើរទៅទង្គិះនឹងទ្វារបែក ទើបប្រាប់ឲ្យគេទៅនាំថ្នាំងដទៃមកអង្គាសព្រះភិក្ខុសង្ឃ ។ ព្រះសាស្តាទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ទើបត្រាស់ថា នាងមិនគួរគិតព្រោះហេតុថ្នាំងសប្បិបែក ដើម្បីជាហេតុឲ្យតាំងកថាឡើង ។ ខណៈនោះនាងមល្លិកា ទើបនាំសំបុត្រចេញមក ដាក់ត្រង់ព្រះភក្ត្រព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នេះជាដំណឹងការស្លាប់របស់សេនាបតីនឹងបុត្រទាំង ៣២ នាក់ នាងខ្ញុំមិនបានគិតសូម្បីរឿងនេះ ហេតុអ្វីនឹងគិតព្រោះហេតុថ្នាំងសប្បិ (បែក) ។ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ឲ្យបដិសំយុត្តដោយសាមញ្ញលក្ខណៈ មានការមិនទៀងជាដើមថា ម្នាលនាងមល្លិកា កុំគិតឡើយ

ធម្មតាក្នុងសង្សារវដ្ដៈ មានទីបំផុតហើយខាងដើម និងទីបំផុតខាងចុង ដែលនរណាៗ ទៅតាមដឹងមិនបាន រមែងប្រព្រឹត្តទៅដូច្នោះ ហើយស្ដេចត្រឡប់ ។ នាងមល្លិកាហៅកូនប្រសារ ៣២ នាក់ មកឲ្យឱវាទ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យនាងមល្លិកាចូលគាល់ ត្រាស់សួរថា ក្នុងរវាងសេនាបតី និងយើង ទោសដែលបែកគ្នាមានឬ មិនមាន ។ នាងទូលថា មិនមាន ។ ព្រះរាជាទ្រង់ជ្រាបថា សេនាបតីនោះមិនមានកំហុស តាមពាក្យរបស់នាង ទើបមានសេចក្ដីក្ដៅក្រហាយ កើតការខូចព្រះទ័យយ៉ាងខ្លាំង ។ ព្រះអង្គទ្រង់រំពឹងថា បាននាំសម្លាញ់អ្នកលើកតម្កើងយើងថា ធ្វើវត្ថុដែលរកទោសមិនបានបែបនេះមកឲ្យវិនាសហើយ តាំងពីនោះទៅ ក៏មិនបានការសប្បាយព្រះទ័យ សូម្បីក្នុងប្រាសាទ ឬក្នុងពួកស្រីស្នំ ឬសេចក្ដីសុខក្នុងរាជសម្បត្តិ ទ្រង់ក៏ត្រាច់ទៅក្នុងទីនោះៗ ។ កិច្ចយ៉ាងនេះឯងបានមានហើយ ។ សំដៅដល់រឿងនេះ ទើបពោលទុកថា ដោយរាជករណីយកិច្ចយ៉ាងណាមួយ ដូច្នេះ ។ បទថា **ទីឃំ ការាយនំ** សេចក្ដីថា ទីឃការាយនៈ ដែលជាក្មួយរបស់ពន្ធុលៈសេនាបតី គិតថា ព្រះរាជាទ្រង់សម្លាប់អ៊ំរបស់យើង ដែលមិនបានធ្វើខុស ដោយមិនមានហេតុ ព្រះរាជាទ្រង់បានតាំងទុកក្នុងតំណែងសេនាបតីហើយ ។ ពាក្យនោះ

លោកពោលសំដៅដល់រឿងនេះ ។

**[៣២១]** ពាក្យថា **មហច្ចរាជានុភាវេន** សេចក្តីថា ដោយរាជានុភាព ដ៏ធំ សំដៅសេចក្តីថា ដោយពួកពលច្រើនសន្ធឹកសន្ធាប់ល្អដោយភេទដ៏វិចិត្រ ដូចវាយប្រហារផែនដីឲ្យវិនាស ដូចញុំាងសាគរឲ្យរញ្ជួយ ដូច្នោះ ។ បទថា **បាសាទិកានិ** សេចក្តីថា ដែលឲ្យកើតសេចក្តីជ្រះថ្លា ព្រមទាំងគួរទស្សនា តែម្យ៉ាង ។ បទថា **បាសាទនីយានិ** ជាវេវចនៈរបស់ពាក្យនោះ ។ ន័យ មួយទៀត បទថា **បាសាទិកានិ** សេចក្តីថា គួរមើល (គួរទស្សនា) ។ បទថា **បាសាទនីយានិ** បានដល់ ឲ្យកើតសេចក្តីជ្រះថ្លា ។ បទថា **អប្បសទ្ទានិ** គឺ មិនមានសំឡេង ។ បទថា **អប្បនិគ្ឃោសានិ** សេចក្តីថា វៀរចាកសំឡេង គឹកកង ព្រោះអត្ថថា មិនប្រាកដ ។ បទថា **វិជនវាតានិ** សេចក្តីថា ប្រាស ចាកក្លិនរបស់ខ្លួន ។ បទថា **មនុស្សរាហស្សេយ្យកានិ** សេចក្តីថា សមគួរ ដល់ការងារដែលនឹងគប្បីធ្វើក្នុងទីកំបាំងរបស់មនុស្ស អត្ថថា សមគួរដល់ អ្នកដែលប្រឹក្សាយ៉ាងលាក់កំបាំង ។

បទថា **បដិសល្លានសារុប្បានិ** សេចក្តីថា សមគួរដល់ភាពជាបុគ្គល តែម្នាក់ពួនសម្ងំនៅ ។ បទថា **យត្ថ សុទំ មយំ** សេចក្តីថា ព្រះមានព្រះភាគ

ស្តេចមិនធ្លាប់បានទៅក្នុងទីនោះ ក្នុងពាក្យនេះមានអត្ថដូច្នេះ ព្រះមានព្រះ-ភាគ ស្តេចគួរចូលទៅក្នុងទីនោះ ព្រោះជាទីដែលពួកយើងទាំងឡាយ មានសេចក្តីសុខ ។

បទថា **អត្ថិ មហារាជា** សេចក្តីថា សេនាបតីជាអ្នកឆ្លាត រមែងជ្រាបថា ព្រះរាជាទ្រង់រាប់អានព្រះមានព្រះភាគ ។ សេនាបតីនោះនឹងបញ្ជូនចារបុរសទៅ ដរាបដឹងទីប្រថាប់របស់ព្រះមានព្រះភាគហើយ ដោយគិតថា បើព្រះរាជាសួរយើងថា ព្រះមានព្រះភាគទ្រង់ប្រថាប់ទីណា ក៏គួរនឹងក្រាបទូលបានដោយមិនបង្អែបង្អង់ ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។

**[៣២២]** បទថា **អារាមំ បាវិសិ** សេចក្តីថា ទ្រង់តាំងបន្ទាយទុកក្រៅនិគមហើយ ស្តេចចូលទៅជាមួយនឹងការាយនៈសេនាបតី ។ លោកពោលថា **វិហារោ** សំដៅយកព្រះគន្ធកុដិ ។ បទថា **អាឡិន្ទំ** គឺ ខាងមុខ ។ បទថា **ឧក្កាសិត្វា** គឺ ធ្វើសំឡេងគ្រហែម ។ បទថា **អគ្គឡំ** គឺ សន្ទះទ្វារ ។ បទថា **អាកោដេ្តហិ** លោកអធិប្បាយទុកថា ទ្រង់គោះជិតប្រហោងសោរតិចៗ ដោយចុងព្រះនខា ។ បានឮថា ពួកអមនុស្ស រមែងគោះទ្វារផ្នែកខាងលើ ទីឃជាតិក៏គោះផ្នែកខាងក្រោម ទើបមិនគោះយ៉ាងនោះ គឺ គោះ

ជិតប្រហោងត្រង់កណ្តាល នេះជាមារយាទក្នុងការគោះទ្វារ ទើបបុរាណាចារ្យ សម្តែងទុកដោយប្រការដូច្នេះ ។ បទថា **តត្ថេវ** គឺ ក្នុងទីដែលភិក្ខុទាំងឡាយពោលហើយនុ៎ះឯង ។ ពាក្យថា **ខគ្គញ្ច ឧណ្ហីសញ្ច** នោះ ជាត្រឹមតែទេសនា ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់ប្រគល់រាជកកុធភ័ណ្ឌទាំង ៥ ដែលមកហើយ គឺ ផ្លិតវាលវីជនី ឧណ្ហិស្ស ព្រះខ័ន ឆត្រ និងស្បែកព្រះបាទ ព្រះរាជាស្តេចចុះចាកអំពីយានចតទុក ។

សួរថា ក៏ព្រះរាជាទ្រង់ប្រគល់បញ្ចរាជកកុធភ័ណ្ឌ ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះស្តេចមិនគួរចូលទៅកាន់សម្នាក់ព្រះសម្មាសម្ពុទ្ធ ដែលជាទីគោរពក្រៃលែងដោយភេទនៃឥស្សរិយយស ទ្រង់គិតថា នឹងចូលទៅគាល់តែមួយព្រះអង្គ នឹងបានសន្ទនាតាមពេញព្រះទ័យរបស់ព្រះអង្គ ។ ក៏ក្នុងបណ្តារាជកកុធភ័ណ្ឌទាំង ៥ ព្រះអង្គឲ្យត្រឡប់ហើយ តែមិនបានពោលថា លោកចូរត្រឡប់ ។ ហើយត្រឡប់ទៅដោយខ្លួនឯងទាំងអស់តែម្តង ។ ព្រះរាជាទ្រង់ប្រគល់ទៅដោយហេតុ ២ ប្រការ ដូចពោលមកនេះ ។ បទថា **រហាយតិ** សេចក្តីថា រមែងធ្វើទីកំបាំង គឺ ពួនសម្ងំ ។ បានឮថា សេនាបតីនោះ មានបំណងដូច្នេះថា ព្រះរាជានេះ សូម្បីកាលមុនក៏ប្រឹក្សាចតុកណ្ណមន្ត

នឹងព្រះសមណគោតម ហើយឲ្យចាប់អំរបស់យើងព្រមទាំងបុត្រ ៣២ នាក់ សូម្បីគ្រានេះ ក៏គង់ប្រឹក្សាចតុកណ្ណមន្ត្រ បន្ទាប់ឲ្យចាប់យើងទៀតទេដឹងហ្ន៎ សេនាបតីនោះ មានការគិតដូច្នេះ ព្រោះអំណាចនៃសេចក្តីក្រោធ ។

បទថា **វិវរិ ភគវា ទ្វារំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់មិនបាន ក្រោកឡើងបើកទ្វារ ។ តែទ្រង់លាព្រះហស្តត្រាស់ថា ចូរបើកចុះ ។ តអំពីនោះ ទ្វារក៏បើកឯងតែម្តង ពោលថា បពិត្រព្រះមានព្រះភាគ ព្រះអង្គកាល ឲ្យទាននៅក្នុងកោដិនៃកប្បមិនមែនតិច មិនធ្លាប់ធ្វើកម្ម គឺ ការបិទទ្វារដោយព្រះហស្តរបស់ព្រះអង្គ ។ ក៏ទ្វារនោះ ត្រូវបើកចេញ ដោយព្រះទ័យរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបគួរពោលបានថា ព្រះមានព្រះភាគបើកទ្វារហើយ ។ បទថា **វិហារំ បវិសិត្វា** សេចក្តីថា ចូលទៅកាន់ព្រះគន្ធកុដិហើយ ។ កាលព្រះរាជាស្តេចចូលទៅហើយ ការាយនៈសេនាបតី ក៏កាន់យកបញ្ចរាជកកុធភ័ណ្ឌត្រឡប់មកកាន់បន្ទាយ ហៅវិឌូឌភៈមកថា សម្លាញ់ ចូរលើកស្វេត្រឆត្រឡើង ។ វិឌូឌភៈសួរថា ព្រះជនករបស់ខ្ញុំទៅហើយឬ ។ ឆ្លើយថា កុំសួរដល់ព្រះជនកឡើយ បើលោកមិនលើក ខ្ញុំនឹងកាន់ស្វេត្រ-ឆត្រនោះ លើកឡើងដោយខ្លួនឯង ។ វិឌូឌភៈទើបពោលថា ខ្ញុំនឹងលើក

ដោយខ្លួនឯងសម្លាញ់ ។ការាយនៈសេនាបតី ចងសេះទុកឲ្យព្រះរាជាមួយក្បាល ដាវមួយ និងស្រីស្នំម្នាក់ប៉ុណ្ណោះ ប្រាប់ថា បើព្រះរាជាចង់មានជីវិតរស់នៅ កុំតាមមក ហើយលើកស្វេត្រឆត្រឲ្យវិឌូឌភៈ ហើយនាំវិឌូឌភៈនោះ ទៅកាន់នគរសាវត្ថីតែម្តង ។

**[៣២៣]** បទថា **ធម្មន្វយោ** សេចក្តីថា ដឹងតាម គឺ អនុមាន គឺ យល់ធម៌ ពោលគឺ បច្ចក្ខញាណ ។

ឥឡូវនេះ ពាក្យថា **សម្មាសម្ពុទ្ធោ ភគវា** ដូច្នេះជាដើម រមែងមានដល់ព្រះរាជានោះ ដោយសេចក្តីដឹងតាមធម៌ យ៉ាងណា ដើម្បីសម្តែងសេចក្តីដឹងតាមធម៌យ៉ាងនោះ ទើបពោលថា **ឥធ បនាហំ ភន្តេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អាបាណកោដិកំ** សេចក្តីថា ជីវិត ឈ្មោះថាបាណៈ ធ្វើទីបំផុតនៃជីវិត ដែលមានខ្យល់ជាទីបំផុតនោះ ទុកក្នុងខាងក្នុង លោកអធិប្បាយថា សូម្បីក្នុងសម័យជិតស្លាប់ ក៏នៅសញ្ជរទៅពិតមែន ទើបឈានកន្លងជីវិតនោះទៅមិនបាន ។ បាឋៈថា **អាបនកោដិកំ** ដូច្នេះក៏មាន ។ សំដៅសេចក្តីថា មានជីវិតជាទីបំផុត ។ អធិប្បាយថា បុគ្គលខ្លះឈានធ្វើជីវិតដែលមានបាណៈជាទីបំផុតហើយ ត្រាច់ទៅ ព្រោះហេតុនៃជីវិតឯណា

ភិក្ខុទាំងឡាយ រមែងមិនជាយ៉ាងនោះ ។ ពាក្យថា **អយម្បិ ខោ មេ ភន្តេ** ព្រះអដ្ឋកថាចារ្យរមែងសម្ដែងថា ប្រការនេះរមែងជាយ៉ាងនេះ ព្រោះព្រះពុទ្ធទ្រង់ត្រាស់ដឹងល្អហើយ ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ និងព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីជ្រះថ្លាក្នុងធម៌របស់ព្រះមានព្រះភាគនៃខ្ញុំព្រះអង្គនេះ រមែងជាយ៉ាងនេះ ។ ក្នុងបទគ្រប់បទ ក៏មានន័យនេះឯង ។

**[៣២៥]** បទថា **ន វិយ មញ្ញេ ចក្ខុំ ពន្ធន្តេ** (សេចក្ដីថា មិនទំនងឲ្យពួកជនមើលមើលជាប់ភ្នែកបាន) សេចក្ដីថា ដូចមិនចងភ្នែក ។ ព្រោះសម្លឹងមើលឃើញមិនគួរជ្រះថ្លា ហើយមិនធ្វើការមើលទៀត ដូច្នោះ គេទើបឈ្មោះថា មិនចងភ្នែក ។ ឃើញគួរជ្រះថ្លាហើយ នៅធ្វើកិច្ចក្នុងការក្រឡេកមើលរឿយៗ ដូច្នោះ គេឈ្មោះថា ចងភ្នែក ។ ក៏លោកទាំងនេះជាអ្នកមិនគួរជ្រះថ្លា ដូច្នោះ ព្រះរាជាទើបត្រាស់យ៉ាងនោះ ។

បទថា **ពន្ធុករោគោ នោ** បានដល់ រោគនៃត្រកូល (រោគកម្មពន្ធុ) ។ អាចារ្យទាំងឡាយពោលថា មានរោគបែបនេះ កើតក្នុងត្រកូលរបស់យើងទាំងឡាយ ។ បទថា **ឧឡារំ** គឺ មានសក្តិធំ ។ បទថា **បុព្វេនាបរំ** បានដល់

យ៉ាងដទៃ គឺ ផ្សេងអំពីមុន ។ គឺ ធ្វើកសិណបរិកម្ម ឲ្យកើតសមាបត្តិ ឈ្មោះថា ដ៏ឯទូលំទូលាយ គឺ វិសេសជាងមុន ។ ធ្វើសមាបត្តិឲ្យជាបទដ្ឋាន ចម្រើនវិបស្សនាកាន់យកព្រះអរហត្ត ឈ្មោះថា ដ៏ឯទូលំទូលាយ គឺ វិសេស ក្រៃលែងជាងពីមុន ។

[៣២៦] បទថា **ឃាតេតាយំ វា ឃាតេតុំ** សេចក្តីថា ដើម្បីឲ្យសម្លាប់ អ្នកដែលគួរសម្លាប់ ។ បទថា **ជាបេតាយំ វា ជាបេតុំ** សេចក្តីថា នឹងឲ្យ រឹបអូសអ្នកដែលគួររឹបអូសដោយទ្រព្យ គឺ ធ្វើឲ្យសាបសូន្យអស់ ឲ្យមិន មានទ្រព្យ ។ បទថា **បព្វាជេតាយំ វា បព្វាជេតុំ** គឺ ឲ្យនិរទេសអ្នកដែល គួរនិរទេសចេញអំពីរដ្ឋ ។

[៣២៨] បទថា **ឥសិទន្តបុរាណា** គឺ ឥសិទន្តៈ និងបុរាណៈ ។ ក្នុង អ្នកទាំង ២ នោះ ម្នាក់ជាព្រហ្មចារី (អ្នកប្រព្រឹត្តធម៌ជាប្រក្រតី) ម្នាក់ ជាសទារសន្តោស (ត្រេកអរតែភរិយារបស់ខ្លួន) ។ បទថា **មមភត្តា** សេចក្តី ថា ឈ្មោះថា **មមភត្តតា** ព្រោះអត្ថថា ភត្តដែលជារបស់នៃខ្លួន របស់ជន ទាំងនោះមានហើយ ។ បទថា **មមយានា** សេចក្តីថា ឈ្មោះថា យានជំនិះ របស់យើង ព្រោះអត្ថថា យានជំនិះជារបស់យើងមានហើយ ។ បទថា

**ជីវិតំ ទាតា** បានដល់ ជាអ្នកឲ្យការប្រព្រឹត្តទៅនៃជីវិត ។ បទថា **វីមំ-សមានោ** គឺ កាលនឹងសាកល្បង ។

បានឮថា ក្នុងកាលនោះ ព្រះរាជាទ្រង់មិនបានផ្ទំលក់ឡើយ ទ្រង់ផ្ទំដូចជាលក់ ។ ទីនោះ បានត្រាស់សួរជាងឈើទាំងនោះថា ព្រះមានព្រះភាគប្រថាប់នៅទិសាភាគណា កាលទ្រង់ព្រះសណ្ដាប់ថា ទិសាភាគឯណោះ ទើបប្រឹក្សាគ្នាថា ព្រះរាជាទ្រង់បែរព្រះសិរសាទៅកាន់ទិសាភាគដែលព្រះសម្មាសម្ពុទ្ធប្រថាប់ បែរព្រះបាទមក (ត្រង់នេះ) បើព្រះសាស្ដា ទ្រង់បែរព្រះសិរសាទៅកាន់ទិសាភាគដែលព្រះរាជាប្រថាប់ បែរព្រះបាទមក យើងនឹងធ្វើយ៉ាងណាល្អ ។ តពីនោះ ជាងឈើទាំងនោះ ទើបគិតគ្នាថា ព្រះរាជាទ្រង់ទាស់ព្រះទ័យ ទ្រង់ធ្លាប់ឲ្យវត្ថុណាដល់ពួកយើង ក៏ទ្រង់កាត់វត្ថុនោះចេញ ជាងឈើទាំងឡាយនិយាយគ្នាថា ក៏ពួកយើងមិនអាចនឹងបែរជើងទៅទិសព្រះសាស្ដាបាន ទើបបែរជើងទៅទិសព្រះរាជា ហើយទើបដេក ។ ព្រះរាជានេះ ទ្រង់សំដៅដល់ប្រការនោះ ទើបត្រាស់យ៉ាងនេះ ។

**[៣៣០]** បទថា **បក្កាមិ** សេចក្ដីថា ព្រះរាជាស្ដេចចេញចាកព្រះគន្ធកុដិហើយ ទ្រង់ដំណើរទៅដល់ទីដែលការាយនៈនៅ មិនឃើញការាយនៈ

នោះក្នុងទីនោះ ទើបស្តេចទៅកាន់បន្ទាយដែលសម្រាកពល ។ សូម្បីក្នុងទីនោះក៏មិនឃើញអ្នកណា ទើបត្រាស់សួរស្ត្រីនោះ ។ ស្ត្រីនោះ ទើបក្រាបទូលរឿងរ៉ាវទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឥឡូវនេះយើងមិនគប្បីទៅក្នុងនគរនោះតែម្នាក់ឯង តែយើងនឹងទៅកាន់នគររាជគ្រឹះត្រឡប់មកជាមួយក្មួយ ហើយដណ្តើមរាជសម្បត្តិរបស់យើង យើងនឹងទៅកាន់ព្រះនគររាជគ្រឹះ ទ្រង់បានសោយព្រះក្រយាហារបាយចុងអង្ករ ទ្រង់សោយទឹកល្អក់ក្នុងរវាងផ្លូវ ។ អាហាររបស់ព្រះអង្គ ជាអាហារប្រណីត ទើបមិនរលួយទៅដោយងាយ ។ ព្រះអង្គសូម្បីស្តេចដល់ព្រះនគររាជគ្រិះក៏ជាវេលាវិកាល សូម្បីទ្វារព្រះនគរក៏បិទហើយ ។ ទ្រង់ត្រិះរិះថា ថ្ងៃនេះយើងនឹងដេកក្នុងសាលា (នេះ) ស្អែកឡើងចាំចូលទៅរកក្មួយរបស់យើង ដូច្នេះ ទើបទ្រង់ផ្ទំក្នុងសាលាខាងក្រៅព្រះនគរ ។ ព្រះអង្គស្តេចក្រោកឡើងរហូតដល់អស់រាត្រី ស្តេចទៅខាងក្រៅច្រើនដង ។ តាំងពីនោះ ក៏មិនអាចទ្រង់ព្រះដំណើរទៅដោយព្រះបាទ ទ្រង់ផ្ទំលើភ្លៅរបស់ស្ត្រីនោះ ពេលជិតភ្លឺទ្រង់ក៏សោយទីវង្គត់ ។ ស្រីស្នំជ្រាបថា ព្រះរាជាសុគតហើយ ក៏ផ្តើមបរិទេវនាការស្រែកយំដោយសំឡេងខ្លាំងៗ ថា ឥឡូវនេះព្រះបាទកោសល

ស្វាមីរបស់យើងសោយរាជសម្បត្តិក្នុងរដ្ឋទាំង ២ មកផ្ទុំសោយទីវង្គត់ យ៉ាងអនាថា ក្នុងសាលារបស់មនុស្សគ្មានទីពឹងខាងក្រៅព្រះនគរ របស់អ្នកដទៃ ដូច្នេះជាដើម ។ ពួកមនុស្សបានស្តាប់ដំណឹងនេះ ទើបមកក្រាបទូលចំពោះព្រះរាជា ។ ព្រះរាជាស្តេចមកទតហើយ ទ្រង់ចាំបាន ទ្រង់ជ្រាបហេតុដែលស្តេចមកហើយ ទ្រង់ឲ្យបាត់ធ្វើសរីរកិច្ចយ៉ាងសមព្រះកិត្តិយស ទ្រង់ឲ្យអ្នកកាន់ការវាយស្គរស្រែកប្រកាសថា យើងនឹងចាប់ព្រះបាទវិឌូឌភៈ ហើយឲ្យប្រជុំពួកពល ។ អាមាត្រទាំងឡាយ នាំគ្នាមកក្រាបទៀបព្រះយុគលបាទ ទូលថា មហាបពិត្រ ប្រសិនបើម្ចាស់អ៊ំរបស់ព្រះអង្គមិនមានរោគ ព្រះអង្គស្តេចក៏គួរទៅ តែឥឡូវនេះ ព្រះបាទវិឌូឌភៈ សមគួរលើកឆត្រឡើង ព្រោះអាស្រ័យព្រះអង្គនោះឯង សូមទ្រង់ជ្រាប ហាមទុកហើយ ។

បទថា **ធម្មចេតិយានិ** ជាពាក្យប្រាប់ដល់ការធ្វើសេចក្តីគោរពព្រះធម៌ ។

ពិតណាស់ កាលធ្វើសេចក្តីគោរពក្នុងរតនៈណាមួយ ក្នុងបណ្តារតនៈទាំង ៣ ក៏រមែងជាការធ្វើក្នុងគ្រប់រតនៈតែម្តង ។ ព្រោះដូច្នោះ កាលធ្វើសេចក្តីគោរពក្នុងព្រះមានព្រះភាគ ក៏រមែងជាការធ្វើសេចក្តីគោរពក្នុងព្រះធម៌ផង ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា សេចក្តីគោរពទាំង

ឡាយ ៗ បទថា **អាទិព្រហ្មចរិយកានិ** សេចក្ដីថា ដែលជាខាងដើមរបស់មគ្គព្រហ្មចរិយៈ មានន័យថា ដែលជាការបដិបត្តិក្នុងចំណែកខាងដើម ៗ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

“ ចប់អដ្ឋកថា ធម្មចេតិយសូត្រទី ៩ ”

# អ ដ្ឋ ក ថា

## កណ្ណកត្ថលសូត្រទី ១០

**[៣៣២]** *កណ្ណកត្ថលសូត្រ មានពាក្យចាប់ផ្តើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖*

*ក្នុងព្រះសូត្រនោះ ពាក្យថា* ***ឧទញ្ញាយំ***[១] *នេះ ជាឈ្មោះទាំងរដ្ឋទាំងព្រះនគរនោះ ថា ឧទញ្ញា ។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យឧទញ្ញា-នគរនោះ ។ បទថា* ***កណ្ណកត្ថលេ មិគទាយេ*** *សេចក្តីថា ក្នុងទីមិនឆ្ងាយពីព្រះនគរនោះ មានភូមិភាគដែលគួររីករាយមួយកន្លែង ឈ្មោះថា កណ្ណក-ត្ថលៈ ។ ភូមិភាគនោះគេនាំគ្នាហៅថា មិគទាយវ័ន ព្រោះទ្រង់ព្រះរាជទានទុកដើម្បីឲ្យអភ័យដល់ម្រឹគទាំងឡាយ ក្នុងទីកណ្ណកត្ថលមិគទាយវ័ននោះ ។ បទថា* ***កេនចិទេវ ករណីយេន*** *សេចក្តីថា មិនមែនកិច្ចយ៉ាងដទៃ ជាករណី-យកិច្ចដែលបានពោលទុកក្នុងសូត្រមុនទុំះឯង ។*

**[៣៣៣]** *បទថា* ***សោមា ច ភគិនី សកុលា ច ភគិនី*** *ព្រះភគិនី*

---

១-ឆ.ឧរុញ្ញាយំ , សី.ឧជុញ្ញាយំ

ទាំងពីរនេះ គឺ ព្រះភគិនីព្រះនាមថា **សោមា** និងព្រះភគិនីព្រះនាមថា **សកុលា** ត្រកូលទ្រង់ជាប្រជាបតី របស់ព្រះរាជា ។ បទថា **ភត្តាភិហារេ** បានដល់ក្នុងទីសោយព្រះក្រយាហារ ។ ក៏កន្លែងសោយព្រះក្រយាហាររបស់ព្រះរាជានាងគ្រប់ៗ គ្នានឹងត្រូវកាន់វែកជាដើម ។ ទៅថ្វាយព្រះរាជា ។ ព្រះនាងទាំងពីរនោះ បានទៅហើយដោយទំនងនោះ ។

**[៣៣៤]** បទថា **កឹ បន មហារាជា** ជាពាក្យសួរថា ព្រោះហេតុអ្វីទើបត្រាស់យ៉ាងនោះ ។ ឆ្លើយថា ដើម្បីដោះពាក្យរិះគន់ព្រះរាជាចេញ ។ ព្រោះពួកបរិស័ទនឹងគប្បីគិតគ្នាយ៉ាងនេះថា ព្រះរាជានេះ កាលស្ដេចមកក៏នាំដំណឹងរបស់មាតុគ្រាមមកទូលផង ពួកយើងសម្គាល់ថា មកគាល់ព្រះមានព្រះភាគដោយធម្មតារបស់ខ្លួន ឯព្រះរាជានេះ យកដំណឹងរបស់មាតុ-គ្រាមមក នឹងជាទាសៈរបស់មាតុគ្រាមទេដឹង សូម្បីកាលមុន ព្រះអង្គក៏ស្ដេចមកដោយហេតុនេះដូចគ្នា ដូច្នេះ ។ម្យ៉ាងទៀត ព្រះរាជានោះ ត្រូវសួរហើយ នឹងទូលដល់ហេតុដែលមករបស់ខ្លួន ពាក្យរិះគន់យ៉ាងនេះ នឹងមិនកើតឡើងដល់ព្រះអង្គដោយអាការយ៉ាងនេះ ព្រោះដូច្នោះ ដើម្បីនឹងទ្រង់ដោះស្រាយពាក្យរិះគន់ ទើបត្រាស់យ៉ាងនោះ ។

[៣៣៦] បទថា **អត្ថុទាហាសិ** ប្រែថា ពោលហើយ ។ ពាក្យថា **គ្មានសមណៈ ឬព្រាហ្មណ៍ណា ដែលដឹងធម៌ទាំងពួង និងឃើញធម៌ទាំងពួង ក្នុងគ្រាតែមួយ** សេចក្តីថា បុគ្គលណានឹងដឹង ឬនឹងឃើញធម៌ទាំងពួង ដែលជាអតីត អនាគត និងបច្ចុប្បន្ន ដោយអាវជ្ជនៈដួងតែមួយ ដោយចិត្តដួងតែមួយ នៃបុគ្គលនោះ រមែងមិនមាន ។ ពិតណាស់ អ្នកណាៗ សូម្បីនឹកហើយថា យើងនឹងដឹងរឿងគ្រប់យ៉ាងដែលជាអតីត ដោយចិត្តដួងតែមួយ ក៏មិនអាចនឹងដឹងអតីតបានទាំងអស់ នឹងដឹងបានត្រឹមតែមួយផ្ទៃប៉ុណ្ណោះ ។ ចំណែកដែលជាអនាគត និងបច្ចុប្បន្ន ក៏នឹងមិនដឹងរឿងគ្រប់យ៉ាង ដោយចិត្តនោះ ។ ក្នុងបទក្រៅពីនេះ ក៏ន័យនេះ ។ ត្រាស់បញ្ហានេះ ដោយចិត្តដួងតែមួយយ៉ាងនេះឯង ។ បទថា **ហេតុរូបំ** បានដល់ សភាវៈនៃហេតុដែលកើតពីហេតុ ។ បទថា **សហេតុរូបំ** បានដល់ ដែលកើតព្រមដោយហេតុ ។

[៣៣៧] បទថា **សម្បរាយិការហំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមទូលសួរដល់គុណដែលនឹងមានក្នុងបរលោក ។

[៣៣៨] បទថា **បញ្ចិមានិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់អង្គ

ជាទីតាំងនៃសេចក្តីព្យាយាម ៥ លាយដោយលោកុត្តរៈក្នុងព្រះសូត្រនេះ ។ ឯព្រះចូឡសមុទត្ថេរអ្នកនៅក្នុងករវលង្គណៈ កាលគេសួរថា លោកម្ចាស់ លោកពេញចិត្តអ្វី ដូច្នេះ ឆ្លើយថា អាត្មាពេញចិត្តលោកុត្តរៈតែម្យ៉ាង ។

[៣៣៩] បទថា **បធានវេមត្តតំ** បានដល់ ការផ្សេងគ្នានៃសេចក្តីព្យាយាម ។ ពិតហើយ សេចក្តីព្យាយាមរបស់បុថុជ្ជនក៏ដទៃ របស់ព្រះសោតាបន្នក៏ដទៃ របស់ព្រះសកទាគាមីក៏ដទៃ របស់ព្រះអនាគាមីក៏ដទៃ របស់ព្រះអរហន្តក៏ដទៃ របស់ព្រះអសីតិមហាសាវកក៏ដទៃ របស់ព្រះអគ្គសាវកទាំងពីរក៏ដទៃ របស់ព្រះបច្ចេកពុទ្ធក៏ដទៃ របស់ព្រះសព្វញ្ញុពុទ្ធក៏ដទៃ ។ សេចក្តីព្យាយាមរបស់បុថុជ្ជន មិនដល់សេចក្តីព្យាយាមរបស់ព្រះសោតាបន្ន ។ល។ សេចក្តីព្យាយាមរបស់ព្រះបច្ចេកពុទ្ធ ក៏មិនដល់សេចក្តីព្យាយាមរបស់ព្រះសព្វញ្ញុពុទ្ធ ។ ព្រះមានព្រះភាគត្រាស់ថា **បធានវេមត្តតំ វទាមិ** ប្រែថា តថាគតពោលសេចក្តីផ្សេងគ្នាដោយសេចក្តីព្យាយាម ទ្រង់សំដៅយកសេចក្តីនេះ ។

បទថា **ទន្តការណំ គច្ឆេយ្យុំ** សេចក្តីថា ក្នុងបណ្តាការទូន្មានទាំងឡាយ មានទូន្មានមិនឲ្យកាច មិនឲ្យចាក់ មិនឲ្យដាក់ធុរៈចោល ហេតុណា

រមែងប្រាកដ គប្បីចូលដល់ហេតុនោះ ។ បទថា **ទន្តភូមី** បានដល់ ពួកសត្វដែលទូន្មានហើយគប្បីទៅ ។ សូម្បីបុគ្គល ៤ ពួក គឺ បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ឈ្មោះថា អ្នកមិនមានសទ្ធា ក្នុងបទទាំងឡាយថា **អស្សទ្ធោ** ជាដើម ។ ពិតហើយ បុថុជ្ជន ឈ្មោះថា មិនមានសទ្ធា ព្រោះមិនទាន់ដល់សទ្ធារបស់ព្រះសោតាបន្ន ។ ព្រះសោតាបន្ន... របស់ព្រះសកទាគាមី ។ ព្រះសកទាគាមី... របស់ព្រះអនាគាមី ។ ព្រះអនាគាមីឈ្មោះថា មិនមានសទ្ធា ព្រោះមិនទាន់ដល់សទ្ធារបស់ព្រះអរហន្ត ។ អាពាធ រមែងកើតឡើងសូម្បីដល់ព្រះអរហន្ត ព្រោះដូច្នោះ អាពាធសូម្បីទាំង ៥ រមែងឈ្មោះថា ជាអាពាធច្រើន ។ ក៏ព្រះអរិយសាវករមែងមិនមានឈ្មោះថា អ្នកអួតអាង អ្នកមានមារយាទ ។ ព្រោះហេតុនោះឯង ព្រះថេរៈទើបពោលថា អាត្មាពេញចិត្តដែលទ្រង់ត្រាស់អង្គនៃការព្យាយាម ៥ ឲ្យលាយដោយលោកុត្តរៈ ។ ចំណែកក្នុង **អស្សខឡុង្កសូត្រ** ត្រាស់ទុកថា ឈ្មោះថា **សម្មោធិ** សូម្បីនៃព្រះអរិយសាវក មកហើយក្នុងព្រះតម្រាស់នេះថា **តយោ ច ភិក្ខវេ អស្សខឡុង្កេ តយោ ច បរិសខឡុង្កេ ទេសិស្សាមិ** ដោយអំណាចនៃបុថុជ្ជនជាដើមនោះ ទើបត្រាស់ថា

លាយដោយលោកុត្តរៈ ។

ចំណែកបុថុជ្ជន មិនទាន់ដល់ព្រមនូវសេចក្តីព្យាយាមក្នុងសោតាបត្តិមគ្គ ។ល។ ព្រះអនាគាមី មិនទាន់ដល់ព្រមនូវសេចក្តីព្យាយាមក្នុងព្រះអរហត្តមគ្គ ។ សូម្បីអ្នកខ្ជិលច្រអូស ក៏មាន ៤ ដូចគ្នា ដូចអ្នកមិនមានសទ្ធា ។ អ្នកមានបញ្ញាទន់ខ្សោយ ក៏ដូចគ្នា ។

ម្យ៉ាងទៀត គប្បីជ្រាបការប្រៀបផ្ទឹមដោយឧបមា ក្នុងចំណែកខ្មៅដោយពាក្យថា **អទន្តហត្ថិអាទយោ វិយ** (ដូចដំរីដែលនៅមិនបានទូន្មានជាដើម) និងក្នុងចំណែកស ដោយពាក្យថា **យថា បន ទន្តហត្ថិអាទយោ** (ដូចជាដំរីដែលទូន្មានហើយជាដើម) ដូច្នេះ ជាដើម ។ ក៏បុគ្គលដែលវៀរចាកមគ្គប្បធាន ប្រៀបដូចដំរីជាដើម ដែលនៅមិនបានទូន្មាន បុគ្គលមានមគ្គប្បធាន ប្រៀបដូចដំរីជាដើម ដែលទូន្មានហើយ ។ ដំរីជាដើម ដែលមិនបានទូន្មាន ក៏មិនអាចដើម្បីនឹងមិនធ្វើអាការកាច ចាក់ ដាក់ធុរៈទៅទទួលការទូន្មានឡើយ ឬដែលគេទូន្មានហើយបានយ៉ាងណា បុគ្គលវៀរចាកមគ្គប្បធាន ក៏ដូច្នោះដែរ រមែងមិនអាចដើម្បីសម្រេចគុណដែលអ្នកមានមគ្គប្បធានគប្បីដល់ ឬគប្បីញុំាងគុណដែលអ្នកមានមគ្គប្បធាន គប្បី

ឲ្យកើត ឲ្យកើតឡើង ។ មួយវិញទៀត ដំរីជាដើមដែលទូន្មានហើយ ក៏មិនធ្វើអាការកោច មិនចាក់រុក មិនដាក់ធុរៈ រមែងអាចទៅកាន់កន្លែងដែលសត្វទូន្មានហើយគប្បីទៅ ឬគប្បីដល់ភូមិដែលសត្វទូន្មានហើយគប្បីដល់ យ៉ាងណា អ្នកមានមគ្គប្បធានក៏ដូច្នោះដែរ ក៏អាចសម្រេចគុណដែលអ្នកមានមគ្គប្បធាន គប្បីសម្រេច អាចញ៉ាំងគុណដែលអ្នកមានមគ្គប្បធាន គប្បីឲ្យកើត ឲ្យកើតឡើងបាន ។ លោកពោលអធិប្បាយទុកដូច្នេះថា បុគ្គលមានសោតាបត្តិមគ្គប្បធាន រមែងអាចសម្រេចឱកាសដល់បុគ្គលមានសោតាបត្តិមគ្គប្បធានសម្រេច ដើម្បីនឹងញ៉ាំងគុណដល់បុគ្គលមានសោតាបត្តិមគ្គប្បធានគប្បីឲ្យកើត ឲ្យកើតឡើងបាន ។ល។ អ្នកមានអរហត្តមគ្គប្បធាន រមែងអាចសម្រេចឱកាសដល់អ្នកមានអរហត្តមគ្គប្បធានសម្រេច ដើម្បីនឹងញ៉ាំងគុណដល់បុគ្គលមានអរហត្តមគ្គប្បធានគប្បីឲ្យកើត ឲ្យកើតឡើងបាន ។

[៣៤០] បទថា ***សម្មប្បធានា*** បានដល់ សេចក្តីព្យាយាមប្រពៃ គឺសេចក្តីព្យាយាមជាប់ដោយមគ្គប្បធាន ។ បទថា ***ន កិញ្ចិ នានាករណំ វទាមិ យទិទំ វិមុត្តិយា វិមុត្តិ*** តថាគតរមែងមិនពោលការធ្វើផ្សេងគ្នាណា គឺ វិមុត្តិនិងវិមុត្តិទេ សេចក្តីថា ការធ្វើផ្សេងៗ គ្នា ប្រារព្ធផលវិមុត្តិរបស់

បុគ្គលក្រៅពីនេះ នឹងផលវិមុត្តិរបស់បុគ្គលម្នាក់ទៀត ដែលគួរនឹងពោល យ៉ាងណា តថាគតរមែងមិនពោលដល់ការផ្សេងគ្នា ដែលគួរពោលនោះ យ៉ាងណា គឺ តថាគតពោលថា មិនមានសេចក្តីផ្សេងគ្នាទេ ។ ពាក្យថា **អច្ចិយា វា អច្ចឹ** សេចក្តីថា ឬអណ្តាតភ្លើងនិងអណ្តាតភ្លើង ។ សូម្បីក្នុង ២ បទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក៏បទថា **អច្ចឹ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។

**[៣៤១]** បទថា **កឹ បន ត្វំ មហារាជ** សេចក្តីថា បពិត្រមហារាជ ទ្រង់មិនជ្រាបទេឬថា ទេវតាមានយ៉ាងនេះ គឺ មានទេវតាជាន់ចាតុម្មហារាជ មានទេវតាជាន់តាវត្តិង្ស ។ល។ មានទេវតាជាន់បរនិម្មិតវសវត្តី មានទេវតាជាន់ខ្ពស់ៗ ឡើងទៅទៀត ព្រះអង្គត្រាស់យ៉ាងនេះ ព្រោះហេតុអ្វី ។ បន្ទាប់ពីនោះ ព្រះរាជាកាលនឹងត្រាស់សួរពាក្យនេះថា ខ្ញុំព្រះអង្គដឹងថាមានតែទេវតាទាំងឡាយមកកាន់មនុស្សលោក ឬមិនមកកាន់មនុស្សលោក ទើបត្រាស់ពាក្យថា **យទិ វា តេ ភន្តេ** ដូច្នេះជាដើម ។ បទថា **សព្យាបជ្ឈា** បានដល់ មានទុក្ខ គឺ លះបង់ទុក្ខផ្លូវចិត្តមិនបាន ដោយសមុច្ឆេទប្បហាន ។ បទថា **អាគន្តារោ** សេចក្តីថា អ្នកមកដោយអំណាចឧប្បត្តិ ។ បទថា **អព្យា-**

បញ្ញា បានដល់ លះបង់សេចក្ដីទុក្ខបានដោយសមុច្ឆេទ ។ បទថា **អនាគន្តារោ** បានដល់ អ្នកមិនមកដោយអំណាចនៃឧប្បត្តិ ។

**[៣៤២]** បទថា **បហោតិ** ប្រែថា រមែងអាច ។ ពិតណាស់ ព្រះរាជារមែងធ្វើអ្នកដែលដល់ព្រមដោយលាភ និងសក្ការៈ សូម្បីមានបុណ្យ ដោយមិនមានអ្នកណានឹងចូលទៅជិតបាន ឲ្យឃ្លាតចាកឋានៈនោះ ។ រមែងធ្វើសូម្បីអ្នកមិនមានបុណ្យនោះ មិនបានវត្ថុត្រឹមតែថា ត្រាច់ទៅកាន់ស្រុកទាំងអស់ដើម្បីបិណ្ឌៈ ហើយញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយប្រការដែលជាអ្នកដល់ព្រមដោយលាភ និងសក្ការៈឲ្យឃ្លាតចាកឋានៈនោះ ។ រមែងអាចដើម្បីប្រកបសូម្បីអ្នកមានព្រហ្មចរិយៈជាមួយនឹងស្រី ឲ្យដល់សីលវិនាស ឲ្យសឹកដោយពលការ ឬឲ្យឃ្លាតចាកឋានៈនោះ ។ មិនឲ្យអាមាត្រដែលប្រកបព្រមដោយកាមគុណ សូម្បីមិនបានប្រព្រឹត្តព្រហ្មចរិយៈ ឲ្យចូលទៅកាន់គុក មិនឲ្យឃើញសូម្បីមុខរបស់ស្ត្រីទាំងឡាយ ឈ្មោះថា រមែងធ្វើឲ្យឃ្លាតចាកឋានៈនោះ ។ តែកាលឲ្យឃ្លាតចាករដ្ឋ ឈ្មោះថា បណ្ដេញទៅតាមត្រូវការ ។

បទថា **ទស្សនាយបិ នប្បហោន្តិ** សេចក្ដីថា ទេវៈអ្នកមានទុក្ខរមែង

មិនអាចនឹងឃើញដោយចក្ខុវិញ្ញាណនូវទេពអ្នកមិនមានទុក្ខ ជាន់កាមាវចរ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះមិនមានឋានៈក្នុងកពនោះដោយសមគួរ ។ តែរមែងអាចឃើញដោយចក្ខុវិញ្ញាណ នូវទេពជាន់រូបាវចរថា រមែងឈរផង រមែងអង្គុយផង ក្នុងវិមានតែមួយនោះឯង ។ តែមិនអាចនឹងឃើញ នឹងកំណត់ នឹងចាក់ធ្លុះលក្ខណៈ ដែលទេពទាំងនេះឃើញហើយ កំណត់ហើយ ចាក់ធ្លុះហើយ ។ រមែងមិនអាចនឹងឃើញដោយញាណចក្ខុ (ដោយប្រការដូច្នេះ) ។ ទាំងមិនអាចនឹងឃើញទេពដែលខ្ពស់ៗ ឡើងទៅ សូម្បីការឃើញដោយចក្ខុវិញ្ញាណនោះឯង ។ បទថា **កោនាមោ អយំ ភន្តេ** សេចក្តីថា ព្រះរាជាសូម្បីទ្រង់ស្គាល់ព្រះថេរៈ ក៏ត្រាស់សួរដូចមិនស្គាល់ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះជាអ្នកប្រាថ្នាដើម្បីទ្រង់សរសើរ ។

**[៣៤៣]** បទថា **អានន្ទូ នាម** បានដល់ មានសការៈគួរត្រេកអរ ។ សូម្បីការត្រាស់សួរដល់ព្រហ្ម ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ បទថា **អថ ខោ អញ្ញតរោ បុរិសោ** សេចក្តីថា បានឮថា ពាក្យនោះ វិឌូឌភៈទុំះឯង ត្រាស់ហើយ ។ ជនទាំងនោះ ក្រោធហើយថា លោក

ពោលហើយ លោកពោលហើយ ទើបឲ្យពួកពលរៀងៗ ខ្លួន ក្រោកឡើង សូម្បីធ្វើការឈ្លោះដល់គ្នានិងគ្នាក្នុងទីនោះឯង រាជបុរសនោះ បានពោលពាក្យនោះដើម្បីហាម ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ ។

ម្យ៉ាងទៀតទេសនានេះ បញ្ចប់ហើយដោយអំណាចនៃនេយ្យបុគ្គលដូច្នេះឯង ។

" ចប់អដ្ឋកថា កណ្ណកត្ថលសូត្រទី ១០ "

ចប់ រាជវគ្គ ទី ៤

## រួមក្នុងវគ្គនេះ មាន ១០ សូត្រ គឺ ៖

១-ឃដិការសូត្រ
២-រដ្ឋបាលសូត្រ
៣-មឃទេវសូត្រ
៤-មធុរសូត្រ
៥-ពោធិរាជកុមារសូត្រ
៦-អង្គុលិមាលសូត្រ
៧-បិយជាតិកសូត្រ
៨-ពាហិតិយសូត្រ
៩-ធម្មចេតិយសូត្រ
១០-កណ្ណកត្ថលសូត្រ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្មួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម កឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆវី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គីម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ិន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -សូ បូរី | 100 AUS |
| -លោក ឥន ចាន់រ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឪ មុយ ឧបាសិកា តែ ចាន់ណារ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាបួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉ោគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ិម គិមហេង | 50 AUS |
| -ឧបាសិកា ឃីម វីឡាត់ | 50 AUS |
| -ឧបាសក តូ សវឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គីម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ុម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គីម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |

| | |
|---|---|
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភារ៉ ឧបាសិកា កាំង គីមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារីម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងីមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

